មស៣

មេរៀនដ៏
សាមញ្ញក្នុង
ព្រះគម្ពីរ



# មេរៀននៃការប្រោសលោះ

ពត៌មានសំខាន់ក្នុងការរក្សាសិទ្ធ
រក្សាសិទ្ធ © ២០១៦ ដោយ ចូណាថាន់ អេដវើដស៏ រក្សាសិទ្ធគ្រប់បែបយ៉ាង។សូមប្រកាសធ្វើការអនុញ្ញាតក្នុងការចែកចាយដរាបណាមេរៀននេះត្រូវបានរក្សាទ្រង់ទ្រាយដើមមិនមានការកែប្រែ៉ មិនលក់យកម្រៃ៉ រាល់ទាំងការចែកចាយត្រូវតែផ្តល់ដំណឹងដល់អ្នកគ្រប់គ្រងជាមុន( ម្ចាស់កម្មសិទ្ធ) ។នេះគឺជាចំនុចដែលមិនអាចបិដសេធបានដែលមាននៅជុំវិញពិភពលោក៉ គឺត្រូវបានអនុញ្ញាតអោយមានការចែកចាយដោយគោលបំណងនៃការចែកចាយត្រូវនឹងអ្វីដែលបានលើកឡើងគឺៈគាំទ្ររសេចក្តីពិតដូចដែលបានបង្ហាញ;ថ្វាយសិរីល្អនិងការគោរពដល់ព្រះជាម្ចាស់៉ហើយនឹងផ្សព្វផ្សាយដំណឹងល្អនៃព្រះយេស៊ូគ្រីស្ទ។

លើកលែងតែមានការកែប្រែពីការបកបកប្រែពីព្រះគម្ពីរបកប្រែចាស់។

- ព្រះគម្ពីរបរិសុទ្ធ= បកប្រែចាស់
- ព្រះគម្ពីរដ៏វិសុទ្ធ=បកប្រែថ្មី

# អារម្ភកថា

រាល់ទាំងកិច្ចការនៅក្នុងការចងក្រងមេរៀនដ៏សាមញ្ញក្នុងព្រះគម្ពីរនេះ,ត្រូវបានធ្វើឡើងសម្រាប់ការប្រើប្រាស់គ្រប់ប្រទេសនៅក្នុងពិភពលោកដើម្បីជាពន្លឺរដល់ព្រលឹងវិញ្ញាណ។ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់តាមរយៈព្រះយេស៊ូគ្រីស្ទ។វាគឺជាអំណរដ៏វិសេសនៅក្នុងការចងក្រងមេរៀនអំពីដំណឹងល្អនៃព្រះអម្ចាស់! ˝គ្មានអ្វីដែលទ្រង់ធ្វើមិនបាននោះឡើយ។˝(ម៉ាថាយ ១៩;២៦)

មេរៀននេះសូមធ្វើការប្រកាសឧទិសដល់កូនៗរបស់ខ្ញុំ; កាប់ព្រីយ៉ែល(២០១០)´អេវេនចូលីន(២០១២)´ ហើយនឹង គេណើឡូពី(២០១៣)។ខ្ញុំពិតជារំភើបរីករាយខ្លាំងណាស់នៅក្នុងការផ្សាយដំណឹងល្អនៃព្រះយេស៊ូជាមួយនិងអ្នក។ចាប់តាំងពីមេរៀននៃព្រះគម្ពីរសម្រាប់កុមារដែលយើងតែងតែអាននៅពេលយប់ដែលព្រះបន្ទូលនៃព្រះមិនត្រូវបានបង្រមនោះ, ដំណឹងល្អគឺជាការបំភ្លឺនៅក្នុងគ្រួសារយើង។ខ្ញុំតែងតែទន្ទឹមរង់ចាំពេលវេលាដែលយើងអាចអានមេរៀននេះជាមួយនឹងគ្នា!

ខ្ញុំសូមថ្លែងអរគុណដល់ប្រពន្ធរបស់ខ្ញុំ ម៉ារីស្សា សម្រាប់ការអត់ធ្មត់នៅក្នុងការស្តាប់ខ្ញុំក្នុងពេលដែលខ្ញុំរៀប ˝គ្រឹះដ៏រឹងមាំ˝ នៃមេរៀនដ៏សាមញ្ញក្នុងព្រះគម្ពីរ។នាងបានអានដើម្បីកែសម្រួល ហើយធ្វើការសាកល្បងមេរៀននៃការប្រោសលោះ នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន។ជំនួយរបស់នាងគឺជាអ្វីដែលមានតម្លៃបំផុត។

ខ្ញុំសូមថ្លែងអំណរគុណសម្រាប់ការលះបង់របស់លោក អែលជី ប័តឡឺ ហើយនឹងប្រេដលី បាល័ត។ អស់រយៈពេលជាច្រើនម៉ោងដែលត្រូវបានចំណាយនៅក្នុងការជួយខ្ញុំអោយបានឃើញកាន់តែច្បាស់ហើយនឹងផ្លូវដ៏សាមញ្ញនិងសេចក្តីពិតនៅក្នុងមេរៀននេះ។មេរៀននេះនឹងមិនអាចបានដូចជាពេលនេះនោះឡើយប្រសិនបើមិនមានការជួយពីពួកគាត់។ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះប្រេនឌី បាល័តដែលបានផ្តល់ជូននូវររបៀបនៅក្នុងការដឹកនាំនៃរបៀបងាយស្រួលនៅក្នុងការរចនា រូបភាពសម្រាប់កិច្ចការនេះ។យោបល់នៅក្នុងការរចនារបស់គាត់ហើយនឹងគំរូពីការរចនាមេរៀននៃព្រះគម្ពីរ បានជួយខ្ញុំអោយអាចស្វែងរកវិធីនៅក្នុងការបង្ហាញនៃព្រះគម្ពីរដូចដែលមាននៅក្នុងរូបភាពនេះ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណចំពោះឪពុកម្តាយរបស់ខ្ញុំ ឌុកនិងដេប៊ី អេដវើដស៍។ តាមរយៈពួកគាត់ទើបខ្ញុំអាចរៀនបានថាព្រះទ្រង់ជាអ្នកណាហើយមានអ្វីខ្លះដែលព្រះអង្គបានធ្វើសម្រាប់ជីវិតខ្ញុំ។

# សារបាននៃមេរៀន

ពត៌មានបន្ថែមសម្រាប់មេរៀន........................................................................ ៦
សេចក្តីផ្តើមនៃមេរៀន.................................................................................... ១៣
មេរៀនទី ១: កាលដើមដំបូង.........................................................................១៤
មេរៀនទី ២: ការធ្លាក់ទៅក្នុងអំពើបាបរបស់មនុស្ស....................................២០
មេរៀនទី ៣: ពិភពលោកមានបញ្ហារជាមួយអំពើបាប...................................២៦
មេរៀនទី ៤: គ្រួសារនៃសេចក្តីជំនឿ........................................................... ៣២
មេរៀនទី ៥: អ៊ីស្រាអែលក្លាយជាទាសករហើយនឹងការប្រោសលោះ.................៣៨
មេរៀនទី ៦: ភាពរីកចំរើននិងការធ្លាក់ចុះរបស់អ៊ីស្រាអែល..............................៤៤
មេរៀនទី ៧: ព្រះជន្មរបស់ព្រះយេស៊ូ............................................................៥០
មេរៀនទី ៨: យប់ចុងក្រោយ,ថ្ងៃមួយនៃក្តីងងឹត.......................................... ៥៦
មេរៀនទី ៩: ការសុគតនិងការរស់ពីសុគតឡើងវិញនៃព្រះយេស៊ូ...................... ៦២
មេរៀនទី ១០: ការចាប់ផ្តើមនៃជំនាន់គ្រីស្ទាន!............................................. ៦៨
មេរៀនទី ១១: រហូតដល់ព្រះយេស៊ូយាងមកវិញ.......................................... ៧៤
មេរៀនទី ១២: រង្វាន់ដ៏អស់កល្បជានិច្ច.......................................................៨០
លំហាត់សម្រាប់ការសង្ខេបមេរៀន................................................................៨៦
ចម្លើយសម្រាប់សំនួរមេរៀន.........................................................................៨៨
សេចក្តីបន្ថែម.............................................................................................១០០

# ពត៌មានបន្ថែមសម្រាប់មេរៀន

## *ការសិក្សាបន្ថែមក្នុងមេរៀនៃព្រះគម្ពីរ*

មសព

នៅក្នុងមេរៀននិមួយៗនៃមេរៀននៃការប្រោសលោះមានការសិក្សាបន្ថែមនៅក្នុងព្រះគម្ពីរ។ក្នុងមេរៀនទាំងនោះមានពត៌មានបន្ថែមចំពោះការបង្ហាញនៃការប្រោសលោះ។មេរៀនទាំងនោះនឹងត្រូវបង្ហាញដូចជាលេខយោងនៅក្នុងមេរៀនម្តងទៀតនៅក្នុងទំព័រចុងក្រោយនៃមេរៀននិមួយៗដែលមានខាងក្រោមលេខយោង។ខាងក្រោមនេះគឺជាមេរៀនបន្ថែមដែលមាននៅក្នុងមេរៀននៃការប្រោសលោះ។

| | |
|---|---|
| មេរៀនទី ១ | មសព ១.១ ព្រះ |
| | មសព ១.២ ហេតុអ្វីបានជាយើងត្រូវថ្វាយបង្គំព្រះ? |
| មេរៀនទី ២ | មសព ២.១ សាតាំង-សត្រូវដ៏ធំរបស់មនុស្ស |
| | មសព ២.២ អំពើបាបនិងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ |
| | មសព ២.៣ តើអ្នកណាមានបាប? |
| មេរៀនទី ៣ | មសព ៣.១ ទូកលោកណូអេ-ជាដំណាងនៃពួកជំនុំ |
| | មសព ៣.២ តើអាចអោយព្រះ "ដ៏ល្អ"ធ្វើយ៉ាងដូច្នោះម្តេចបាន? |
| មេរៀនទី ៤ | មសព ៤.១ ពេលដែលព្រះបង្កើតសេចក្តីសន្យា |
| | មសព ៤.២ តើអ៊ីស្រាអែលនៅតែជាប្រជារាស្ត្រដែលព្រះជ្រើសរើសដែលឬទេនៅសព្វថ្ងៃនេះ? |
| មេរៀនទី ៥ | មសព ៥.១ តើអ្នកសង្គ្រោះជាអ្វី? |
| | មសព ៥.២ ម៉ូសេ -ជាតំណាងអោយព្រះយេស៊ូ |
| | មសព ៥.៣ បុណ្យរំលង-ការបង្ហាញថាព្រះយេស៊ូជាយញ្ញបូជា |
| | មសព ៥.៤ តើគ្រីស្ទានគួរគោរពក្រឹត្យវិន័យចាស់ដែរឬទេ? |
| | មសព ៥.៥ ឈាមរបស់យញ្ញបូជា |
| មេរៀនទី ៦ | មសព ៦.១ "សូមបើកអោយយើងមានស្តេចមួយមក" ការដាស់តឿនចំពោះការស្រលាញ់លោកីយ៍។ |
| | មសព ៦.២ តើមនុស្សម្នាក់ "បានស្របតាមព្រះហឫទ័យព្រះដោយរបៀបណា?" |
| មេរៀនទី ៧ | មសព ៧.១ ហេតុអ្វីបានជាការប្រសូត្រពីស្ត្រីព្រហ្មចារីរបស់ព្រះយេស៊ូមានសារៈសំខាន់? |
| | មសព ៧.២ ហេតុអ្វីបានជាការជ្រមុជទឹករបស់ព្រះយេស៊ូមានសារៈសំខាន់? |
| | មសព ៧.៣ ពួកមេដឹកនាំសាសនាយូដានៅក្នុងជំនាន់ព្រះយេស៊ូ |
| | មសព ៧.៤ ហេតុរអ្វីបានជា "អ្នកសង្គ្រោះដែលគ្មានបាប"ម្នាក់មានសារៈសំខាន់? |
| មេរៀនទី ៨ | មសព ៨.១ គ្រប់ទាំងចំនុចអំពីពិធីរំលឹកព្រះអម្ចាស់ |
| | មសព ៨.២ លក្ខណៈនៃព្រះ (ផ្នែកទី ១) |
| | មសព ៨.៣ លក្ខណៈនៃព្រះ (ផ្នែកទី ២) |
| | មសព ៨.៤ លក្ខណៈនៃព្រះ (ផ្នែកទី ៣) |
| | មសព ៨.៥ "ទូលបង្គំសូមទោសព្រះជាម្ចាស់" វិប្បដិសារីនិងការផ្លាស់ប្រែ |
| មេរៀនទី ៩ | មសព ៩.១ ចោរដែលនៅលើឈើឆ្កាង |
| មេរៀនទី ១០ | មសព ១០.១ អំណោយទាននៃការធ្វើការអស្ចារ្យនៅក្នុងសញ្ញាថ្មី(ផ្នែកទី ១) |
| | មសព ១០.២ អំណោយទាននៃការធ្វើការអស្ចារ្យនៅក្នុងសញ្ញាថ្មី(ផ្នែកទី ២) |
| | មសព ១០.៣ គ្រប់ទាំងចំនុច អំពីការប្រព្រឹត្ត |
| | មសព ១០.៤ របៀបនៅក្នុងការប្រែក្លាយជាគ្រីស្ទាន |
| | មសព ១០.៥ គ្រប់ចំនុចអំពីពិធីជ្រមុជទឹក(ផ្នែកទី ១) |
| | មសព ១០.៦ គ្រប់ចំនុចអំពីពិធីជ្រមុជទឹក(ផ្នែកទី ២) |
| មេរៀនទី ១១ | មសព ១១.១ តើយើងត្រូវធ្វើអ្វីខ្លះបន្ទាប់ពីយើងទទួលបានសេចក្តីសង្គ្រោះ? |
| | មសព ១១.២ ការបោកបញ្ឆោត |
| | មសព ១១.៣ ការយល់ខុសទាំងប្រាំមួយចំនុចអំពីជំនឿគ្រីស្ទាន |
| មេរៀនទី ១២ | មសព ១២.១ ទទួលបានសេចក្តីសង្គ្រោះដោយសារព្រះគុណតាមរយៈសេចក្តីជំនឿ-ជំនុំជំរះដោយភាពស្មោះត្រង់ |
| | មសព ១២.២ រឿងនៃព្រះគម្ពីរ |
| | មសព ១២.៣ ការសម្លឹងមើលអោយកាន់តែជ្រៅក្នុងគម្ពីរយ៉ូហាន ៣:១៦ |

# ពត៌មានបន្ថែមសម្រាប់មេរៀន

## *ការបង្ហាញនៃមេរៀននៃការប្រោសលោះ*

រូបភាពខាងក្រោមនេះបង្ហាញពីមេរៀនទាំងដប់ពីរដែលមាននៅក្នុង មេរៀននៃការប្រោសលោះ។ មេរៀននិមួយៗនឹងមានទំនាក់ទំនងជាមួយនឹងគ្នាដើម្បីដឹកនាំសិស្សដែលសិក្សាព្រះគម្ពីរអោយចេះអោយតម្លៃហើយនឹងទទួលស្គាល់គំនិតសំខាន់នៃការប្រោសលោះ។




## *គម្រោងនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន*

មេរៀននិមួយៗនឹងត្រូវចំណាយពេលប្រហែលជា ១៥-២០នាទីក្នុងការអាន។មិនរួមបញ្ចូលជាមួយនឹងសំនួរដែលជាការរំលឹកឡើងវិញ ការសញ្ជឹងគិតអំពីមេរៀន ឬពេលវេលាដែលត្រូវចំណាយនៅក្នុងការមើលទៅក្នុងបទគម្ពីរនោះទេ។

តាមរយៈបទពិសោធន៏ផ្ទាល់ខ្លួនអ្នកចងក្រងសូមលើកទឹកចិត្តនៅក្នុងការរៀបចំពេលវេលាយ៉ាងតិច ៣០នាទី នៅក្នុងការសិក្សា។ធ្វើយ៉ាងដូច្នោះអ្នកនឹងអាចបង្កើតឱកាសដ៏ល្អសម្រាប់ការសិក្សាហើយនឹងការចងចាំជាជាងការអានត្រួសៗនៅក្នុងមេរៀន។







## *គម្រោងនៅក្នុងការសិក្សាជាក្រុម*

ដូចជាការសិក្សាផ្ទាល់ខ្លួនដែរនៅក្នុងក្រុមតូចមួយអាចនឹងចំណាយប្រហែលជា ២០-៣០នាទីនៅក្នុងការអានមេរៀន។សូមធ្វើការត្រៀមខ្លួននៅក្នុងការចំណាយពេលវេលាបន្ថែមលើនេះដើម្បីធ្វើការពិភាក្សាអំពីមេរៀនសួរសំនួរអំពីមេរៀនពិនិត្យមើលបទគម្ពីរដែលបានលើកឡើងឬក៏ចំណាយពេលជាមួយគ្នាដើម្បីបង្កើនទំនាក់ទំនងហើយនឹងអធិស្ឋាន។

តាមរយៈបទពិសោធន៏ផ្ទាល់ខ្លួនអ្នកចងក្រងសូមលើកទឹកចិត្តអោយរៀបចំពេលវេលាប្រហែលជាមួយម៉ោងសម្រាប់ការសិក្សា។ធ្វើយ៉ាងដូច្នេះនឹងជួយបង្កើតអោយមានបរិយាកាសនៃការពិភាក្សាហើយនឹងការសួរសំនួរដ៏ល្អប្រសើរមួយ។

សូមមើលឧទាហរណ៏ដែលមានខាងក្រោមៈ ប្រសិនបើមានអ្នកណាម្នាក់មានចំណាប់អារម្មណ៏នៅក្នុងការសិក្សាមួយមេរៀនក្នុងមួយសប្តាហ៏នោះ៎ អាចនឹងត្រូវចំណាយពេលប្រហែលជាបីខែដើម្បីបញ្ចប់មេរៀននេះ។ សូមធ្វើការជ្រើសរើសពេលវេលាក្នុងការសិក្សាដែលសក្តិសមជាមួយនិងសេចក្តីត្រូវការរបស់សិស្ស។




## ...អ្វីដែលមនុស្សម្នាក់សាបព្រោះ៎ គាត់នឹងប្រមូលបានផលនោះឯង

*អ្នកដឹកនាំការសិក្សានឹងទទួលបានលទ្ធផលដោយក្តីបំណងប្រាថ្នានិងការព្យាយាមដែលគាត់បានតាំងចិត្តនោះ។តើយើងអាចប្រមូលផលនៃព្រះពរតាមរយៈការសិក្សាជាក្រុមដោយរបៀបណា?*

- ព្យាយាមអានហើយស្វែងយល់មុនពេលការសិក្សាព្រះគម្ពីរចាប់ផ្តើម។អ្នកត្រូវតែយល់ពីអ្វីមួយមុនពេលដែលអ្នកបង្ហាញដល់អ្នកដ៏ទៃ។
- មានការលើកទឹកចិត្តនៅក្នុងាការសិក្សាជាក្រុមជាជាងការបង្រៀនតែម៉្យាង។
- អនុញ្ញាតអោយមានពេលវេលាគ្រប់គ្រាន់សម្រាប់សិស្សនៅក្នុងការពិចារណាហើយឆ្លើយសំនួរ និងការពិភាក្សា។
- ត្រៀមខ្លួនជាស្រេច! សម្រាប់អ្វីដែលកើតឡើងក្នុងជីវិត។នៅពេលដែលមានការអាកខានមិនបានសិក្សាឬសិស្សមានការរំខាននោះ៎សូមកុំបោះបង់ចោលឡើយ!

# ព័ត៌មានបន្ថែមសម្រាប់មេរៀន

## *លេខយោង*

គ្រប់ទាំងមេរៀនដែលមាននៅក្នុងមេរៀនត្រូវបានចងក្រងក្នុងគោលបំណងបង្ហាញពីការប្រើព្រះបន្ទូលព្រះជាប្រភពនៃព័ត៌មានទាំងអស់ដែលមាននៅក្នុងមេរៀននេះ។ការដកស្រង់ចេញពីព្រះគម្ពីរឬការបញ្ជាក់នឹងត្រូវបានបង្ហាញជាមួយនឹងលេខយោង។ប្រសិនបើអ្នកមិនដែលបានជួបប្រទះជាមួយនឹងលេខយោងទេនោះសូមចំណាំឧទាហរណ៏ខាងក្រោម;

## ព្រះទ្រង់ជាព្រះនៃក្តីស្រលាញ់.[១]

ឧទាហរណ៏ដែលនៅក្នុងប្រយោគខាងឆ្វេងជាមួយនឹងលេខសំគាល់ខាងលើជាការបញ្ជាក់នៅចុងប្រយោគ។នៅខាងក្រោមនៃទំព័រគឺជាលេខយោង។នៅក្នុងលេខយោងនេះនឹងមានខគម្ពីរដែលបានប្រើធ្វើជាការបញ្ជាក់ឬព័ត៌មានផ្សេងៗដែលត្រូវការ។




---

[១] ១ យ៉ូហាន ៤:៨

# ពត៌មានបន្ថែមសម្រាប់មេរៀន

## *សំនួរពិភាក្សា*

ក៏មានសំនួរដែលមានភាពងាយស្រួលនៅក្នុងការពិភាក្សានៅខាងក្រោមទំព័រផងដែរ។សំនួរទាំងនេះគឺជាការផ្តល់យោបល់នៅក្នុងការសួរដូច្នេះសូមប្រើប្រាស់សំនួរទាំងនេះតាមដែលត្រូវការ។លោកអ្នកក៏អាចសួរសំនួរដែលលោកអ្នកមានផងដែរ!សំនួរជួយអោយការសិក្សារព្រះគម្ពីរកាន់តែប្រសើរឡើង។អ្នកដែលដឹកនាំការសិក្សាព្រះគម្ពីរគួរតែធ្វើការពិចារណាអំពីសំនួរដែលពួកគាត់សួរ។សំនួរខ្លះអាចជាសំនួរ "បើកចំហរ"ហើយសំនួរខ្លះទៀតជា "ជាសំនួរច្បាស់លាស់"សំនួរទាំងពីប្រភេទសុទ្ធតែមានប្រយោជន៏។យើងមានគោលបំណងផ្សេងៗពីគ្នា។

### *សំនួរដែលច្បាស់លាស់:*

សំនួរនេះអាចជាសំនួរដែលចម្លើយថា "ពិតមែន" ឬ "មិនមែន",ឬចម្លើយតែមួយម៉ាត់ប៉ុណ្ណោះ។

*ឧទាហរណ៏:*

- *According to the Bible, who created the world?*
- *What Bible book is the creation found in?*




### *សំនួរបើកចំហរ:*

សំនួរនេះជាសំនួរទាមទារការគិតពិចារណាហើយចម្លើយនោះគឺច្រើនជាងពាក្យមួយម៉ាត់។

*ឧទាហរណ៏:*

- *Why do you think God created man in His image?*
- *How do you feel about an all powerful God who loves you?*



### *សំនួរពិភាក្សា:*

- *How do you feel about a God who loves you?*

# ពត៌មានបន្ថែមសម្រាប់មេរៀន

## *ការស្វែងរកបទគម្ពីរណាមួយ*

វាគឺការដែលមានប្រយោជន៍ប្រសិនបើយើងដឹងពីរបៀបស្វែងរកបទគម្ពីរដែលបានលើកឡើងក្នុងការសិក្សាព្រះគម្ពីរឬក៏ជាការចែកចាយព្រះបន្ទូលនៃព្រះនោះ។មានពេលជាច្រើនគ្រូអធិប្បាយឬគ្រូបង្រៀននឹងប្រាប់អោយមនុស្សគ្រប់គ្នាបើកគម្ពីររបស់ពួកគេដើម្បីផ្ទៀង។មានមនុស្សខ្លះអាចនឹងមានការភាន់ច្រឡំមិនដឹងថាងនឹងត្រូវបើកទៅទំព័រណាឬមានការខ្មាស់អៀនដោយព្រោះតែអ្នកដ៏ទៃអាចស្វែងរកខគម្ពីរលឿនហើយគេមិនអាច។

ប្រសិនបើគ្រូអធិប្បាយប្រាប់អោយគ្រប់គ្នាបើកទៅគម្ពីរយ៉ូហាន បី ដប់ប្រាំមួយ,តើមានន័យយ៉ាងដូចម្តេ? យ៉ូហានបី ដប់ប្រាំមួយគឺផ្តោតទៅលើចំនុចបីផ្សេងពីគ្នា:(១)គឺជាឈ្មោះគម្ពីរ,(២)ជំពូករបស់គម្ពីរ,ហើយ (៣) ខ ដែលមាននៅក្នុងជំពូកនោះ។(សូមមើលការបង្ហាញដែលកំណត់សំគាល់ដោយរូបភាពសម្រាប់ឈ្មោះគម្ពីរ-ជំពូក-ខ ដែលនៅទំព័របន្ទាប់)



អ្វីដែលត្រូវបានលើកឡើងដំបូងនោះគឺជាឈ្មោះរបស់គម្ពីរ។នៅក្នុងឧទាហរណ៏នៃគម្ពីរយ៉ូហាន ៣:១៦, មនុស្សម្នាក់ដែលកំពុងតែស្វែងរកអត្ថបទគម្ពីរគឺត្រូវចាប់ផ្តើមជាមួយនឹងគម្ពីរយ៉ូហាន។នៅខាងលើនៃទំព័រនិមួយៗមានដាក់ឈ្មោះនៃគម្ពីរ។ប្រសិនបើមនុស្សម្នាក់នោះមិនដឹងថានឹងត្រូវបើកទៅកន្លែងណានោះ,ពួកគាត់អាចស្វែងរកមើលនៅក្នុងសារបានដែលមាននៅទំព័រដើមនៃព្រះគម្ពីរ។



នៅពេលបានបើកទៅគម្ពីរយ៉ូហានហើយនោះ,យើងត្រូវស្វែងរកជំពូក។ជំពូកនិមួយៗត្រូវបានកំណត់សំគាល់ដោយលេខធំៗ។



នៅក្នុងជំពូកនិមួយៗតែងតែចាប់ផ្តើមដោយ "ខមួយ" ហើយបន្តរតាមលេខរៀងរហូតដល់ចប់ជំពូកនិមួយៗ។តាមធម្មតាខនិមួយៗគឺជាគំនិតមួយ,ជាការសរសេរក្នុងឃ្លានិមួយៗ។ការដែលហៅឈ្មោះគម្ពីរ,ជំពូក,ហើយនិងខគឺជាទំលាប់ដែលមនុស្សប្រើនៅក្នុងការបញ្ជាក់ពីបទគម្ពីរនិមួយៗ។ពេលខ្លះគ្រូអធិប្បាយអាចនឹងហៅលេខទំព័រដែលអាចស្វែងរកគម្ពីរណាមួយនោះ។(ការដែលហៅយ៉ាងដូច្នោះអាចធ្វើទៅបានលើកលែងតែគ្រូអធិប្បាយហើយនឹងអ្នកស្តាប់ប្រើប្រាស់ព្រះគម្ពីរបកប្រែដូចគ្នាតែប៉ុណ្ណោះ។)

នៅពេលដែលទារកកំពុងតែរៀនដើរនោះ,គ្មានអ្នកណាម្នាក់រំពឹងថាពួកគេអាចធ្វើបានដោយជោគជ័យតាំងពីពេលចាប់ផ្តើមដំបូងនោះឡើយ។ការពិតក៏ដូចគ្នាយ៉ាងដូច្នោះដែរនៅពេលដែលអ្នកណាម្នាក់ចាប់ផ្តើមរៀនជិះកង់នៅពេលដំបូង។វាក៏មានភាពដូចគ្នាដែរ,នៅពេលដែលយើងរៀនស្វែងរកអត្ថបទគម្ពីរដែលអ្នកណាម្នាក់ប្រាប់អោយយើងបើកទៅគម្ពីរណាមួយនោះ,គ្មានអ្នកណាម្នាក់ដែលមានជំនាញយ៉ាងល្អដោយគ្មានការហ្វឹកហាត់នោះឡើយ។ការដែលយើងព្យាយាមម្តងហើយម្តងទៀតដោយការអត់ធ្មត់នោះ,មនុស្សគ្រប់គ្នាអាចរៀនស្វែងរកអត្ថបទគម្ពីរបានយ៉ាងល្អ!




# ការហ្វឹកហាត់បន្ថែមក្នុងមេរៀនៈ

សូមស្វែងរកអត្ថបទគម្ពីរដែលមាននៅខាងក្រោមនៅក្នុងព្រះគម្ពីររបស់អ្នក។ប្រសិនបើអ្នកមិនធ្លាប់បានធ្វើពីមុនទេនោះ, សូមចាប់ផ្តើមដោយការស្វែងរកគម្ពីរទាំងនោះនៅក្នុងសារបាននៃព្រះគម្ពីររបស់អ្នក។បន្ទាប់មកសូមបំពេញក្នុងប្រអប់ខាងក្រោម។

| អត្ថបទគម្ពីរ | ឈ្មោះគម្ពីរ | ជំពូក | | ខ | របៀបសរសេរ |
|---|---|---|---|---|---|
| ឧទាហរណ៍: កាឡាទី បួន, បួន | កាឡាទី | បួន | : | បួន | កាឡាទី៤:៤ |
| លោកុប្បត្តិ មួយ,មួយ | | | : | | |
| យ៉ូហាន បី,ដប់ប្រាំមួយ | | | : | | |

# ពត៌មានបន្ថែមសម្រាប់មេរៀន

## ខគម្ពីរចងចាំ

> *"ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីអោយអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ តែអោយមានជីវិតអស់កល្បជានិច្ចវិញ។"*
>
> --យ៉ូហាន ៣:១៦

នៅក្នុងមេរៀននេះ,ខគម្ពីរចងចាំគឺជាគម្ពីរយ៉ូហាន ៣:១៦។ដោយព្រោះតែបទគម្ពីរនេះគឺជាខគម្ពីរដែលមានប្រជាប្រិយភាពដែលមនុស្សជាច្រើនបានស្គាល់នោះ,ក៏មានអត្ថន័យដែលយើងគួរតែបានអោយតម្លៃនៅក្នុងការសិក្សាផងដែរ។នៅក្នុងមេរៀននិមួយៗ,គម្ពីរយ៉ូហាន ៣:១៦ គឺជាផ្នែកមួយនៃគំនិតសំខាន់ដែលមាននៅពេលបញ្ចប់មេរៀន។គឺមានន័យថាគម្ពីរនេះគឺជាចំណងនៅក្នុងមេរៀនទាំងអស់ហើយក៏ជាចំនុចសំខាន់នៃការប្រោសលោះផងដែរ។អ្នកចងក្រងមេរៀននេះសូមលើកទឹកចិត្តដល់អ្នកទាំងអស់គ្នាថាមិនត្រឹមតែអានឬធ្វើការទន្ទិញដើម្បីអោយចងចាំពាក្យតែប៉ុណ្ណោះទេប៉ុន្តែសូមអោយបានពិចារណាដើម្បីអោយបានយល់ពីមេរៀនដែលមាននៅក្នុងបទគម្ពីរនេះ។



# សេចក្តីផ្តើម

ព្រះជាម្ចាស់,ដែលជាអ្នកបង្កើតហើយជាអ្នកដែលបានផ្តល់ជីវិតដល់មនុស្សគ្រប់គ្នាបានប្រទានព្រះគម្ពីរមកដល់យើងទាំងអស់គ្នា។នៅក្នុងព្រះគម្ពីរនេះ,ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់យើងអំពីរឿងតែមួយប៉ុណ្ណោះគឺ:ការប្រោសលោះមនុស្សពីអំពើបាបហើយនឹងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ។នៅក្នុងព្រះគម្ពីរនេះមានគម្ពីរចំនួន ៦៦កណ្ឌដែលត្រូវបានចូលរួមសរសេរដោយមនុស្សជាង៤០នាក់ផ្សេងៗពីគ្នាហើយនៅលើទ្វីបបីផ្សេងគ្នាដែលត្រូវបានឆ្លងកាត់អស់រយៈពេលជា១៥០០ឆ្នាំ។ហើយគម្ពីរនេះត្រូវបានទទួលការដឹកនាំតែមួយប៉ុណ្ណោះគឺមកពី:ព្រះ។

ពាក្យខ្លះដូចជា "ការប្រោសលោះ" "អំពើបាប" " ព្រះគម្ពីរ" ហើយសូម្បីតែពាក្យ "ព្រះជាម្ចាស់" អាចនឹងគ្មានន័យអ្វីទាល់តែសោះសម្រាប់ខ្លួនអ្នក។ប្រហែលវាគឺជាលើកដំបូងដែលអ្នកបានស្តាប់ឮអំពីព្រះហើយនឹងព្រះគម្ពីរ។ប្រហែលជាអ្នកកំពុងតែបានស្តាប់ឮពីព្រះអង្គម្តងទៀត។ការនេះបានបង្ហាញយ៉ាងច្បាស់ថាអ្នកគឺជាមនុស្សដែលយកចិត្តទុកដាក់ចំពោះជំនឿសាសនាឬមានគំនិតគិតពីជីវិតខាងព្រលឹងវិញ្ញាណ។ខ្ញុំអាចមើលឃើញការនេះតាមរយៈការសម្រេចចិត្តរបស់អ្នកក្នុងការសិក្សារអំពីព្រះហើយនឹងព្រះគម្ពីរ។មេរៀននេះត្រូវបានចងក្រងឡើងដើម្បីជួយចំរើននឹងពង្រឹងជំនឿរបស់អ្នកលើដំណឹងល្អនៃព្រះយេស៊ូហើយពីអ្វីដែលព្រះអង្គបានធ្វើសម្រាប់ មនុស្សទាំងអស់។

សម្រាប់ការសម្លឹងមើលត្រួសៗក្នុងមេរៀននេះមានដូចជា:កាលដើមដំបូងឡើយព្រះបានបង្កើតរបស់គ្រប់សារពើ។មនុស្សត្រូវបានបង្កើតមកអោយយដូចជារូបអង្គនៃព្រះ,គឺត្រូវបានបង្កើតមកជាមួយនឹងព្រលឹងដែលមិនចេះស្លាប់។នៅពេលដែលមនុស្សទទួលបានអំណោយទៀននៃការជ្រើសរើស,មនុស្សបានជ្រើសរើនៅក្នុងការបដិសេធព្រះហើយស្តាប់តាមខ្លួនឯងវិញ។អំពើបាបដែលមិនអាចលុបជ្រះមួយនេះបានបំផ្លាញពិភពលោកជាមួយនឹងការឈឺចាប់,ការរងទុក្ខវេទនា,ហើយនឹងសេចក្តីស្លាប់។មនុស្សបានមានបញ្ហារជាមួយនឹងអំពើបាបហើយមិនអាចរកវិធីណាក្នុងការសង្គ្រោះខ្លួនឯងអោយរួចពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណបានឡើយ។

ប៉ុន្តែព្រះទ្រង់មានគម្រោងមួយ។នៅពេលមួយដែលបានកំណត់ជាស្រេចនោះ,ព្រះអង្គបានបញ្ជូនព្រះយេស៊ូអោយមកក្នុងផែនដីនេះ។ព្រះយេស៊ូបានបង្ហាញផ្លូវ,ព្រះអង្គបានរស់នៅក្នុងជីវិតមួយដែលគ្មានបាបណាទាល់តែសោះហើយទ្រង់ត្រូវបានគេធ្វើគត់នៅលើឈើឆ្កាង។ការសុគតហើយនឹងការរស់ពីសុគតឡើងវិញដែលពោរពេញដោយសិរីល្អរបស់ទ្រង់បានប្រទានឱកាសអោយមនុស្សទាំងអស់បានទទួលសេចក្តីសង្គ្រោះពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណប្រសិនបើមនុស្សជ្រើសរើសក្នុងការមានជំនឿហើយស្តាប់តាមព្រះ។តាមរយៈការស្តាប់តាមដំណឹងល្អ,យើងទាំងអស់គ្នាអាចទទួលបានសេចក្តីសង្គ្រោះអោយរួចផុតពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណហើយរស់នៅអស់កល្បជានិច្ចក្នុងស្ថានសួគ៌ជាមួយនឹងព្រះ!

សូមព្រះប្រទានពរដែលអ្នកចាប់ផ្តើមក្នុងការស្វែងយល់ពីព្រះទ័យដែលព្រះអង្គមានសម្រាប់អ្នកហើយនឹងជីវិតរបស់អ្នក!

# មេរៀនទី ១:កាលដើមដំបូងឡើយ

## *សេចក្តីផ្តើមៈតើយើងកើតមកពីណា?*



កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃនិងផែនដី។[១] ការកត់ត្រាដ៏អស្ចារ្យមួយនេះគឺជាការកត់ត្រាដំបូងដែលមាននៅក្នុងព្រះគម្ពីរ។នេះគឺជាចម្លើយដំបូងសម្រាប់សំនួរសំខាន់ៗជាច្រើនដូចជាៈតើយើងកើតមកពីណា?ចម្លើយនោះគឺថាៈយើងកើតមកពីព្រះ។ ព្រះគម្ពីរចាប់ផ្តើមជាមួយនឹងគម្ពីរដែលហៅថាលោកុប្បត្តិ។ពាក្យនេះគឺជាពាក្យដែលមាននៅក្នុងភាសាហេព្រើរដែលមានន័

១.១ យថា ការចាប់ផ្តើម។[២] គម្ពីរលោកុប្បត្តិពន្យល់ពីការចាប់ផ្តើមដំបូងនៃសកលលោក,មនុស្សហើយនឹងប្រវត្តិសាស្ត្រដ៏អស្ចារ្យនៃមរតក៏តែមួយរបស់យើងទាំងអស់គ្នា។ដោយព្រោះតែអាចនឹងមានផលពិបាកក្នុងការដែលយើងអាចយល់បានទាំងស្រុងនោះ,យើងនៅតែអាចដឹងបានថាព្រះទ្រង់មានព្រះវត្តមានតាំងតែពីដើមរៀងមកហើយទ្រង់បានបង្កើតជីវិតតាំងតែមិនទាន់មានអ្វីទាំងអស់។[៣]

## *ការបង្កើត*

នៅថ្ងៃទីមួយ,ព្រះបានមានបន្ទូលថា "ចូរមានពន្លឺ" ហើយពន្លឺក៏មានឡើង។ទ្រង់បានញែកពន្លឺចេញពីភាពងងឹត។នៅថ្ងៃទីពីរ,ព្រះបានញែកទឹកចេញជាពីរហើយធ្វើអោយមានចន្លោះនៅកណ្តាលទឹកនោះ។ហើយនេះជារបៀបដែលផ្ទៃសមុទ្រហើយនឹងផ្ទៃមេឃត្រូវបានបង្កើត។[៤]

ថ្ងៃទីបី, ព្រះបានបង្កើតអោយមានដីគោក។ទ្រង់បានលំអរដីគោកនោះដោយដើមឈើព្រៃ,ផ្កា,ហើយនឹងស្មៅ។ទ្រង់បានបង្កើតអោយមានភ្នំ,និងជ្រលងភ្នំ,ទួលតូចធំហើយនឹងព្រៃឈើតូចធំទាំងប៉ុន្មានដែលមាន។បន្ទាប់មក,ថ្ងៃទីបួនព្រះបានបង្កើតអោយមានពន្លឺថ្ងៃ,ខែហើយនឹងផ្កាយ។[៥] នៅថ្ងៃទីប្រាំ,ព្រះបានបង្កើតសត្វដែលហែលនៅក្នុងទឹកហើយនឹងសត្វដែលហើរនៅលើមេឃទាំងអស់។ បន្ទាប់មកនៅថ្ងៃទីប្រាំមួយ,ព្រះបានបង្កើតសត្វដែលដើរនៅលើដីគោកទាំងអស់ទ្រង់បានបង្កើតរបស់ទាំងអស់ទៅតាមព្រះទ័យទ្រង់។[៦]

## *ការបង្កើតរបស់ព្រះជាម្ចាស់ដែលវិសេសបំផុត*



ក្រោយមកព្រះបានមានបន្ទូលថា "ចូរយើងបង្កើតមនុស្សអោយដូចជាយើង។" ទ្រង់ក៏បានយកដីមកសូនហើយផ្លុំខ្យល់ដង្ហើមជីវិតចូលទៅ។នោះមនុស្សក៏មានជីវិតឡើង។[៧] នេះជាចំនុចដែលធ្វើអោយមនុស្សវិសេសជាងរបស់ណាទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកក្នុងពិភពលោកនេះ។ដោយព្រោះតែគ្មានរបស់ណាផ្សេងទៀតដែលមានរូបអង្គដូចជាព្រះនោះឡើយ។តើការនេះមានន័យថាយើងមានរូបអង្គដូចជាព្រះដោយព្រោះតែយើងមានស្បែកហើយនឹងសក់មែនទេ?មិនមែនឡើយ, គឺមានន័យថាយើងមានព្រលឹងវិញ្ញាណដែលរស់នៅជាមួយនឹងយើង,ជាផ្នែកមួយដែលមិនចេះស្លាប់ហើយត្រូវបានបង្កើតមកអោយដូចជារូបអង្គនៃព្រះ។រូបកាយខាងសាច់ឈាមរបស់យើងនឹងត្រូវវិនាសផុតទៅ,ប៉ុន្តែព្រលឹងវិញ្ញាណរបស់យើងនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច។

មនុស្សជាច្រើននឹងប្រាប់អ្នកថាអ្នកគ្មានអ្វីប្រសើរជាងសត្វតិរិច្ឆាននោះឡើយ;គេនិយាយថាអ្នកគ្រាន់តែជាការប្រមូលផ្តុំនូវសាច់ហើយនឹងឆ្អឹងដែលកើតពីសត្វដែលតូចបំផុតតែប៉ុណ្ណោះ។គោលគំនិតនេះបានទាញមនុស្សអោយឃ្លាតឆ្ងាយពីភាពបរិសុទ្ធដែលយើងមាននៅក្នុងការបង្កើតរបស់ព្រះជាម្ចាស់។ការដែលមានរូបអង្គនៃព្រះគឺជាកិត្តិយសដ៏វិសេសជាទីបំផុត។អ្នកជាមនុស្សវិសេស,គ្មានអ្វីប្រៀបស្មើរបានឡើយ,ហើយត្រូវបានបង្កើតឡើងដោយព្រះដ៏មានឫទ្ធានុភាព។ដោយព្រោះហេតុផលនេះ,ទ្រង់យកព្រះទ័យទុកដាក់ចំពោះអ្នកហើយទ្រង់ស្រលាញ់អ្នក។សេចក្តីស្រលាញ់ដ៏អស្ចារ្យដែលគ្មានអ្វីប្រៀបស្មើរនេះគឺសម្រាប់មនុស្សលោកទាំងអស់។[៨]

---

[១] លោកុប្បត្តិ ១:១
[២] ការសិក្សាមេរៀនបន្ថែម (មសព)១,១ ព្រះ
[៣] ទំនុកតម្កើង ៩០:២
[៤] លោកុប្បត្តិ ១:៦-៨
[៥] លោកុប្បត្តិ ១:១៤-១៩
[៦] លោកុប្បត្តិ ១:២៤-២៦
[៧] លោកុប្បត្តិ ១:២៧
[៨] លោកុប្បត្តិ៨:១៥-១៦

សំនួរពិភាក្សាៈ

- <u>តើផ្នែកណាមួយនៃការបង្កើតដែលអ្នកចង់ឃើញបំផុត?</u>
- <u>តើអ្នកគិតយ៉ាងដូចម្តេចអំពីព្រះដែលស្រលាញ់អ្នក?</u>

មនុស្សម្នាក់ដែលត្រូវបានដឹកនាំអោយសរសេរព្រះគម្ពីរឈ្មោះថាដាវីឌសរសើរដំកើងព្រះដោយពោលពាក្យថា: ១.២

*លបង្គំនឹងអរព្រះគុណដល់ទ្រង់ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ។*[៩-១០]

បន្ទាប់ពីថ្ងៃទីប្រាំមួយ,ការបង្កើតត្រូវបានហើយស្រេចសព្វគ្រប់។នៅថ្ងៃទីប្រាំពីរ,ព្រះទ្រង់សម្រាក។គម្ពីរលោកុប្បត្តិកត់ត្រាព្រះបន្ទូលរបស់ព្រះថាការបង្កើតរបស់ព្រះអង្គ"ល្អ"ប្រាំមួយដងនៅក្នុងជំពូកទីមួយ!ហើយការពិតនោះ,នៅពេលដែលព្រះអង្គបង្កើតសព្វគ្រប់ហើយនោះ,ទ្រង់បានហៅថាល្អប្រសើរ។[១១] មនុស្សហើយនឹងព្រះជាម្ចាស់អាចរស់នៅក្នុងទំនាក់ទំនងដ៏វិសេសហើយនឹងភាពល្អឥតខ្ចោះ។នៅពេលនោះមិនទាន់មានសេចក្ដីអាក្រក់ណាសោះឡើយ,ដ្បិតព្រះជាម្ចាស់ទ្រង់ល្អហើយទ្រង់បង្កើតសុទ្ធតែការដែលល្អ។

# *កិច្ចការដែលត្រូវធ្វើ*

មនុស្សដែលព្រះបង្កើតពីដីមកមានឈ្មោះថាអ័ដាម។[១២] ភាសាដែលប្រើនៅក្នុងព្រះគម្ពីរគឺជាភាសាហេព្រើរ,ពាក្យថាអ័ដាមគឺមានន័យថាមនុស្សប្រុសឬមនុស្ស។អ័ដាមគឺជាមនុស្សដែលល្អឥតខ្ចោះ,គាត់ជាតំណាងនៃមនុស្សជាតិទាំងអស់។ព្រះបានយកអ័ដាមដាក់នៅក្នុងសួនច្បារដ៏ស្អាតមួយដែលហៅថាអេដែន។ព្រះបានប្រទានឱ្យអ័ដាមមានការងារដែលត្រូវធ្វើ។មានរុក្ខជាតិនិងដើមឈើជាច្រើនដែលគាត់ត្រូវថែរក្សា។ដោយព្រោះតែមានមនុស្សជាច្រើនយល់ឃើញថាការងារគឺជាភាពអវិជ្ជមានរបស់មនុស្សនោះ,យើងគួរតែនឹកចាំថាអ័ដាមបានទទួលការងារពីព្រះជាម្ចាស់។ព្រះជាម្ចាស់បានបង្កើតតែរបស់ដែលល្អតែប៉ុណ្ណោះ។នៅពេលដែលយើងបំពេញកិច្ចការដោយអាកប្បកិរិយាល្អ,ការងារនោះផ្ដល់ឱ្យនូវស្មារតីនៃគោលបំណងហើយនឹងការសម្រេចដែលយើងរំពឹង។

# *អំណោយទាននៃជីវិតហើយនឹងការជ្រើសរើស*

នៅក្នុងសួនច្បារនោះក៏មានដើមឈើវិសេសពីរដើមដែលត្រូវបានប្រទានមកជាព្រះពរពីព្រះគឺ:ដើមឈើជីវិតហើយនឹងដើមដឹងខុសត្រូវល្អនិងអាក្រក់។[១៣] ដើមឈើនៃជីវិតបញ្ជាក់ថាព្រះទ្រង់មានព្រះទ័យចែករំលែកនូវអំណោយទាននៃជីវិតអស់កល្បជានិច្ចជាមួយនឹងអ័ដាម។គម្ពីរលោកុប្បត្តិបានបង្ហាញថាអ័ដាមអាចរីករាយជាមួយនឹងទំនាក់ទំនងដ៏ល្អឥតខ្ចោះជាមួយនឹងព្រះហើយការប្រកបជាមួយទ្រង់នឹងនៅតែបន្តរ។

ព្រះជាម្ចាស់ទ្រង់មិនមានព្រះទ័យអោយមនុស្សដែលទ្រង់បង្កើតមក,បំរើទ្រង់ដោយព្រោះតែតួរនាទីនោះទេ,ប៉ុន្តែដោយការតាំងចិត្តវិញ។ដូច្នេះហើយព្រះទ្រង់បានប្រទានអោយអ័ដាមនូវអំណោយទានមួយទៀតគឺជា:ការជ្រើសរើស។អ្វីដែលត្រូវជ្រើសរើសនោះគឺដើមឈើដឹងខុសត្រូវល្អនិងអាក្រក់ហើយនឹងការស្ដាប់តាមព្រះ។ព្រះទ្រង់បានដាក់បញ្ញាអំពីដើមឈើនោះថា:កុំអោយបរិភោគពីដើមនោះអោយសោះ។តាមរយៈការនេះ,ព្រះបានអនុញ្ញាតអោយអ័ដាមមានការជ្រើសរើសនៅក្នុងការស្ដាប់តាមព្រះហើយបដិសេធខ្លួនគាត់។ការជ្រើសរើសមួយទៀតគឺគាត់អាចជ្រើសរើសនក្នុងការស្ដាប់តាមខ្លួនឯងហើយបដិសេធព្រះ(ដោយការបរិភោគផ្លែពីដើមឈើវិសេសនោះ)។ បង្រួមអោយខ្លី,លោកអ័ដាមអាចបន្តរចុះចូលក្នុងសិរីល្អនៃព្រះឬក៏គាត់អាចប្រឆាំងបះបោរហើយជ្រើសរើសយកអ្វីដែលគាត់គិតថាល្អសម្រាប់ខ្លួនគាត់។



[៩] ទំនុកដំកើង ១៣៩:១៤
[១០] មសព ១.២ ហេតុអ្វីបានជាយើងត្រូវថ្វាយបង្គំព្រះ?
[១១] លោកុប្បត្តិ១:២៧-៣១
[១២] លោកុប្បត្តិ ២:១៩
[១៣] លោកុប្បត្តិ ២:៨-១៥

សំនួរពិភាក្សា:
- តើអ្នករីករាយចំពោះការងាររបស់អ្នកដែរឬទេ?
- ហេតុអ្វីបានជាព្រះមិនបង្កើតមនុស្សមកអោយស្រលាញ់ទ្រង់ដូចជាមនុស្សយន្តតែម្ដងទៅ?

នេះជារបៀបដែលព្រះប្រទានអោយលោកអ័ដាម(និងយើងទាំងអស់គ្នា)នូវទំនាក់ទំនងនៃសេចក្តីស្រលាញ់ហើយនឹងភាពជិតស្និត:តាមរយៈសិរីភាពនៃការជ្រើសរើស។ការដែលមិនអនុញ្ញាតអោយមានការជ្រើសរើសអាចបំផ្លាញនូវភាពរីករាយនៃការប្រកបទាក់ទងហើយនឹងសេចក្តីស្រលាញ់នៃព្រះដ៏ពិតប្រាកដរវាងព្រះជាមួយនឹងមនុស្ស។ការអនុញ្ញាតអោយមានការជ្រើសរើស(សម្រាប់មនុស្សជ្រើសរើនៅក្នុងការស្តាប់តាមព្រះ)ជាទំនាក់ទំនងដ៏ល្អដែលព្រះទ្រង់សព្វព្រះហឫទ័យយ៉ាងពិតប្រាកដ។ [១៤]

មានលទ្ធផលដែលចេញពីការជ្រើសរើស។ប្រសិនបើអ័ដាមជ្រើសរើសស្តាប់បង្គាប់ព្រះ,គាត់នឹងបានបន្តរស់នៅជាមួយនឹងភាពជិតស្និតហើយនឹងជីវិតដ៏ល្អឥតខ្ចោះមួយនេះ។ប៉ុន្តែប្រសិនបើអ័ដាមជ្រើសរើសស្តាប់តាមខ្លួនឯងនោះគាត់នឹងត្រូវស្លាប់[១៥]។នេះគឺជាការលើកឡើងជាលើកដំបូងអំពីសេចក្តីស្លាប់ដែលមាននៅក្នុងព្រះគម្ពីរ។ជាការបញ្ជាក់ថាពេលនោះមិនទាន់មានបញ្ហារអំពីសេចក្តីស្លាប់នៅឡើយទេ។លទ្ធផលនៃសេចក្តីស្លាប់គឺមានពីរសណ្ឋាន:សេចក្តីស្លាប់ខាងសាច់ឈាម(ការដាច់ចេញនៃរូបកាយហើយនឹងព្រលឹងវិញ្ញាណ)ហើយនឹងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ(ការដាច់ចេញពីព្រះវត្តមាននៃព្រះ)។

# *គ្រួសារដំបូង*



ពេលដែលលោកអ័ដាមធ្វើការតែឯងនោះ,គាត់ឯកការណាស់។គ្រប់ទាំងសត្វទាំងអស់សុទ្ធតែមានគូរ,សត្វទាំងនោះបង្កើតកូនបន្តរពូជ,ប៉ុន្តែអ័ដាមនៅតែម្នាក់ឯង។ព្រះទ្រង់ទតឃើញថាអ័ដាមនៅតែឯង,ក៏ធ្វើអោយអ័ដាមដេកលង់លក់ទៅ។ទ្រង់បានដកយកឆ្អឹងជំនីមួយពីទ្រូងរបស់គាត់បានបង្កើតជាអ្នកជំនួយម្នាក់សម្រាប់បុរស-គឺជាស្រ្តី។នៅពេលដែលអ័ដាមក្រោកឡើងគាត់បានឃើញអ្នកជំនួយរបស់គាត់នៅក្បែគាត់។គឺជាស្រ្តីគាត់បានហៅនាងថាអេវ៉ា។ឈ្មោះរបស់នាងមានន័យថាជីវិតឬរស់នៅ[១៦]។ ដូចជាលោកអ័ដាមដែរ,នាងគឺជាមនុស្សស្រីតែម្នាក់ហើយក៏ជាតំណាងអោយមនុស្សជាតិទាំងអស់ ។

អេវ៉ាត្រូវបានបង្កើតមកដើម្បីធ្វើជាជំនួយដល់អ័ដាមនៅគ្រប់ទាំងផ្លូវ។[១៧] គម្ពីរលោកុប្បត្តិចែងថានាង"សក្តិសម"មានន័យថានាងគឺជាដៃគូរដ៏សក្តិសមបំផុត។អេវ៉ាមិនត្រូវបានបង្កើតមកអោយធ្វើជាមនុស្សដែលមានឋានៈទាបជាងអ័ដាមនៅក្នុងចំនុចណាមួយនោះទេ។នាងគឺជាអ្វីគ្រប់យ៉ាងដែលអ័ដាមត្រូវការ។ព្រះបាននាំអោយអ័ដាមហើយនឹងអេវ៉ាមករស់នៅជាមួយគ្នាជាប្តីហើយនឹង ប្រពន្ធដែលជាគ្រួសារដំបូងបំផុត។ទ្រង់បានប្រទានដល់គេនូវចំនុចសំខាន់នៃលក្ខណៈរបស់មនុស្សគឺជាការ:ក្លាយជាសាច់ឈាមតែមួយ។គឺមានន័យថាប្តីម្នាក់ហើយនឹងប្រពន្ធម្នាក់ចែករំលែកនូវទំនាក់ទំនងខាងសាច់ឈាមដែលមិនអាចមានអ្វីប្រៀបប្រដូចបាន, មនោសញ្ចេតនា,ហើយនឹងទំនាក់ទំនងខាងព្រលឹងវិញ្ញាណដែលមានសម្រាប់តែគេទាំងពីរនាក់តែប៉ុណ្ណោះ។អំណោយទានពីព្រះសម្រាប់ការរៀបអាពាហ៏ពិពាហ៏គឺជាព្រះពរដ៏វិសេសមួយផ្សេងទៀតដែលព្រះទ្រង់បានប្រទានមកអោយមនុស្ស។ព្រះទ្រង់មានបន្ទូលថា:

> *ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ ។[១៨]*

តាមរយៈលោកអ័ដាមនិងអេវ៉ា,ព្រះបានប្រទានអំណោយដ៏ល្អឥតខ្ចោះមកកាន់របស់ដែលទ្រង់បានបង្កើតគឺ:គ្រួសារ។សិស្សដែលសិក្សាព្រះគម្ពីរអាចមើលឃើញពីព្រះពរនៃគ្រួសារដំបូងហើយយកព្រះពរនោះមកអនុវត្តនៅក្នុងក្រុមគ្រួសាររបស់គេនៅសព្វថ្ងៃនេះ។ចំនុចដែលមានសម្រាប់ពិភពលោកនេះអាចហូរចូលទៅគ្រប់ទាំងកុលសម្ព័ន្ធឬប្រជាជាតិទាំងអស់។ដោយព្រោះតែមានការបែងចែកចំពោះវប្បធម៌ដែលមាននៅក្នុងពិភពលោកនេះ,ជំនឿដែលមាននៅក្នុងក្រុមគ្រួសារអាចនឹងមានភាពខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយទៀត។ក្នុងការដែលមានអ្នកណាម្នាក់យល់ដឹងពីទំនៀមទំលាប់ដែលមានទូរទាំងពិភពលោកនោះ,គឺជាសេក្តីពិតដ៏សាមញ្ញសម្រាប់ធ្វើជាភស្តុតាង។ព្រះជាម្ចាស់បានប្រទានបញ្ញត្តិសម្រាប់ក្រុមគ្រួសារមកគឺជាផលប្រយោជន៏របស់មនុស្សជាតិទាំងអស់។តើអ្វីខ្លះដែលជាបញ្ញាត្តិសម្រាប់ពិភពលោកអាចរៀនបានពីគ្រួសារដំបូង?

---

[១៤] រ៉ូម ៦:១៧-១៨
[១៥] លោកុប្បត្តិ ២:១៧
[១៦] លោកុប្បត្តិ ៣:២០
[១៧] លោកុប្បត្តិ ២:១៨-២២
[១៨] លោកុប្បត្តិ ២:២៤

<u>សំនួរពិភាក្សា:</u>

- សូមផ្តល់ឧទាហរណ៏នៃឃ្លាដែលថា "ការជ្រើសរើសតែងតែមានលទ្ធផលមកជាមួយ"?
- តើអ្វីជាចំនុចដែលមិនអាចប្រៀបផ្ទឹមបានចំពោះទំនាក់ទំនងដែលប្តីហើយនឹងប្រពន្ធមាន?

# *បញ្ញត្តិដែលទទួលបានពីក្រុមគ្រួសារដំបូងមាន:*



១ គ្រួសារដំបូងចាប់ផ្តើមជាមួយនឹងបុរសម្នាក់ហើយនឹងស្ត្រីម្នាក់។ព្រះមិនបានប្រទានអោយលោកអ័ដាមឬបុរសដ៏ទៃទៀត ក្រៅពីស្ត្រីតែម្នាក់នោះឡើយដែលជាដៃគូរដ៏ល្អឥតខ្ចោះ។ហើយអ័ដាមក៏ត្រូវបានបំពេញដោយអេវ៉ាតែម្នាក់,មិនមែនដោយស្ត្រីជាច្រើននោះឡើយ។

២ ស្ត្រីត្រូវបានបង្កើតមកដើម្បីជាជំនួយ។លោកអ័ដាមហើយនឹងអេវ៉ាធ្វើការជាមួយគ្នា។លោកអ័ដាមមិនបានបណ្តោយអោយអេវ៉ាធ្វើការតែម្នាក់ឯងពេលដែលគាត់សម្រាកនោះទេ។

៣ បុរសជាអ្នកដឹកនាំនៅក្នុងគ្រួសារ។លោកអ័ដាមត្រូវបានបង្កើតមកជាមុនដំបូងហើយត្រូវបានប្រទានអោយមានការងារធ្វើ។អេវ៉ាត្រូវបានបង្កើតដើម្បីធ្វើជាដៃគូរហើយជាជំនួយ។ក្នុងកាលដែលអ្នកទាំងពីមានតួរនាទីខុសគ្នានៅក្នុងគ្រួសារនោះ,សេចក្តីស្រលាញ់ដែលព្រះមានសម្រាប់អ្នកទាំងពីគឺជាអ្វីដែលអស្ចារ្យបំផុត។អ័ដាមមិនបានធ្វើបាបដល់អេវ៉ានោះទេ។គាត់មានអំណរជាខ្លាំង,ដែលមានអេវ៉ាជាអំណោយមកពីព្រះ។

៤ ការរៀបអាពាហ៏ពិពាហ៏គឺជាការបង្កើតគ្រួសារថ្មី។ដូចជាលោកអ័ដាមហើយនឹងអេវ៉ា,គូរស្រករដែលទើបតែរៀបអាពាហ៏ពិពាហ៏ថ្មោងថ្មីទាំងអស់បង្ហាញពីការទទួលខុសត្រូវចំពោះអំណាចរបស់ព្រះដែលទ្រង់បានប្រទានអោយ។គ្រួសារថ្មីមួយមិនត្រូវបានដឹកនាំដោយឪពុកម្តាយខាងប្តីឬឪពុកម្តាយខាងប្រពន្ធឡើយ។ក្នុងកាលដែលយើងគោរពឪពុកម្តាយរបស់យើងនោះ,បុរសនិងស្ត្រីគ្រប់រូបត្រូវតែទទួលខុសត្រូវចំពោះគ្រួសារថ្មីនៅពេលដែលពួកគេបង្កើតនៅពេលដែលគេសម្រេចចិត្តរៀបអាពាហ៏ពិពាហ៏។

## *រំលឹកឡើងវិញ:កាលដើមដំបូងឡើយ*

គម្ពីរលោកុប្បត្តិបានបង្ហាញអំពីព្រះចេស្តារបស់ព្រះដែលជាអ្នកបង្កើតសកលលោកទាំងមូលហើយនឹងពិភពលោកយើងនេះក្នុងរយៈពេលប្រាំមួយថ្ងៃយ៉ាងអស្ចារ្យបំផុត។ក្នុងនាមជាមនុស្សដែលមានរូបអង្គនៃព្រះនៅជាមួយនោះ, មនុស្សគ្រប់រូបគួរតែមានសេចក្តីអំណរដែលបានដឹងថាយើងវិសេសយ៉ាងណាចំពោះព្រះជាម្ចាស់។ព្រះបានដាក់អ័ដាមនៅក្នុងសួនច្បារជាមួយនឹងកិច្ចការមួយដ៏វិសេស។អំណោយទាននៃការជ្រើសរើសត្រូវបានប្រទានមកអោយមនុស្សដើម្បីធ្វើអោយមានទំនាក់ទំងដែលកើតឡើងដោយការតាំងចិត្តដោយសេចក្តីស្រឡាញ់និងការគោរពរវាងព្រះជាម្ចាស់ជាមួយនឹងមនុស្ស។វាគឺជាពេលវេលាមួយដែលមានការប្រកបទាក់ទយ៉ាងល្អឥតខ្ចោះរវាងព្រះជាម្ចាស់ហើយនឹងមនុស្ស។ខគម្ពីរចងចាំសម្រាប់មេរៀននេះមានដូចខាងក្រោម:

> *"ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីអោយអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើង តែអោយមានជីវិតអស់កល្បជានិច្ចវិញ។"* - យ៉ូហាន ៣:១៦

ដោយព្រោះតែយើងមិនទាន់បានសិក្សាអំពីព្រះរាជបុត្រានៃព្រះតែមួយនៅក្នុងមេរៀននេះនៅឡើយ, យើងនៅតែអាចអោយតម្លៃទៅលើខគម្ពីរដែលយើងបានទទួលពីមេរៀនទីមួយនេះ។យើងអាចដឹងថាព្រះទ្រង់ស្រលាញ់យើង។ទ្រង់បានបង្កើតយើងអោយដូចជារូបអង្គទ្រង់។ហើយទ្រង់ក៏មានព្រះទ័យអោយយើងមានជីវិតអស់កល្បជានិច្ចដោយគ្មានការភ័យខ្លាចចំពោះសេចក្តីស្លាប់ដែរ។នេះគឺជាការលើកទឹកចិត្តដ៏វិសេសដែលបានដឹងថាព្រះនៃរបស់ទាំងអស់ទតមកកាន់អ្នកហើយនឹងខ្ញុំយ៉ាងវិសេស!

# លំហាត់មេរៀន

## មេរៀនទី ១:កាលដើមដំបូងឡើយ

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១. គម្ពីរចែងថាព្រះក៏ត្រូវបានបង្កើតក្នុងពេលដែលផែនដីនេះត្រូវបានបង្កើតមកដែរ។ |
| ☐ | ☐ | ២. គម្ពីរលោកុប្បត្តិពន្យល់អំពីការចាប់ផ្តើមនៃសកលលោក,មនុស្ស,ហើយនឹងប្រវត្តិសាស្ត្រដ៏វិសេសនៃមរតកតែមួយរបស់យើង។ |
| ☐ | ☐ | ៣. ព្រះបានបង្កើតពិភពលោកអស់រយៈពេលជាងរាប់លានឆ្នាំ។ |
| ☐ | ☐ | ៤. មនុស្សត្រូវបានបង្កើតនៅក្នុងរូបភាពរបស់សត្វ។ |
| ☐ | ☐ | ៥. អ្នកជាមនុស្សវិសេស,គ្មានអ្វីប្រៀបបាន,ហើយត្រូវបានបង្កើតដោយព្រះដ៏មានព្រះចេស្តា។. |
| ☐ | ☐ | ៦. ស្ត្រីត្រូវបានបង្កើតមកដើម្បីជួយដល់បុរស។ |
| ☐ | ☐ | ៧.ព្រះបានបង្កើតបុរសអោយមានប្រពន្ធច្រើន។ |
| ☐ | ☐ | ៨.មានចំនុចតែបន្តិចបន្តួចប៉ុណ្ណោះដែលបង្ហាញពីភាពមិន ទទួលខុសត្រូវសម្រាប់ការរៀបអាពាហ៏ពិពាហ៏ថ្មោងថ្មី។ |

## ស្វែងរកបទគម្ពីរ

១.កាលដើមដំបូងឡើយ ព្រះ ______________________ ផ្ទៃមេឃ និងផែនដី។(លោកុប្បត្តិ ១:១)

២. រួចព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ______________________ នោះក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី៦។(លោកុប្បត្តិ ១:៣១)

៣.ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ដ្បិតទ្រង់បានបង្កើតទូលបង្គំមក ______________________ ឯស្នាដៃនៃទ្រង់ក៏សុទ្ធតែអស្ចារ្យទាំងអស់ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ។(ទំនុកដំកើង១៣៩:១៤)

៤. ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ______________________ ហើយអ្នកទាំង២នោះនឹងត្រឡប់ជា។(លោកុប្បត្តិ ២:២៤)



## សំនួរសំខាន់

១. តើមានអ្វីខ្លះដែលជាលទ្ធផលនៃការមិនជឿថាយើងមានរូបអង្គដូចជាព្រះនៅក្នុងខ្លួនយើង?

២. តើអ្វីគឺជាអំណោយទាននៃ"ការជ្រើសរើស"ហើយតើអ្វីជាលទ្ធផលនៃការជ្រើសរើសនោះ?

៣.សូមពន្យល់ថាតើប្តីហើយនឹងប្រពន្ធក្លាយជា"សាច់តែមួយ"ដោយរបៀបណាហើយហេតុអ្វីបានជាទំនាក់ទំនងដែលពួកគេមាននោះមិនអាចប្រៀបប្រដូចបាន?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ១:

- ១.១ ព្រះជាម្ចាស់
- ១.២ ហេតុអ្វីបានជាយើងត្រូវថ្វាយបង្គំព្រះ?

បទគម្ពីរសម្រាប់មេរៀនបន្ទាប់

- លោកុប្បត្តិ ១-៣



# មេរៀនទី ២:ការធ្លាក់ទៅក្នុងអំពើបាបរបស់មនុស្ស

## សេចក្តីផ្តើម:ការចូលមកដល់របស់សត្រូវ



លោកអ័ដាមបានបង្រៀនដល់អេវ៉ាអំពីអំណោយទាននៃព្រះអំពីការជ្រើសរើស។ពេលនេះពួកគេទាំងពីរត្រូវបានប្រទានអោយនូវអភ័យឯកសិទ្ធនៃការជ្រើសរើសនៅក្នុងការស្តាប់តាមព្រះឬស្តាប់តាមខ្លួនគេ។ពេលនោះគឺជាពេលវេលានៃសេចក្តីសុខសាន្តហើយនឹងភាពជិតស្និត។នៅក្នុងអណាចក្រនៃព្រលឹងវិញ្ញាណ,ព្រះបានបង្កើតជីវិតដែលនៅក្នុងស្ថានសួគ៌ដើម្បីបម្រើដល់ទ្រង់។ទេវតាមួយនៅក្នុងចំណោមទេវតាដែលព្រះបានបង្កើតបានជ្រើសរើសនៅក្នុងការស្តាប់តាមខ្លួនឯងជាជាងការស្តាប់តាមព្រះ។លទ្ធផលដែលចេញពីការជ្រើសរើសនោះបានបំផ្លាញចិត្តរបស់វា។វាបានបញ្ឆោតទេវតាផ្សេងទៀតអោយឈប់បម្រើព្រះហើយមកបម្រើវាវិញ។មានសង្គ្រាមដ៏សំបើមនៅក្នុងអណាចក្រនៃព្រលឹងវិញ្ញាណ។ទេវតាដែលអាក្រក់ហើយនឹងអស់ទាំងទេវតាដែលដើរតាមវាត្រូវបានបណ្តេញចេញពីស្ថានសួគ៌។ក្រោយការនោះមកវាបានបង្ហាញខ្លួននៅក្នុងសួនច្បារអេដែន។

## សេចក្តីល្បួង

សត្រូវមួយនេះមានឈ្មោះថា សាតាំង។ភាសាដែលប្រើនៅក្នុងព្រះគម្ពីរគឺជាភាសាហេព្រើរហើយនឹងភាសាក្រិច,
សាតាំងមានន័យថាការបោកបញ្ឆោត ហើយនឹង រង់ចាំក្នុងការកុហក។សាតាំងក៏ត្រូវបានហៅថាអារក្សដែលមានន័យថាអ្នកកុហ
២.១ កបោកប្រាស់។ព្រះគម្ពីរបានបង្ហាញពីលក្ខណៈហើយនឹងគោលបំណងរបស់អារក្សយ៉ាងច្បាស់។[១] វាបានជ្រើសរើសធ្វើជា
មេបោកបញ្ឆោតដែលរង់ចាំនៅក្នុងការកុហកដើម្បីល្បួងមនុស្សអោយធ្លាក់ទៅក្នុងការបដិសេធព្រះហើយបែរមកស្តាប់តាមខ្លួនឯងវិញ។សេចក្តីល្បួងរបស់សាតាំងបានយកអំណោយទាននៃការជ្រើសរើសដែលព្រះប្រទានមកត្រូវបំផ្លាញ។សេចក្តីល្បួងធ្វើឲ្យការបដិសេធព្រះក្លាយជាអ្វីមួយដែលជាការចាប់អារម្មណ៍ឬធ្វើអោយមានការស្កប់ចិត្តជាជាងការស្តាប់តាមព្រះអង្គ។[២]

បន្ទាប់ពីត្រូវបានបណ្តេញចេញពីស្ថានសួគ៌ហើយនោះ,អារក្សវាបានសម្លឹងមើលឃើញផ្លូវដែលអាចធ្វើការសងសឹកជាមួយនឹងព្រះជាម្ចាស់បាន។វាបានសម្រេចចិត្តរង់ចាំដើម្បីកុហកហើយនឹងបំផ្លាញការប្រកបទាក់ទងដ៏ល្អឥតខ្ចោះរវាងមនុស្សជាមួយនឹងព្រះ។ថ្ងៃមួយ, ពេលដែលអ័ដាមនិងអេវ៉ានៅក្បែរដើមឈើដឹងខុសត្រូវល្អនិងអាក្រក់។សាតាំងបានយករូបភាពជាសត្វពស់,ហើយបានលូនមកក្បែរស្ត្រី។វាបាននិយាយថា"តើព្រះបានហាមមិនអោយនាងបរិភោគផ្លែពីដើមនេះមែនទេ?"ដោយមិនបានដឹងពីល្បិចកលរបស់វាអេវ៉ាបានប្រាប់សត្វនោះពីបញ្ញត្តិរបស់ព្រះ។សាតាំងបានប្រាប់ទៅនាងថានាងនឹងមិនត្រូវស្លាប់ឡើយផ្ទុយទៅវិញនាងនឹងបានដូចជាព្រះ។[៣] សង្ខេបអោយខ្លី,សាតាំងវាបានមួលបង្កាច់ព្រះថាទ្រង់ជាព្រះដែលមានភាពអាត្មានិយមដោយមិនអនុញ្ញាតអោយអេវ៉ាបានរីករាយជាមួយនឹង"ការយល់ដឹងពីការល្អនិងអាក្រក់"។

## អំពើបាប

អេវ៉ាបានធ្វើការសម្រេចចិត្តជាលទ្ធផលដែលមានឥទ្ធិពលនៅគ្រប់ពេលវេលាទាំងអស់។នាងបានបេះផ្លែនោះមកហើយបានបរិភោគ។[៤] (នាងមិនត្រូវបានបង្ខំអោយបរិភោគវានោះទេ។ប៉ុន្តែដោយសារតែបំណងចិត្តរបស់នាងវិញ,ដែលនាងបានបរិភោគផ្លែឈើនោះ។)បន្ទាប់មក,នាងបានអោយផ្លែឈើនោះទៅអ័ដាមហើយគាត់ក៏បានបរិភោគដែរ។ជាមួយនឹងការជ្រើសរើសនេះ,អ័ដាមនិងអេវ៉ាបានធ្វើការសម្រេចចិត្តថាគេជាអ្នកកំណត់នូវអ្វីដែល"ល្អ"ដោយការបដិសេធបញ្ញត្តិរបស់ព្រះជាម្ចាស់។សង្ខេបយ៉ាងខ្លី,គេបានធ្វើការប្រកាសថាគេបានបដិសេធព្រះហើយស្តាប់តាមខ្លួនគេវិញ។



---

[១] មសព ២,១ សាតាំង:សត្រូវដ៏ធំបំផុតរបស់មនុស្ស
[២] យ៉ាកុប ១:១៣-១៥
[៣] លោកុប្បត្តិ ៣:១-៥
[៤] លោកុប្បត្តិ ៣:៦

សំនួរពិភាក្សា:
- តើសេចក្តីល្បួងគឺជាអ្វី?
- តើសាតាំងក្លាយជា" អ្នកបោកបញ្ឆោត" ដោយរបៀបណា?

ព្រះគម្ពីរបានផ្តល់អោយនូវពាក្យមួយដែលវិសេសនៅពេលដែលអ្នកណាម្នាក់មិនស្តាប់តាមព្រះ។ពាក្យនោះហៅថា បាប ។ អំពើបាបគឺជាការប្រព្រឹត្តឬអាកប្បកិរិយាណាមួយដែលមិនស្តាប់តាមអំណាចឬបញ្ញាត្តិរបស់ព្រះ។[៥] នៅពេលដែលមានអ្នកណាម្នាក់ប្រព្រឹត្តអំពើបាប,ពួកគាត់កំពុងតែស្វែងរកផ្លូវដែលផ្គាប់ចិត្តខ្លួនឯងហើយឃ្លាតឆ្ងាយពីព្រះដែលគាត់បានបដិសេធផ្លូវដ៏ល្អរបស់ព្រះ។ការនេះគឺជាការប្រឆាំងបះបោរចំពោះសេចក្តីស្រលាញ់ហើយនឹងការប្រកបទាក់ទងដែលព្រះបានបង្កើតសម្រាប់មនុស្ស។

# ការប្រកបទាក់ទងដ៏ល្អឥតខ្ចោះត្រូវបានបាត់បង់

អ័ដាមនិងអេវ៉ាពិតជាទទួលបានចំណេះដឹងអំពីការល្អហើយនឹងអាក្រក់នៅពេលដែលគេបានបរិភោគផ្លែពីដើមដឹងខុសត្រូវនោះ។រំពេចនោះ,គេដឹងថាពួកគេបានធ្វើអ្វីដែលខុសហើយមានបាប។ពួកគបានដឹងថាគេនៅអាក្រាតហើយមានសេចក្តីអៀនខ្មាស។នោះគេព្យាយាមគ្របបាំងសេចក្តីអៀនខ្មាសដោយយកស្លឹកល្វាមកដេរភ្ជាប់គ្នា[៦] ។នេះគឺជាគំនិតដ៏ល្ងង់ខ្លៅដោយព្រោះតែស្លឹកឈើមិនអាចគ្របបាំងភាពអាក្រាតរបស់ពួកគេបានទាំងអស់នោះទេ។ហើយវាក៏ជាតំណាងឲ្យបញ្ហារដ៏ធំដែរ។មិនខ្វល់ថាគេព្យាយាមយកឈ្នះអំពើបាបរបស់គេយ៉ាងណានោះទេ,ពួកគេមិនអាចលប់បំបាត់អំពើបាបដោយខ្លួនគេបានឡើយ។



ព្រះជ្រាបថាអ័ដាមហើយនឹងអេវ៉ាពួននៅក្នុងសួនច្បារ។ទ្រង់បានសួរថា "តើឯងនៅឯណា?"[៧] ទ្រង់ជាព្រះដែលទតឃើញ,ហើយជ្រាបគ្រប់ទាំងអស់ មិនមែនព្រះអង្គមិនអាចស្វែងរកពួកគេនោះទេ។ព្រះទ្រង់សួរដោយព្រោះទ្រង់មានព្រះទ័យអោយអ័ដាមចូលខ្លួនទទួលខុសត្រូវចំពោះអ្វីដែលគាត់បានប្រព្រឹត្ត។សង្ខេបអោយខ្លីព្រះទ្រង់មានបន្ទូលថា,"តើឯងនៅកន្លែងណាក្នុងទំនាក់ទំនងជាមួយនឹងអញ?"អ័ដាមបានបន្ទោសដល់អេវ៉ាហើយអេវ៉ាបានបន្ទោសដល់សត្វពស់។គ្មានអ្នកណាម្នាក់ទទួលខុសត្រូវឡើយទោះបីជាពួកគេបានជ្រើសរើសនៅក្នុងការប្រព្រឹត្តអំពើបាបក៏ដោយ។

ព្រះបានប្រកាសអំពីការដាក់ទោសដល់អ្នកណាដែលមិនបានស្តាប់តាមព្រះអង្គ។ សាតាំងបានក្លាយជាសត្រូវរបស់មនុស្ស។វាបានព្យាយាមបន្តរបំផ្លាញភាពជិតស្និតរបស់មនុស្សជាមួយនឹងព្រះ,ប៉ុន្តែវាមិនអាចបំផ្លាញដល់ទីបំផុតនោះទេ(នឹងបន្តរនៅចំនុចនេះបន្តិចទៀត)។នៅក្នុងចំណោមការដាក់ទោសនោះព្រះបានបណ្តេញអ័ដាមនិងអេវ៉ាចេញពីសួនច្បារ[៨]។ ការប្រកបរបស់គេជាមួយនឹងព្រះត្រូវបានកាត់ផ្តាច់ដោយសារអំពើបាប។

# ការជ្រើសរើសក្នុងការប្រព្រឹត្តអំពើបាបនាំមកនូវលទ្ធផល

ដោយព្រោះតែអំពើបាប,អ័ដាមហើយនឹងអេវ៉ាបានឈានទៅរកវ័យចាស់ជរាហើយនឹងស្លាប់។នេះគឺជាការដាស់តឿនដំបូងអំពីសេចក្តីស្លាប់:សេចក្តីស្លាប់ខាងសាច់ឈាម(ការដាច់ចេញរវាងរូបកាយហើយនឹងព្រលឹងវិញ្ញាណ)។យើងទាំងអស់គ្នាប្រឈមមុខជាមួយនឹងបញ្ហារនៃសេចក្តីស្លាប់ដោយព្រោះតែអំពើបាប[៩] ។ដោយព្រោះតែអំពើបាប,រាល់ទាំងសេចក្តីអាក្រក់អាចនឹងកើតមានឡើង;ធ្វើអោយមានការឈឺចាប់,ការរងទុក្ខវេទនា,ហើយនឹងមេរោគជាដើម។អំពើបាបក៏ដឹកនាំទៅរកការបំផ្លាញដ៏ធំផងដែរ,គឺជាសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ(ការដាច់ចេញនៃព្រលឹងវិញ្ញាណរបស់យើងឆ្ងាយពីព្រះ)។វាគឺជាការដាក់ទោសដ៏អស់កល្បជានិច្ចនៅក្នុងស្ថាននរក[១០] ។អំពើបាបគឺជាបញ្ហារធំបំផុតសម្រាប់មនុស្ស។

---

[៥] មសព២,២ អំពើបាបនិងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ
[៦] លោកុប្បត្តិ៣:៧
[៧] លោកុប្បត្តិ ៣:៩
[៨] លោកុប្បត្តិ ៣:២១-២៤
[៩] រ៉ូម ៦:២៣
[១០] ២ថែស្សាឡូនិច ១:៧-៩

សំនួរពិភាក្សា:

- ហេតុបានជាអំពើបាបហៅថាជាការបះបោរខាងព្រលឹងវិញ្ញាណ?
- តើអ្នកធ្លាប់មានអារម្មណ៍ថាអ្នកធ្លាប់ប្រព្រឹត្តអំពើបាបពីមុនមកដែរទេ?ហេតុអ្វី?

មនុស្សម្នាក់អាចនឹងឆ្ងល់ថាតើអាចអោយព្រះនៃសេចក្តីស្រលាញ់អាចបណ្តេញមនុស្សដែលទ្រង់បានបង្កើតដោយសេចក្តីស្រលាញ់ចេញពីព្រះវត្តមានទ្រង់បានដោយរបៀបណា?យើងទាំងអស់គ្នាត្រូវតែដឹងថាទោះបីជាព្រះទ្រង់ស្រលាញ់យើងយ៉ាងណាក៏ដោយ,ទ្រង់ក៏ជាព្រះដ៏បរិសុទ្ធដែរ[១១] ។ ជាព្រះដ៏បរិសុទ្ធគឺមានន័យថាដ៏ខ្ពស់ដ៏មានឫទ្ធានុភាព,ឬញែកចេញដោយឡែក។ព្រះទ្រង់ដាច់ដោយឡែកពីអំពើបាប។ទ្រង់មានព្រះទ័យអោយយើងទាំងអស់គ្នារស់អស់កល្បជានិច្ចនៅក្នុងស្ថានសួគ៍, ដែលជារង្វាន់ដ៏អស់កល្បជានិច្ចនៃជីវិតដែលគ្មានអំពើបាបហើយនឹងលទ្ធផលរបស់អំពើបាបនោះគឺ:ជាការឈឺចាប់,សេចក្តីរងទុក្ខវេទនា,ហើយនឹងសេចក្តីស្លាប់។តើព្រះជាម្ចាស់ដែលទ្រង់ស្រលាញ់យើងដែរឬទេប្រសិនបើទ្រង់បិទព្រះនេត្រទ្រង់ចំពោះអំពើបាបហើយអនុញ្ញាតអោយស្ថានសួគ៌ហើយនឹងមនុស្សដែលបានសង្គ្រោះត្រូវបំផ្លាញដោយសារអំពើបាបនោះ?សេចក្តីស្រលាញ់ដែលព្រះមានចំពោះមនុស្សម្នាក់មិនអាចបំផ្លាញសេចក្តីស្រលាញ់ដែលទ្រង់មានចំពោះមនុស្សដ៏ទៃទៀតនោះឡើយ។

សេចក្តីពិតដ៏គួរអោយសោកសៅនោះគឺថាគ្មានផ្លូវណាដែលយើងអាចដកយកអំពើបាបចេញដោយខ្លួនយើងបាននោះឡើយ។អំពើបាបគឺដូចជាមេរោគយ៉ាងដូច្នោះដែរ។នៅពេលដែលយើងមិនស្តាប់តាមព្រះ,យើងត្រូវបានឆ្លងមេរោគនោះ។នៅពេលណាដែលមេរោគនោះឆ្លងចូលក្នុងខ្លួនយើងហើយនោះគឺគ្មានវិធីណាដែលអាចព្យាបាលបានឡើយ។វាដូចជាអាវមួយដែលត្រូវបានសំអាតរួចហើយ,ប៉ុន្តែក្រោយមកវាជាប់ស្នាមប្រលាក់។នៅពេលដែលអាវនោះមានស្នាមប្រលាក់ហើយនោះ,មិនខ្វល់ថាអ្នកព្យាយាមដុះរុះវាយ៉ាងណានោះទេ,អ្នកមិនអាចដកយកស្នាមប្រលាក់នោះចេញបានឡើយ។នៅពេលដែលមនុស្សគ្រប់គ្នា



២.៣ ឈានមកដល់អាយុរមួយដែលអាចយល់ដឹងអំពីអ្វីដែលត្រូវហើយនឹងខុសនៅក្នុងការប្រព្រឹត្តរបស់គេម្នាក់ៗ,តាមរយៈផ្លូវណាមួយនោះ,យើងសម្រេចចិត្តនៅក្នុងការប្រព្រឹត្តអ្វីដែលខុសឆ្គង[១២]។ ដោយសារតែមូលហេតុនេះហើយ,អំពើបាបមានឥទ្ធិពលលើយើងទាំងអស់គ្នា.មនុស្សមួយចំនួនអាចគិតថាអំពើបាបគឺមានសម្រាប់តែគ្រីស្ទានឬមនុស្សដែលមានជំនឿលើព្រះតែប៉ុណ្ណោះ។វាជាការមិនពិតនោះទេ,មនុស្សគ្រប់គ្នាសុទ្ធតែមានបាប ។មនុស្សគ្រប់គ្នារំពឹងហើយរំពឹងទៀតដើម្បីអាចនឹងមានផ្លូវ ក្នុងការដកយកបញ្ហារដ៏ធំនេះចេញពីខ្លួនយើងទាំងអស់គ្នា។ [១៣]

# ប៉ុន្តែព្រះទ្រង់មានគម្រោងមួយ

ចាប់តាំងពីមុនពេលដែលពិភពលោកត្រូវបានបង្កើត,ព្រះទ្រង់មានគម្រោងរួចមកហើយ។សេចក្តីស្រលាញ់ដែលព្រះអង្គមានសម្រាប់មនុស្សបានដឹកនាំអោយមានគម្រោងនេះឡើង។[១៤] ទ្រង់បានជ្រាបថាមនុស្សនឹងធ្លាក់ទៅក្នុងអំពើបាបប្រសិនបើទ្រង់ប្រទានអោយគេមានការជ្រើសរើស,ព្រះទ្រង់បានធ្វើអោយមានផ្លូវដែលអាចរក្សាការប្រកបដែលទ្រង់មានជាមួយរបស់ដែលមានរូបអង្គនៃទ្រង់ឡើងវិញ។ទោះបីជាទ្រង់បរិសុទ្ធហើយមិនអាចមានចំណែកជាមួយអំពើបាបក៏ដោយ,ព្រះបានរៀបគម្រោងសម្រាប់យញ្ញបូជាមួយដែលអាចដកយកអំពើបាបដល់អស់អ្នកណាដែលមានជំនឿ។តាមរយៈការលះបង់របស់មនុស្សម្នាក់ដែលគ្មានបាបណាសោះនោះ,អាចធ្វើអោយទោសកំហុសទាំងប៉ុន្មានត្រូវបានលើកលែងទោស។គម្រោងនោះគឺត្រូវតំរូវអោយព្រះយេស៊ូយាងមកក្នុងពិភពលោកនេះ។មានតែទ្រង់មួយប៉ុណ្ណោះដែលអាចរស់នៅក្នុងជីវិតដែលគ្មានអំពើបាបណាទាល់តែសោះ,ទ្រង់តែមួយដែលអាចធ្វើជាយញ្ញបូជាដ៏ឥតខ្ចោះដើម្បីដកយើងអំពើបាបរបស់យើងចេញបាន។

គម្ពីរលោកុប្បត្តិបានបង្ហាញពីគម្រោងរបស់ព្រះនៅក្នុងសេចក្តីទំនាយ។នៅពេលដែលព្រះកំណត់ដាក់ទោសដល់សាតាំងនោះ,ព្រះបានប្រកាសថាសាតាំងបានក្លាយជាសត្រូវរបស់មនុស្ស។ហើយវាបានបន្តរនៅក្នុងការបំផ្លាញការប្រកបរបស់មនុស្សជាមួយនឹងព្រះ,ប៉ុន្តែវាមិនអាចបំផ្លាញជារៀងរហូតនោះទេ។

> *អញនឹងធ្វើឲ្យឯង ហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នាពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ˝* [១៥]

---

[១១] ១យ៉ូហាន ១:៥
[១២] រ៉ូម ៣:២៣
[១៣] មសព ២.៣ តើអ្នកណាខ្លះមានបាប?
[១៤] ១ពេត្រុស ១:២០
[១៥] លោកុប្បត្តិ ៣:១៥(មានការបន្ថែម)

សំនួរពិភាក្សា:
- តើមានវិធីអ្វីខ្លះដែលមនុស្សព្យាយាមដកអំពើបាបចេញដោយខ្លួនគេ?
- សូមពន្យល់ពីគម្រោងដែលព្រះមានសម្រាប់ប្រោសលោះមនុស្សដោយគំនិតរបស់អ្នក។

មនុស្សមួយចំនួនអាចនឹងគិតថាព្រះទ្រង់បានមានបន្ទូលប្រាប់ដល់សាតាំងថាមនុស្សម្នាក់ហើយនឹងពស់មួយនឹងត្រូវប្រយុទ្ធគ្នា។ប្រហែលជាសត្វពស់នឹងត្រូវខាំមនុស្សនៅត្រង់កែងជើងហើយមនុស្សនឹងត្រូវជាន់ក្បាលរបស់សត្វពស់នោះ។អ្វីដែលព្រះទ្រង់មានព្រះបន្ទូលនោះគឺថាកូនមនុស្សគឺព្រះយេស៊ូគ្រីស្ទនឹងត្រូវយាងមកយ៉ាងពិតប្រាកដ។



សាតាំងបានព្យាយាមយកឈ្នះទ្រង់ដោយឆ្កាងព្រះអង្គនៅលើឈើឆ្កាង។ទោះបីជាទង្វើរនេះមើលទៅដូចមានលទ្ធផលសម្រាប់វាក៏ដោយ, ប៉ុន្តែការនោះបានបង្ហាញថាវាគ្រាន់តែជាការដែលខាំកែងជើងទ្រង់តែប៉ុណ្ណោះ។ការសុគតរបស់ព្រះយេស៊ូបានសង្គ្រោះមនុស្សពីអំពើបាប, ហើយនៅក្នុងរូបភាពនេះ, ព្រះយេស៊ូបានជាន់ក្បាលរបស់សាតាំង។នៅពេលដែលព្រះយេស៊ូចេញពីផ្នូរហើយមានជ័យជំនះលើសេចក្តីស្លាប់,ទ្រង់បានយកឈ្នះលើសាតាំងនៅគ្រប់ផ្លូវទាំងអស់។

## រំលឹកឡើងវិញ:ការធ្លាក់ទៅក្នុងអំពើបាបរបស់មនុស្ស

អ័ដាមនិងអេវ៉ាបានរស់នៅក្នុងស្ថានបរមសុខដ៏ល្អឥតខ្ចោះដែលហៅថាអេដែន។ទេវតាមួយនៅក្នុងចំណោមទេវតារបស់ព្រះ,សាតាំង,បានជ្រើសរើសនៅក្នុងការបដិសេធព្រះហើយស្តាប់តាមខ្លួនឯង។ដោយការបះបោររបស់វា,សាតាំងបានសម្រេចចិត្តនៅក្នុង ការរង់ចាំដើម្បីល្បួងអេវ៉ាអោយធ្លាក់ទៅក្នុងអំពើបាប។នៅពេលដែលមានសេចក្តីល្បួងមកដល់,អ័ដាមហើយនឹងអេវ៉ាបានធ្លាក់ទៅក្នុងអំពើបាបដោយការជ្រើសរើសក្នុងការបដិសេធព្រះហើយចង់អោយខ្លួនគេបានដូចជា ព្រះ។ការកាត់ទោសដ៏បរិសុទ្ធនៃព្រះគឺបានបណ្តេញអ័ដាមនិងអេវ៉ាចេញពីសួនច្បារហើយ ការប្រកបទាក់ទងដ៏ល្អរវាងព្រះហើយនឹងមនុស្សត្រូវបានបាត់បង់ទៅ។ដោយព្រោះតែមានបាបនៅក្នុងពិភពលោក, លទ្ធផលដែលកើតមកតាមក្រោយដូចជា: ការឈឺចាប់,ការរងទុក្ខវេទនា,ជំងឺ,ហើយនឹងសេចក្តីស្លាប់។ប៉ុន្តែព្រះទ្រង់មានគម្រោងមួយ។ទ្រង់បានកំណត់ថាពេលមួយសាតាំងនឹងត្រូវបានបំបាក់។ក់។

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

យើងបានឃើញពីដំបូងហើយអំពីសេចក្តីត្រូវការសម្រាប់ព្រះយេស៊ូធ្វើជាយញ្ញបូជាសម្រាប់អំពើបាប។ពេលនេះយើងអាចចាប់ផ្តើមឃើញពីសេចក្តីស្រលាញ់ដ៏អស្ចារ្យដែលព្រះមានសម្រាប់មនុស្ស! ទោះបីជាមនុស្សបានបះបោរ, បដិសេធព្រះហើយស្តាប់តាមខ្លួនឯងក៏ដោយ, សេចក្តីស្រលាញ់របស់ព្រះនៅតែបន្តនៅក្នុងការផ្សះផ្សារមនុស្សអោយបានរស់នៅក្នុងសភាពដើមរបស់គេដែលជាកូនរបស់ព្រះហើយជាអ្នកដែលមានរូបអង្គដូចជាព្រះ។

# លំហាត់មេរៀន
## មេរៀនទី ២:ការធ្លាក់ទៅក្នុងអំពើបាបរបស់មនុស្ស

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.សាតាំងគឺជាទេវតាដែលបានជ្រើសរើសនៅក្នុងការស្តាប់តាមខ្លួនឯងហើយបដិសេធព្រះ។ |
| ☐ | ☐ | ២. សាតាំងមិនបានតាំងចិត្តនៅក្នុងការបំផ្លាញភាពជិតស្និតរវាងមនុស្សនិងព្រះនោះទេ។ |
| ☐ | ☐ | ៣. ដោយព្រោះតែអំពើបាប,អ័ដាមនិងអេវ៉ាបានឈានទៅរកវ័យចាស់ជរាហើយនឹងស្លាប់។ |
| ☐ | ☐ | ៤. បាបក៏ដឹកនាំទៅរកការបំផ្លាញដ៏ធំដែរ,សេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ(ការដាច់ចេញនៃព្រលឹងវិញ្ញាណរបស់យើងពីព្រះ)។ |
| ☐ | ☐ | ៥. មានផ្លូវរបស់មនុស្សជាច្រើនដែលយើងអាចដកអំពើបាបចេញដោយខ្លួនឯងបាន។ |
| ☐ | ☐ | ៦. អំពើបាបជាបញ្ហារសម្រាប់តែគ្រីស្ទានតែប៉ុណ្ណោះ,អ្នកដទៃទៀតមិនមានបញ្ហារនោះទេ។ |
| ☐ | ☐ | ៧.ព្រះមានគម្រោងមួយសម្រាប់យញ្ញបូជាមួយដែលអាចដកអំពើបាបសម្រាប់អស់អ្នកដែលមានជំនឿ។ |
| ☐ | ☐ | ៨. នៅក្នុងរូបភាពមួយ,ព្រះយេស៊ូបានជាន់ក្បាលសាតាំងដោយការសុគតលើឈើឆ្កាង។ |



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. រួចពស់ក៏និយាយទៅស្ត្រីថា អ្នក________________________________។ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបាន________________________________ព្រមទាំងដឹងការខុសត្រូវផង(លោកុប្បត្តិ ៣:៤-៥)។

២.ដ្បិតឈ្នួលរបស់អំពើបាប នោះជា________________________________តែអំណោយទាននៃព្រះវិញ គឺ________________________________ដោយព្រះគ្រីស្ទយេស៊ូ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។(រ៉ូម ៦:២៣)

៣. នេះជាដំណឹង ដែលយើងខ្ញុំបានឮពីទ្រង់ ហើយក៏ប្រាប់មកអ្នករាល់គ្នា គឺថាព្រះទ្រង់ជា__________________________ គ្មាន ________________________________នៅក្នុងទ្រង់សោះ(១យ៉ូហាន ១:៥)។

៤.អញនឹងធ្វើឲ្យឯង ហើយនឹងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹង____________________ ហើយឯងនឹង________________________________(លោកុប្បត្តិ ៣:១៥)។



## សំនួរសំខាន់

១. ហេតុអ្វីបានជាសាតាំងព្យាយាមល្បួងអេវ៉ា?

២.ហេតុអ្វីបានជាព្រះមិនទតរំលងអំពើបាបរបស់យើងហើយបន្តរនៅក្នុងទំនាក់ទំនងនៃសេចក្តីស្រលាញ់ទៀត?

៣. សូមពន្យល់ពីសេចក្តីទំនាយហើយនឹងរូបភាពពីលក្ខណៈនៃគម្ពីរលោកុប្បត្តិ ៣:១៥)

# គំនិតបន្ថែមនិងសំនួរដែលអាចនឹងមាន

# សេចក្ដីអធិស្ឋាន

# ការត្រៀមខ្លួន

មសព ការសិក្សារបន្ថែមសម្រាប់មេរៀនទី២:

- ២.១ សាតាំង: សត្រូវដ៏ធំរបស់មនុស្ស
- ២.២ អំពើបាបហើយនឹងសេចក្ដីស្លាប់ខាងព្រលឹងវិញ្ញាណ
- ២.៣ តើអ្នកណាខ្លះមានបាប?

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- លោកុប្បត្តិ ៤-១១

# មេរៀនទី ៣: ពិភពលោកមានបញ្ហារជាមួយនឹងអំពើបាប

## *សេចក្តីផ្តើម: ភាពរីករាលដាលនៃអំពើបាប*

បន្ទាប់ពីត្រូវបានបណ្តេញពីសួនច្បារអេដែន,អ័ដាមនិងអេវ៉ាបានចាប់ផ្តើមជីវិតថ្មីដែលមានការលំបាកហើយពិភពលោកកាន់តែអាក្រក់ឡើង។ក្រោយមក,កូនប្រុសទាំងពីររបស់ពួកគេបានកត់មក(កាអ៊ីន,អេបិល)ហើយគ្រួសាររបស់ពួកគេក៏បានរីកចំរើន។អ័ដាមហើយនឹងគ្រួសាររបស់គាត់ព្យាយាមរក្សាទំនាក់ទំនងជាមួយនឹងព្រះតាមរយៈការថ្វាយសត្វជាយញ្ញបូជា។ក្រោយមកសេចក្តីអំណរនៃជីវិតដ៏សាមញ្ញរបស់ពួកគេត្រូវបានបំផ្លាញដោយសារអំពើបាប។



## *ការហូរចូលនៃអំពើបាប*

អ័ដាមហើយនឹងអេវ៉ាបានរងទុក្ខវេទនាឈឺចិត្តយ៉ាងខ្លាំងដោយព្រោះតែកូនប្រុសច្បងរបស់ពួកគេកាអ៊ីនបានធ្លាក់ទៅក្នុងអំពើបាបដ៏ធំ។ព្រះបានដាស់តឿនដល់កាអ៊ីនថាអំពើបាបនឹងប្រើប្រាស់គាត់ប្រសិនណាបើគាត់មិនមានការប្រុងប្រយ័ត្ន។



*បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី?បើឯងធ្វើមិនល្អ នោះមានដង្វាយលោះបាបដេកនៅមាត់ទ្វារស្រាប់ហើយ ចិត្តវានឹងបណ្តោយតាមឯង ហើយឯងមានអំណាចលើវាដែរ។.* [១]

កាអ៊ីនបានប្រឆាំងនឹងការត្រាស់ហៅរបស់ព្រះសម្រាប់សេចក្តីសុខសាន្តនៅពេលដែលគាត់សម្លាប់ប្អូនរបស់គាត់ដោយព្រោះតែភាពច្រណែន។ទង្វើរដ៏ឃោរឃៅនោះជាទង្វើរដែលងាកទៅរកសេចក្តីអាក្រក់ដំបូងបំផុត។មនុស្សគឺមានភាពអាត្មានិយម,សំអប់គ្នា,បោកបញ្ឆោត,កាប់សម្លាប់,ហើយបានជ្រើសរើសនៅក្នុងការប្រព្រឹត្តអំពើអាក្រក់ជាច្រើន។នៅទីបំផុត,ព្រះបានទតមើលមកកាន់របស់ដែលទ្រង់បានបង្កើតដោយសេចក្តីស្រលាញ់ទាំងព្រះទ័យសោកស្តាយហើយនឹងព្រះទ័យអាណិតអាសូរ,ដោយរបស់ទាំងនោះបានខូច។ព្រះគម្ពីរចែងថា:

*ព្រះយេហូវ៉ាទ្រង់ឃើញថា ការអាក្រក់របស់មនុស្សបានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ*[២]

## *គ្រួសារនៃសេចក្តីជំនឿ*

ពីជំនាន់មួយទៅជំនាន់មួយ,បានបង្ហាញថាគុណតម្លៃនៃការដែលមានរូបអង្គនៃព្រះត្រូវបានបំផ្លាញដោយអំពើបាបកាន់តែខ្លាំងឡើង។ក្នុងពេលដែលមើលទៅដូចជាបាត់បង់ទៅហើយនោះ,មានគ្រួសារមួយដែលនៅតែបម្រើព្រះនៅក្នុងចំណោមមនុ ស្សអាក្រក់នៅក្នុងពិភពលោកទាំងមូល។ក្រុមគ្រួសារនេះជាគ្រួសាររបស់បុរសម្នាក់ដែលមានឈ្មោះថាណូអេ,ប្រពន្ធរបស់គាត់,កូនប្រុសបីនាក់ហើយនឹងប្រពន្ធរបស់គេ។នៅក្នុងជំនាន់មួយដែលពោរពេញដោយការអាក្រក់,ព្រលឹងទាំងប្រាំបីនេះបានព្យាយាមរស់នៅដោយសេចក្តីជំនឿហើយស្តាប់តាមព្រះ។

---

[១] លោកុប្បត្តិ ៦:២២

[២] ហេព្រើរ ១១:១

សំនួរពិភាក្សា:

- តើអ្នកបានដឹងអ្វីខ្លះអំពីភាពច្រណែនរបស់កាអ៊ីន? (សូមមើលពីការនេះនៅក្នុងគម្ពីរលោកុប្បត្តិ ៤)
- តើអ្នកគិតថាលោកអ័ដាមនិងអេវ៉ាមានអារម្មណ៍យ៉ាងណានៅពេលដែលគេបានដឹងពីអំពើបាបរបស់កាអ៊ីន?



ព្រះបានទតឃើញពីជំនឿរបស់លោកណូអេ។ទ្រង់បានបង្ហាញគម្រោងមួយដល់លោកណូអេ។ព្រះទ្រង់នឹងបានធ្វើអោយមានទឹកជំនន់ដែលគ្របដណ្តប់ផែនដីទាំងមូល។ មនុស្សអាក្រក់ទាំងអស់ត្រូវបានបំផ្លាញ,ហើយព្រះបានចាប់ផ្តើមផែនដីសារជាថ្មីជាមួយនឹងគ្រួសាររបស់លោកណូអេ,ជាគ្រូវនៃមនុស្សជាតិ។ព្រះបានសង្គ្រោះលោកណូអេហើយនឹងគ្រួសាររបស់គាត់នៅក្នុងទូកធំមួយដែលត្រូវបានហៅថា "ហិប"[៣] លោកណូអេបានសាងសង់ទូកធំ។ព្រះបានបញ្ជូនសត្វគ្រប់ប្រភេទតាមពូជទៅក្នុង

៣.១ ទូកធំនោះ។លោកណូអេហើយនឹងគ្រួសាររបស់គាត់បានថែរក្សាសត្វទាំងនោះ

។ការនេះប្រហែលជាចម្លែកសម្រាប់លោកណូអេ។ប៉ុន្តែទោះបីជាគាត់មិនយល់ជាហេតុអ្វីក៏ដោយនោះ,លោកណូអេបានស្តាប់តាមហើយនឹងធ្វើតាមបង្គាប់ព្រះគ្រប់ជំពូក។ព្រះគម្ពីរបានចែងថាជំនឿរបស់លោកណូអេអស្ចារ្យណាស់។

*"ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្តីដែលព្រះបានបង្គាប់គាត់ធ្វើការនោះសំរេចទាំងអស់។"*[៤]

យើងទាំងអស់គ្នាអាចរៀនមេរៀនពីជំនឿប្រភេទនេះបាន។ពេលខ្លះព្រះអាចនឹងត្រាស់ហៅយើងអោយធ្វើអ្វីមួយដែលមើលទៅចម្លែកសម្រាប់យើង។ប៉ុន្តែជំនឿរបស់យើងលើព្រះគួរតែដឹកនាំយើងអោយស្តាប់តាមបង្គាប់របស់ព្រះអង្គ។ជំនឿអាចបកស្រាយបានថាការទុកចិត្តទាំងស្រុងឬទំនុកចិត្ត[៥] ។យើងគួរតែមានការទុកចិត្តទាំងស្រុងហើយនឹងទំនុកចិត្តលើគម្រោងរបស់ព្រះសម្រាប់ជីវិតរបស់យើង!

# *ទឹកជំនន់ពន្លិចផែនដី*

នៅពេលដែលលោកណូអេបានសាងសង់ទូកធំរួចរាល់ហើយនោះ,ព្រះបានហៅសត្វ គ្រប់ប្រភេទតាមពូជនៅក្នុងពិភពលោកអោយចូលទៅក្នុងទូក។ពេលណាដែលលោកណូអេហើយនឹងគ្រួសាររបស់គាត់បានចូលទៅក្នុងទូកធំហើយនោះ,ព្រះបានបិទទ្វារទូក។បន្ទាប់មកក៏ចាប់ផ្តើមមានភ្លៀង។ព្រះក៏បានធ្វើអោយមានទឹកចេញពីទីដែលជ្រៅបំផុតនៃផែនដីឡើងមកដែរ។ ទឹកក៏ចាប់ផ្តើមគ្របដណ្តប់ផ្ទៃដីទាំងមូល។ប្រហែលជាមានមនុស្សខ្លះបានរត់សំដៅទៅទូកធំហើយគោះទ្វារ។យើងមិនអាចដឹងបានថាតើលោកណូអេគិតបែបណានោះទេ,ប៉ុន្តែដោយព្រោះតែលោកណូអេគឺជាមនុស្សដូចជាយើងដែរនោះ,យើងអាចស្រមៃបានថាគាត់អាចមានអារម្មណ៍សោកសៅណាស់នៅពេលដែលឮសម្លេងស្រែកយំរបស់គេ។ជីវិតដែលនៅខាងក្រៅទូកទាំងប៉ុន្មានត្រូវសំអាតចេញពីផែនដីទាំងអស់។

គឺដោយព្រោះតែអំពើបាបទើបធ្វើអោយមានទឹកជំនន់កើតឡើង[៦]។ ហើយដោយព្រោះតែអំពើបាបទើបមនុស្សទាំងអស់នោះត្រូវយំសោក។ដោយព្រោះតែអំពើបាបទើបជីវិតទាំងអស់ត្រូវបោសសំអាតចេញពីផែនដី។តើវាជាភាពសោកសៅ ៣.២
យ៉ាងណាចំពោះព្រះជាម្ចាស់ដែលទ្រង់ត្រូវបំផ្លាញរបស់ដែលទ្រង់បានបង្កើតស្ទើរតែទាំងស្រុង[៧]។យើងអាចសិក្សានូវមេរៀនពីការនេះបានគឺថាៈព្រះទ្រង់បរិសុទ្ធ,ហើយទ្រង់មិនអាចមានចំណែកជាមួយនឹងអំពើបាបបានឡើយ។ យើងទាំងអស់គ្នាត្រូវតែប្រាកដថាអំពើបាបរបស់យើងត្រូវបានដកចេញពីជីវិតរបស់យើង។នៅក្នុងជំនាន់របស់យើងទាំងអស់គ្នា,ផ្លូវតែមួយដែលអាចដកយកអំពើបាបចេញពីជីវិតរបស់យើងបានគឺមានតែតាមរយៈការស្តាប់បង្គាប់ដោយសេចក្តីជំនឿនៅក្នុងព្រះយេស៊ូគ្រីស្ទតែប៉ុណ្ណោះ។[៨]

អស់រយៈពេលជាងមួយឆ្នាំ,ដែលទឹកជំនន់បានគ្របដណ្តប់នៅលើផែនដីទាំងមូល។នៅទីបំផុតទឹកក៏បានស្រកហើយឱកាសថ្មីសម្រាប់មនុស្សក៏មានឡើង។លោកណូអេបានរៀបចំសត្វសម្រាប់ជាយញ្ញបូជានៅក្នុងការគោរពដល់ព្រះ។ព្រះបានបង្កើតសញ្ញាដ៏វិសេសជាមួយនឹងមនុស្សគឺថាទ្រង់នឹងមិនបំផ្លាញពិភពលោកដោយសារទឹកជំនន់ទៀតនោះទេ។[៩]

---

៣ មសព ៣.១ ទូកលោកណូអេ-ជាដំណាងនៃពួកជំនុំ
៤ លោកុប្បត្តិ ៦:២២
៥ ហេព្រើរ ១១:១
៦ ហាបាគុ ១:១៣;១ពេត្រុស ១:១៦;មសព ៣,២ តើអាចអោយព្រះដ៏ល្អធ្វើយ៉ាងដូច្នោះដោយរបៀបណា?
៧ ១យ៉ូហាណ១:៥-៧
៨ ហេព្រើរ ១:១-៤
៩ លោកុប្បត្តិ ៨:២០-៩:២៣

សំនួរពិភាក្សា:

- តើអ្វីគឺជាភាពខុសគ្នាចំពោះការជឿលើព្រះហើយនិងទុកចិត្តព្រះ?
- តើអ្នកគិតថាលោកណូអេហើយនឹងគ្រួសារគាត់មានអារម្មណ៍យ៉ាងណាបន្ទាប់ពីទឹកជំនន់ស្រកទៅ?

# បាបបង្ខូចផែនដីថ្មី

មើលទៅហាក់បីដូចជារាល់ទាំងអំពើអាក្រក់ត្រូវបានសម្អាតចេញពីផែនដីហើយ។យ៉ាងណាមិញ,លោកណូអេហើយនឹងគ្រួសាររបស់គាត់នៅតែមាន"បញ្ហារនៃអំពើបាប"ដដែល។ទោះបីជាពួកគេជាមនុស្សដែលមានជំនឿរឹងមាំហើយស្រលាញ់ព្រះក៏ដោយ,គឺនៅតែមានពេលវេលាដែលពួកគេមានបញ្ហារជាមួយនឹងអំពើបាប។គម្ពីរលោកុប្បត្តិបានកត់ត្រាអំពីពេលមួយដែលលោកណូអេបានស្រវឹងយ៉ាងខ្លាំងហើយនៅអាក្រាតកាយ,កូនប្រុសរបស់គាត់ម្នាក់មិនបានបង្ហាញពីការគោរពដល់គាត់។លទ្ធផលនៃអំពើបាបបាននាំយកបណ្តាសាមកលើក្រុមគ្រួសាររបស់គាត់ [១០]។

គ្រួសាររបស់លោកណូអេបានចំរើនឡើងនៅលើផែនដី។ទីក្រុងដ៏ធំត្រូវបានបង្កើតឡើង,ហើយមនុស្សបានសម្រេចការដ៏អស្ចារ្យជាច្រើន។ មានមូលហេតុមួយដែលមនុស្សធ្វើការជាមួយគ្នាបានយ៉ាងល្អដោយព្រោះតែគេប្រើភាសាតែមួយ ។មានទីក្រុងដ៏អស្ចារ្យមួយដែលត្រូវបានហៅថាបាបិល។នៅក្នុងទីក្រុងនោះមនុស្សប្រមូលគ្នាដើម្បីសាងសង់ប៉មមួយដែលខ្ពស់រហូតដល់លើមេឃហើយគេចង់សង់អោយដល់ស្ថានសួគ៌។គោលបំណងរបស់គេគឺមិនមែនដើម្បីថ្វាយសិរីល្អដល់ព្រះនោះទេ,ប៉ុន្តែដើម្បីធ្វើអោយខ្លួនគេបានការកោតសរសើរវិញ ។ពួកគេចង់ស្មើរជាមួយនឹងព្រះ។[១១]



ការនេះគឺដូចជាអំពើបាបដំបូងដែលសាតាំងបានប្រើនៅក្នុងការបញ្ឆោតអេវ៉ាដែរ!វាបានប្រាប់ស្ត្រីថានាងនឹងបានដូចជាព្រះ។មនុស្សមានបញ្ហារយ៉ាងខ្លាំងនៅក្នុងការកំណត់ថាតើអ្នកណាដែលនឹងត្រូវសោយរាជ្យធ្វើជាព្រះនៅក្នុងជីវិតរបស់គេ។យើងត្រូវតែជ្រើសរើសនៅក្នុងការបម្រើអ្នកណាម្នាក់[១២] ។

មានមនុស្សជាច្រើនជ្រើសរើសនៅក្នុងការបម្រើខ្លួនរបស់គេ។ពួកគេគឺជាព្រះសម្រាប់ជីវិតរបស់ខ្លួនគេ,ទោះបីជាគេចង់ឬមិនចង់ក៏ដោយ។[១៣]ព្រះទ្រង់មានព្រះទ័យអោយយើងចុះចូលក្នុងសេចក្តីស្រលាញ់របស់ទ្រង់ហើយអនុញ្ញាតអោយទ្រង់ដឹកនាំជីវិតរបស់យើង[១៤] ។តាមរយៈការនេះអនុញ្ញាតអោយទ្រង់បានបង្ហាញយើងទាំងអស់គ្នាពីផ្លូវនៅក្នុងការប្រោសលោះហើយនឹងជីវិតអស់កល្បជានិច្ច។

ដោយព្រះគុណនៃទ្រង់,ព្រះបានយាងចុះមកហើយបានដាក់ភាសាដ៏ទៃនៅក្នុងគំនិតហើយនឹងមាត់របស់មនុស្ស[១៥] ។ភ្លាមនោះ,មនុស្សមិនអាចនិយាយរកគ្នាបានដូចមុនទៀតនោះទេ។ដោយព្រោះតែការបំភាន់នៅក្នុងភាសាជាច្រើន។ទ្រង់បានបញ្ឈប់អំពើបាបនៃការបដិសេធមួយនេះ។ទ្រង់ជ្រាបថាអំនួតដែលកើតពីប៉មបាបិលរិតតែធ្វើអោយពិភពលោកកាន់តែអាក្រក់ឡើង!

---

[១០] លោកុប្បត្តិ ៩:18-២៣
[១១] លោកុប្បត្តិ ១១:១
[១២] លោកុប្បត្តិ ១១:៣
[១៣] យ៉ូស្វេ ២៤:១៤-១៥
[១៤] រ៉ូម ៦:១៥-១៨
[១៥] លោកុប្បត្តិ ១១:៩

សំនួរពិភាក្សា:

- តើយើងអាចរៀនមេរៀនអ្វីខ្លះពីអំពើបាបរបស់លោកណូអេ?
- ហេតុអ្វីបានជាអ្នកគិតថាមនុស្សតែងតែចង់"ស្មើរជាមួយនឹងព្រះ"?

ដោយព្រោះតែមានការភាន់ច្រឡំយ៉ាងខ្លាំងនោះ,មនុស្សបានប្រមូលគ្នាមកជាក្រុមតូចៗហើយបានខ្ចាត់ខ្ចាយទៅពាសពេញពិភពលោក។ហើយនេះជាដើមកំណើតដែលធ្វើអោយមានកុលសម្ព័ន្ធ,ហើយនឹងវប្បធម៌ជាច្រើននៅក្នុងពិភពលោក។ប្រសិនបើមនុស្សមិនមានអំនួតយ៉ាងខ្លាំងនោះទេ,ប្រហែលជាមនុស្សនៅតែមានភាសាតែមួយរហូតដល់សព្វថ្ងៃហើយ។តែជាអកុសល,បាបហើយនឹងសាតាំងវានឹងមិនឈរនៅស្ងៀមហើយអនុញ្ញាតហើយមានសន្តិភាពនៅលើផែនដីនេះនោះទេ។សាតាំងវាតែងតែច្រណែនចំពោះសិរីល្អនៃព្រះ,ហើយវាតែងតែស្វែងរកវិធីនៅក្នុងការនាំយកអំពើបាប,ការបំផ្លាញ,ហើយនឹងសេចក្តីស្លាប់មកដល់មនុស្សដែលត្រូវបានបង្កើតនៅក្នុងរូបអង្គនៃព្រះ។



## *រំលឹកឡើងវិញៈពិភពលោកមានបញ្ហារជាមួយនឹងអំពើបាប*

អ័ដាមនិងអេវ៉ាបានសម្លឹងមើលទាំងចិត្តខ្ទេចខ្ទាំនៅពេលដែលអំពើបាបមានឥទ្ធិពលលើកូនរបស់ពួកគេ។ក្នុងពេលដែលគ្រួសារនៃមនុស្សមានការរីកចំរើននោះ,អំពើបាបក៏រីករាលដាលដែរ។ពិភពលោកទាំងមូលបានប្រែទៅជាអាក្រក់ដែលធ្វើអោយព្រះដ៏មានព្រះគុណសម្រេចព្រះទ័យបំផ្លាញផែនដីដោយទឹកជំនន់ដ៏ធំ។មានតែលោកណូអេហើយនឹងគ្រួសារគាត់ដែលមានជំនឿដ៏រឹងមាំតែប៉ុណ្ណោះដែលនៅមានជីវិត។យ៉ាងណាមិញអំពើបាបបានជ្រាបចូលទៅក្នុងគ្រួសារសុចរិតមួយនេះហើយវាបានបន្តរបំផ្លាញសិរីល្អនៃមនុស្សជាតិ។នៅពេលដែលមនុស្សបានប្រមូលគ្នាមកដើម្បីសង់ប៉មមួយឡើងដើម្បីធ្វើអោយខ្លួនគេបានដូចជាព្រះនោះ,ព្រះដែលជាអ្នកបង្កើត(ដោយព្រះគុណទ្រង់)បានបំភាន់ភាសារបស់គេហើយធ្វើអោយគេបែកខ្ញែកទៅជុំវិញផែនដីទាំងមូល។

ព្រះគម្ពីរបានបង្ហាញថាបញ្ហារនៃអំពើបាបមិនបានទៅណាឆ្ងាយនោះទេ។សូម្បីតែគ្រួសារដែលមានជំនឿរឹងមាំដូចជាគ្រួសាររបស់លោកណូអេក៏មានបញ្ហារជាមួយនឹងអំពើបាបដែរ។តាមរយៈរឿងនេះបានបង្ហាញយ៉ាងច្បាស់ថាត្រូវតែធ្វើអ្វីមួយដើម្បីផ្សះផ្សាទំនាក់ទំនងរវាងព្រះជាមួយនឹងមនុស្ស។ព្រះជាម្ចាស់បានបង្ហាញពីគម្រោងរបស់ព្រះអង្គ,បន្ទាប់ពីយើងបានសិក្សាអំពីពិភពលោកមានបញ្ហារជាមួយនឹងអំពើបាបហើយនោះ,ប្រហែលជាខគម្ពីរនេះនឹងអាចបង្ហាញថាព្រះទ្រង់មានព្រះទ័យស្រលាញ់យ៉ាងណាចំពោះយើងទាំងអស់គ្នាៈ

> *"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

# លំហាត់មេរៀន
## មេរៀនទី៣:ពិភពលោកមានបញ្ហារជាមួយនឹងអំពើបាប

ត្រូវ ខុស

☐ ☐ ១. ក្នុងពេលដែលគ្រួសាររបស់មនុស្សមានការរីកចំរើនកាន់តែច្រើនឡើងគេគ្មានបញ្ហារជាមួយនឹងអំពើបាបទៀតនោះទេ។

☐ ☐ ២. កាអ៊ីនបានប្រឆាំងនឹងការត្រាស់ហៅរបស់ព្រះសម្រាប់សេចក្តីសុខសាន្តនៅពេលដែលគាត់សម្លាប់ប្អូនរបស់គាត់ដោយភាពច្រណែន។

☐ ☐ ៣. លោកណូអេមានជំនឿលើព្រះដោយបានស្តាប់តាមហើយធ្វើតាមបញ្ញត្តិរបស់ព្រះ។

☐ ☐ ៤. មានមនុស្សជាងរាប់ពាន់អ្នកដែលបានរស់មានជីវិតនៅពេលមានទឹកជំនន់ពន្លិចផែនដី។

☐ ☐ ៥.ទោះបីជាគ្រួសាររបស់លោកណូអេមានជំនឿរឹងមាំក៏ដោយ,នៅតែមានពេលដែលពួកគេមានបញ្ហារជាមួយនឹងអំពើបាបដដែល។

☐ ☐ ៦. មូលហេតុមួយដែលមនុស្សធ្វើការជាមួយគ្នាបានយ៉ាងល្អគឺដោយព្រោះតែនៅក្នុងពេលនោះគេមានភាសាតែមួយប៉ុណ្ណោះ។

☐ ☐ ៧. មនុស្សដែលនៅក្នុងជំនាន់ប៉មបាបិលគេសង់ប៉មឡើងដើម្បីថ្វាយសិរីល្អដល់ព្រះ។

☐ ☐ ៨. មនុស្សជាក្រុមៗហើយនឹងភាសាផ្សេងៗគ្នាមានការចាប់ផ្តើមនៅជំនាន់ប៉មបាបិល។



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី បើឯងធ្វើមិនល្អ នោះមានដង្វាយលោះបាបដេកនៅមាត់ទ្វារស្រាប់ហើយ ចិត្តវានឹង ________________________ ហើយឯងមានអំណាចលើវាដែរ។(លោកុប្បត្តិ ៤:៧)

២. ព្រះយេហូវ៉ាទ្រង់ឃើញថា ការអាក្រក់របស់មនុស្សបានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែ________________________ដូច្នោះ(លោកុប្បត្តិ ៦:៥)

៣,ណូអេក៏ធ្វើដូច្នោះ____________________ដែលព្រះបានបង្គាប់ គាត់ធ្វើការនោះសំរេចទាំងអស់ ។(លោកុប្បត្តិ ៦:២២)

៤.តែបើសិនជាឯងរាល់គ្នាមិនគាប់ចិត្តនឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាទេ________________________ដែលឯងចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ ទោះបើជាព្រះទាំងប៉ុន្មាន ដែលពួកឰយុកោឯងបានគោរពប្រតិបត្តិនៅខាងនាយទន្លេ ឬអស់ទាំងព្រះរបស់សាសន៍អាម៉ូរីនេះ ដែលឯងរាល់គ្នានៅក្នុងស្រុកគេក្តី តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹង________________________តែមួយប៉ុណ្ណោះ។(យ៉ូស្វេ ២៤:១៥)



## សំនួរសំខាន់

១. តើលោកណូអេបង្ហាញសេចក្តីជំនឿរបស់គាត់លើព្រះដោយរបៀបណា?

២. ហេតុអ្វីបានជាព្រះសម្រេចព្រះទ័យនៅក្នុងការពន្លិចផែនដីទាំងមូល?

៣.ហេតុអ្វីបានជាព្រះរាប់ថាជាព្រះគុណ នៅក្នុងការដែលទ្រង់បំភាន់មនុស្សជាមួយនឹងភាសាផ្សេងៗពីគ្នា?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៣:

- ៣.១ ទូកលោកណូអេៈជាតំណាងអោយពួកជំនុំ
- ៣.២ តើអាចអោយព្រះដ៏ល្អធ្វើយ៉ាងដូច្នោះដោយរបៀបណា?

បទគម្ពីរសម្រាប់មេរៀនបន្ទាប់

- លោកុប្បត្តិ ១២,២០-២២



# មេរៀនទី ៤:គ្រួសារនៃសេចក្តីជំនឿ

## *សេចក្តីផ្តើម: ជំនាន់សង្ឃ*



ពេលវេលាកន្លងទៅ,សង្ឃភាគច្រើនជាដឹកនាំគ្រួសារហើយនឹងកុលសម្ព័ន្ធរបស់គេ។នៅក្នុងជំនាន់នៃព្រះគម្ពីរមួយនេះ,សង្ឃភាគច្រើនគឺជាឪពុកហើយជាជីតានៃគ្រួសារដ៏ធំដែលមានសមាជិកជាច្រើន,អស់ទាំងអ្នកដែលធ្វើការជាមួយហើយនឹងអ្នកបម្រើសម្លឹងមើលទៅគាត់ជាអ្នកដឹកនាំហើយជាចាស់ទុំ។សង្ឃមានតួរនាទីជាអ្នកនៅកណ្តាលហើយជាអ្នកដឹកនាំខាងព្រលឹងវិញ្ញាណក្រុមគ្រួសាររបស់គេចូលទៅរកព្រះជាម្ចាស់[១] ។នៅក្នុងជំនាន់នេះ,ព្រះបន្ទូលនៃព្រះមិនទាន់បានកត់ត្រានោះទេ,ដូច្នេះហើយមនុស្សធម្មតាត្រូវទាមទារអោយមានការបង្ហាញដោយផ្ទាល់ពីស្ថានសួគ៌ឬត្រូវមានសង្ឃជាអ្នកដឹកនាំពួកគេ។មនុស្សធម្មតាមានផ្លូវតិចតួចបំផុតនៅក្នុងការយល់ដឹងថាតើព្រះទ្រង់ជានរណាហើយអ្វីជាគោលបំណងរបស់មនុស្ស។[២]

## *លោកអ័ប្រាហាំជាសង្ឃ*

មានសង្ឃម្នាក់ដែលព្រះបានជ្រើសរើសជាអ្នកដែលគួរទុកចិត្តនៅក្នុងការដឹកនាំមនុស្សនៅក្នុងផ្លូវដ៏ត្រឹមត្រូវរបស់ព្រះគឺជាលោកអ័ប្រាហាំ[៣] ។គាត់មានជំនឿលើព្រះនៅក្នុងចំនុចមួយចំនួនដែលមនុស្សជាច្រើនមិនអាចមានដូចជាគាត់។នៅពេលដែលគម្ពីរលោកុប្បត្តិលើកឡើងអំពីគាត់,ឈ្មោះរបស់គាត់គឺអាប់រ៉ាម។ក្រោយមក,ព្រះបានផ្លូវឈ្មោះរបស់គាត់ទៅជាអ័ប្រាហាំដែលមានន័យថា "ឪពុកនៃជាតិសាសន៏ជាច្រើន"[៤] ។ព្រះបានត្រាស់ហៅអ័ប្រាហាំអោយចាកចេញពីសាច់ញាតិរបស់គាត់ហើយទៅរស់នៅក្នុងប្រទេសថ្មីមួយ។ដោយសេចក្តីជំនឿ,អ័ប្រាហាំបានដឹកនាំប្រពន្ធរបស់គាត់ព្រមទាំងអ្នកបម្រើរបស់ពួកគេទាំងអស់ចាកចេញពីឪពុករបស់គាត់ទៅទឹកដីថ្មីមួយដែលហៅថាកាណាន។



គម្ពីរលោកុប្បត្តិបានរៀបរាប់យ៉ាងច្រើនអំពីគ្រួសាររបស់លោកអ័ប្រាហាំជាងមនុស្សផ្សេងទៀត។នៅក្នុងចំណោម៥០ជំពូកនៃគម្ពីរទាំងមូល,មាន៣៩ជំពូករៀបរាប់អំពីគ្រួសាររបស់លោកអ័ប្រាហាំ!លោកអ័ប្រាហាំមានការផ្សងព្រេងព្រមទាំងបញ្ហារជាច្រើននៅក្នុងជីវិតរបស់គាត់។គាត់គឺជាអ្នកចម្បាំង,ជាអ្នកគង្វាល,ជាអ្នកជំនួញហើយជាអ្នកដឹកនាំ។នៅទីបំផុត,គាត់បានឈានទៅដល់វ័យចាស់ជរា។អំឡុងពេលដែលគាត់ជាមនុស្សដែលមានភាពជោគជ័យនៅក្នុងជីវិតហើយមានទ្រព្យសម្បត្តិជាបរិបូរនោះ,គាត់គ្មានអ្នកណានឹងបន្តរវេនដែលគាត់អាចផ្ទេរកេរ្តិ៍មរតករបស់គាត់ទៅអោយនោះទេ។អ័ប្រាហាំមានសេចក្តីអៀនខ្មាសដោយព្រោះឈ្មោះរបស់គាត់មានន័យថា "ឪពុកនៃជាតតិសាសន៏ជាច្រើន"ប៉ុន្តែគាត់មិនអាចមានកូនសូម្បីតែមួយ។ទោះបីជាលោកអ័ប្រាហាំហើយនឹងប្រពន្ធរបស់គាត់ព្យាយាមរកផ្លូវដែលធ្វើអោយអ័ប្រាហាំក្លាយជាឪពុកក៏ដោយនោះ,ព្រះទ្រង់មានគម្រោងសម្រាប់ពួកគេ[៥] ។

---

[១] យ៉ូប ១:៣

[២] សូមមើលទៅក្នុងសេចក្តីបន្ថែម ក: ជំនាន់ខាងព្រលឹងវិញ្ញាណទាំងបី

[៣] លោកុប្បត្តិ ១២-២៥

[៤] លោកុប្បត្តិ ១៧:៥

[៥] លោកុប្បត្តិ ១៦:១-១៦,១៨:១-១៥



សំនួរពិភាក្សា:

- តើអ្នកណាខ្លះដែលជាតំណាងដូចជាសង្ឃនៅសម័យនេះដែលអ្នកធ្លាប់ជួបប្រទះ?
- លោកអ័ប្រាហាំនិងសារ៉ាមិនអាចមានកូនអស់រយៈពេលជាច្រើនឆ្នាំតើអ្នកគិតថាផលលំបាករបស់គាត់យ៉ាងណាទៅ?

សារ៉ាបានបានកន្លងផុតនូវឱកាសដែលស្រ្តីធម្មតាអាចមានគភ៌ក៏ទៅហើយ។យ៉ាងណាមិញ,ព្រះបានធ្វើអោយគាត់មានផ្ទៃពោះយ៉ាងអស្ចារ្យ។ ភាពសោកសៅហើយនឹងការទន្ទឹងរង់ចាំរបស់អ័ប្រាហាំហើយនឹងសារ៉ាបានក្លាយទៅជាសម្លេងយំរបស់ក្មេងប្រុសមួយ។អ័ប្រាហាំបានដាក់ឈ្មោះឲ្យកូននោះថាអ៊ីសាក់,ដែលមានន័យថា"សំណើច"។ពិតណាស់អ័ប្រាហាំហើយនឹងសារ៉ាសើចដោយសុភមង្គលហើយនឹងអំណរដែលព្រះបានប្រទានពរដល់ពួកគេក្នុងការដែលគេមានវ័យចាស់ណាស់ទៅហើយជាមួយនឹងកូនប្រុសមួយនេះ[៦] ។

# អ័ប្រាហាំត្រូវបានសាកល្បង

អ៊ីសាក់បានចំរើនឡើង,ព្រះបានត្រាស់ហៅអ័ប្រាហាំម្តងទៀត។គាត់ត្រូវយកកូនប្រុសរបស់គាត់មួយនេះដែលគាត់ស្រលាញ់,ថ្វាយអ៊ីសាក់ជាយញ្ញបូជានៅលើអាសនាថ្វាយដល់ព្រះ[៧] ។អ័ប្រាហាំត្រូវសម្លាក់កូនប្រុសតែមួយរបស់គាត់។ មុនពេលដែលយើងមានភាពព្រឺព្រួចនោះ,យើងត្រូវតែចងចាំថាព្រះទ្រង់ពិតជាមិនមានព្រះទ័យចង់បានយញ្ញបូជាយ៉ាងដូច្នោះនោះទេ។ ព្រះទ្រង់សព្វព្រះទ័យក្នុងសាកល្បងសេចក្តីជំនឿរបស់លោកអ័ប្រាហាំតែប៉ុណ្ណោះ។



នៅពេលដែលពួកគេទៅដល់កន្លែងដែលត្រូវថ្វាយយញ្ញបូជាហើយនោះ,អ៊ីសាក់បានជួយអ័ប្រាហាំសាងអាសនា។បន្ទាប់មកអ៊ីសាក់ត្រូវបានចងដាក់នៅលើអាសនា។ពិតជា,គាត់មានការភ័យខ្លាចណាស់ហើយ,ដោយភាពងឿងឆ្ងល់,ហើយមានទុក្ខសោកយ៉ាងខ្លាំង។អ័ប្រាហាំក៏មានទុក្ខយ៉ាងខ្លាំងនៅក្នុងចិត្តរបស់គាត់ណាស់ព្រមទាំងមានវិប្បដិសារីនៅក្នុងចិត្តណាស់ដែរ។នៅពេលដែលគាត់លើកកាំបិតឡើងរៀបនឹងសម្លាប់កូនរបស់គាត់នោះ,ទេវតានៃព្រះបានស្រែកមកឃាត់គាត់ថាឈប់:

> *"កុំឲ្យលូកដៃទៅលើកូនក្មេងនោះឡើយ*
> *កុំឲ្យធ្វើអ្វីដល់វាឲ្យសោះ*
> *ដ្បិតឥឡូវនេះអញដឹងថា*
> *ឯងកោតខ្លាចដល់ព្រះហើយ ដោយ*
> *ព្រោះមិនបានសំចៃទុកនូវកូនឯងតែ១*
> *នេះនឹងអញសោះ."[៨]*

ព្រះបានផ្តល់អោយនូវចៀមឈ្មោលដែលនៅជាប់នឹងគុម្ពព្រៃដែលនៅក្បែរនោះគឺជាយញ្ញបូជាជំនួសអ៊ីសាក់។អ័ប្រាហាំបានស្រាយចំណងកូនរបស់គាត់,ហើយបានយកចៀមឈ្មោលមកថ្វាយយញ្ញបូជានៅលើអាសនាថ្វាយដល់ព្រះ។អ័ប្រាហាំហើយនឹងអ៊ីសាក់បានត្រឡប់ទៅផ្ទះវិញជាមួយនឹងគ្នាដោយសេរីភាពដ៏លើសលប់។

# ទំនាយអំពីព្រះយេស៊ូនៅក្នុងព្រះពរ

ព្រះបានត្រាស់ហៅអ័ប្រាហាំអោយចេញមកខាងក្រៅនៅពេលយប់ហើយមើលទៅកាន់ផ្កាយនៅលើមេឃ។ព្រះមានបន្ទូលថា:

> *"អញនឹងឲ្យពរដល់ឯង ហើយនឹងចំរើនពូជឯងឲ្យមានគ្នាសន្ធឹកដូចផ្កាយនៅលើមេឃ,ហើយដូចខ្សាច់នៅមាត់សមុទ្រ,ពូជឯងនឹងបានគ្រប់គ្រងលើទ្វារក្រុងនៃពួកខ្មាំងសត្រូវ ។ គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង ពីព្រោះឯងបានស្តាប់តាមពាក្យអញ[៩] ។"*

---

[៦] លោកុប្បត្តិ ២១:១-១៧

[៧] លោកុប្បត្តិ ២២:១-២

[៨] លោកុប្បត្តិ ២២:១២

[៩] លោកុប្បត្តិ ២២:១៧-១៩

សំនួរពិភាក្សា:

- text



គម្រោងរបស់ព្រះសម្រាប់ការប្រោសលោះបានបន្តនៅក្នុងជំនាន់សង្ឃ។
ចាប់តាំងពីអ័ដាមដល់ណូអេ,ដល់អ័ប្រាហាំ,ព្រះបានបង្កើតសញ្ញាហើយនឹងសេ
ចក្ដីសន្យាដែលបានប្រទានព្រះពរដល់មនុស្សនៃជំនឿដ៏អស្ចារ្យនេះ[១០]។ហើយ
ទ្រង់ក៏បានបង្ហាញពីគម្រោងរបស់ព្រះអង្គនៅក្នុងការប្រោសលោះពិភព ៤.១
លោកផងដែរ។សូមពិចារណាពីលោកអ័ប្រាហាំៈគាត់ត្រូវបានហៅអោយ
បូជាកូនរបស់គាត់ប៉ុន្តែក្រោយមកកូនរបស់គាត់ត្រូវបានដោះលែងអោយមាន
សេរីភាពរួចពីសេចក្ដីស្លាប់នោះ។ព្រះបានប្រទានព្រះរាជបុត្រាទ្រង់តែមួយម
កធ្វើជាយញ្ញបូជា។



អ្វីដែលខុសគ្នានោះគឺព្រះមិនបានរំដោះព្រះយេស៊ូនោះទេ។ទ្រង់បានអនុញ្ញាតអោយព្រះយេស៊ូសុគតនៅលើឈើឆ្កាង។ទ្រង់បានសុគតជាយញ្ញបូជាសម្រាប់អំពើបាបរបស់យើង[១១]។ តើយើងបានបម្រើព្រះដ៏អស្ចារ្យយ៉ាងណាទៅ!សូមពិចារណាពីចំនុចនេះៈព្រះមិនបានទាមទារអោយអ័ប្រាហាំធ្វើអ្វីដែលព្រះអង្គទ្រង់មិនមានព្រះទ័យនៅក្នុងការធ្វើដោយព្រះអង្គផ្ទាល់នោះឡើយ!ការពិតព្រះបានអនុញ្ញាលោកអ័ប្រាហាំជៀសផុតពីការឈឺចាប់ដ៏ខ្លាំងមួយនោះ។ប៉ុន្តែព្រះអង្គទ្រង់បានឆ្លងកាត់នូវការឈឺព្រះទ័យដោយព្រោះតែសេចក្ដីស្រលាញ់ដ៏អស្ចារ្យដែលទ្រង់មានសម្រាប់យើងទាំងអស់គ្នា។

សូមពិចារណាអំពីសេចក្ដីសន្យាដែលទ្រង់បានអោយលោកអ័ប្រាហាំមើលទៅលើមេឃនៅពេលយប់ៈដំបូង,ទ្រង់បានសន្យាថាពូជលោកអ័ប្រាហាំនឹងបានចម្រើនឡើងដូចជាផ្កាយនៅលើមេឃ។រូបភាពមួយនេះបានក្លាយជាការពិតដែលលោកអ័ប្រាហាំបានក្លាយជាឪពុកនៃជាតិសាសន៍ដ៏ធំមួយដែលហៅថាអ៊ីស្រាអែល។ព្រះក៏បានសន្យាថាគ្រប់ទាំងមនុស្សនៅក្នុងពិភពលោកទាំងមូលនឹងបានទទួលព្រះពរ។គឺផ្តោតទៅលើព្រះយេស៊ូ,ទ្រង់បានយាងមកជាពូជពង្សរបស់លោកអ័ប្រាហាំ[១២] ។តាមរយៈព្រះយេស៊ូ,ដំណឹងរបស់គ្រីស្ទានបានមកដល់គ្រប់ទាំងមនុស្សជាតិទាំងអស់ ,ហើយអ្នកណាក៏អាចទទួលបានសេចក្ដីសង្គ្រោះដោយព្រះគុណនៃព្រះតាមរយៈសេចក្ដីជំនឿបានដែរ[១៣] !ពិតណាស់ពិភពលោកទាំងមូលទទួលបានព្រះពរដោយព្រោះតែសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ!

# *គ្រួសាររបស់លោកអ័ប្រាហាំនៅតែមានបញ្ហារជាមួយអំពើបាប*

សាតាំងវានៅតែមមារញឹកគ្រប់ពេលទាំងអស់,នៅក្នុងការល្បួងហើយនឹងបំផ្លាញមនុស្សជាតិ។ក្នុងពេលដែលសង្ឃដឹកនាំគ្រួសារគេអោយអំពាវនាវរកព្រះនាមព្រះអម្ចាស់នោះ,មនុស្សដែលកោតខ្លាចព្រះទាំងនេះនៅតែមានបញ្ហារជាមួយនឹងអំពើបាប។តើព្រះជាអម្ចាស់ទ្រង់មានព្រះគុណករុណាហើយនឹងការអត់ធ្មត់យ៉ាងណាទៅនំ,ដែលទ្រង់បានអត់ទ្រាំជាមួយនឹងមនុស្សដែលមានពេលខ្លះប្រឆាំងនឹងទ្រង់!សេចក្ដីសន្យានៃព្រះសង្គ្រោះជាព្រះមេស៊ីនឹងមិនយាងមកជាឆាប់នោះឡើយ!

ទោះបីជាសង្ឃដូចជាអ័ប្រាហាំមិនមែនសុទ្ធតែប្រព្រឹត្តការដែលត្រឹមត្រូវនោះទេ,ហើយវាជាការសំខាន់ដែលយើងបានដឹងអំពីការនេះ។[១៤] អ័ប្រាហាំជាមនុស្សម្នាក់,ហើយគាត់មិនមែនជាមនុស្ស"វិសេស"នោះទេ។លោកណូអេ,លោកអ័ប្រាហាំហើយនឹងសង្ឃដ៏ទៃទៀតដែលមាននៅក្នុងព្រះគម្ពីរ,មានបញ្ហារជាមួយអំពើបាបដូចជាអ្នកហើយនឹងខ្ញុំដែរ។ពួកគេត្រូវបានល្បួង,មានពេលខ្លះពួកគេត្រូវបានធ្លាក់ទៅក្នុងសេចក្ដីល្បួងនៃអំពើបាបទាំងនោះ។ការសម្រេចចិត្តរបស់ពួកគេនៅក្នុងការបដិសេធព្រះហើយនឹងស្តាប់តាមខ្លួនឯងត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរទុកជាឧទាហរណ៍សម្រាប់យើងទាំងអស់គ្នា។

---

[១០] មសព ៤.១ ពេលដែលព្រះបង្កើតសេចក្ដីសន្យា
[១១] ១យ៉ូហាន ២:២
[១២] ម៉ាថាយ១:១-១៧,លូកា ៣:២៣-២៨
[១៣] រ៉ូម ១:១៦, អេភេសូ ២:៨-១០
[១៤] លោកុប្បត្តិ ១២:១០-២០;រ៉ូម ១៥:៤

សំនួរពិភាក្សា:

- នៅក្នុងឧទាហរណ៍ដែលនិយាយអំពីកូនប្រុសរបស់លោកអ័ប្រាហាំហើយនឹងព្រះរាជបុត្រានៃព្រះតើមានអ្វីជាភាពខុសគ្នារ?
- ហេតុអ្វីបានជាយើងត្រូវសិក្សាអំពីអំពើបាបរបស់លោកអ័ប្រាហាំ?

មិនមែនតែម្តងនោះទេប៉ុន្តែពីរដងដែលអ័ប្រាហាំធ្វើខុស,អ័ប្រាហាំមានការភ័យខ្លាចថាអ្នកដំទៃអាចនឹងសម្លាប់គាត់ដោយព្រោះតែភាពច្រណែនដែលគាត់មានប្រពន្ធដ៏ស្រស់ស្អាត។ដូច្នេះហើយបានជាគាត់បញ្ឆោតគេដោយប្រាប់ថានាងជាប្អូនស្រីរបស់គាត់[១៥] ។ ទង្វើរដែលបង្ហាញពីភាពកំសាករបស់គាត់ត្រូវបានត្រាប់តាមដោយកូនប្រុសរបស់គាត់អ៊ីសាក់។ក្នុងវ័យជំទង់,គាត់ក៏មានសេចក្តីភ័យខ្លាចចំពោះការបាត់បង់ជីវិតរបស់គាត់ហើយបានប្រាប់អ្នកដំទៃថាប្រពន្ធគាត់គឺជាប្អូនស្រីរបស់គាត់[១៦] ។ចៅរបស់លោកអ័ ប្រាហាំ,យ៉ាកុបបានកុហកឪពុករបស់គាត់នៅក្នុងការក្លែងខ្លួនធ្វើជាបងប្រុសរបស់គាត់ដើម្បីបញ្ឆោតឲ្យឪពុកបានឲ្យពរដល់គាត់ជាមួយនឹងមរតករបស់គ្រួសារមកកាន់គាត់ ![១៧] ចៅទួតរបស់លោកអ័ប្រាហាំបានលក់ប្អូនប្រុសរបស់គេឲ្យធ្វើជាទាសករហើយបានកុហកដល់ឪពុករបសគេ,ដោយប្រាប់ថាកូនប្រុសរបស់គាត់បានស្លាប់ទៅហើយ![១៨]



# គ្រួសារលោកអ័ប្រាហាំបានរីកចំរើនទៅជាប្រជាជាតិតូចមួយ

បន្ទាប់ពីលោកអ័ប្រាហាំស្លាប់ទៅ,គ្រួសាររបស់គាត់បានចំរើនឡើង។ព្រះបានប្រទានឈ្មោះដល់គ្រួររបស់គាត់ថាអ៊ីស្រាអែល
ដែលមានន័យថាមានជ័យជំនះនៅចំពោះព្រះ[១៩] ។ឈ្មោះនេះត្រូវជាមួយនឹងចំនុចដែលថាអ៊ីស្រាអែលនឹងបានក្លាយជាប្រទេសដែល
៤.២ ពោរពេញដោយព្រះពរដែលព្រះនឹងបានប្រទានព្រះពរដល់ពិភពលោកទាំងមូល។ [២០] ប្រជាជាតិអ៊ីស្រាអែលដ៏តូចត្រូវបានរុំព័
ទ្ធដោយប្រទេសធំៗហើយនឹងមនុស្សអាក្រក់ជាច្រើន។ព្រះជ្រាបថាប្រសិនបើគេរស់នៅក្នុងទឹកដីកាណានពួកគេនឹងទទួលឥទ្ធិព
លដោយសារអំពើបាបជាច្រើនពីប្រទេសទាំងនោះ,ដូច្នេះហើយព្រះបានដឹកនាំកូនចៅជំនាន់ក្រោយរបស់លោកអ័ប្រាហាំអោយទៅរស់
នៅក្នុងប្រទេសអេស៊ីព្ទ។នៅទីនោះពួកគេត្រូវរស់នៅអស់រយៈពេល៤០០ឆ្នាំ។

## រំលឹកឡើងវិញៈ គ្រួសារនៃសេចក្តីជំនឿ

នៅក្នុងជំនាន់នេះ,សង្ឃដូចជាលោកអ័ប្រាហាំបានធ្វើជាអ្នកដឹកនាំខាងព្រលឹងវិញ្ញាណរវាងសម្ព័ន្ធគ្រួសាររបស់គាត់ចូលទៅរកព្រះ។ព្រះបានសន្យាជាមួយនឹងលោកអ័ប្រាហាំថាពូជរបស់គាត់នឹងធ្វើអោយពិភពលោកទាំងមូលទទួលបានព្រះពរពីព្រះ(ព្រះគម្ពីរនឹងបង្ហាញថាព្រះយេស៊ូបានសម្រេចសេចក្តីសន្យារបស់ព្រះ!)មនុស្សដែលពេញដោយសេចក្តីជំនឿទាំងនេះមានពេលខ្លះបានប្រឆាំងជាមួយនឹងព្រះហើយស្តាប់តាមខ្លួនឯង។ជីវិតរបស់ពួកគេគឺជាឧទាហរណ៏សម្រាប់យើងទាំងអស់គ្នាឲ្យបានយល់ថាមនុស្សទាំងអស់ត្រូវការជំនួយខាងព្រលឹងវិញ្ញាណហើយមនុស្សមិនអាចជួយខ្លួនឯងបានឡើយ។ជាចុងក្រោយ,ព្រះបានដឹកនាំកូនចៅជំនាន់ក្រោយរបស់លោកអ័ប្រាហាំទៅរស់នៅក្នុងទឹកដីនៃប្រទេសអេស៊ីព្ទជាកន្លែងដែលពួកគេរីកចំរើនទៅជាប្រទេសមួយ។ជាមួយនឹងសេចក្តីសន្យាដែលព្រះមានជាមួយលោកអ័ប្រាហាំ,ខគម្ពីរចងចាំសម្រាប់មេរៀននេះបានបង្ហាញនូវផ្លូវមួយទៀតដែលបញ្ជាក់ពីគម្រោងនៃព្រះដ៏វិសេសហើយនឹងសេចក្តីស្រលាញ់ដ៏អស្ចារ្យដែលព្រះមានសម្រាប់យើងទាំងអស់គ្នាៈ ។

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[១៥] លោកុប្បត្តិ ២០:១-១៨
[១៦] សូមមើលក្នុងលោកុប្បត្តិ ២៦
[១៧] សូមមើលក្នុងលោកុប្បត្តិ ២៧
[១៨] សូមមើលក្នុងលោកុប្បត្តិ ៣៧
[១៩] លោកុប្បត្តិ ៣២:២៨
[២០] មសព ៤.២ តើប្រជាជាតិអ៊ីស្រាអែលនៅតែជាប្រជារាស្ត្រជ្រើសរើសរបស់ព្រះដែរឬទេសព្វថ្ងៃនេះ?

# លំហាត់មេរៀន
## មេរៀនទី ៤: គ្រួសារនៃសេចក្តីជំនឿ

ត្រូវ ខុស

☐ ☐ ១. នៅក្នុងជំនាន់នេះ,ព្រះបន្ទូលព្រះមិនទាន់មានការកត់ត្រានោះទេ,ដូច្នេះហើយមនុស្សធម្មតាទាមទារអោយមានការបង្ហាញពីស្ថានសួគ៌ដោយផ្ទាល់ឬត្រូវបានដឹកនាំដោយសង្ឃ។

☐ ☐ ២.លោកអ័ប្រាហាំមានកូនជាច្រើនក្នុងពេលដែលគាត់មានវ័យក្មេងនៅឡើយ។

☐ ☐ ៣.លោកអ័ប្រាហាំបដិសេធនៅក្នុងការថ្វាយយញ្ញបូជាកូនប្រុសរបស់គាត់នៅលើអាសនា។

☐ ☐ ៤. ព្រះមិនបានបញ្ជាអោយលោកអ័ប្រាហាំធ្វើអ្វីដែលព្រះទ្រង់មិនមានព្រះទ័យនៅក្នុងការធ្វើដោយព្រះអង្គផ្ទាល់នោះឡើយ។

☐ ☐ ៥. សេចក្តីសន្យារបស់ព្រះសម្រាប់ព្រះពរនៃពិភពលោកទាំងមូលត្រូវបានសម្រេចដោយព្រះយេស៊ូ។

☐ ☐ ៦. សង្ឃដែលមាននៅក្នុងគម្ពីរលោកុប្បត្តិមិនដែលមានបញ្ហារជាមួយអំពើបាបឡើយ។

☐ ☐ ៧. ព្រះបានប្រទានឈ្មោះដល់គ្រួសារនេះថាអ៊ីស្រាអែល
មានន័យថាឪពុកនៃជាតិសសាន៏ជាច្រើន។

☐ ☐ ៨. ព្រះដឹកនាំប្រជាជាតិអ៊ីស្រាអែលទៅរស់នៅក្នុងប្រទេសអេស៊ីព្ទដើម្បីស្វែងរកការងារល្អប្រសើរ។



## ស្វែងរកអត្ថបទព្រះគម្ពីរ

១.ឈ្មោះឯងមិនត្រូវហៅថា ________________________ ទៀតទេ គឺត្រូវហៅថា________________________វិញ ដ្បិតអញបានតាំងឯងឲ្យធ្វើជាឪពុកនៃសាសន៍ជាច្រើន។(លោកុប្បត្តិ ១៧:៥)

២. រួចទ្រង់មានព្រះបន្ទូលថា កុំឲ្យលូកដៃទៅលើកូនក្មេងនោះឡើយ កុំឲ្យធ្វើអ្វីដល់វាឲ្យសោះ ដ្បិតឥឡូវនេះអញដឹងថា ________________________ ដោយព្រោះមិនបានសំចៃទុកនូវកូនឯងតែ១នេះនឹងអញសោះ។(លោកុប្បត្តិ ២២:១២)

៣. គ្រប់ទាំងសាសន៍នៅផែនដី ________________________ ដោយសារពូជឯង ពីព្រោះឯង ________________________។(លោកុប្បត្តិ ២២:១៨)



## សំនួរសំខាន់

១. ហេតុអ្វីបានជាព្រះប្រាប់អោយលោកអ័ប្រាហាំបូជាកូនប្រុសតែមួយរបស់គាត់ជាយញ្ញបូជា?

២. តើចំនុចមួយណានៅក្នុងចំណោមសេចក្តីសន្យាដែលបង្ហាញថាសេចក្តីសន្យារបស់ព្រះចំពោះលោកអ័ប្រាហាំបង្ហាញពីគម្រោងរបស់ព្រះអង្គនៅក្នុងការប្រោសលោះពិភពលោកតាមរយៈព្រះយេស៊ូ?

៣. ហេតុអ្វីបានជាមានសារៈសំខាន់ដែលយើងបានដឹងថាមនុស្សដូចជាលោកអ័ប្រាហាំមានបញ្ហារជាមួយនឹងអំពើបាប?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្ដីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៤:

- ៤.១ ពេលដែលព្រះបង្កើតសេចក្ដីសន្យា
- ៤,២តើអ៊ីស្រាអែលនៅតែជាប្រជារាស្ត្រដែលជ្រើសរើសដែរឬទេសព្វថ្ងៃនេះ?

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- និក្ខមនំ ១-៣,១២
- ចោទិយកថា ៥-៦

# មេរៀនទី ៥: អ៊ីស្រាអែលក្លាយជាទាសករហើយនឹងការប្រោសលោះ

## *ប្រជារាស្ត្រអ៊ីស្រាអែលក្លាយជាទាសករ*



គម្ពីរបន្ទាប់នៃព្រះគម្ពីរគឺ,និក្ខមនំ,ចាប់ផ្តើមជាមួយនឹងប្រជាជនអ៊ីស្រាអែលនៅក្នុងប្រទេសអេស៊ីព្ទ។បន្ទាប់ពីស្តេចផារ៉ោនដែលមានចិត្តល្អ[១] បានសុគតទៅសេចក្តីផារ៉ោនថ្មីបានឡើងគ្រប់គ្រង(ផារ៉ោននៅក្នុងភាសាអេស៊ីព្ទគឺជាឋានៈរបស់"ស្តេច")។ ផារ៉ោនមានការភ័យខ្លាចដោយព្រោះតែអ៊ីស្រាអែលកាន់តែចំរើនឡើហើយក្លាយជាប្រទេសមួយក្រែងអ៊ីស្រាអែលធ្វើសង្គ្រាមទាស់នឹងប្រទេសអេស៊ីព្ទ។ផារ៉ោនបានដាក់បញ្ជាបង្ខំធ្វើអោយអ៊ីស្រាអែលក្លាយជាទាសករ។[២] អស់រយៈ

៥.១ ពេលជាង៤០០ឆ្នាំ,អ៊ីស្រាអែលបានក្លាយជាទាសករ។ប៉ុន្តែព្រះទ្រង់បានឮសម្រែករបស់ពួកគេ។ពួកគេត្រូវការអ្នកសង្គ្រោះដើម្បីដោះអោយគេមានសេរីភាព។(អ្នកសង្គ្រោះគឺជាអ្នករំដោះអ្នកដ៏ទៃពីគ្រោះថ្នាក់។)[៣]

## *ម៉ូសេ:អ្នកសង្គ្រោះរបស់អ៊ីស្រាអែល*

ស្តេចផារ៉ោនដ៏អាក្រក់ថ្មីមួយទៀតបានព្យាយាមទប់ស្កាត់ការលូតលាស់របស់អ៊ីស្រាអែលដោយការសម្លាប់ក្មេងប្រុសដែលកើតមកទាំងអស់។ស្ត្រីសាសន៏អ៊ីស្រាអែលម្នាក់បានលាក់កូនប្រុសរបស់នាងនៅក្នុងកន្ត្រកហើយបានបណ្តែតកូននោះនៅក្នុងទន្លេនីលដើម្បីជៀសផុតពីការសម្លាប់របស់ទាហានអេស៊ីព្ទ។ព្រះនាងរបស់ប្រទេសអេស៊ីព្ទម្នាក់បានឃើញកូននោះនៅ ក្នុងគុម្ពត្រែងនៅជ្រាំងទន្លេ។ព្រះនាងបានដាក់ឈ្មោះអោយក្មេងនោះថាម៉ូសេ,ដែលមានន័យថាយកចេញ,ដោយព្រោះតែព្រះនាងបានយកគាត់ចេញពីទន្លេមក។តាមរយៈគម្រោងរបស់ព្រះជាម្ចាស់,ម្តាយរបស់ម៉ូសេត្រូវបានហៅមកអោយមើលថែកូនរបស់គាត់។នៅពេលដែលគាត់ផ្តាច់ដោះនោះ,"គាត់ត្រូវបាននាំមកអោយរស់នៅជាមួយនឹងព្រះនាងនៃប្រទេសអេស៊ីព្ទ។



ម៉ូសេរស់នៅក្នុងពិភពពីរផ្សេងគ្នា។ជីវិតមួយដែលពោរពេញដោយភាពកក់ក្តៅហើយនឹងទ្រព្យសម្បត្តិរបស់រាជ្យវង្សរបស់ស្តេចអេស៊ីព្ទ។ជីវិតមួយទៀតគឺជាភាពខ្វល់ខ្វាយ,ដោយព្រោះតែគាត់ដឹងថាប្រជាជាតិអ៊ីស្រាអែលកំពុងរងទុក្ខវេទនា។

ថ្ងៃមួយ,ម៉ូសេបានឃើញសាសន៏អេស៊ីព្ទធ្វើទារុណកម្មដាក់សាសន៏អ៊ីស្រាអែលម្នាក់។គាត់មិនអាចអត់ទ្រាំចំពោះអ្វីដែលគាត់បានឃើញនោះទេ។ដោយកំហឹងដ៏ខ្លាំង,ម៉ូសេបានសម្លាប់សាសន៏អេស៊ីព្ទនោះ។(ដូចជាមនុស្សដែលមានជំនឿរឹងមាំផ្សេងទៀតដែលមាននៅក្នុងគម្ពីរដែរ,ម៉ូសេនៅតែមានបញ្ហារជាមួយនឹងអំពើបាប។គាត់មានទោសដោយព្រោះបានសម្លាប់ជីវិតមនុស្សហើយធ្លាក់ទៅក្នុងសេចក្តីកំហឹងរបស់ខ្លួនគាត់។ទោះបីជាគាត់បានក្លាយជាមនុស្សដែលអស្ចារ្យក៏ដោយ,គាត់នៅតែជាមនុស្ស)។ស្តេចនៃប្រទេសអេស៊ីព្ទព្យាយាមសម្លាប់ម៉ូសេដើម្បីសងសឹក។គាត់បានបោះបង់ចោលភាពជាវង្សានុវង្សរបស់ប្រទេសអេស៊ីព្ទ,ម៉ូសេបានរត់ទៅរស់នៅក្នុងនគរផ្សេងទៀតហើយបានធ្លាក់ខ្លួនធ្វើជាអ្នកគង្វាលចៀម។



---

[១] លោកុប្បត្តិ ៤៧:៥-៦
[២] សូមមើលក្នុង និក្ខមនំ ១-២
[៣] សូមមើលក្នុង មសព ៥,១:តើអ្នកសង្គ្រោះជាអ្វី?

សំនួរពិភាក្សា:

- យើងនឹងបានឃើញថាម៉ូសេក្លាយជាអ្នកដឹកនាំដ៏អស្ចារ្យហើយជាអ្នកសង្គ្រោះ។ហេតុអ្វីបានជាយើងចំណាយពេលសិក្សាអំពីអំពើបាបរបស់គាត់?
- តើអ្នកធ្លាប់រស់នៅក្នុង"ប្រភពពីរផ្សេគ្នា"ដែរឬទេ?(អាចជាការប្រៀបប្រដូច។)

# ព្រះជាម្ចាស់ និង ផារ៉ោន





ច្រើនឆ្នាំបានកន្លងផុតទៅ។ថ្ងៃមួយ,កាលគាត់កំពុងឃ្វាលសត្វចៀម,គាត់បានឃើញភ្លើងចម្លែកមួយនៅជើងភ្នំ។នៅពេលដែលគាត់ទៅមើល,គាត់បានឃើញគុម្ពព្រៃកំពុងឆេះ។វានៅតែបន្តរឆេះហើយមិនស្រពោនឡើយ។ព្រះបានមានព្រះបន្ទូលមកកាន់ម៉ូសេពីគុម្ពព្រៃដែលកំពុងឆេះនោះ។ទ្រង់មានបន្ទូលប្រាប់ម៉ូសេថាទ្រង់បានឮពីសម្រែករបស់ប្រជាជនអ៊ីស្រាអែល ។ព្រះទ្រង់មានព្រះទ័យអោយម៉ូសេក្លាយជាអ្នកសង្គ្រោះរបស់
៥.២ ប្រជាជាតិមួយនេះ។ម៉ូសេមានការស្ទាក់ស្ទើរនៅក្នុងការធ្វើជាអ្នកដឹកនាំយ៉ាងដូច្នោះ,ប៉ុន្តែនៅចុងក្រោយគាត់បានយល់ព្រមនៅក្នុងការជួយ។[៤]

នៅពេលដែលម៉ូសេមកឈរចំពោះមុខផារ៉ោន,គាត់បានប្រាប់ដល់ស្តេចថាព្រះនៃប្រជាជនអ៊ីស្រាអែលបញ្ជាដល់ផារ៉ោនអោយអនុញ្ញាតអោយពួកគេចេញទៅ។ការនេះធ្វើអោយផារ៉ោនមានសេចក្តីអាម៉ាស់,ដោយព្រោះតែផារ៉ោនគិតខ្លួនទ្រង់គឺជាព្រះដែលគ្រប់គ្រងប្រទេសអេស៊ីព្ទ។នៅពេលដែលស្តេចផារ៉ោនមិនព្រមស្តាប់តាមនោះ,ព្រះបានប្រើម៉ូសេអោយធ្វើការអស្ចារ្យដែលបានហៅថា "គ្រោះកាចទាំងដប់"។គ្រោះកាចទាំងដប់នេះត្រូវបានបង្កើតមកដើម្បីបង្ហាញពីឫទ្ធានុភាពរបស់ព្រះដែលមានលើស្តេចផារ៉ោន។ឧទាហរណ៍មួយចំនួនដូចជា:ទឹកទន្លេក្លាយទៅជាឈាម,មានសត្វល្អិតមួយចំនួនដូចជាកង្កែប,រុយ,មមង់ដែលចូលមកក្នុងទឹកដីនោះ[៥] ។

គ្រប់ពេលដែលកើតមានគ្រោះកាច,ស្តេចផារ៉ោនធ្វើពុតជាសោកស្តាយហើយសូមទោសរហូតដល់ម៉ូសេដកយកគ្រោះកាចនោះចេញ,ឬទោះបីជាយ៉ាងណាស្តេចផារ៉ោននៅតែប្រឆាំងជាមួយនឹងការជាស់តឿនរបស់ព្រះជាម្ចាស់ដោយមិនដែលមានភាពសោកស្តាយ។មិនថាមានរឿងអ្វីកើតឡើងនោះទេ,នៅពេលចុងក្រោយស្តេចផារ៉ោននៅតែរឹងទទឹងឬ "មានចិត្តរឹង"។គ្រោះកាចនោះកាន់តែខ្លាំងឡើងៗ។សត្វទាំងអស់ចាប់ផ្តើមងាប់ហើយបានបាត់បង់គ្រប់ទាំងផលចំរូតទាំងអស់។

# បុណ្យរំលង:តំណាងឲ្យព្រះយេស៊ូ

គ្រោះកាចចុងក្រោយគឺជាគ្រោះកាចដែលខ្លាំងលើសជាងគ្រោះកាចណាទាំងអស់[៦] ។ព្រះបានបញ្ជូនទេវតានៃសេចក្តីស្លាប់មកក្នុងប្រទេសអេស៊ីព្ទ។ព្រះបានបញ្ជាអោយគ្រប់ផ្ទះទាំងអស់ត្រូវសម្លាប់ចៀមមួយហើយលាបផ្ទឹមទ្វារដោយឈាមរបស់ចៀមនោះ។កាលណាទេវតាចូលទៅក្នុងទីក្រុងនោះ,ហើយទេវតាមើលលើទ្វារផ្ទះនីមួយៗ។ប្រសិនបើមានឈាមនៅលើទ្វារ,នោះទេវតានឹងរំលងហើយមិនធ្វើអ្វីដល់អ្នកនៅក្នុងផ្ទះនោះឡើយ។ប្រសិនបើផ្ទះនោះគ្មានឈាមនៅលើផ្ទឹមទ្វារនោះទេ,នោះទេវតាចូលទៅហើយដកយកព្រលឹងរបស់កូនច្បងរបស់គ្រួសារនោះ(កូននោះត្រូវស្លាប់)។ប្រជាជនអ៊ីស្រាអែលទាំងអស់បានស្តាប់តាមព្រះ,ប៉ុន្តែប្រជាជនអេស៊ីព្ទមិនព្រមស្តាប់តាមនោះទេ។នៅយប់នោះប្រជាជនអេស៊ីព្ទ(សូម្បីតែស្តេចផារ៉ោន)បានស្រែកយំនៅពេលដែលគេបានដឹងពីអ្វីដែលបានកើតឡើង។

---

[៤] សូមមើលក្នុង មសព ៥,២ :ម៉ូសេ -តំណាងអោយព្រះយេស៊ូ
[៥] និក្ខមនំ ៥-១០
[៦] និក្ខមនំ១១

សំនួរពិភាក្សា:
- តើអ្នកគិតយ៉ាងដូចម្តេចដែលស្តេចផារ៉ោនមិនព្រមស្តាប់តាមលោកម៉ូសេជាច្រើនដង?
- តើអាចអោយមនុស្សនៅក្នុងពេលបច្ចុប្បន្ននេះមានចិត្តរឹងដូចស្តេចផារ៉ោនដោយរបៀបណា?



ព្រះក៏បានបញ្ជាអោយប្រជាជនអ៊ីស្រអែលរៀបចំម្ហូបអាហារពិសេសមួយ។ដែលហៅថាបុណ្យរំលង ,ដោយព្រោះតែពួកគេត្រូវបានតម្រូវអោយបរិភោគនៅក្នុងផ្ទះដែលគ្របដណ្តប់ដោយឈាមកាលដែលទេវតានៃសេចក្តីស្លាប់រំលងពួកគេ[៧]។អាហារដ៏វិសេសមួយពេលនេះគឺជាតំណាងអោយព្រះយេស៊ូគ្រីស្ទ។ដែលទ្រង់បានយាងមកធ្វើជា។ចៀមនៃបុណ្យរំលង។ដែលបានសុគតសម្រាប់អំពើបាបរបស់យើងទាំងអស់គ្នា។ដូចជាកូនចៀមនោះដែរ,ព្រះលោហិតរបស់ព្រះអង្គអាចការពារយើងពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ[៨] ។

៥.៣

## *ការចេញពីប្រទេសអេស៊ីព្ទ*

ស្តេចផារ៉ោនដែលបានបំបាក់ហើយធ្លាក់ខ្លួន,បានដោះលែងប្រជាជនអ៊ីស្រាអែល។ពួកគេបានប្រមូលទ្រព្យសម្បត្តិទាំងប៉ុន្មានហើយចាកចេញពីប្រទេសអេស៊ីព្ទនៅយប់នោះភ្លាម។ប្រជាជនអ៊ីស្រាអែលបានចាប់ផ្តើមការធ្វើដំណើរដ៏វែងឆ្ងាយត្រឡប់ទៅកាន់ទឹកដីសន្យាវិញ,ទឹកដីកាណាន។ពេលដែលពួកគេកំពុងតែធ្វើដំណើរនោះ,ស្តេចផារ៉ោនបានផ្លាស់ប្តូរគំនិត។ទ្រង់ហើយនឹងកងទាហានរាជ្យរថរបស់ទ្រង់បានដេញតាមប្រជាជនអ៊ី ស្រាអែល។គេបានតាមទាន់ប្រជាជនអ៊ីស្រាអែលនៅកន្លែងមួយដែលហៅថាសមុទ្រក្រហម។ប្រជាជនអ៊ីស្រាអែលត្រូវបានហ៊ុំព័ទ្ធដោយសមុទ្រហើយនឹងកងទ័ពរបស់ស្តេចផារ៉ោន។

ព្រះបានមានព្រះបន្ទូលប្រាប់ម៉ូសេអោយលើកដំបងរបស់គាត់ឡើងហើយលាតដៃរបស់គាត់ទៅលើ សមុទ្រ។នោះពេលដែលគាត់ធ្វើដូច្នោះ,ព្រះបានញែកទឹកចេញជាពីរ!កាលសមុទ្រញែកជាពីរហើយលេចដីគោកដែលនោះបាតសមុទ្រឡើងមកនោះ,ប្រជាជនអ៊ីស្រអែលប្រញាប់ឆ្លងទៅ។ផារ៉ោនបញ្ជាអោយទាហានរាជ្យរថដេញតាមពួកគេ។នៅពេលដែលប្រជាជនអ៊ីស្រអែលបានទៅដល់កន្លែងដែលមានសុវត្ថិភាពហើយទាហានរបស់អេស៊ីព្ទនៅក្នុងសមុទ្រនៅឡើយនោះ,ព្រះបានធ្វើអោយទឹកសមុទ្រត្រឡប់មកដូចដើមវិញ។ទាហានរបស់អេស៊ីព្ទត្រូវបានបំផ្លាញទាំងអស់។ព្រះបានសង្គ្រោះប្រជាជនអ៊ីស្រអែល។[៩]

## *ក្រឹត្យវិន័យលោកម៉ូសេ*




បន្ទិចក្រោយមកបន្ទាប់ពីព្រឹត្តិការណ៏នោះ,ព្រះបានត្រាស់ហៅលោកម៉ូសេអោយឡើងទៅលើភ្នំមួយដែលហៅថាស៊ីណៃ។នៅលើភ្នំនោះ,ព្រះបានប្រទានក្រឹត្យវិន័យទាំងដប់ប្រការដល់លោកម៉ូសេ។ក្រឹត្យវិន័យទាំងដប់ប្រការនោះគឺជាច្បាប់សម្រាប់ខាងសីលធម៌នេះគឺជាគ្រឹះនៃសេចក្តីសន្យាមួយដែលព្រះមានជាមួយនឹង អ៊ីស្រាអែល។ ចុងក្រោយ,ច្បាប់ទាំង៦១៣បានក្លាយជាក្រឹត្យវិន័យរបស់លោកម៉ូសេ។[១០] គម្ពីរនិក្ខមនំ,លេវីវិន័យ,ជនគណនា,ចោទិយកថាមានផ្ទុកនូវក្រឹត្យវិន័យលោកម៉ូសេ។

៥.៤

ក្រឹត្យវិន័យទាំងនោះគឺដើម្បីបង្រៀនប្រជាជនអ៊ីស្រាអែលអោយស្រលាញ់ហើយនឹងគោរពដល់ព្រះ។ក្រឹត្យវិន័យនោះក៏បង្រៀនមនុស្សអោយចេះស្រលាញ់គ្នាទៅវិញទៅមកដែរ។តាមរយៈអ៊ីស្រាអែល,ព្រះបានបង្ហាញពីគម្រោងការប្រោសលោះពិភពលោកទាំងមូលអោយយើងបានស្គាល់។

---

[៧] និក្ខមនំ១២
[៨] ១ពេត្រុស ១:១៨-១៩; ១កូរិនថូស ៥:៧; មសព ៥.៣ បុណ្យរំលង-ការបង្ហាញពីការសុគតរបស់ព្រះយេស៊ូ។
[៩] និក្ខមនំ១៣-២៨
[១០] មសព ៥,៤ តើគ្រីស្ទានត្រូវស្តាប់តាមក្រឹត្យលោកម៉ូសេដែរទេ?

សំនួរពិភាក្សា:

- ការឆ្លងកាត់សមុទ្រក្រហមគឺជាព្រឹត្តិការណ៏ដ៏អស្ចារ្យដែលបង្ហាញពីព្រះចេស្តានៃព្រះលើធម្មជាតិ។ប្រសិនបើអ្នកត្រូវបានអនុញ្ញាតអោយធ្វើជាសក្សីលើព្រឹត្តិការណ៏ណាមួយនៅក្នុងព្រះគម្ពីរតើអ្នកចង់ឃើញព្រឹត្តិការណ៏មួយណាជាងគេ?

# *យញ្ញបូជាជាឈាម*



ក្រឹត្យវិន័យបានបង្ហាញពីរោងឧបោសថ(ក្រោយមកហៅថាព្រះវិហារ)ជាកន្លែងដែលប្រជារាស្ត្ររបស់ព្រះអាចចូលមកដើម្បីថ្វាយបង្គំព្រះនៅកន្លែងមួយដែលបានកំណត់។ នៅទីនោះក៏មានសង្ឃដែលមានតួរនាទីជាអ្នកថ្វាយយញ្ញបូជាជាសត្វសម្រាប់ជា ដង្វាយលោះបាបដល់មនុស្សគ្រប់គ្នា។របៀបនៃការថ្វាយយញ្ញបូជាគឺដើម្បីបង្រៀនដល់ប្រជាជនអ៊ីស្រាអែលអោយបានយល់ថាដើម្បីសូមអោយមានការអត់ទោសដល់អំពើបាប,គឺមានតែមនុស្សដែលគ្មានបាបម្នាក់ស្លាប់ជំនួសតែប៉ុណ្ណោះ។នេះជាអ្វីដែល ព្រះសព្វព្រះទ័យអោយគេធ្វើ។សម្រាប់សញ្ញាដែលពួកគេមាន,ប្រជាជនអ៊ីស្រាអែលអាចយកឈាមរបស់សត្វមកជំនួសបាន។វាគ្រាន់តែអាចលុបលាងបាបរបស់គេបណ្តោះអាសន្ន ប៉ុណ្ណោះទេ។

ព្រះជាម្ចាស់បានបង្រៀនដល់ប្រជារាស្ត្រព្រះអង្គពីអ្វីត្រូវធ្វើនៅក្នុងការរង់ចាំពេលវេលានៃការយាងមករបស់ព្រះយេស៊ូ។របៀបនៃការថ្វាយយញ្ញបូជាគឺជាស្រមោល ៥.៥
នៃការសុគតរបស់ព្រះយេស៊ូ។[១១]ទ្រង់បានយាងមកក្នុងនាមជាយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់អំពើបាបរបស់មនុស្សទាំងអស់។ព្រះលោហិតរបស់ព្រះអង្គបានលាងជំរះអំពើបាបរបស់មនុស្សជារៀងរហូត,ដោយមិនត្រូវការថ្វាយយញ្ញបូជាម្តងហើយម្តងទៀតនោះឡើយ។

## *រំលឹកឡើងវិញ:អ៊ីស្រាអែលក្លាយជាទាសករហើយនឹងការប្រោសលោះ*

បន្ទាប់ពីបានទៅរស់នៅក្នុងប្រទេសអេស៊ីព្ទហើយបានរីកចំរើនជាប្រទេសមួយ,អ៊ីស្រាអែលបានក្លាយជាទាសករដោយសារស្តេចអាក្រក់។ក្រោយមក,ព្រះបានប្រើម៉ូសេអោយទៅរំដោះប្រជាជនរបស់ព្រះអង្គ។កាលដែលពួកគេត្រឡប់មកទឹកដីសន្យាវិញនោះ,ព្រះបានបានបង្កើតសញ្ញាដ៏វិសេសជាមួយនឹងពួកគេតាមរយៈក្រឹត្យវិន័យលោកម៉ូសេ។ស្រមោលរបស់ព្រះយេស៊ូត្រូវបានបង្ហាញតាមរយៈរបៀបនៃការថ្វាយយញ្ញបូជា,ដែលទ្រង់បានយាងមកដើម្បីធ្វើជាយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់អំពើបាបរបស់មនុស្សទាំងអស់។តាមរយៈក្រឹត្យវិន័យលោកម៉ូសេ ការប្រកបទាក់ទងរវាងព្រះជាមួយនឹងមនុស្សមានភាពល្អប្រសើរឡើង។ពេលនេះមនុស្សអាចអានហើយយល់ពីព្រះបន្ទូលនៃព្រះបាន។[១២] កាលដែលគម្រោងរបស់ព្រះមិនបានបិទនោះ,បានបង្ហាញយ៉ាងច្បាស់ថាព្រះទ្រង់មានព្រះទ័យស្រលាញ់ដល់យើងទាំងអស់គ្នាយ៉ាងច្រើនលើសលុប។

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[១១] មសព ៥.៥ ឈាមរបស់យញ្ញបូជា
[១២] សូមមើលនៅក្នុងសេចក្តីបន្ថែម ក:ជំនាន់ទាំងបីខាងព្រលឹងវិញ្ញាណ

# លំហាត់មេរៀន

## មេរៀនទី ៥:អ៊ីស្រាអែលក្លាយជាទាសករហើយនឹងការប្រោសលោះ

ត្រូវ ខុស

☐ ☐ ១. នៅក្នុងជំនាន់នេះ,ព្រះបន្ទូលព្រះមិនទាន់មានការកត់ត្រានោះទេ,ដូច្នេះហើយមនុស្សធម្មតាទាមទារអោយមានការបង្ហាញពីស្ថានសួគ៌ដោយផ្ទាល់ឬត្រូវបានដឹកនាំដោយសង្ឃ។

☐ ☐ ២.លោកអ័ប្រាហាំមានកូនជាច្រើនក្នុងពេលដែលគាត់មានវ័យក្មេងនៅឡើយ។

☐ ☐ ៣.លោកអ័ប្រាហាំបដិសេធនៅក្នុងការថ្វាយយញ្ញបូជាកូនប្រុសរបស់គាត់នៅលើអាសនា។

☐ ☐ ៤. ព្រះមិនបានបញ្ជាអោយលោកអ័ប្រាហាំធ្វើអ្វីដែលព្រះទ្រង់មិនមានព្រះទ័យនៅក្នុងការធ្វើដោយព្រះអង្គផ្ទាល់នោះឡើយ។

☐ ☐ ៥. សេចក្តីសន្យារបស់ព្រះសម្រាប់ព្រះពរនៃពិភពលោកទាំងមូលត្រូវបានសម្រេចដោយព្រះយេស៊ូ។

☐ ☐ ៦. សង្ឃដែលមាននៅក្នុងគម្ពីរលោកុប្បត្តិមិនដែលមានបញ្ហារជាមួយអំពើបាបឡើយ។

☐ ☐ ៧. ព្រះបានប្រទានឈ្មោះដល់គ្រួសារនេះថាអ៊ីស្រាអែលមានន័យថាឪពុកនៃជាតិសសាន៏ជាច្រើន។

☐ ☐ ៨. ព្រះដឹកនាំប្រជាជាតិអ៊ីស្រាអ៊ែលទៅរស់នៅក្នុងប្រទេសអេស៊ីព្ទដើម្បីស្វែងរកការងារល្អប្រសើរ។



## ស្វែងរកអត្ថបទព្រះគម្ពីរ

១.ឈ្មោះឯងមិនត្រូវហៅថា ______________________ ទៀតទេ គឺត្រូវហៅថា ______________________ វិញ ដ្បិតអញបានតាំងឯងឲ្យធ្វើជាឪពុកនៃសាសន៍ជាច្រើន។(លោកុប្បត្តិ ១៧:៥)

២. រួចទ្រង់មានព្រះបន្ទូលថា កុំឲ្យលូកដៃទៅលើកូនក្មេងនោះឡើយ កុំឲ្យធ្វើអ្វីដល់វាឲ្យសោះ ដ្បិតឥឡូវនេះអញដឹងថា ______________________ ដោយព្រោះមិនបានសំចៃទុកនូវកូនឯងតែ១នេះនឹងអញសោះ។(លោកុប្បត្តិ ២២:១២)

៣. គ្រប់ទាំងសាសន៍នៅផែនដី ______________________ ដោយសារពូជឯង ពីព្រោះឯង ______________________។(លោកុប្បត្តិ ២២:១៨)



## សំនួរសំខាន់

១. ហេតុអ្វីបានជាព្រះប្រាប់អោយលោកអ័ប្រាហាំបូជាកូនប្រុសតែមួយរបស់គាត់ជាយញ្ញបូជា?

២. តើចំនុចមួយណានៅក្នុងចំណោមសេចក្តីសន្យាដែលបង្ហាញថាសេចក្តីសន្យារបស់ព្រះចំពោះលោកអ័ប្រាហាំបង្ហាញពីគម្រោងរបស់ព្រះអង្គនៅក្នុងការប្រោសលោះពិភពលោកតាមរយៈព្រះយេស៊ូ?

៣. ហេតុអ្វីបានជាមានសារៈសំខាន់ដែលយើងបានដឹងថាមនុស្សដូចជាលោកអ័ប្រាហាំមានបញ្ហារជាមួយនឹងអំពើបាប?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៥:

- ៤.១ ពេលដែលព្រះបង្កើតសេចក្តីសន្យា
- ៤,២តើអ៊ីស្រាអែលនៅតែជាប្រជារាស្ត្រដែលជ្រើសរើសដែរឬទេសព្វថ្ងៃនេះ?

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- និក្ខមនំ ១-៣,១២
- ចោទិយកថា ៥-៦

# មេរៀនទី៦:ភាពរីកចំរើននិងការធ្លាក់ចុះរបស់អ៊ីស្រាអែល

## *សេចក្តីផ្តើម: អ៊ីស្រាអែលនៅក្នុងទឹកដីសន្យា*



ពេលដែលអ៊ីស្រាអែលបានចូលទៅដល់ក្នុងទឹកដីសន្យានោះ,លោកម៉ូសេបានបាត់បង់ជីវិតទៅហើយ។អ្នកដឹកនាំថ្មី,លោកយ៉ូស្វេបានដឹកនាំគេនៅក្នុងការវាយដណ្តើមទឹកដី។ព្រះគម្ពីរបានកត់ត្រាអំពីប្រវត្តិសាស្រ្តនៅក្នុងជំនាន់នោះដែលត្រូវបានហៅតាមឈ្មោះរបស់អ្នកដឹកនាំរបស់គេគឺ:យ៉ូស្វេ។ដូចជាមនុស្សនៅក្នុងជំនាន់របស់លោកណូអេហើយនឹងទឹកជំនន់ដែរ,ប្រទេសដែលនៅក្នុងទឹកដីកាណានគ្មានសីលធម៌ទាល់តែសោះ។ពួកគេប្រៀបបានដូចជាជំងឺមហារីកនៃអំពើបាបដែលអាចមានផលប៉ះពាល់ដល់ពិភពលោកទាំងមូល។ដោយសារព្រះគុណនៃទ្រង់,ព្រះបានប្រើអ៊ីស្រាអែលនៅក្នុងការបំផ្លាញប្រទេសទាំងនោះ។ បន្ទាប់មក,អ៊ីស្រាអែលបានប្រែក្លាយជាប្រទេសដែលបរិសុទ្ធមួយហើយជាអ្នកដែលរក្សានូវវិហារនៃសេចក្តីសង្ឃឹមសម្រាប់ពិភពលោកដែលអាចដឹកនាំមនុស្សអោយត្រឡប់មករកព្រះវិញ។

## *ការវិលជុំនៃអំពើបាបហើយនឹងការផ្លាស់ប្រែ*

ក្នុងពេលដែលអ៊ីស្រាអែលបានទទួលជ័យជំនះជាច្រើនហើយបានគ្រប់គ្រងផ្នែកជាច្រើននៃទឹកដីសន្យានោះ,ក៏មានពេលដែលពួកគេអនុញ្ញាតអោយប្រទេសអាក្រក់ទាំងនោះនៅមានជីវិតរស់នៅ។ដោយព្រោះតែគេមិនបានបោសសំអាតអំពើបាបចេញពីទឹកដីនោះ,ពួកគេបានធ្លាក់ទៅក្នុងអន្ទាក់នៃអំពើបាបហើយពេលខ្លះគេក៏បានធ្លាក់ទៅក្នុងសេចក្តីល្បួង។អ៊ីស្រាអែលបានក្បត់នឹងសេចក្តីជំនឿដែលគេមានលើព្រះហើយថ្វាយបង្គំរូបចម្លាក់និងព្រះក្លែងក្លាយ។

ព្រឹត្តិការណ៏ដែលបានកើតឡើងយមានដូចតទៅ:ដំបូងអ៊ីស្រាអែលបានប្រឆាំងជាមួយនឹងព្រះ។បន្ទាប់មកមានប្រទេសមួយចំនួនបានមកធ្វើអោយគេក្លាយជាទាសករ,អ៊ីស្រាអែលត្រូវបានរំលឹកដើម្បីអោយដឹងថាអំពើបាបវាអាក្រក់យ៉ាងណា។ក្រោយមកព្រះបានបញ្ជូនអោយមានវិរៈជនដ៏អស្ចារ្យដែលហៅថាពួកចៅហ្វាយ ដើម្បីមកដឹកនាំអ៊ីស្រាអែលអោយវិលត្រឡប់ទៅរកព្រះវិញ។(បុរសស្រ្តីអស្ចារ្យទាំងនោះបានធ្វើការអស្ចារ្យជាច្រើនដែលមានកត់ត្រានៅក្នុងព្រះគម្ពីរដែលមានឈ្មោះថាពួកចៅហ្វាយ។)គម្ពីរពួកចៅហ្វាយបានបញ្ចប់ដោយព្រឹត្តិការណ៏យ៉ាងអាប់អួរ។អស់រយៈពេលជាងរាប់រយឆ្នាំនៃការវិលជុំនេះ,ប្រទេសមួយនេះគ្មានកម្លាំង,គ្មានការណ៏ដឹកនាំច្បាស់លាស់នោះឡើយ។ព្រះគម្ពីរចែងថា:




> *នៅគ្រានោះឯងគ្មានស្តេចនៅស្រុកអ៊ីស្រាអែលទេ គឺមនុស្សទាំងឡាយតែងប្រព្រឹត្តការអ្វីតាមដែលគេយល់ឃើញថាត្រឹមត្រូវគ្រប់គ្នា.*[1]

[1] ពួកចៅហ្វាយ២១:២៥

សំនួរពិភាក្សា:

- តើអ្វីខ្លះដែលជាព្រះក្លែងក្លាយដែលយើងអាចនឹងធ្លាក់ទៅក្នុងការ ថ្វាយបង្គំរបស់ទាំងនោះក្នុងពេលបច្ចុប្បន្ននេះ?(តម្រុយ: ព្រះក្លែងក្លាយទាំងនោះមិនមែនសុទ្ធតែជារូបចម្លាក់នោះទេ)
- តើមានមេរៀនអ្វីដែលយើងអាចសិក្សាពីការវិលជុំនៃអំពើបាបហើយនឹងការរំដោះនេះ?

# *អ៊ីស្រាអែលទាមទារអោយមានស្ដេច*



សម្លឹងមើលទៅប្រទេសដ៏ទៃទៀតដែលនៅជុំវិញពួកគេ,អ៊ីស្រាអែលបានឃើញថាប្រទេសទាំងនោះមានស្ដេច។អ៊ីស្រាអែលខុសពីប្រទេសទាំងនោះ។ព្រះគឺជាស្ដេចរបស់គេហើយពួកចៅហ្វាយគឺជាអ្នកដឹកនាំរបស់គេ។អ៊ីស្រាអែលបានធុញទ្រាន់នៅក្នុងការបម្រើព្រះហើយចង់បាន
៦.១ ស្ដេចដែលជាមនុស្សវិញ[២]។ ព្រះបានដាស់តឿនពួកគេតាមរយៈពួកហោរា។(ហោរាគឺជាមនុស្សដែលព្រះបានមានព្រះបន្ទូលទៅកាន់គេដោយផ្ទាល់ហើយគេក៏បានប្រាប់ប្រជាជនពីអ្វីដែលព្រះបានមានព្រះបន្ទូល។មានពេលជាច្រើនដែលពួកគេធ្វើការអស្ចារ្យដើម្បីបញ្ជាក់ពីអំណាចដែលគេបានទទួលពីព្រះ)។ព្រះបានដាស់តឿនថាប្រសិនបើអ៊ី ស្រាអែលមានស្ដេច,ស្ដេចនោះអាចនឹងមិនកោតខ្លាចព្រះហើយនឹងដឹកនាំមនុស្សឲ្យធ្លាក់ទៅក្នុងអំពើបាប។ប្រជាជនអ៊ីស្រាអែលមិនព្រមស្ដាប់តាមឡើយ;ដូច្នេះហើយព្រះបានអនុញ្ញាតអោយគេមានស្ដេចមួយអង្គ។[៣] អ្នកឃើញដែរទេ,ព្រះជាម្ចាស់នៅតែអនុញ្ញាតអោយមនុស្សដែលមានរូបអង្គដូចជាព្រះអង្គនូវអំណោយទាននៃការជ្រើសរើស។ទោះបីជាគេមានការជ្រើសរើសមិនល្អក៏ដោយ,ព្រះទ័យព្រះអង្គសម្រាប់ទំនាក់ទំនងគឺដោយការជ្រើសរើសនិងដោយការតាំងចិត្តតាមរយៈសេចក្ដីស្រលាញ់។

# *ជំនាន់មួយដ៏រុងរឿង*

ស្ដេចទីមួយមានឈ្មោះថាសុល។ទ្រង់ត្រូវបានជ្រើសរើសដោយផ្ទាល់ពីព្រះហើយបានតែងតាំងដោយហោរាសាំយូអែល។នៅពេលដែលស្ដេចសុលជ្រើសរើសផ្លូវដែលមិនស្ដាប់តាមព្រះនោះ,សាំយូអែលត្រូវបានបញ្ជូនអោយប្រកាសនូវរាជសារមួយនេះ:

> *"តែឥឡូវនេះ រាជ្យទ្រង់មិនបាននៅតទៅទៀតទេ ដ្បិតព្រះយេហូវ៉ាទ្រង់រកបានមនុស្សម្នាក់ទៀត ដែលត្រូវនឹងព្រះហឫទ័យទ្រង់ ហើយទ្រង់បានតាំងអ្នកនោះឲ្យធ្វើជាអ្នកគ្រប់គ្រង លើពួករាស្ត្រទ្រង់វិញ ពីព្រោះព្រះករុណាមិនបានកាន់តាមសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់មកសោះ.*[៤] ៦.២

ស្ដេចទីពីរមានឈ្មោះថាដាវីឌ។ស្ដេចដាវីឌគឺជាមនុស្សដែលស្របតាមព្រះហឫទ័យព្រះ។ គាត់គោរពព្រះជាម្ចាស់ហើយបានដឹកនាំប្រជារាស្ត្រអោយដើរនៅក្នុងផ្លូវបរិសុទ្ធរបស់ព្រះ។ដោយព្រោះហេតុនេះបានជាព្រះប្រទានពរដល់គាត់។គ្រួសាររបស់គាត់បានក្លាយជាគ្រួសាររាជ្យវង្សដែលបានសោយរាជ្យរហូតដល់ការធ្លាក់ចុះ។ព្រះយេស៊ូគឺជាវង្សានុវង្ស របស់ស្ដេចដ៏អស្ចារ្យនេះ។ដូចជាខ្សែស្រលាយដែលបញ្ជាក់ពីគ្រួសាររបស់សាសន៍យូដា(ពូជពង្សរបស់អ៊ីស្រាអែលដែលនៅសល់ពីការធ្លាក់ចុះ)បានបង្ហាញថាព្រះយេស៊ូសក្តិសមធ្វើជាព្រះសង្គ្រោះហើយជាអ្នកប្រោសលោះពិភពលោកទាំងមូលដ៏ពិតប្រាកដ។

---

[២] ១សាំយ៉ូអែល ៨:៥;មសព ៦,១ "សូមបើកអោយយើងមានស្ដេចមួយអង្គមក!" ការដាស់តឿនអំពីអំពើបាបនៃពិភពលោក។
[៣] ១សាំយ៉ូអែល ៨:១១-២២
[៤] ១សាំយ៉ូអែល ១៣:១៤;មសព ៦,២ តើយើងអាចធ្វើជាបុរសនិងស្ត្រីដែលគាប់ព្រះហឫទ័យព្រះដោយរបៀបណា?

សំនួរពិភាក្សា:

- តើអ្នកគិតយ៉ាងដូម្ដេចនៅពេលដែលព្រះទ្រង់នៅតែបន្តប្រទានអោយមានការជ្រើសរើសដល់យើង,ដែលទ្រង់មិនបានធ្វើអោយយើងថ្វាយបង្គំទ្រង់ដូចជាមនុស្សយន្ត?

ស្តេចដាវីឌហើយនឹងបុត្រាទ្រង់ស្តេចសាឡូម៉ូនបានដឹកនាំអ៊ីស្រាអែលទៅរកការរីកចំរើនដ៏អស្ចារ្យ។ស្តេចដាវីឌបាននាំយកសេចក្តីសុខសាន្តមកកាន់ទឹកដីនោះ,ហើយដឹកនាំមនុស្សអោយគោរពនិងថ្វាយបង្គំព្រះជាម្ចាស់ ។ស្តេចសាឡូម៉ូនបានសាងសង់រោងឧបោសថដ៏ធំសម្រាប់ប្រជារាស្ត្រអ៊ីស្រាអែលចូលមកថ្វាយបង្គំព្រះ។ប្រទេសដែលនៅជុំវិញបានបញ្ជូនអ្នកសើបអង្កេតអោយមកសើបពីស្ថានភាពនៅក្នុងប្រទេសអ៊ីស្រាអែល។អណាចក្រមួយនេះបានរីកចំរើនទៅរកភាពរឹងមាំ, ទ្រព្យសម្បត្តិហូរហៀរហើយនឹងសិរីរុងរឿង។មើលទៅអ៊ីស្រាអែលបានក្លាយជាប្រទេសបរិសុទ្ធមួយហើយបានដឹកនាំពិភពលោកទាំងមូលអោយមានការផ្លាស់ប្តូរត្រឡប់មករកព្រះវិញ។

# ការធ្លាក់ចុះរបស់អ៊ីស្រាអែល

សាតាំងវាតែងតែពួនផ្ទក់,វាបានល្បួងហើយនឹងបំផ្លាញមនុស្សជាតិ។ក្នុងពេលដែលស្តេចដាវីឌហើយនឹងស្តេចសាឡូម៉ូនគឺជាស្តេចនៅក្នុងចំណោមស្តេចដ៏អស្ចារ្យនោះ,ពួកគេនៅតែមានបញ្ហារជាមួយនឹងអំពើបាប។ពួកគេមានទោសជាមួយនឹងអំពើបាបដ៏អាក្រក់មួយចំនួនដូចជាសាហាយស្មន់,សម្លាប់មនុស្ស,ថ្វាយបង្គំរូបព្រះ,ហើយនឹងភាពក្រអើតក្រទមជាដើម។នៅចុងបញ្ចាប់នៃការគ្រងរាជ្យរបស់ស្តេចសាឡូម៉ូន,ប្រជារាស្ត្រអ៊ីស្រាអែលមានការធុញទ្រាន់នឹងរាជ្យវង្សរបស់ស្តេច។ ពួកគេមានអារម្មណ៏ថាប្រទេសទាំងមូលធ្វើការជាច្រើនសម្រាប់តែផលប្រយោជន៏របស់គ្រួសាររាជ្យវង្ស។ដោយហេតុនោះ បានជាធ្វើអោយមានសង្គ្រាមរវាងគ្នាឯងកើតមានឡើង។មានតែពូជអំបូរពីរប៉ុណ្ណោះនៅក្នុងចំណោមពូជអំបូរទាំងដប់ពីរដែលមានភាពស្មោះត្រង់ជាមួយនឹងវង្សស្តេចដាវីឌ។ពូជអំបូរជាច្រើនបានបែងចែកនគរហើយចាប់ផ្តើមនគរថ្មីមួយ(ដែលគេនៅតែរក្សាឈ្មោះថាអ៊ីស្រាអែលដដែល)។

ពូជអំបូរដែលមានភាពស្មោះត្រង់ត្រូវបានហៅថាយូដា។ស្តេចរបស់ប្រទេសអ៊ីស្រាអែលថ្មីទាំងអស់សុទ្ធតែជាស្តេចអា ក្រក់។ចុងក្រោយ,ពួកគេត្រូវបានចាប់យកទៅធ្វើជាទាសករហើយមិនអាចវិលត្រឡប់មកវិញបានឡើយ។នៅក្នុងប្រទេសយូដាដែលមានភាពស្មោះត្រង់,មានទាំងស្តេចល្អហើយនឹងស្តេចអាក្រក់។

នៅចុងក្រោយស្តេចភាគច្រើនសុទ្ធសឹងជាស្តេចដែលអាក្រក់។ស្តេចទាំងនោះបានដឹកនាំប្រទេសយូដាអោយធ្លាក់ទៅក្នុងអំពើបាបហើយនឹងការបំផ្លេចបំផ្លាញ។ព្រះបានធ្វើអោយប្រជាជនទាំងនោះ ចេញពីប្រទេសរបស់គេហើយបានក្លាយជាទាសករហើយព្រះបានបំផ្លាញភាពស្រស់ស្អាតនៃទីក្រុង របស់គេដើម្បីបង្រៀនគេពីទោសកំហុសរបស់ខ្លួនគេ។ចុងក្រោយទ្រង់បានអនុញ្ញាតអោយគេវិលត្រឡប់មកទឹកដីសន្យាវិញ,ប៉ុន្តែវាមិនបានដូចពីមុនដែលជាប្រទេសដែលមានកិត្យានុភាពដូចជាពេលដែលលោកម៉ូសេហើយនឹងយ៉ូស្វេដឹកនាំគេ,ឬដូចជាពេលដែលស្តេចអស្ចារ្យដូចជាស្តេចដាវីឌហើយនឹងសាឡូម៉ូនសោយរាជ្យនោះឡើយ[៩] ។



[៩] សូមមើលនៅក្នុងគម្ពីរទំនុកតម្កើងសម្រាប់ការសរសើររបស់ស្តេចដាវីឌថ្វាយដល់ព្រះ។

សំនួរពិភាក្សា:

- ប្រសិនបើអ៊ីស្រាអែលជាប្រជារាស្ត្រវិសេសរបស់ព្រះ,ហេតុអ្វីបានជាទ្រង់អនុញ្ញាតអោយពួកគេត្រូវចាប់ខ្លួន,ធ្វើជាទាសករ?

# ពួកហោរាបង្ហាញផ្លូវ

ព្រះបានត្រាស់ហៅពួកហោរាអោយមកបង្រៀនដល់ពួកគេនៅក្នុងពេលវេលានោះ។ពួកហោរាទាំងនោះបានបង្រៀនដល់ប្រជារាស្ត្ររបស់ព្រះឲ្យគេធ្វើការផ្លាស់ប្រែ។ ពួកហោរាបានប្រកាសពីប្រវត្តិសាស្ត្រនៃសង្គ្រាមដែលមានរយៈពេលជាងរាប់រយឆ្នាំមុន។ ពួកគេបានបង្រៀនពីការកាត់ទោសរបស់ព្រះចំពោះមនុស្សអាក្រក់។ គេក៏បានបង្រៀនអំពីព្រះមេស៊ីផងដែរ(មានន័យថាអ្នកដែលបានជ្រើសរើស)។ព្រះអង្គត្រូវបានចាក់ប្រេងតាំងដោយព្រះចេស្តានៃព្រះដើម្បីសង្គ្រោះដល់អស់អ្នកណាដែលមានជំនឿហើយស្តាប់តាមព្រះ។មានទំនាយរាប់រយដែលបានទាយអំពីព្រះមេស៊ី។អ្វីដែលជាចំនុចល្អនៃទំនាយទាំងនោះគឺថាព្រះយេស៊ូបានសម្រេចគ្រប់ទាំងទំនាយអស់ទាំងនោះ!ទ្រង់គឺជាផ្លូវ ដែលព្រះបានបង្កើតមកនៅក្នុងការប្រោសលោះមនុស្សពីអំពើបាប។ខាងក្រោមនេះជាឧទារណ៍មួយចំនួនអំពីសេចក្តីទំនាយ:




## រំលឹកឡើងវិញ:ភាពរីកចំរើននិងការធ្លាក់ចុះរបស់អ៊ីស្រាអែល

ពេលដែលអ៊ីស្រាអែលបានទៅដល់ទឹកដីកាណានហើយនោះ,ពួកគេបានចាប់ផ្តើមវាយយកទឹកដីហើយតាំងលំនៅ។អំពើបាបមិនបានដកចេញពីពួកគេទាំងស្រុងនោះទេហើយវាបានចាប់ផ្តើមបំផ្លាញប្រទេសរបស់គេ។ទោះបីជាពួកចៅហ្វាយ,ស្តេច,ហើយហោរាបានព្យាយាមដឹកនាំហើយនឹងបង្រៀនគេពីផ្លូវរបស់ព្រះក៏ដោយ,ពួកគេមិនអាចបញ្ឈប់អ៊ីស្រាអែលពីអំពើបាបហើយនឹងការបដិសេធព្រះបានឡើយ។នៅទីបំផុតអណាចក្រនេះត្រូវបានបំផ្លាញនៅសល់តែសំណល់តែប៉ុណ្ណោះ។វាគឺជាពេលវេលានៃភាពងងឹតដែលបង្ហាញថាអំពើបាបគឺជាបញ្ហារដែលមនុស្សមិនអាចដោះស្រាយបានដោយខ្លួនឯងនោះឡើយ។

ប៉ុន្តែព្រះទ្រង់មានគម្រោង។គ្រប់ទាំងប្រវត្តិសាស្ត្រ,គ្រប់ទាំងការបង្កើត ,គ្រប់ទាំងជំនាន់ទាំងអស់គឺត្រូវបានរៀបចំសម្រាប់ការយាងមករបស់ព្រះយេស៊ូ។នៅក្នុងពេលវេលាដែលបានកំណត់,គម្រោងនៃការប្រោសលោះក៏បានមកដល់។អស់រយៈពេលជាងរាប់ពាន់ឆ្នាំ,មនុស្សបានស្វែងរកហើយនឹងទន្ទឹងចាំមើលផ្លូវដែលអាចវិលត្រឡប់ទៅរកព្រះវិញ។គម្រោងរបស់ព្រះនៅក្នុងការប្រោសលោះមនុស្សនៅពិភពលោកជិតដល់ពេលចាប់ផ្តើមហើយ។តើយើងបម្រើព្រះដ៏អស្ចារ្យយ៉ាងណាទ់!គ្មានអ្នកណាដែលស្រលាញ់ហើយយកចិត្តទុកដាក់ចំពោះយើងដូចជាព្រះនោះឡើយ។

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

៦ សម្រាប់ប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរនៅជំនាន់នេះសូមមើលនៅក្នុង:ពង្សាវតាក្សត្រទី១និងទី២,របាក្សត្រទី១និងទី២,អែសរ៉ា,នេហេមា,នាងអេសធើរ

៧ សូមមើលក្នុងគម្ពីរដូចជា យេរេមា,មីកា,ឬសេផានា

៨ សូមមើលក្នុងគម្ពីរ ដានីយ៉ែល

៩ សូមមើលក្នុងគម្ពីរដូចជា អូបាឌា,យូណាស,ឬណាហ៊ុមជាដើម

១០ យ៉ូហាន ១៤:៦

# លំហាត់មេរៀន
## មេរៀនទី ៦: ភាពរីកចំរើននិងការធ្លាក់ចុះរបស់អ៊ីស្រាអែល

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.អ៊ីស្រាអែលត្រូវបានបង្កើតមកដើម្បីធ្វើជាប្រជាជាតិបរិសុទ្ធហើយជាអ្នករក្សានូវសេចក្តីសង្ឃឹមដែលអាចនាំមនុស្សឲ្យវិលត្រឡប់មករកព្រះវិញ។ |
| ☐ | ☐ | ២. អ៊ីស្រាអែលមិនដែលមានបញ្ហារជាមួយអំពើបាបនោះទេក្នុងពេលដែលធ្វើដំណើរចូលទៅក្នុងទឹកដីសន្យា។ |
| ☐ | ☐ | ៣.ព្រះទ្រង់សព្វព្រះហឫទ័យចំពោះទំនាក់ទំនងដោយការជ្រើសរើសហើយនឹងការតាំងចិត្តដោយសេចក្តីស្រលាញ់។ |
| ☐ | ☐ | ៤. ស្តេចដាវីឌហើយនឹងបុត្រាទ្រង់គឺជាស្តេចដែលបានដឹកនាំប្រទេសអ៊ីស្រាអែលទៅរកភាពរុងរឿងដ៏អស្ចារ្យ។ |
| ☐ | ☐ | ៥. ដោយព្រោះតែស្តេចដាវីឌហើយនឹងបុត្រាទ្រង់ស្តេចសាឡូម៉ូនជាស្តេចនៅក្នុងចំណោមស្តេចដ៏អស្ចារ្យពួកទ្រង់មិនដែលមានបញ្ហារជាមួយនឹងអំពើបាបឡើយ។ |
| ☐ | ☐ | ៦. នៅចុងបញ្ចប់ស្តេចភាគច្រើនជាស្តេចអាក្រក់ហើយបានដឹកនាំយូដាសអោយធ្លាក់ទៅក្នុងអំពើបាបហើយនឹងការបំផ្លាញ។ |
| ☐ | ☐ | ៧. ព្រះបានត្រាស់ហៅពួកហោរាអោយមកបង្រៀននៅក្នុងជំនាន់ទាំងនេះ។ |
| ☐ | ☐ | ៨.ព្រះយេស៊ូមិនបានសម្រេចសេចក្តីទំនាយណាមួយនៅក្នុងព្រះគម្ពីរនោះឡើយ។ |



## ស្វែងរកអត្ថបទព្រះគម្ពីរ

១.នៅគ្រានោះឯង គ្មានស្តេចនៅស្រុកអ៊ីស្រាអែលទេ គឺមនុស្សទាំងឡាយតែងប្រព្រឹត្តការអ្វី តាមដែលគេ __________________ ថាត្រឹមត្រូវគ្រប់គ្នា។ (ពួកចៅហ្វាយ ២១:២៥)

២. តែឥឡូវនេះ រាជ្យទ្រង់មិនបាននៅតទៅទៀតទេ ដ្បិតព្រះយេហូវ៉ាទ្រង់រកបានមនុស្សម្នាក់ទៀត _________________ ហើយទ្រង់បានតាំងអ្នកនោះ ឲ្យធ្វើជាអ្នកគ្រប់គ្រង លើពួករាស្ត្រទ្រង់វិញ ពីព្រោះព្រះករុណាមិនបានកាន់តាមសេចក្តី ដែលព្រះយេហូវ៉ាបានបង្គាប់មកសោះ។(១សាយូអែល ១៣:១៤)

៣. គេយកសំលៀក__________________ចែកគ្នា,ឯអាវវែងរបស់ទូលបង្គំ គេក៏__________________ (ទំនុកតម្កើង ២២:១៨ សេចក្តីទំនាយអំពីព្រះយេស៊ូ)

៤. តែទ្រង់ត្រូវរបួស __________________, ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយ __________________ ដោយសារស្នាមរំពាត់នៅអង្គទ្រង់។(អេសាយ ៥៣:៥ សេចក្តីទំនាយអំពីព្រះយេស៊ូ)



## សំនួរសំខាន់

១. ហេតុអ្វីបានជាអ៊ីស្រាអែលនៅតែមានបញ្ហារជាមួយនឹងអំពើបាបពេលដែលគេបានរស់នៅក្នុងទឹកដីសន្យា?

២. ហេតុអ្វីបានជាព្រះនៅតែអនុញ្ញាតអោយអ៊ីស្រាអែលធ្វើការជ្រើសរើសខុស(ចង់បានស្តេចជាមនុស្ស)ក្រៅពីទ្រង់ប្រាប់គេពីអ្វីដែលត្រូវធ្វើគ្រប់ពេលវេលាវិញ?

៣. តើអ្វីខ្លះដែលជាភស្តុតាងដែលព្រះគម្ពីរប្រើនៅក្នុងការបង្ហាញថាព្រះយេស៊ូគឺជាផ្នែកមួយនៅក្នុងគម្រោងរបស់ព្រះដើម្បីប្រោសលោះមនុស្សពីបាប?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្ដីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៦:

- ៦.១ "សូមបើកអោយយើងមានស្ដេចមួយអង្គ!"- ការដាស់តឿនអំពីអំពើបាបនៃពិភពលោក
- ៦,២ តើយើងអាចធ្វើជាបុរសឬស្ត្រីដែល "គាប់ព្រះហឫទ័យព្រះដោយរបៀបណា?"

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- លូកា ១-២
- យ៉ូហាន ១
- ម៉ាថាយ ៥

# មេរៀនទី ៧:ព្រះជន្មរបស់ព្រះយេស៊ូ

## *សេចក្ដីផ្ដើម:ពេលវេលាដែលបានកំណត់*



មានភាពស្ងប់ស្ងាត់អំពីពួកហោរាអស់រយៈពេលជាង៤០០ឆ្នាំ។ជំនាន់នេះប្រជារាស្ត្ររបស់ព្រះដែលនៅសេសសល់ត្រូវបានហៅថាសាសន៍យូដា។ពួកគេរស់នៅក្រោមការគ្រប់គ្រងដ៏ព្រៃផ្សៃនៃចក្រភពដ៏មានឥទ្ធិពលមួយហៅថារ៉ូម។ផលប៉ះពាល់នៃអំពើបាបហើយនឹងការបះបោរមានទំងន់យ៉ាងធ្ងន់ដែលធ្លាក់លើសាសន៍យូដា។ពួកគេទន្ទឹងរង់ចាំសម្រាប់សេចក្ដីសន្យានៃការយាងមករបស់ព្រះមេស៊ីដើម្បីរំដោះគេអោយមានសេរីភាព។

ក្នុងពេលវេលានេះព្រះជាម្ចាស់បានរៀបគម្រោងក្នុងប្រោសលោះមនុស្សពីអំពើបាបរៀបនឹងសម្រេចហើយ។មុនពេលការយាងមករបស់ព្រះអង្គនៅលើផែនដីនេះ,ព្រះយេស៊ូគឺគង់នៅជាមួយនឹងព្រះវរបិតានៅក្នុងស្ថានសួគ៌ទ្រង់ជាផ្នែកមួយនៃព្រះដ៏អស់កល្បជានិច្ច។ទ្រង់គឺជាព្រះបន្ទូលដែលបានក្លាយជាសាច់ឈាម[១] ។ព្រះយេស៊ូបានលះបង់នូវភាពល្អឥតខ្ចោះនៃស្ថានសួគ៌មករស់នៅក្នុងចំណោមមនុស្ស។តើសេចក្ដីស្រលាញ់នៃព្រះមួយនេះ  អស្ចារ្យចំពោះយើងទាំងអស់គ្នាយ៉ាងណាន់!

## *ព្រះគ្រីស្ទបានប្រសូតហើយ!*

ពួកហោរាបានទាយអំពីគម្រោងរបស់ព្រះជាម្ចាស់។ពួកគេក៏បានទាយអំពីទីកន្លែងដែលព្រះសង្គ្រោះនឹងត្រូវប្រសូតផងដែរ!

> *"តែឯង ឱបេថ្លេហិម-អេប្រាតាអើយ ឯងដែលតូចនៅក្នុងពួកយូដាទាំងពាន់ៗនឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក"[២]*



៧.១ ស្ត្រីព្រហ្មចារីសាសន៍យូដាម្នាក់មានឈ្មោះថាម៉ារាជាគូរដណ្ដឹងរបស់បុរសម្នាក់ដែលមានឈ្មោះថាយ៉ូសែប។យប់មួយពេលដែលនាងកំពុងតែដេក,មានទេវតានៃព្រះបានមកជួបនឹងនាង។ទេវតាបានពោលទៅកាន់នាងថាព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងមកសណ្ឋិតលើម៉ារា,ហើយនាងនឹងមានផ្ទៃពោះក្នុងកាលដែលនាងជាស្ត្រីព្រហ្មចារីនៅឡើយ[៣] ។ បុត្រនេះនឹងធ្វើជាអ្នកប្រោសលោះ។ត្រូវដាក់ព្រះនាមដល់បុត្រនេះថាយេស៊ូ, ទោះបីជានាងនឹងជួបបញ្ហារជាច្រើនយ៉ាងណាក៏ដោយ,ក៏នាងព្រមធ្វើតាមព្រះហឫទ័យព្រះនៅក្នុងការធ្វើជាមាតានៃព្រះមេស៊ីដែរ។ព្រះយេស៊ូបានប្រសូតនៅក្នុងភូមិបេថ្លេហិម។ដោយហេតុនោះ, ព្រះយេស៊ូបានសម្រេចសេចក្ដីទំនាយអំពីការប្រសូតដែលបានទាយរាប់រយឆ្នាំមុន។

## *ព្រះយេស៊ូចាប់ផ្ដើមពន្ធ័កិច្ចព្រះអង្គ*

គម្ពីរដែលប្រាប់អំពីព្រះជន្មរបស់ព្រះយេស៊ូគឺមាននៅក្នុងគម្ពីរម៉ាថាយ,ម៉ាកុស,លូកា,ហើយនឹងយ៉ូហាន។គម្ពីរទាំងនេះហៅថាដំណឹងល្អ។ ពាក្យថា "ដំណឹងល្អ" គឺមានន័យថាដំណឹងអំពីការល្អ។ព្រះយេស៊ូមានព្រះជន្មសាមសឹបវស្សានៅពេលដែលព្រះអង្គចាប់ផ្ដើមពន្ធ័កិច្ចរបស់ព្រះអង្គ។ទ្រង់បានចាប់ផ្ដើមដោយការទទួលពិធីជ្រមុជទឹក។នៅពេលដែលព្រះយេស៊ូក្រោកចេញពីទឹកមក,ស្ថានសួគ៌បានបើកចំហរនៅវេលាដែលរីករាយបំផុតព្រះគម្ពីរចែងថា:

---

[១] យ៉ូហាន ១:១-៤,ហើយសូមមើលក្នុង ភីលីព ២:៦
[២] មីកា ៥:១
[៣] មសព ៧,១:ហេតុអ្វីបានជាការប្រសូតពីស្ត្រីព្រហ្មចារីមានសារៈសំខាន់?

សំនួរពិភាក្សា:

- *តើម៉ារាមានមានអារម្មណ៏យ៉ាងនៅពេលដែលនាងបានឮដំណឹងនេះ?ចុះចំណែកយ៉ូសែបវិញ?*
- *តើអ្នកអ្នកនឹងឆ្លើយតបយ៉ាងណាប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យធ្វើការវិសេសណាមួយនោះ?*

*ហើយព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើទ្រង់ មានរូបរាងដូចជាសត្វព្រាប ក៏ឮសំឡេងចេញពីមេឃថា "ឯងជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់"។*[៤]



ជាមួយនឹងការប្រទានពរពីស្ថានសួគ៌,ព្រះយេស៊ូបានចាប់ផ្ដើមប្រាប់មនុស្សគ្រប់គ្នាអំពីនគរស្ថានសួគ៌ថាជិតមកដល់ហើយ!ព្រះយេស៊ូក៏បានប្រមូលសិស្សរបស់ព្រះអង្គពីគ្រួសារផ្សេងៗពីគ្នា។អ្នកខ្លះគឺជាអ្នកនេសាទត្រីក្រ។អ្នកខ្លះទៀតជាអ្នកនយោបាយ, ហើយមានម្នាក់ជាអ្នកប្រមូលពន្ធ។អ្នកទាំងអស់នោះបានក្លាយជាសាវ័ករបស់ព្រះយេស៊ូ។[៥] ពួកអ្នកទាំងនោះបានរៀនហើយបានមើលពីរបៀបនៅក្នុងការជួយដល់ពួកជំនុំបន្ទាប់ពីពន្ធ័កិច្ចរបស់ព្រះយេស៊ូបានសម្រេច។ក៏មានស្ត្រីដែលពោរពេញដោយសេចក្ដីជំនឿដែលបានផ្គត់ផ្គង់ជាហិរញ្ញវត្ថុសម្រាប់សេចក្ដីត្រូវការរបស់ព្រះយេស៊ូហើយនឹងសាវ័ករបស់ព្រះអង្គផងដែរ។[៦]



# ព្រះយេស៊ូ:គ្រូអស្ចារ្យ

គម្ពីរដំណឹងល្អពោរពេញទៅដោយការបង្រៀនរបស់ព្រះយេស៊ូ។យើងក៏អាចមើលឃើញពីការបង្រៀនដែលយើងមិនធ្លាប់បានឃើញពីមុន;ដូចដែលមាននៅក្នុងការបង្រៀននៅលើភ្នំជាដើម[៧] ។ព្រះយេស៊ូបានប្រើឱកាសយ៉ាងដូច្នោះនៅក្នុងការបង្រៀនអំពីគោលបំណងរបស់ព្រះអង្គហើយនឹងគោលបំណងនៅក្នុងជីវិតរបស់មនុស្សម្នាក់ៗ។ទ្រង់មានព្រះទ័យឲ្យមនុស្សបានស្គាល់ពីផ្លូវដែលព្រះបានរៀបចំទុកសម្រាប់ការប្រោសលោះមនុស្ស។ពេលខ្លះ,ទ្រង់បង្រៀនមនុស្សដែលមានចំនួនតិច។ពេលខ្លះទៀតទ្រង់បង្រៀនមនុស្សរាប់ពាន់នាក់។កាលដែលពន្ធ័កិច្ចរបស់ព្រះអង្គកាន់តែមានប្រជាប្រិយភាពឡើង,មនុស្សមកពីគ្រប់ទីកន្លែងមកគាល់នឹងទ្រង់។ព្រះយេស៊ូបានបង្រៀនគេដោយប្រើឧទាហរណ៏ដ៏សាមញ្ញ។ដោយព្រោះតែមនុស្សភាគច្រើនគឺជាអ្នកស្រែចំការ,ព្រះអង្គតែងតែបង្រៀនដោយយកធម្មជាតិមកធ្វើជាឧទាហរណ៏[៨] ។

មានមេដឹកនាំសាសនាយូដាជាច្រើនមានភាពច្រណែនចំពោះប្រជាប្រិយភាពរបស់ព្រះយេស៊ូ។ពួកគេមិនសប្បាយចិត្តដែលព្រះយេស៊ូមិនបានចូលសាលារៀនត្រឹមត្រូវដូចពួកគេ,ប៉ុន្តែទ្រង់បានយល់ច្បាស់ពីក្រឹត្យវិន័យលោកម៉ូសេ។ពួកគេមិនសប្បាយចិត្តដែលព្រះយេស៊ូមានប្រជាប្រិយភាពក្នុងចំណោមហ្វូងមនុស្សជាជាងពួកគេ។ហើយពួកគេក៏មិនពេញចិត្តដែលព្រះយេស៊ូបង្រៀនថាព្រះអង្គយាងមកពីស្ថានសួគ៌ ហើយស្មើរនឹងព្រះជាម្ចាស់ ដែលជាព្រះវរបិតាដែរ។ពួកគេគិតថាព្រះយេស៊ូគឺជាគ្រូក្លែងក្លាយ,ហើយពួកគេបានព្យាយាមបង្កើតល្បិចកលនៅក្នុងការធ្វើគត់ព្រះអង្គ។



[៤] លូកា ៣:២២,មសព ៧,២ ហេតុអ្វីបានជាការ ជ្រមុជទឹករបស់ព្រះយេស៊ូមានសារៈសំខាន់?
[៥] យ៉ូហាន ១:៣៥-៥១;ម៉ាថាយ ៤:១៨-២២; ៩:៩-១៣; ១០:១-៤
[៦] លូកា ៨:១-៣
[៧] ម៉ាថាយ ៥-៧
[៨] ម៉ាថាយ ១៣:១-២៣

សំនួរពិភាក្សា:

- *ហេតុអ្វីបានជាព្រះយេស៊ូជ្រើសរើសសិស្សពីសណ្ឋានផ្សេងៗពីគ្នាយ៉ាងដូច្នេះ?*
- *ហេតុអ្វីបានជាព្រះយេស៊ូរើសយកការធ្វើចំការមកបង្រៀនមនុស្សអំពីព្រះ?*

# ព្រះយេស៊ូៈអ្នកធ្វើការអស្ចារ្យដ៏អស្ចារ្យ



ព្រះយេស៊ូបានធ្វើការអស្ចារ្យដើម្បីបង្ហាញថាទ្រង់ពិតជាមានអំណាចហើយនឹងចេស្តាពីស្ថានសួគ៌។[៩] ទ្រង់បានព្យាបាលអ្នកដែលមានជំងឺជាច្រើនដូចជាៈទ្រង់បានបើកភ្នែកមនុស្សខ្វាក់ឲ្យមើលឃើញ។ព្រះអង្គអាចធ្វើឲ្យមនុស្សថ្លង់ស្តាប់ឮ។ព្រះអង្គអាចប្រោសមនុស្សស្លាប់ឲ្យមានជីវិតរស់ឡើងវិញ។គ្រប់ទាំងការអស្ចារ្យទាំងអស់នេះគឺដើម្បីបង្ហាញមនុស្សថាទ្រង់មានអំណាចពីព្រះ។ព្រះអង្គមានអំណាចលើជំងឺហើយនឹងសេចក្តីស្លាប់ដើម្បីបង្ហាញថាព្រះមានអំណាចលើសាតាំង។ ពួកមេដឹកនាំសាសនាយូដាបានច្រណែនចំពោះការអស្ចារ្យដែលព្រះយេស៊ូបានធ្វើ។ពួកគេបានបដិសេធចំពោះអំណាចដ៏អស្ចារ្យរបស់ព្រះហើយព្យាយាមនិយាយថាព្រះយេស៊ូមានអំណាចគឺដោយព្រោះតែអារក្សទៅវិញ។ពួកគេបានធ្វើអោយខ្លួនគេខ្វាក់ភ្នែកពីសេចក្តីពិតដែលថាៈ ព្រះយេស៊ូធ្វើការអស្ចារ្យដើម្បីបង្ហាញពីព្រះចេស្តានៃព្រះដែលទ្រង់មានលើសជាងសាតាំង!

# ជីវិតមួយដែលគ្មានអំពើបាបណាសោះ

៧.៣

ព្រះជន្មរបស់ព្រះយេស៊ូគឺជាអ្វីមួយដែលយើងមិនអាចប្រៀបធៀបទៅនឹងអ្នកណាម្នាក់នោះឡើយដោយព្រោះព្រះអង្គមិនដែលប្រព្រឹត្តអំពើបាបណាទាល់តែសោះ[១០] !ព្រះអង្គបានធ្វើតាមក្រឹត្យវិន័យលោកម៉ូសេបានយ៉ាងល្អឥតខ្ចោះហើយទ្រង់មិនដែលប្រព្រឹត្តទង្វើរណាដែលបង្ហាញពីការមិនស្តាប់បង្គាប់នោះឡើយ។សាតាំងវាបានមកជួបនឹងព្រះយេស៊ូដើម្បីល្បួងព្រះអង្គដោយផ្ទាល់ប៉ុន្តែវាមិនអាចបង្ខូចសិរីល្អរបស់ព្រះយេស៊ូបានឡើយ។ដោយព្រោះតែព្រះអង្គបានរងសេចក្តីល្បួងប៉ុន្តែគ្មានបាបណាសោះនោះ,ព្រះយេស៊ូអាចនឹងអាណិតអាសូរដល់យើងនៅពេលណាដែលយើងមានបញ្ហារជាមួយនឹងសេចក្តីល្បួង។

ព្រះជន្មរបស់ព្រះយេស៊ូដែលគ្មានអំពើបាបណាទាល់តែសោះមានសារៈសំខាន់ដោយព្រោះតែជាផ្លូវរបស់ព្រះសម្រាប់ធ្វើជាយញ្ញបូជា។នៅក្នុងក្រឹត្យវិន័យលោកម៉ូសេ,សង្ឃថ្វាយយញ្ញបូជាដល់ព្រះដោយប្រើសត្វដែលល្អឥតខ្ចោះ។សត្វដែលល្អឥតខ្ចោះហើយគ្មានស្នាមទាំងនេះគឺដើម្បីបង្ហាញថាព្រះទ្រង់នឹងអត់ទោសបាបដល់មនុស្សនៅពេលដែលមានយញ្ញបូជាដ៏បរិសុទ្ធត្រូវបានថ្វាយជំនួសអំពើបាបរបស់ពួកគេ។សត្វទាំងនោះគឺជាតំណាងអោយព្រះយេស៊ូ,ដែលទ្រង់បានរស់នៅក្នុងជីវិតដែលគ្មានអំពើបាបណាទាល់តែសោះហើយជាយញ្ញបូជាដ៏ល្អឥតខ្ចោះ។

# ភាពច្រណែនហើយនឹងការក្បត់

បន្ទាប់ពីការបង្រៀនអស់រយៈពេលបីឆ្នាំ,ព្រះយេស៊ូបានយាងចូលក្នុងទីក្រុងយេរូសាឡឹមជាលើកចុងក្រោយ។ទ្រង់បានចូលទៅព្រះវិហារ។ជាកន្លែងបរិសុទ្ធសម្រាប់ពួកសាសន៍យូដាថ្វាយបង្គំព្រះ។តែជាអកុសល,មានមនុស្សជាច្រើនបានចាប់ផ្តើមធ្វើជំនួញនៅក្នុងព្រះវិហារ។ពួកគេបានធ្វើការប្តូរប្រាក់ហើយលក់ទំនិញនៅទីនោះ។ព្រះយេស៊ូក្រោធយ៉ាងខ្លាំងដោយព្រោះតែគេមិនបានគោរពដល់ព្រះ។ព្រះអង្គបានចាប់ផ្តើមផ្កាប់តុដូរលុយរបស់ពួកគេ។ហើយទ្រង់បានបណ្តេញពួកអ្នកដូរលុយចេញពីព្រះវិហារ។ ព្រះអង្គបានបន្ទោសដល់ពួកមេដឹកនាំសាសនាដែលគេបង្រៀនដល់មនុស្សប៉ុន្តែខ្លួនគេមិនបានស្តាប់តាមបញ្ញត្តិរបស់ព្រះ។ [១១]

ការស្តីបន្ទោសរបស់ព្រះអង្គបានធ្វើអោយពួកមេដឹកនាំសាសនាមានកំហឹងកាន់តែខ្លាំងឡើង។ព្រះយេស៊ូបានបង្ហាញពីការអាក្រក់របស់ពួកគេ។ពួកគេចង់ធ្វើគត់ព្រះអង្គ,ប៉ុន្តែពួកមិនអាចស្វែងរកឱកាសបានឡើយ។ពួកគេមានការភ័យខ្លាចចំពោះហ្វូងមនុស្សដែលមើលទៅហាក់បីដូចជាស្រលាញ់ព្រះយេស៊ូណាស់។ពួកគេបានចាប់ផ្តើមបង្កើតគម្រោងនៅក្នុងការកំចាត់មនុស្សម្នាក់នេះដែលតែងតែបង្ករបញ្ហារយ៉ាងច្រើនដល់គេ។

---

[៩] ឧទាហរណ៏មួយចំនួនអំពីការធ្វើការអស្ចារ្យរបស់ព្រះយេស៊ូមាននៅក្នុងគម្ពីរ ម៉ាថាយ ៩,ម៉ាកុស ៧,យ៉ូហាន ៩,១១

[១០] ម៉ាថាយ ៤:១-១១;២កូរិនថូស ៥:២១,១ពេត្រុស ២:២៧,ហេព្រើរ ៤:១៥, សមព ៧,៣ ហេតុអ្វីបានជាអ្នកសង្គ្រោះ"គ្មានបាបម្នាក់"មានសារៈសំខាន់?

[១១] សូមមើលក្នុង ម៉ាថាយ ២៣;លូកា ១៩:៤៥-៤៨

សំនួរពិភាក្សា:

- *ហេតុអ្វីបានជាពួកមានដឹកនាំសាសន៏យូដាស្អប់ព្រះយេស៊ូខ្លាំងដល់ម្លេះ?*
- *តើអ្នកធ្លាប់មានទំនាស់ជាមួយនឹងអ្នកណាម្នាក់ដោយព្រោះតែភាពច្រណែនដែលឬទេ?*

# *ការក្បត់*

សាវ័ករបស់ព្រះយេស៊ូម្នាក់ដែលមានឈ្មោះថាយូដាសអ៊ីស្ការ៉ាយុត។យូដាសបានសម្រេចចិត្តក្បត់ព្រះយេស៊ូហើយបញ្ជូនព្រះអង្គទៅអោយមេដឹកនាំសាសនា។ព្រះគម្ពីរបានបង្ហាញពីអារម្មណ៍របស់គាត់តែបន្តិចនោះទេ,ប៉ុន្តែយើងអាចដឹងបានថាៈគាត់មិនត្រូវបានគេបញ្ឆោតនោះឡើយ។ដោយគ្មានការសង្ស័យសាតាំងបានមានឥទ្ធិពលលើគាត់។យូដាសបានជ្រើសរើស នៅក្នុងការក្បត់ព្រះយេស៊ូ។គាត់បានទៅជួបនឹងពួកមេដឹកនាំសាសនាដោយសំងាត់។គាត់បានសួរគេថាតើគេនឹងអោយប្រាក់គាត់ប៉ុន្មានប្រសិនបើយូដាសបញ្ជូនព្រះយេស៊ូដល់ពួកគេ។ពួកគេបានរាប់ប្រាក់ចំនួនសាមសឹបដួងហើយបានអោយទៅយូដាស។គាត់បានចាកចេញទៅហើយបានរង់ចាំ ឱកាសនៅក្នុងការក្បត់ព្រះយេស៊ូ។រយៈពេលរាប់រយឆ្នាំមុនពេលដែលការនេះកើតឡើង,ព្រះបានដឹកនាំមនុស្សម្នាក់ដែលមានឈ្មោះថាសាការីអោយធ្វើសេចក្តីទំនាយមួយអំពីការក្បត់នេះ:

*"នោះខ្ញុំនិយាយនឹងគេថា បើឯងរាល់គ្នាឃើញថាល្អ នោះសូមឲ្យឈ្នួលមកអញ ពុំនោះ កុំរវល់អី ដូច្នេះ គេក៏ថ្លឹងប្រាក់៣០ដួងសំរាប់ជាឈ្នួលរបស់ខ្ញុំ ។រួចព្រះយេហូវ៉ាទ្រង់បង្គាប់មកខ្ញុំថា ចូរបោះប្រាក់នោះឲ្យដល់ជាងស្មូនចុះ គឺជាតម្លៃយ៉ាងល្អ ដែលគេបានកាត់ថ្លៃដល់ខ្ញុំ នោះខ្ញុំក៏យកប្រាក់៣០ដួងនោះ ទៅបោះឲ្យជាងស្មូនក្នុងព្រះវិហារនៃព្រះយេហូវ៉ា។[១២]"*




## *រំលឹកឡើងវិញ:ជីវិតរបស់ព្រះយេស៊ូ*

តាមពេលវេលាដែលបានកំណត់,ព្រះយេស៊ូបានប្រសូតនៅក្នុងពិភពលោក។ការប្រសូតដ៏អស្ចារ្យរបស់ព្រះអង្គត្រូវបានទស្សន៍ទាយអស់រយៈពេលរាប់រយឆ្នាំហើយបន្ទាប់មកក៏បានកើតឡើងដូចការដែលបានទាយទុកនោះ។ព័ន្ធកិច្ចរបស់ព្រះអង្គបានបង្ហាញអោយបានឃើញច្បាស់ពីការបង្ហាត់បង្រៀនហើយនឹងការអស្ចារ្យជាច្រើន។នៅពេលចុងក្រោយដែលព្រះអង្គមានព្រះជន្មនៅលើផែនដីនេះ,ពួកមេដឹកនាំសាសនាហើយនឹងសាវ័ករបស់ព្រះអង្គផ្ទាល់បានរៀបគម្រោងដើម្បីធ្វើគត់ព្រះអង្គ។ដូចដែលសេចក្តីទំនាយបានទាយ,យូដាសបានយកប្រាប់សាមសឹបដួងហើយបានរង់ចាំឱកាសប ញ្ជូនព្រះអង្គ។ ព្រះជន្មរបស់ព្រះយេស៊ូវិសេសខ្លាំងណាស់ដែលលោកសាវ័កយ៉ូហានបាននិយាយថាមានការជាច្រើនដែលមិនអាចនឹងសរសេរអស់:

*មានការជាច្រើនទៀត ដែលព្រះយេស៊ូបានធ្វើដែរ ខ្ញុំស្មានថា បើនឹងសរសេរទុក ដោយលំដាប់តមក នោះលោកីយ៍ទាំងមូលក៏មិនល្មមគ្រាន់ ដើម្បីនឹងដាក់អស់ទាំងសៀវភៅ ដែលត្រូវសរសេរនោះផង។[១៣]*

នៅពេលដែលយើងពិចារណាពីអ្វីដែលព្រះយេស៊ូបានធ្វើ,ការទាំងនោះអស្ចារ្យខ្លាំងណាស់ដែលយើងបានដឹងពីអ្វីដែលព្រះអង្គបានសម្រេចក្នុងការបំពេញព័ន្ធកិច្ចអស់រយៈពេលជាងបីឆ្នាំ!ពេលនេះដែលយើងបានសិក្សាអំពីព្រះជន្មរបស់ព្រះយេស៊ូហើយនោះ,ប្រហែលជាយើងអាចយល់ពីខគម្ពីរនេះកាន់តែខ្លាំងទៀត:

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[១២] សាការី ១១:១២-១៣
[១៣] យ៉ូហាន ២១:២៥

# លំហាត់មេរៀន
## មេរៀនទី ៧:ព្រះជន្មរបស់ព្រះយេស៊ូ

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១. សាសន៍យូដាមិនដែលចង់បានសេចក្ដីសន្យាអំពីព្រះមេស៊ីមកប្រោសលោះគេនោះឡើយ។ |
| ☐ | ☐ | ២. មុនពេលដែលព្រះអង្គយាងមកក្នុងផែនដី,ព្រះយេស៊ូគឺបានគង់នៅជាមួយនឹងព្រះវរបិតាជាផ្នែកមួយនៃព្រះដ៏អស់កល្បជានិច្ច។ |
| ☐ | ☐ | ៣. ពាក្យថាដំណឹងល្អគឺមានន័យថាដំណឹងអំពីការអាក្រក់។ |
| ☐ | ☐ | ៤. ដោយព្រោះតែមនុស្សជាច្រើនជាអ្នកធ្វើការរោងចក្រ,ទើបព្រះយេស៊ូតែងតែបង្រៀនដោយប្រើម៉ាស៊ីនយកមកធ្វើជាឧទាហរណ៍។ |
| ☐ | ☐ | ៥. ព្រះយេស៊ូធ្វើការអស្ចារ្យដើម្បីបង្ហាញថាទ្រង់ពិតជាមានអំណាចហើយនឹងព្រះចេស្ដាពីស្ថានសួគ៌។ |
| ☐ | ☐ | ៦. ពួកមេដឹកនាំសាសនាយូដាតែងតែពេញចិត្តហើយនឹងស្រលាញ់ព្រះយេស៊ូ។ |
| ☐ | ☐ | ៧. យូដាសអ៊ីស្ការ៉ាយុតបានយល់ព្រមក្បត់ព្រះយេស៊ូដើម្បីប្រាក់សាមសិបដួង។ |
| ☐ | ☐ | ៨. ព្រះយេស៊ូមានបាប,ដូចជាមនុស្សផ្សេងទៀតនៅលើផែនដីដែរ។ |



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. តែឯង ឱបេថ្លេហិម-អេប្រាតាអើយ ឯងដែលតូចនៅក្នុងពួកយូដាទាំង៣ន់ៗ នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នក______________________ ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក (មីកា ៥:១)

២. ហើយព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើទ្រង់ មានរូបរាងដូចជាសត្វព្រាប ក៏ឮសំឡេងចេញពីមេឃថា
____________________________ ជាទីពេញចិត្តអញណាស់។(លូកា ៣:២២)

៣.កាលទ្រង់យាងចូលដល់ក្នុងព្រះវិហារហើយ នោះទ្រង់ចាប់តាំងដេញពួកអ្នកដែលលក់ដូរចេញ ។ ដោយព្រះបន្ទូលថា
មានសេចក្តីចែងទុកមកថា «ដំណាក់អញជាទី _____________» តែអ្នករាល់គ្នាបានយកធ្វើជា______________។ (លូកា ១៩:៤៥-៤៦)

៤.មានការជាច្រើនទៀត ដែលព្រះយេស៊ូបានធ្វើដែរ ខ្ញុំស្មានថា បើនឹងសរសេរទុក ដោយលំដាប់តមក នោះ___________
ក៏មិនល្មមគ្រាន់ ដើម្បីនឹងដាក់អស់ទាំងសៀវភៅ ដែលត្រូវសរសេរនោះផង___________________។ (យ៉ូហាន ២១:២៥)



## សំនួរសំខាន់

១. ហេតុអ្វីបានជាមានសារៈសំខាន់ចំពោះសេចក្តីពិតដែលថាព្រះយេស៊ូបានសម្រេចសេចក្តីទំនាយ?

២. តើអ្វីគឺជាគោលបំណងក្នុងការដែលព្រះយេស៊ូធ្វើការជាអស្ចារ្យជាច្រើន?

៣. ហេតុអ្វីបានជាមានសារៈសំខាន់ដែលយើងដឹងថាព្រះយេស៊ូគ្មានបាប?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព **ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៧:**

- ៧.១ ហេតុអ្វីបានជាការប្រសូតពីស្រ្តីព្រហ្មចារីមានសារៈសំខាន់?
- ៧.២ ហេតុអ្វីបានជាការជ្រមុជទឹករបស់ព្រះយេស៊ូមានសារៈសំខាន់?
- ៧.៣ ហេតុអ្វីបានជា ״អ្នកសង្រ្គោះគ្មានបាបម្នាក់״មានសារៈសំខាន់?

**បទគម្ពីរសម្រាប់មេរៀនបន្ទាប់**



- ម៉ាថាយ ២៦-២៧

# មេរៀនទី ៨:យប់ចុងក្រោយមួយ,ថ្ងៃមួយពោរពេញដោយភាពងងឹត

## *សេចក្តីផ្តើម:គម្រោង*



មានគម្រោងជាច្រើនដែលត្រូវបានបង្កើតហើយនឹងត្រូវសម្រេចនៅក្នុងរយៈដ៏ខ្លី។យូដាសបានបង្កើតគម្រោងនៅក្នុងការក្បត់ព្រះយេស៊ូហើយបញ្ជូនព្រះអង្គទៅពួកមេដឹកនាំសាសនា។ពួកគេមានគម្រោងដាក់ទោសព្រះយេស៊ូអោយសុគត។សាតាំងវាមានគម្រោងនៅក្នុងការបំផ្លាញព្រះរាជបុត្រានៃព្រះ។សូម្បីតែគម្រោងដ៏ស្វារ្យបំផុតដែលព្រះជាម្ចាស់មានគម្រោងនៅក្នុងការប្រោសលោះមនុស្សពីអំពើបាប,ក៏នឹងជិតត្រូវបានសម្រេចដែរ។គម្រោងដែលព្រះជាម្ចាស់មាននឹងត្រូវសម្រេចគឺនៅសល់តែមួយយប់ចុងក្រោយហើយនឹងមួយថ្ងៃដែលពោរពេញដោយភាពងងឹតតែប៉ុណ្ណោះ។[១]

## *ការប្រកបគ្នា*

នៅយប់ដែលព្រះយេស៊ូត្រូវគេបញ្ជូន,ទ្រង់បានប្រមូលសាវ័កព្រះអង្គទៅក្នុងបន្ទប់ខាងលើមួយ។ពួកគេហើយនឹងទ្រង់បានបរិភោគអាហារជុំគ្នា។បន្ទាប់ពីបរិភោគអាហារ,ព្រះយេស៊ូមានព្រះបន្ទូលពីអ្វីមួយដែលវិសេស។ទ្រង់បានបង្កើតការប្រកបគ្នាមួយ។ ពិធីនេះក៏ត្រូវបានហៅថា "ពិធីរំលឹកព្រះអម្ចាស់។" នេះគឺជាការប្រារពដ៏វិសេសដែលគ្រីស្ទានរក្សារហូតដល់សព្វថ្ងៃនេះ។



*"គ្រាដែលកំពុងតែបរិភោគ នោះព្រះយេស៊ូទ្រង់យកនំប៉័ង
ហើយកាលទ្រង់បានប្រទានពរ នោះក៏កាច់ប្រទានទៅពួកសិស្ស
ដោយព្រះបន្ទូលថា ចូរយកបរិភោគចុះ នេះហើយជារូបកាយខ្ញុំ។
រួចទ្រង់យកពែងមកប្រទានពរ ក៏ហុចទៅឲ្យគេ ដោយព្រះបន្ទូលថា
ចូរបរិភោគពីពែងនេះទាំងអស់គ្នាចុះ ។ ដ្បិតនេះជាឈាមខ្ញុំ
គឺជាឈាមនៃសញ្ញាថ្មី ដែលបានច្រួចចេញ សំរាប់មនុស្សជា
ច្រើនប្រយោជន៍នឹងផ្តាច់បាប ។ តែខ្ញុំប្រាប់អ្នករាល់គ្នាថា
ពីនេះតទៅមុខ ខ្ញុំមិនផឹកពីផលផ្លែទំពាំងបាយជូរ
ទៀតទេ ដរាបដល់ថ្ងៃណាដែលខ្ញុំនឹងផឹកជាថ្មី
ជាមួយនឹងអ្នករាល់គ្នា នៅក្នុងនគរព្រះវរបិតានៃខ្ញុំ."[២]*

នំប៉័ងហើយនឹងផលពីដើមទំពាំងបាយជូរ(ទឹកទំពាំងបាយជូរ)មិនមែនប្រែទៅជារូបកាយហើយនឹងព្រះលោហិតនៃព្រះយេស៊ូដោយវេទមន្តនោះទេ។(សព្វថ្ងៃនេះក៏មិនបានប្រែទៅយ៉ាងដូច្នោះដែរ)។របស់ទាំងនោះគឺជាតំណាងឲ្យរូបកាយហើយនឹងព្រះលោហិតរបស់ព្រះអង្គ។គ្រីស្ទានប្រើតំណាងទាំងនេះនៅថ្ងៃអាទិត្យដើម្បីនឹកចាំពីការសុគតរបស់ព្រះយេស៊ូ ។[៣] ៨.១

ព្រះយេស៊ូបានមានបន្ទូលនឹងយូដាសថាទ្រង់ជ្រាបអំពីការក្បត់របស់គេ។យ៉ាងណាក្តី,យូដាសនៅតែមិនព្រមធ្វើការផ្លាស់ប្រែរឡើយ។តែផ្ទុយទៅវិញ,យូដាសបានចេញទៅរកមេដឹកនាំសាសនា។នៅវេលាដដែលនោះ,ព្រះយេស៊ូបានបានមានបន្ទូលប្រាប់សិស្សព្រះអង្គថាទ្រង់នឹងត្រូវសុគតបន្តិចទៀតនោះ។ទ្រង់បានជ្រាបអំពីគម្រោងរបស់ព្រះជាម្ចាស់ដែលតម្រូវឲ្យទ្រង់សុគតនៅលើឈើឆ្កាង។ទ្រង់ក៏បានមានបន្ទូលថាសាវ័ករបស់ព្រះអង្គនឹងបដិសេធហើយគេនឹងរត់ចោលទ្រង់។

---

[១] បទគម្ពីរដែលបង្ហាញពីមួយយប់ចុងក្រោយនៃព័ន្ធកិច្ចរបស់ព្រះយេស៊ូមាននៅក្នុងគម្ពីរ ម៉ាថាយ ២៦-២៨,ម៉ាកុស ១៤-១៦,លូកា ២២-២៤,ហើយនឹងយ៉ូហាន ១៨-១៩

[២] ម៉ាថាយ ២៦:២៦-២៩(ក៏សូមមើល ក្នុង ម៉ាកុស ១៤:២២-២៦,លូកា ២២:១៤-២៣)

[៣] កិច្ចការ ២០:៧,១កូរិនថូស ១១:២៣-២៦,សូមមើលក្នុង មសព ៧,១...:គ្រប់ចំនុវអំពីការប្រកបគ្នា។

សំនួរពិភាក្សា:

- សូមពន្យល់ដោយគំនិតរបស់អ្នក តើការប្រកបគ្នាជាអ្វី ហេតុអ្វីបានជាវាមានសារៈសំខាន់?

# *សេចក្តីអធិស្ឋាននៅក្នុងសួនច្បារ*

ព្រះយេស៊ូបានដឹកនាំសាវ័ករបស់ព្រះអង្គទៅភ្នំដើមអូលីវដើម្បីអធិស្ឋាន។សាវ័ករបស់ព្រះអង្គទាំងអស់,រួមទាំងយូដាស, ស្គាល់កន្លែងនេះ។សាវ័ករបស់ព្រះអង្គបានរង់ចាំនៅក្បែរនោះ,ព្រះយេស៊ូបានលត់ជង្គង់អធិស្ឋាន។ព្រះយេស៊ូមានព្រះទ័យថប់ព្រួយហើយតប់ប្រមល់យ៉ាងខ្លាំង។សេចក្តីអធិស្ឋានរបស់ព្រះអង្គគឺជាការកំសាន្តដល់ព្រះទ័យទ្រង់:

> *"ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពីទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ"*[៤]

ព្រះយេស៊ូអធិស្ឋានសូមអោយពែងកន្លងផុត ទៅគឺផ្តោតទៅលើសេចក្តីក្រោធនៃព្រះ។ចាប់តាំងពីពេលដំបូងដែលអំពើបាបចូលមកក្នុងពិភពលោក,សេចក្តីក្រោធហើយនឹងការជំនុំជំរះនៃព្រះបានទាស់នឹងមនុស្សមានបាប។ព្រះយេស៊ូមានទុក្ខព្រួយយ៉ាងខ្លាំងក្រៃលែង,ដោយព្រោះតែទ្រង់ជ្រាបពីសារៈសំខាន់នៃការស្លាប់របស់មនុស្ស គ្មានកំហុសដើម្បីប្រោសលោះអំពើបាបរបស់មនុស្សដែលមានបាប។ដោយព្រោះតែព្រះយេស៊ូរស់នៅក្នុងជីវិតមួយដ៏ល្អឥតខ្ចោះដោយគ្មានអំពើបាប,មានតែទ្រង់មួយប៉ុណ្ណោះដែលអាចសុគតដើម្បីសង្គ្រោះមនុស្សពីអំពើបាបបាន។

# *ការចាប់ខ្លួនព្រះយេស៊ូ*

អំឡុងពេលដែលព្រះយេស៊ូកំពុងអធិស្ឋាន,សូរសម្រឹបជើងរបស់ពួកទាហ៊ានបានមកពេញសួនច្បារ។ពួកសាវ័ករបស់ព្រះយេស៊ូបានដេកលង់លក់។ពួកគេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលពួកគេភ្ញាក់ឡើងឃើញហ្វូងមនុស្សនៅជុំវិញពួកគេ។ យូដាសអ៊ីស្ការ៉ាយ៉ុតបាននៅក្នុងចំណោមពួកអ្នកដែលបង្ករបញ្ហារទាំងនោះដែរ។វាបានប្រាប់ដល់ពួកសង្ឃថាអោយរកមើលជាអ្នកដែលវាថើប។ការនេះគឺជាសញ្ញាដើម្បីឲ្យបានដឹងថាអ្នកណាជាមនុស្សដែលត្រូវចាប់ខ្លួន។



យូដាសបានបោះជំហានមកមុខ។វាបានថើបព្រះយេស៊ូហើយបាននិយាយថា "ជំរាបសួរ,លោកគ្រូ" ព្រះយេស៊ូឆ្លើយថា, "សម្លាញ់អើយ,ចូរធ្វើអ្វីដែលឯងមកធ្វើចុះ. "ដោយមានសញ្ញារដើម្បីបញ្ជាក់ដល់ពួកទាហានពួកគេបានឈានជើងចូលចាប់ព្រះយេស៊ូ។នៅក្នុងចំនុចនេះសាវ័ករបស់ព្រះយេស៊ូបានបោះបង់ចោលទ្រង់ហើយបានរត់ចេញទៅ។ត្រូវនឹងអ្វីដែលព្រះយេស៊ូបានមានបន្ទូល។

# *កាត់ទោសដោយអយុត្តិធម៌*

ព្រះយេស៊ូត្រូវបាននាំមកចំពោះមុខសាលាកាត់ក្តីរបស់សាសន៏យូដា។ពួកគេបានព្យាយាមគ្រប់វិធីដើម្បីបញ្ជាក់ថាព្រះយេស៊ូមានកំហុសដែលសក្តិសមនឹងទទួលទោសដល់ស្លាប់។គ្មានអ្នកណាម្នាក់អាចស្វែងរកទោសកំហុសទ្រង់បានឡើយ។ក្រោយមក,បន្ទាប់ពីមានសាក្សីក្លែងក្លាយជាច្រើនហើយនោះ,សម្តេចសង្ឃបានសួរព្រះយេស៊ូឲ្យទ្រង់ឆ្លើយថាតើទ្រង់ពិតជាព្រះគ្រីស្ទ,ជាព្រះរាជបុត្រានៃព្រះមែនឬទេ,ព្រះយេស៊ូមានបន្ទូលឆ្លើយថា:

---

[៤] យ៉ូហាន ១:១-៤,ហើយសូមមើលក្នុង ភីលីព ២:៦

សំនួរពិភាក្សា:

- ហេតុអ្វីបានព្រះយេស៊ូយកព្រះទ័យទុកដាក់ចំពោះសេចក្តីក្រោធរបស់ព្រះជាម្ចាស់ដល់ម្លេះ?
- តើអ្នកគិងថាព្រះយេស៊ូមានព្រះទ័យយ៉ាងណានៅពេលដែលយូដាសក្បត់នឹងទ្រង់?

*"ត្រូវដូចលោកមានប្រសាសន៍ហើយ ១ទៀតខ្ញុំប្រាប់អ្នករាល់គ្នាថា អំណើះទៅមុខ អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយ នៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយទាំងមកលើពពកនៅលើមេឃផង"*[៥]

សម្តេចសង្ឃបានខឹងយ៉ាងខ្លាំងហើយបានហែកអាវរបស់ខ្លួន។គេបានចោទប្រកាន់ព្រះយេស៊ូថាបានប្រមាថ,ដែលបាន
មើលងាយព្រះ។ពួកគេបានគិតថាព្រះយេស៊ូបានប្រមាថដល់ព្រះដោយព្រោះបាននិយាយថាទ្រង់ហើយនឹងព្រះគឺតែមួយ។អ្វី
ដែលគេបដិសេធមិនចង់ឃើញនោះគឺថាព្រះយេស៊ូគឺជាផ្នែកមួយនៃព្រះ។ ទ្រង់បានយាងចុះពីស្ថានសួគ៌ហើយមកពីព្រះ ៨.២
វរបិតា។ពួកអ្នកកាត់ក្តីបានព្រមព្រៀងគ្នាថាព្រះយេស៊ូមានទោសសមនឹង[៦] ស្លាប់។ពួកគេបានចងភ្នែកព្រះអង្គ,ហើយ
បានស្តោះដាក់ព្រះភក្ត្រព្រះអង្គ,ហើយបានទះកំផ្លៀងព្រះអង្គជាមួយនឹងបាតដៃរបស់គេ។គេបានចំអកដាក់ព្រះអង្គហើយបាន
ប្រាប់ឲ្យទ្រង់ទាយសម្រាប់ខ្លួនព្រះអង្គថាតើអ្នកណាបានវាយព្រះអង្គ។

# *មហាជនដែលមានកំហឹងហើយនឹងចៅហ្វាយក្រុងរ៉ូម*

បន្ទាប់មកពួកមេដឹកនាំសាសន៏យូដាបាននាំព្រះយេស៊ូមកក្នុងទីធ្លារបស់ចៅហ្វាយក្រុងរ៉ូម។ពួកគេត្រូវការច្បាប់អនុញ្ញាតពី
លោកប៉ុនទាសភីឡាត់(ចៅហ្វាយក្រុង)ដើម្បីប្រហារជីវិតព្រះយេស៊ូ។នៅពេលដែលយូដាសបានឃើញព្រះយេស៊ូទទួលទារុណ
កម្មនោះ,ភាពក្បត់របស់វាបានធ្វើអោយវាមានអារម្មណ៏ថាមានកំហុស។វាបានរត់ទៅព្រះវិហារហើយបានអង្វរពួកគេអោយទទួ
លយកប្រាក់នោះវិញ។វាបាននិយាយថា, "ខ្ញុំបានជាធ្វើបាប ដោយបញ្ជូនឈាមឥតមានទោសហួសទៅហើយ"[៧] ។នៅពេលដែ
លគេបដិសេធ,វាបានបោះប្រាក់នោះទៅក្នុងវិហារ។បន្ទាប់មកយូដាសបានរត់ចេញទៅហើយចងកសម្លាប់ខ្លួនទៅ។ប្រហែ ៨.៥
លជាលទ្ធផលនៃអំពើបាបធ្ងន់ធ្ងខ្លាំងពេកនៅក្នុងការដែលវាមិនអាចទ្រាំទ្រ។

លោកចៅហ្វាយក្រុងភីឡាត់បានយកព្រះយេស៊ូចូលទៅខាងក្នុងដើម្បីសួរជាសំងាត់។ចាប់តាំងពីពេលនោះ,លោកភីឡាត់បានដឹងថាព្រះយេស៊ូមិនមានទោសកំហុសនោះទេគឺដោយព្រោះតែពួកមេដឹកនាំសាសនាច្រណែននឹងព្រះអង្គវិញ។គាត់បានព្យាយាមដោះលែងឲ្យព្រះយេស៊ូមានសេរីភាព,ប៉ុន្តែហ្វូងមនុស្សសាសន៏យូដាមានកំហឹងយ៉ាងខ្លាំងហើយបានស្រែកទាមទារ ឲ្យព្រះយេស៊ូសុគត។ក្រោយមកលោកភីឡាត់បានអោយគេវាត់ព្រះយេស៊ូនឹងខ្សែតី។ខ្សែតីនោះមានផ្សៀងដោយដែក,ឆ្អឹង,ហើយនឹងអំបែងនៅខាងចុងដែលអាចកាត់ចូលទៅក្នុងសាច់។បន្ទាប់ពីរូបកាយព្រះអង្គត្រូវបានដាច់រហែកដោយការវាយដំហើយនោះ,ពួកទាហានរ៉ូមបានដាក់ម្កុដដែលធ្វើពីបន្លាលើព្រះកេសព្រះយេស៊ូ។គេបានបំពាក់រូបពណ៌ស្វាយលើព្រះកាយដែលពោរពេញដោយព្រះលោហិតហើយនឹងដើមត្រែងនៅក្នុងព្រះហស្តរបស់ព្រះអង្គ។ហើយគេបានចំអកអោយព្រះអង្គដោយការក្រាបចុះហើយនិយាយថា"ថ្វាយបង្គំ ស្តេចសាសន៏យូដា"ហើយគេបានយកដើមត្រែងពីព្រះហស្តព្រះអង្គបានវាយទ្រង់ជាមួយនឹងដើមត្រែងនោះថែមទៀត។ក្រោយមកគេក៏បាននាំយកព្រះអង្គដែលពោរពេញដោយព្រះលោហិតហើយនឹងភាពទ្រុឌទ្រោមមកឯភីឡាត់វិញ។



លោកភីឡាត់បាននាំព្រះយេស៊ូមកចំពោះមុខហ្វូងមនុស្សសាសន៏យូដា។គាត់បានស្រែកឡើងថា, "សូមមើលមកមនុស្សនេះ។"បន្ទាប់មកគាត់ក៏ប្រកាសដោះលែងព្រះយេស៊ូ។លោកភីឡាត់ជឿថាព្រះយេស៊ូគ្មានកំហុសនោះទេ។ប្រហែលជាគាត់បានសង្ឃឹមថាការវាយដំព្រះយេស៊ូអាចធ្វើឲ្យមនុស្សមានចិត្តអាណិតអាសូរព្រះអង្គ។ប៉ុន្តែមេដឹកនាំសាសនាបានត្រៀមជាស្រេចហើយ។នៅពេលដែលលោកភីឡាត់សួរថាតើគាត់ត្រូវធ្វើយ៉ាងណាចំពោះព្រះយេស៊ូ,

---

៥ ម៉ាថាយ ២៦:៦៤

៦ កូឡុស ២:៩;មសព ៨,២-៨,៤ ផ្នែកនៃព្រះជាម្ចាស់(ផ្នែកទី ១-៣)

៧ ម៉ាថាយ ២៧:៤-៥;មសព ៨,៥ "ទូលបង្គំសូមទោស,ព្រះជាម្ចាស់"-ការដឹងកំហុស និងការផ្លាស់ប្រែ

សំនួរពិភាក្សា:

- តើអ្នកគិតយ៉ាងដូចម្តេចដែលលោកភីឡាត់អោយគេវាត់ព្រះយេស៊ូនឹងខ្សែតី?
- ប្រសិនបើលោកភីឡាត់ជឿថាព្រះយេស៊ូគ្មានកំហុស,ហេតុអ្វីបានជាគាត់មិនដោះលែងព្រះយេស៊ូទៅ?

ពួកគេបានប្រាប់ដល់ហ្វូងមនុស្សអោយនិយាយថា, "ឆ្កាងវាទៅ,ឆ្កាងវាទៅ!"លោកភីឡាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង។"ហេតុអ្វី?" គាត់ស្រែក "តើគាត់បានប្រព្រឹត្តទោសអ្វី?" ហ្វូងមនុស្សកាន់តែស្រែកខ្លាំងឡើង, "ឆ្កាងវាទៅ,ឆ្កាងវាទៅ!

# *ការធ្វើដំណើរដ៏ឆ្ងាយ*

មួយសប្តាហ៍មុននេះបន្តិច,មនុស្សក្នុងទីក្រុងបានស្វាគមន៏ព្រះយេស៊ូ។ពួកគេបានស្រែកដោយអំណរថាទ្រង់បានមកហើយ។ពេលនេះគេស្រែករកការសុគតរបស់ព្រះអង្គវិញ។ពួកគេបានស្រែកអោយព្រះលោហិតព្រះអង្គធ្លាក់មកលើខ្លួនគេហើយ នឹងកូនចៅរបស់គេ។ព្រះយេស៊ូប្រហែលជាបានឆ្លងកាត់ការឈឺចាប់យ៉ាងខ្លាំងហើយដែលទ្រង់បានឃើញមនុស្សទាំងនោះស្រែករកការសុគតនៅក្នុងពេលវេលាដ៏ខ្លីប៉ុណ្ណោះដែលគេទើបតែបានសាទរព្រះជន្មរបស់ទ្រង់។

លោកភីឡាត់បានធ្វើតាមការទាមទាររបស់មេដឹកនាំសាសនា។គាត់គឺជាមនុស្សកំសាក។គាត់បានដាក់ទោសព្រះយេស៊ូឲ្យសុគតដោយការឆ្កាង។ទាហានរ៉ូមបានបង្ខំឲ្យព្រះយេស៊ូលីឈើឆ្កាងដ៏ធំមួយឆ្លងកាត់ផ្លូវនៅក្នុងទីក្រុងយេរូសាឡឹម។ពេលដែលព្រះយេស៊ូយាងយឺតៗនោះ,បណ្តាជនបានចេញមកមើលពីការរន្ធត់នោះ។ព្រះលោហិត ហូរស្រក់នៅលើផ្លូវដែលព្រះអង្គឆ្លងកាត់យ៉ាងលំបាកវេទនា។ពួកគេបានដើរយឺតៗទៅកាន់ភ្នំមួយដែលហៅថា គាល់កូថា។កន្លែងនេះមានន័យថាភ្នំលលាដ៏ក្បាល។សូម្បីតែភ្នំក៏មើលទៅដូចជាសេក្តីស្លាប់ដែរ។



## *រំលឹកឡើងវិញៈយប់ចុងក្រោយ,ថ្ងៃមួយពោរពេញដោយភាពងងឹត*

នៅយប់ចុងក្រោយនៃពន្ធកិច្ចរបស់ព្រះយេស៊ូ,ព្រះអង្គបានប្រារពពិធីវិសេសមួយជាមួយនឹងសាវ័ករបស់ព្រះអង្គហើយបានបង្កើតពិធីរំលឹកព្រះអម្ចាស់ដើម្បីនឹកចាំពីការសុគតរបស់ព្រះអង្គ។នៅពេលដែលព្រះអង្គអធិស្ឋាននៅក្នុងសួនច្បារ,ព្រះអង្គត្រូវបានក្បត់ដោយសាវ័ករបស់ទ្រង់ឈ្មោះយូដាសហើយត្រូវបានចាប់ខ្លួន។ការកាត់ក្តីក្លែងក្លាយបានដាក់ទោសព្រះយេស៊ូឲ្យសុគត។ទ្រង់ត្រូវគេវាយដំ,ស្តោះដាក់,ចំអកហើយវាយនឹងរំពាត់។ដោយការកាត់ក្តីអោយប្រហារជីវិតពីចៅហ្វាយក្រុង,ព្រះយេស៊ូត្រូវបាននាំទៅខាងក្រៅក្រុងយេរូសាឡឹមដើម្បីសុគត។សូមអោយអារម្មណ៏សោកសង្រេងនៃផ្នែកនៃដំណឹងល្អមួយនេះជួយដឹកនាំអោយយើងមានអារម្មណ៏ថ្មីមួយក្នុងការយល់ពីសេចក្តីស្រលាញ់របស់ព្រះសម្រាប់មនុស្សៈ

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

# លំហាត់មេរៀន

## មេរៀនទី ៨:យប់ចុងក្រោយមួយ,ថ្ងៃមួយពោរពេញដោយភាពងងឹត

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.ព្រះយេស៊ូបានបង្កើតពិធិប្រកបគ្នានៅយប់មុនពេលព្រះអង្គសុគត។ |
| ☐ | ☐ | ២.នំប៉ុងហើយនឹងផ្លែពីដើមទំពាំងបាយជូរ(ទឹកទំពាំងបាយជូរ)ក្លាយទៅជាព្រះលោហិតហើយនឹងព្រះកាយព្រះយេស៊ូដោយវេទមន្ត។ |
| ☐ | ☐ | ៣. ព្រះយេស៊ូបានផ្តល់ឱកាសអោយយូដាសធ្វើការផ្លាស់ប្រែ។ |
| ☐ | ☐ | ៤. មេដឹកនាំសាសនាបានកាត់ក្តីព្រះយេស៊ូដោយយុត្តិធម៌។ |
| ☐ | ☐ | ៥. យូដាសបានផ្លាស់ប្រែអំពើបាបរបស់គាត់ហើយបានរស់នៅក្នុងជីវិតមួយយ៉ាងសប្បាយរីករាយ។ |
| ☐ | ☐ | ៦. ខ្សែរតីដែលប្រើនៅក្នុងការវាត់ព្រះយេស៊ូមានចុងទៅដោយ,អំបែង,ឆ្អឹង,ហើយនឹងដែក។ |
| ☐ | ☐ | ៧. លោកភីឡាត់ជឿថាព្រះយេស៊ូមានទោស។ |
| ☐ | ☐ | ៨. លោកភីឡាត់ជាមនុស្សក្លាហានហើយមិនអោយហ្វូងមនុស្សបង្ខំបាន។ |

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. គ្រាដែលកំពុងតែបរិភោគ នោះព្រះយេស៊ូទ្រង់យកនំប៉័ង ហើយកាលទ្រង់បានប្រទានពរ នោះក៏កាច់ប្រទានទៅពួកសិស្ស ដោយព្រះបន្ទូលថា ចូរយកបរិភោគចុះ ____________________ (ម៉ាថាយ ២៦:២៦)

២. ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពីទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ ____________________(ម៉ាថាយ ២៦:៣៩)

៣.ត្រូវដូចលោកមានប្រសាសន៍ហើយ ១ទៀតខ្ញុំប្រាប់អ្នករាល់គ្នាថា អំណឹះទៅមុខ អ្នករាល់គ្នានឹងឃើញ____________________អង្គុយ នៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយទាំងមកលើពពកនៅលើមេឃផង។(ម៉ាថាយ ២៦:៦៤)

៤.ដូច្នេះ ព្រះយេស៊ូក៏យាងចេញទៅក្រៅ ទាំងពាក់ភួងបន្លា និងអាវពណ៌ស្វាយនោះ រួចលោកពីឡាត់មានប្រសាសន៍ទៅគេថា ____________________(យ៉ូហាន ១៩:៥)



## សំនួរសំខាន់

១.តើរបស់ដែលប្រើនៅក្នុងពិធីប្រកបគ្នាតំណាងអោយអ្វីខ្លះ?

២. ហេតុអ្វីបានជាព្រះយេស៊ូមានទុក្ខពេលដែលព្រះអង្គអធិស្ឋាន?

៣.តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការដាក់ទោសព្រះយេស៊ូដល់សុគត?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៨:

- ៨.១ គ្រប់ចំនុចអំពីពិធីប្រកបគ្នា
- ៨.២ ផ្នែកនៃព្រះជាម្ចាស់(វគ្គ ១)
- ៨.៣ ផ្នែកនៃព្រះជាម្ចាស់(វគ្គ២)
- ៨.៤ផ្នែកនៃព្រះជាម្ចាស់(វគ្គ ៣)
- ៨.៥ "ទូលបង្គំសូមទោស,ព្រះជាម្ចាស់អើយ" -ការដឹងកំហុសនឹងការផ្លាស់ប្រែ

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- ម៉ាថាយ ២៨
- យ៉ូហាន ១៩-២១

# មេរៀនទី ៩:ការសុគតហើយនឹងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ

## *សេចក្ដីផ្ដើម: ការឆ្កាងព្រះយេស៊ូ*



នៅពេលដែលព្រះយេស៊ូយាងមកដល់ភ្នំគាល់កូថាហើយនោះ,ពួកទាហានបានផ្ដេកព្រះកាយព្រះអង្គនៅលើឈើឆ្កាងហើយបានបោះដែកគោលនៅលើព្រះបាទាហើយនឹងព្រះហស្ដទាំងសងខាងរបស់ព្រះអង្គ។ក្រៅពីព្រះយេស៊ូក៏មានឈើឆ្កាងពីរផ្សេងទៀតដែលនៅក្បែរនោះដែរ។នៅលើឈើឆ្កាងទាំងពីរនោះពួកទាហានបានឆ្កាងអ្នកទោសឧក្រិដ្ឋកម្មពីរអ្នក។ភាពឈឺចាប់ខាងសាច់ឈាមកាន់តែកើនឡើងថែមទៀតនៅពេលដែលត្រូវព្យួរនៅលើឈើឆ្កាងយ៉ាងនោះ។មនុស្សម្នាក់ដែលត្រូវបានព្យួរនៅលើឈើឆ្កាងគឺមិនអាចដកដង្ហើមបានស្រួលឡើយ,ជាពិសេសនៅពេលដែលដៃទាំងពីរត្រូវត្រដាងយ៉ាងដូច្នោះ។ភាពឈឺចាប់ដែលមិនអាចដកដង្ហើមបានកើនឡើងបន្តិចម្ដងៗជាមួយនឹងភាពខ្លោចផ្សាដែលត្រូវគេព្យួរនៅលើឈើឆ្កាងនោះ[១]។



## *ស្ដេចមួយអង្គនៅលើឈើឆ្កាង*

ហ្វូងទាហាន,អ្នកតាមមើល,ហើយនឹងពួកអ្នកដែលដាក់ទោសបានមកដល់ភ្នំគាល់កូថា។គេក៏បានដាក់ស្លាកសញ្ញានៅពីលើព្រះសិរទ្រង់ជាបីភាសាដែលមនុស្សគ្រប់គ្នាអាចអានបាន។ស្លាកសញ្ញានោះបានសរសេរថា "នេះគឺជាយេស៊ូ,ស្ដេចរបស់សាសន៍យូដា។"មេដឹកនាំសាសនាសាសន៍យូដាជាច្រើនបានឈរនៅក្បែរនោះហើយចំអកអោយព្រះយេស៊ូ។(ប៉ុន្តែក្រោយមក ៩.១
មានអ្នកខ្លះបានផ្លាស់ប្រែបន្ទាប់ពីព្រឹត្តិការណ៍នោះ។)[២] ពួកទាហានបានចាប់ឆ្នោតដណ្ដើមយកអាវវែងរបស់ព្រះអង្គ។




មានសិស្សរបស់ព្រះយេស៊ូម្នាក់បានមកឯឈើឆ្កាង។អ្នកដ៏ទៃទៀតបានពួនដោយព្រោះមានការភ័យខ្លាច។ស្ត្រីមួយចំនួនដែលបានដើរតាមព្រះយេស៊ូក៏នៅទីនោះដែរ។ម៉ារីជាមាតាព្រះយេស៊ូនៅទីនោះ។តើវាជាការសោកសៅយ៉ាងណាដែលគាត់បានឃើញកូនរបស់គាត់ត្រូវគេឆ្កាងនៅលើឈើឆ្កាងយ៉ាងដូច្នោះ!បន្ទាប់ពីព្រះអង្គត្រូវបានគេឆ្កាងនៅលើឈើឆ្កាងនោះ,ទ្រង់បានស្រែកឡើងថា"ព្រះវរបិតាអើយ,សូមអត់ទោសដល់គេ,ដ្បិតគេមិនបានដឹងជាគេធ្វើអ្វីនោះទេ"[៣] ,ទោះបីជាទ្រង់រៀបនឹងសុគតក៏ដោយនោះ,សេចក្ដីស្រលាញ់របស់ព្រះយេស៊ូនៅតែមានសម្រាប់មនុស្សដែលធ្វើគត់ព្រះអង្គ។

នៅពេលដែលព្រះយេស៊ូក្លាយជាយញ្ញបូជាសម្រាប់អំពើបាបនោះ, ព្រះវរបិតាបានបែព្រះភក្ត្រចេញ។ផ្ទៃដីទាំងមូលពោរពេញភាពងងឹតអស់រយៈពេលបីម៉ោង។ព្រះយេស៊ូបានស្រែកឡើងថា, "ព្រះអម្ចាស់,ព្រះអម្ចាស់អើយ,ហេតុអ្វីបានជាទ្រង់បោះបង់ចោលទូលបង្គំ!"[៤] ភាពឈឺចាប់ដែលត្រូវបានឃ្លាតឆ្ងាយពីព្រះវរបិតាគឺជាការឈឺចាប់ដ៏ខ្លាំងបំផុត។នៅទីបំផុត,ព្រះយេស៊ូជ្រាបថាការទាំងអស់បានសម្រេចហើយ,ព្រះអង្គមានបន្ទូលថា"ការស្រេចហើយ"[៥] ក្រោយមកទ្រង់ក៏សុគត។

[១] បទគម្ពីរអំពីការសុគតរបស់ព្រយេស៊ូនឹងការរស់ពីសុគតឡើងវិញមាននៅក្នុងគម្ពីរម៉ាថាយ ២៧-២៨,ម៉ាកុស ១៤-១៦,លូកា ២២-២៤,ហើយនឹងយ៉ូហាន ១៩-២១
[២] សូមមើលក្នុងការសិក្សាព្រះគម្ពីរបន្ថែម:មេរៀនទី ២៦:ចោរនៅលើឈើឆ្កាង
[៣] លូកា ២៣:២៤
[៤] ម៉ាថាយ ២៧:៤៦
[៥] យ៉ូហាន ១៩:៣០



### សំនួរពិភាក្សា:

- តើអ្នកអាចអត់ទោសអោយមនុស្សដែលបានបោះដែកគោលលើដៃអ្នកហើយទុកអោយអ្នកស្លាប់ដែរឬទេ?
- ហេតុអ្វីបានជាអ្នកគិតថាការដែលញែកព្រះយេស៊ូចេញពីព្រះវរបិតាគឺជាជាការឈឺចាប់ដ៏ធំបំផុត?

ការសុគតរបស់ព្រះយេស៊ូមើលទៅហាក់បីដូចជាជ័យជំនះបានទៅលើសាតាំងហើយ។ចាប់តាំងពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសួនច្បារអេដែនមក,វាបាននាំយកការបំផ្លាញហើយនឹងការបោកបញ្ឆោតនៃអំពើបាបចូលមកក្នុងពិភពលោក។អស់រយៈពេលជាច្រើនសតវត្សមនុស្សមានបញ្ហារជាមួយនឹងអំពើបាបហើយបានធ្លាក់ទៅក្នុងអំពើបាបនោះ។យ៉ាងណាមិញក្នុងការសុគតមួយនេះ,ព្រះយេស៊ូបានយកឈ្នះលើសាតាំងដោយបាន ផ្តល់ឱកាសនៃការប្រោសលោះពីអំពើបាបដល់មនុស្ស។ទំនាយដំបូងបង្អស់ត្រូវបានសម្រេច:



> *អញនឹងធ្វើឲ្យឯងហើយនឹងស្ត្រី គឺទាំងពូជឯងនឹងពូជ*
> *នាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង*
> *ហើយឯងនឹងចឹកកែងជើងគេ.”*

សាតាំងវាបានខាំងកែងជើងនៅពេលដែលព្រះយេស៊ូសុគត។អ្វីដែលវាមិននឹកស្មាននោះគឺថាការនោះគឺជាការដែលព្រះអង្គកិនក្បាលរបស់វាហើយនឹងបំផ្លាញផែនការនៃការក្តោបក្តាប់មនុស្សនៅក្នុងអំពើបាបរបស់វានោះឡើយ។

# *ហេតុអ្វីបានជាការសុគតរបស់ព្រះយេស៊ូមានសារៈសំខាន់*

ពេលដែលព្រះយេស៊ូសុគត,មានការរញ្ជួយដីយ៉ាងខ្លាំង។វាំងននដែលបាំងនៅក្នុងព្រះវិហារបានរហែកជាពីរ។(នេះគឺជាសញ្ញាដែលបញ្ជាក់ថាជំនាន់ក្រឹត្យវិន័យលោកម៉ូសេបានកន្លងផុតហើយ។ហើយជំនាន់របស់គ្រីស្ទានបានចាប់ផ្តើម។)នៅក្នុងចំនុចមួយនេះយើងបានឃើញពីការសម្រេចនៃគម្រោងរបស់ព្រះជាម្ចាស់គឺថា:ការសុគតរបស់ព្រះយេស៊ូគឺជាយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់ការអត់ទោសដល់អំពើបាប។ហេតុអ្វីបានជាការសុគតរបស់ព្រះអង្គមានសារៈសំខាន់?

- យើងទាំងអស់គ្នាមានអំពើបាប; [៧]
- ព្រះទ្រង់បរិសុទ្ធហើយមិនអាចមានចំណែកជាមួយនឹងអំពើបាបបានឡើយ; [៨]
- ជោគវាសនាចុងក្រោយរបស់មនុស្សមានបាបគឺជាសេចក្តីស្លាប់ក្នុងស្ថាននរក; [៩]
- ព្រះជាម្ចាស់បានប្រកាសថាអំពីបាបអាចដកចេញបាននៅពេលដែលមនុស្សដែលគ្មានអំពើបាបម្នាក់ទទួលយកកំហុសរបស់មនុស្សមានបាប;ព្រះយេស៊ូគឺគ្មានកំហុសហើយទ្រង់គ្មានអំពើបាបសោះឡើយ; [១០]
- យើងទាំងអស់គ្នាបានផ្សះផ្សាជាមួយនឹងព្រះដោយការសុគតរបស់ព្រះគ្រីស្ទ; [១១]




[៦] លោកុប្បត្តិ ៣:១៥
[៧] រ៉ូម ៣:២៣
[៣] ១យ៉ូហាន ១:៥
[៩] ២កូរិនថូស ៥:២១
[១០] រ៉ូម ៦:២៣
[១១] រ៉ូម ៥:១០

## សំនួរពិភាក្សា:

- សូមពន្យល់អំពីទំនាយដំបូងនៃការសុគតរបស់ព្រះយេស៊ូដោយគំនិតរបស់អ្នក។

# ផ្នូរនៅទទេ



បន្ទាប់ពីព្រះអង្គសុគត,សិស្សរបស់ព្រះយេស៊ូម្នាក់ដែលមានឈ្មោះថាយ៉ូសែបហើយមានស្រ្តីមួយចំនួនដែលជាសិស្សរបស់ព្រះយេស៊ូដែរនោះបានយកព្រះសពរបស់ព្រះអង្គពីលើឈើឆ្កាង។គេបានរុំសពព្រះអង្គហើយនៅក្នុងក្រណាត់ហើយបានបញ្ចុះនៅក្នុងផ្នូរ។បន្ទាប់ពីគេបានបញ្ចុះសពព្រះអង្គហើយ,គេបានប្រមៀលថ្មរមួយយ៉ាងធំដើម្បីបិទផ្នូរនោះ។អស់រយៈពេលបីថ្ងៃនោះ,មើលទៅហាក់បីដូចជាព្រះយេស៊ូបានចាកចោលពួកគេហើយព័ន្ធកិច្ចព្រះអង្គបានបរាជ័យទៅហើយ។

នៅព្រឹកថ្ងៃអាទិត្យ,នៅពេលដែលថ្ងៃរះឡើងនោះ,មានស្រ្តីមួយចំនួនបានយកគ្រឿងក្រអូបខ្លះទៅឯផ្នូរដើម្បីអប់សពព្រះយេស៊ូជាការបង្ហាញពីការគោរព។នៅពេលដែលគេទៅដល់,គេបានឃើញថាថ្មរត្រូវបានរមៀលចេញពីមាត់ផ្នូរ។ពួកគេបានរត់ត្រឡប់ទៅប្រាប់ដល់ពួកសិស្សវិញ។នៅពេលដែលពួកគេពីរនាក់បានឮ(ពេត្រុសហើយនឹងយ៉ូហាន),ពួកគេបានរត់ទៅឯផ្នូរ។យ៉ូហានបានចូលទៅមើលនៅក្នុងផ្នូរហើយពេលដែលពេត្រុសមកដល់,គាត់បានរត់ចូលទៅក្នុងផ្នូរដែរ។ពួកគេបានឃើញត្រឹមតែសំពត់រុំសពដែលបានបត់យ៉ាងស្អាតដាក់នៅខាងក្នុងនោះតែប៉ុណ្ណោះ!



អ្នកទាំងពីរក៏ចេញទៅដោយភាពងឿងឆ្ងល់។ស្រ្តីម្នាក់ដែលជាសិស្សបាននៅយំនៅក្នុងផ្នូរ។ភ្លាមនោះព្រះយេស៊ូបានលេចមក។ ទ្រង់មានព្រះជន្មរស់ឡើងវិញ!ដោយមានការរំលឹកពីព្រះយេស៊ូនាងបានរត់ទៅប្រាប់ពួកសិស្សពីអ្វីដែលនាងបានឃើញ។កាលដែលពួកគេនៅជុំគ្នាក្នុងពេលល្ងាចនោះ,ព្រះយេស៊ូបានលេចមកឲ្យគេឃើញ។ទ្រង់មានបន្ទូលថា"សូមសេចក្ដីសុខសាន្តចូលមានដល់អ្នក។"[១២]

សិស្សរបស់ព្រះយេស៊ូម្នាក់(ថូម៉ាស់)មិនបាននៅជាមួយនឹងពួកគេនោះឡើយ។ពេលពួកសិស្សបានជួបនឹងគាត់បានប្រាប់គាត់ពីដំណឹងល្អដែលព្រះយេស៊ូបានរស់ពីសុគតឡើងវិញ!ថូម៉ាស់មិនបានជឿគេនោះឡើយ។គាត់បាននិយាយថាលុះត្រាណាតែគាត់បានឃើញហើយនឹងស្ទាបស្នាមដែកគោលដែលនៅលើព្រះហស្តព្រះអង្គទើបគាត់ព្រមជឿ។ប្រាំបីថ្ងៃបានកន្លងផុតទៅ,ពួកសិស្សបានមកប្រជុំគ្នា(រួមទាំងថូម៉ាស់)។ព្រះយេស៊ូបានលេចមកអោយគេឃើញម្ដងទៀត,ព្រះយេស៊ូបានទតទៅកាន់ថូម៉ាស់។ទ្រង់បានហៅគាត់អោយចូលមកជិតទ្រង់អោយមើលស្នាមរបួសលើព្រះហស្តព្រះអង្គហើយស្ទាបស្នាមរបួសនោះ។ថូម៉ាស់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។គាត់បានត្រឹមតែប្រកាសថាព្រះយេស៊ូជាអ្នកណាតែប៉ុណ្ណោះ។គាត់បាននិយាយថា"ឱព្រះអម្ចាស់ ព្រះនៃទូលបង្គំអើយ" ។ ព្រះយេស៊ូបានមានបន្ទូលទៅកាន់គាត់វិញគឺជាព្រះបន្ទូលដែលជាព្រះពរដល់គ្រីស្ទានគ្រប់ៗគ្នា។

*"ថូម៉ាសអើយ អ្នកជឿដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ អ្នកណាដែលជឿឥតឃើញសោះ។"*[១៣]

---

[១២] យ៉ូហាន ២០:២៣
[១៣] យ៉ូហាន ២០:២៩

សំនួរពិភាក្សា:

- តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្ដេចនៅពេលមានមនុស្សម្នាក់ដែលអ្នកស្រលាញ់បំផុតបានស្លាប់ទៅហើយស្រាប់តែមានជីវិតរស់ឡើងវិញ?
- ហេតុអ្វីបានជាព្រះយេស៊ូមានបន្ទូលថាអស់អ្នកដែលមិនបានឃើញទ្រង់ប៉ុន្តែមានជំនឿជាមនុស្សទទួលបានពរ?

# ហេតុអ្វីបានជាការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូមានសារៈសំខាន់

ជាមួយនឹងព្រឹត្តិការណ៍ដ៏អស្ចារ្យជុំវិញការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ,ធ្វើអោយមានសំនួរមួយសួរថា:ហេតុអ្វីបានជាការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូមានសារៈសំខាន់?

**១** ការរស់ពីសុគតឡើងវិញបញ្ជាក់ពីព្រះចេស្ដារបស់ព្រះយេស៊ូ[១៤],ទ្រង់បានប្រកាសថាទ្រង់យាងមកពីស្ថានសួគ៌,ហើយការដែលរស់ពីសុគតឡើងវិញដ៏អស្ចារ្យបញ្ជាក់ពីការនេះ។

**២** ការរស់ពីសុគតឡើងវិញបញ្ជាក់ពីអ្វីដែលមាននៅក្នុងព្រះគម្ពីរ[១៥],គម្ពីរជាច្រើនកណ្ឌដែលត្រូវបានសរសេរអស់រយៈពេលជាច្រើនឆ្នាំទាយអំពីការយាងមកនៃព្រះមេស៊ីហើយនឹងការប្រោសលោះ,ព្រះគម្ពីរទាំងមូលបានសម្រេចនៅពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ!



**៣** ការរស់ពីសុគតឡើងវិញបង្ហាញពីព្រះចេស្ដារបស់ព្រះលើសេចក្ដីស្លាប់[១៦] ,តាមរយៈការដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ, ព្រះយេស៊ូបានបង្ហាញថាព្រះជាម្ចាស់ព្រះចេស្ដាលើសេចក្ដីស្លាប់ហើយមនុស្សត្រូវបានប្រទានឲ្យមានឱកាសអាចទទួលបានជីវិតអស់កល្បជានិច្ចខាងព្រលឹងវិញ្ញាណបាន។

**៤** ការរស់ពីសុគតឡើងវិញផ្ដល់ឱកាសឲ្យមនុស្សទទួលបានជីវិតអស់កល្បជានិច្ច[១៧],ប្រសិនបើព្រះយេស៊ូគ្រាន់តែសុគតដើម្បីយកឈ្នះតែសេចក្ដីស្លាប់នោះ,អាចនឹងគ្មានជ័យជំនះយ៉ាងពិតប្រាកដនោះឡើយ។សេចក្ដីស្លាប់នឹងមានឥទ្ធិពលជាងព្រះទៅទៀត។វានឹងមិនមានសារៈសំខាន់អ្វីឲ្យយើងទទួលបានសេចក្ដីសង្គ្រោះនោះទេប្រសិនបើជោគវាសនារបស់យើងមានតែសេចក្ដីស្លាប់តែប៉ុណ្ណោះ។មិនត្រូវអោយមានសេចក្ដីសង្គ្រោះនោះដែរ, ប្រសិនបើមនុស្សគ្រប់គ្នាគង់តែស្លាប់ដដែល។ព្រះគម្ពីរបានចែងថា:

> *ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្ដីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើអ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ ។ ហើយអស់អ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ ។ បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទនៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនាលើសជាងមនុស្សទាំងអស់ទៅទៀត។*[១៨]

## *រំលឹងឡើងវិញ:ការសុគតនិងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ*

ព្រះយេស៊ូត្រូវបានសុគត,ទ្រង់ត្រូវគេធ្វើគត់,ហើយបានបញ្ចុះក្នុងផ្នូរ។អស់រយៈពេលបីថ្ងៃដែលមើលទៅហាក់បីដូចជាគ្មានសេចក្ដីសង្ឃឹមអ្វីទាល់តែសោះ។ប៉ុន្ដែព្រះជាម្ចាស់ទ្រង់មានគម្រោង។នៅព្រឹកថ្ងៃអាទិត្យ,ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យរស់ពីសុគតឡើងវិញ។គម្រោងរបស់ព្រះបានសម្រេច!មនុស្សអាចជៀសផុតពីអំពើបាបហើយត្រឡប់មករកទំនាក់ទំនងដ៏ជិតស្និតជាមួយនឹងព្រះវិញបាន!ពិតណាស់,ព្រះបន្ទូលនៃព្រះកាន់តែផ្អែមពិរោះជាងពេលណាទាំងអស់:

> *"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[១៤] រ៉ូម ១:៤
[១៥] ទំនុកដំកើង ១៦៨:៨-១០
[១៦] រ៉ូម ១:១០
[១៧] ១កូរិនថូស ១៥:៥៥-៥៧
[១៨] ១កូរិនថូស ១៥:១៧-១៩

# លំហាត់មេរៀន

## មេរៀនទី ៩:ការសុគតហើយនឹងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.មនុស្សជាច្រើនបានបង្ហាញការគោរពយ៉ាងជ្រាលជ្រៅពេលដែលព្រះអង្គត្រូវគេឆ្កាងនៅលើឈើឆ្កាង។ |
| ☐ | ☐ | ២. ទោះបីជាព្រះអង្គហៀបនឹងសុគតក៏ដោយក៏ព្រះអង្គនៅតែមានសេចក្តីស្រលាញ់ចំពោះមនុស្សដែលធ្វើគត់ទ្រង់ដែរ។ |
| ☐ | ☐ | ៣. នៅពេលដែលវាំងននទៅក្នុងព្រះវិហាររហែកជាពីរគឺជាសញ្ញារដែលបង្ហាញថាជំនាន់ក្រឹត្យវិន័យលោកម៉ូសេបានបញ្ចប់ហើយ,ជំនាន់គ្រីស្ទានជិតចាប់ផ្តើមហើយ។ |
| ☐ | ☐ | ៤.មនុស្សគ្រប់គ្នាសូម្បីតែ(ព្រះយេស៊ូ)ក៏មានបាបដែរ។ |
| ☐ | ☐ | ៥. យើងទាំងអស់គ្នាទទួលបានការផ្សះផ្សាជាមួយនឹងព្រះតាមរយៈការសុគតរបស់ព្រះគ្រីស្ទ។ |
| ☐ | ☐ | ៦. ថូម៉ាស់ជឿអ្នកដែលប្រាប់គាត់ថាគេបានឃើញព្រះយេស៊ូ។ |
| ☐ | ☐ | ៧. ការរស់ពីសុគតឡើងវិញបញ្ជាក់ថាព្រះយេស៊ូពិតជាយាងមកពីស្ថានសួគ៌។ |
| ☐ | ☐ | ៨.ប្រសិនបើព្រះយេស៊ូមិនបានរស់ពីសុគតឡើងវិញទេនោះ,គ្មានសេចក្តីសង្ឃឹមសម្រាប់យើងទាំងអស់គ្នាបន្ទាប់ពីជីវិតមួយនេះឡើយ។ |

## ? ស្វែងរកអត្ថបទព្រះគម្ពីរ

១.ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់______________________(ម៉ាថាយ ២៧:៤៦)

២.អញនឹងធ្វើឲ្យឯង ហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹង__________________ហើយឯងនឹង
________________________។(លោកុប្បត្តិ ៣:១៥)

៣.ថូម៉ាសអើយ អ្នកជឿដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ ________________________________________
ឥតឃើញសោះ។(យ៉ូហាន ២០:២៩)

៤. បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះ___________________________________
មនុស្សទាំងអស់ទៅទៀត។(១កូរិនថូស ១៥:១៩)



## សំនួរសំខាន់

១. នៅក្នុងគំនិតរបស់អ្នក,ហេតុអ្វីបានជាការសុគតរបស់ព្រះយេស៊ូមានសារ:សំខាន់?

២. ហេតុអ្វីបានជាព្រះយេស៊ូមានបន្ទូលប្រាប់ថូម៉ាស់ថា "មានពរហើយដល់អស់អ្នកណាដែលជឿដោយឥតបានឃើញសោះ"?

៣. នៅក្នុងគំនិតរបស់អ្នក,ហេតុអ្វីបានជាការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូមានសារៈសំខាន់?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ៩:

- ៩.១ ចោរនៅលើឈើឆ្កាង

បទគម្ពីរសម្រាប់មេរៀនបន្ទាប់

- កិច្ចការ ១-២



# មេរៀនទី ១០: មនុស្សគ្រប់គ្នាអាចទទួលបានសេចក្ដីសង្គ្រោះ!

## *សេចក្ដីផ្ដើម:សំនួរដ៏សំខាន់*



*តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីទទួលបានសេចក្ដីសង្គ្រោះ?*[១] នេះគឺជាសំនួរដ៏អស្ចារ្យដែលមនុស្សបានសួរចាប់តាំងពីពេលដែលដំណឹងល្អនៃការសុគតរបស់ព្រះយេស៊ូត្រូវបានបង្រៀន។អ្វីដែលជាចំនុចបង្ហាញពីការដែលចង់ទទួលបាន សេចក្ដីសង្គ្រោះនោះគឺសួរថា: តើមនុស្សម្នាក់អាចប្រែក្លាយជាគ្រីស្ទានបានដោយរបៀបណា?តើមនុស្សម្នាក់ចាប់ផ្ដើមទំនាក់ទំនងរបស់គេជាមួយនឹងព្រះយេស៊ូគ្រីស្ទដោយផ្ទាល់ដោយរបៀបណា?តើមនុស្សម្នាក់ក្លាយជាសមាជិកនៃពួកជំនុំដោយរបៀបណា?ទោះបីជាពាក្យទាំងនេះមើលទៅហាក់បីដូចជាមានភាពខុសគ្នាក៏ដោយ,ប៉ុន្តែអ្វីដែលជាចំនុចសំខាន់នោះគឺតែមួយនោះទេ:គឺជាសេចក្ដីត្រូវការសម្រាប់សេចក្ដីសង្គ្រោះពីអំពើបាបនិងសេចក្ដីស្លាប់ខាងព្រលឹងវិញ្ញាណ។

## *ការផ្លាស់ប្រែដំបូង*

បន្ទាប់ពីការពីសុគតឡើងវិញរបស់ព្រះអង្គ,ព្រះយេស៊ូបានគង់នៅលើផែនដីរយៈពេល ៤០ថ្ងៃ។ក្រោយមកទ្រង់ក៏យាងទៅ
១០.១ ស្ថានសួគ៌វិញនៅលើពពក។ក្រោយមកព្រះបានចាត់ព្រះវិញ្ញាណបរិសុទ្ធដើម្បីដឹកនាំសាវ័ករបស់ព្រះយេស៊ូ។[២] ព្រះវិញ្ញាណបរិសុទ្ធបានលេចមកដូចជាភ្លើង។ទ្រង់បានប្រទានអោយពួកគេមានអំណាចធ្វើការអស្ចារ្យដើម្បីនិយាយភាសាដ៏ទៃ។ មានន័យថាពួកគេអាចនិយាយភាសាបរទេសដោយមិនត្រូវការចំណាយពេលរៀន,ឬបទពិសោធន៍នោះឡើយ។ព្រះជាម្ចាស់បានអនុញ្ញាតអោយពួកគេបានរួចផុតពីបណ្ដាសារនៃប៉មបាបិលដែលមានអរស់រយៈពេលជាងរាប់ពាន់ឆ្នាំមុន![៣] ភ្លាមនោះពួកសាវ័កក៏ចាប់ផ្ដើមបង្រៀន។



ការប្រារពពិធីដ៏វិសេសមួយបាននាំយកមនុស្សពីគ្រប់ប្រទេសទាំងអស់មកក្នុងទីក្រុងយេរូសាឡឹម។លោកពេត្រុសបានបង្រៀននៅក្នុងចំណោមហ្វូងមនុស្សដ៏ធំបានក៏បានពន្យល់ថាព្រះយេស៊ូជាអ្នកណា,ហេតុអ្វីបានជាទ្រង់មានសារៈសំខាន់,ហើយថាតើមនុស្សមានទោសដោយព្រោះបានធ្វើគត់ព្រះយេស៊ូដោយរបៀបណា?មានមនុស្សជាច្រើនបានដឹងកំហុសដោយព្រោះអំពើបាបរបស់គេ, នៅពេលដែលបានស្ដាប់ឮពីការបង្រៀននៃដំណឹងល្អ។ពួកគេបានសួរថាតើពួកគេត្រូវធ្វើយ៉ាងណា។លោកពេត្រុសបានឆ្លើយថា:

> *"ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួល*
> *បុណ្យជ្រមុជទឹកទាំងអស់គ្នាដោយនូវព្រះនាមព្រះយេស៊ូគ្រីស្ទប្រយោជន៍ឲ្យបានរួចពីបាប*
> *នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ"*[៤]

មនុស្សជាងបីពាន់អ្នកបានស្ដាប់តាមដំណឹងល្អនៃព្រះយេស៊ូហើយបានទទួលពីធីជ្រមុជទឹក!ជំនាន់គ្រីស្ទានត្រូវបានចាប់ផ្ដើមហើយពួកជំនុំត្រូវបានបង្កើតឡើង។[៥] ព្រះគម្ពីរបានចែងអំពីគ្រីស្ទានទាំងនោះ:

> *" រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង ហើយបរិភោគអាហារដោយអំណរ និងចិត្តស្មោះត្រង់ ។ ព្រមទាំងសរសើរដល់ព្រះ ហើយបណ្ដាជនទាំងអស់គ្នាក៏រាប់អានគេ ចំណែកព្រះអម្ចាស់ ទ្រង់ក៏បន្ថែមនូវអស់អ្នក ដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃទៅ ក្នុងពួកជំនុំថែមទៀត។"*[៦]

---

[១] កិច្ចការ ១៦:៣០
[២] កិច្ចការ ២:១-៤;មសព ១០,១ និង ១០,២ អំណោយទាននៃការធ្វើការអស្ចារ្យក្នុងសញ្ញាថ្មី
[៣] សូមមើលក្នុងគម្ពីរ លោកុប្បត្តិ ១១ អំពីបណ្ដាសារនៃប៉មបាបិល
[៤] កិច្ចការ ២:៣៨
[៥] សម្រាប់មេរៀនបន្ថែមអំពីពួកជំនុំនៃព្រះអម្ចាស់សូមមើលក្នុង មេរៀនដ៏សាមញ្ញក្នុងព្រះគម្ពីរអំពី: មេរៀនអំពីពួកជំនុំ
[៦] កិច្ចការ ២:៤៦-៤៧



### សំនួរពិភាក្សា:

- តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្ដេចប្រសិនបើសុលចាប់ខ្លួនគ្រួសាររបស់អ្នកហើយក្រោយមកគាត់មកថ្វាយបង្គំនៅក្នុងកន្លែងដែលអ្នកប្រជុំគ្នាដើម្បីថ្វាយបង្គំព្រះ?
- តើមានមនុស្សណាម្នាក់ដែលអាក្រក់ខ្លាំងពេកនោក្នុងការប្រែក្លាយជាគ្រីស្ទានដែរឬទេ?

# មនុស្សមានបាបអាក្រក់ជាងគេ

ព្រះគម្ពីរបានបង្ហាញថាពួកមេដឹកនាំសាសនាយូដាបានធ្វើទុក្ខបៀតបៀនពួកជំនុំយ៉ាងខ្លាំង។កាលដែលពួកគេកំពុងតែចោលដុំថ្មសម្លាប់គ្រីស្ទានម្នាក់នោះ,មានបុរសវ័យក្មេងម្នាក់ឈរមើលហើយបានយល់ស្របជាមួយនឹងពួកអ្នកទាំងនោះ។[៧] គាត់បានចាប់ផ្តើមធ្វើការបៀតបៀនដល់ពួកជំនុំរហូតដល់មានអ្នកស្លាប់។[៨] កាលដែលគាត់កំពុងធ្វើដំណើរទៅទីក្រុងផ្សេងទៀតដើម្បីចាប់ខ្លួនគ្រីស្ទាននោះ,ព្រះយេស៊ូបានលេចមកអោយសុលបានឃើញហើយបានធ្វើអោយភ្នែកគាត់ទៅជាងងឹត!ព្រះអង្គបានសួរថា "ហេតុអ្វីបានជាសុលបៀតបៀនព្រះអង្គ?"ព្រះយេស៊ូបង្ហាញថា នៅពេលដែលគ្រីស្ទានម្នាក់រងការបៀតបៀន,ព្រះអង្គក៏ឈឺចាប់ជាមួយនឹងគេដែរ។[៩] ព្រះអង្គបានមានបន្ទូលប្រាប់សុលអោយរង់ចាំនៅក្នុងទីក្រុងដាម៉ាស់។ប៉ុន្មានថ្ងៃក្រោយមក,គ្រីស្ទានម្នាក់ឈ្មោះថា អាណានាសត្រូវបានដឹកនាំដោយព្រះអម្ចាស់អោយស្វែងរកលោកសុល។គាត់បានពាល់ភ្នែកសុល,ហើយគាត់ក៏អាចមើលឃើញម្តងទៀត។ភ្លាមនោះសុលបានលាងជំរះអំពើបាបរបស់គាត់ដោយការទទួលពិធីជ្រមុជទឹក។[១០]



តើអាចអោយមនុស្សដែលអាក្រក់យ៉ាងដូច្នេះទទួលបានឱកាសក្នុងការទទួលបានការប្រោសលោះអំពើបាបបានដោយរបៀបណា?សុលបានធ្វើការបៀតបៀនដល់គ្រីស្ទានរហូតដល់ស្លាប់ហើយបានបង្ខាំងព្រះរាជសាររបស់ព្រះសម្រាប់សេចក្តីសង្គ្រោះដល់មនុស្សដែលបានវង្វេងពីព្រះ!ហេតុផលដែលព្រះប្រទានព្រះគុណដល់សុលដោយព្រោះព្រះអង្គមានព្រះទ័យក្នុងការបង្ហាញថា ព្រះមានព្រះទ័យអោយមនុស្សគ្រប់គ្នាទទួលបានសេចក្តីសង្គ្រោះ,សូម្បីតែមនុស្សនោះជាសត្រូវរបស់ពួកជំនុំក៏ដោយ។ក្រោយមកលោកត្រូវបានហៅថាប៉ូល។តាមរយៈព្រះវិញ្ញាណបរិសុទ្ធ,លោកប៉ូលបានពន្យល់ពីព្រះគុណនៃព្រះដែលមាននៅក្នុជីវិតរបស់គាត់ដូច្នេះថា:

> *ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូទ្រង់បានយាងមកក្នុងលោកីយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ។ដោយហេតុនោះបានជាទ្រង់អាណិតមេត្តាដល់ខ្ញុំ ដើម្បីឲ្យព្រះយេស៊ូគ្រីស្ទបានសំដែងចេញ គ្រប់ទាំងសេចក្តីអត់ធន់របស់ទ្រង់ក្នុងខ្លួនខ្ញុំ ដែលជាអ្នកលេខ១នោះ ឲ្យខ្ញុំបានធ្វើជាគំរូដល់ពួកអ្នក ដែលនឹងជឿដល់ទ្រង់ ប្រយោជន៍ឲ្យគេបានជីវិតអស់កល្បជានិច្ច។* [១១]

# ដំណឹងល្អអំពីសេចក្តីសង្គ្រោះ

លោកប៉ូលបានរាប់ខ្លួនគាត់ថា ជាអ្នកលេខ១ក្នុងចំណោមមនុស្សមានបាបទាំងអស់ ដោយព្រោះតែគាត់បានប្រឆាំងទាស់នឹងព្រះ ហើយបានយល់ស្របនៅក្នុងការចាប់ខ្លួនហើយនឹងបានសម្លាប់គ្រីស្ទាន។គាត់បញ្ជាក់ថាប្រសិនបើព្រះជាម្ចាស់អត់ទោសដល់មនុស្សមានបាបលេខ១បាន, ព្រះទ្រង់អាចនឹងអត់ទោសដល់មនុស្សគ្រប់គ្នា!

ដំណឹងល្អនៃព្រះយេស៊ូគឺជាដំណឹងអំពីការល្អសម្រាប់ហេតុផលល្អគឺថា: យើងទាំងអស់គ្នាអាចទទួលបានសេចក្តីសង្គ្រោះ! សេចក្តីសង្គ្រោះគឺមិនមែនសម្រាប់តែមនុស្សដែលមានពណ៌សំបុរមួយចំនួន,ភាសាមួយចំនួន,វប្បធម៌មួយចំនួន,មានទ្រព្យសម្បត្តិ ឬមានចំណេះដឹងតែប៉ុណ្ណោះទេ។ព្រះទ្រង់មានព្រះទ័យអោយមនុស្សគ្រប់គ្នាទទួលបានសេចក្តីសង្គ្រោះ!ព្រះបានបង្កើតមនុស្សមកអោយដូចជារូបអង្គនៃទ្រង់។មនុស្សម្នាក់ៗមានចំនុចវិសេសហើយនឹងគ្មានអ្វីប្រៀបស្មើរបានឡើយនៅក្នុងព្រះនេត្រនៃព្រះ។ មិនថាមនុស្សម្នាក់នោះជាអ្នកណា,មិនខ្វល់ថាអ្វីដែលពួកគេបានធ្វើនោះទេ,ឬមិនខ្វល់ថាពួកគេមានអារម្មណ៍មិនសក្តិសមយ៉ាងណាក៏ដោយ,ព្រះទ្រង់ស្រលាញ់យើងទាំងអស់គ្នាហើយទ្រង់មានព្រះទ័យអោយមនុស្សគ្រប់គ្នាទទួលបានសេចក្តីសង្គ្រោះ។

[៧] កិច្ចការ ៦-៧

[៨] កិច្ចការ២២:៤

[៩] សុលបានជួបជាមួយនឹងព្រះហើយការសន្ទនាមាននៅក្នុងគម្ពីរ កិច្ចការហើយរំលើកឡើងវិញក្នុងគម្ពីរ កិច្ចការ ២២និង ២៤

[១០] ការជ្រមុជទឹករបស់លោកប៉ុលបានកត់ត្រានៅក្នុងគម្ពីរ កិច្ចការ ៩:១០-២២និង ២២:១៥-១៦

[១១] ១ធីម៉ូថេ១:១៥-១៦

សំនួរពិភាក្សា:

- តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេចប្រសិនបើសុលចាប់ខ្លួនគ្រួសាររបស់អ្នកហើយក្រោយមកគាត់មកថ្វាយបង្គំនៅក្នុងកន្លែងដែលអ្នកប្រជុំគ្នាដើម្បីថ្វាយបង្គំព្រះ?
- តើមានមនុស្សណាម្នាក់ដែលអាក្រក់ខ្លាំងពេកនៅក្នុងការប្រែក្លាយជាគ្រីស្ទានដែរឬទេ?

# *សេចក្តីសង្គ្រោះចាប់ផ្តើមជាមួយនឹងព្រះ*

លោកប៉ូលដែលបានផ្លាស់ប្រែបានពន្យល់ថា ព្រះគ្រីស្ទយេស៊ូបានយាងមកក្នុងពិភពលោកដើម្បីសង្គ្រោះមនុស្សមានបាប។ សេចក្តីសង្គ្រោះចេញពីអំពើបាបហើយពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណត្រូវតែរក្សាក្នុងភាពវិសេសដូចដើម។មនុស្សបានព្យាយាមសង្គ្រោះខ្លួនរបស់គេក្នុងវិធីជាច្រើន,ប៉ុន្តែអំពើបាបខ្លាំងក្លាណាស់ហើយមនុស្សទន់ខ្សោយណាស់។ដោយព្រោះតែមូលហេតុនេះ,សេចក្តីសង្គ្រោះត្រូវចាប់ផ្តើមជាមួយនឹងព្រះ។សូមពិចារណាអំពីចំនុចខាងក្រោម:

| នៅពេលដែលលព្រះទ្រង់ដាក់គម្រោងហើយព្រះទ្រង់សម្រេច | នៅពេលដែលព្រះទ្រង់ដាក់គម្រោងហើយមនុស្សជាអ្នកសម្រេច | នៅពេលដែលមនុស្សដាក់គម្រោងហើយមនុស្សជាអ្នកសម្រេច |
|---|---|---|
| **ព្រះគុណ** | **ជំនឿ** | **ការសន្សំកុសល** |
| *ជាអ្វីមួយដែលមនុស្សម្នាក់មិនសក្តិសមនឹងទទួលបានឬមិនអាចធ្វើអ្វីដើម្បីអោយទទួលបាននោះឡើយ។* | *ជាការបង្ហាញពីការទុកចិត្តទាំងស្រុង។* | *ជារង្វាន់ឬឈ្នួលគឺជាអ្វីដែលមនុស្សទទួលបានពីការប្រឹងប្រែងរបស់ខ្លួនគេ។* |

ព្រះគម្ពីរបានចែងថាមនុស្សមានបាបអាចទទួលបានសេចក្តីសង្គ្រោះដោយសារព្រះគុណតាមរយៈសេចក្តីជំនឿ។[១២] សេចក្តីសង្គ្រោះចាប់ផ្តើមជាមួយនឹងព្រះគុណនៃព្រះ ដោយព្រោះតែទ្រង់មិនគួរនឹងបញ្ជូនព្រះយេស៊ូអោយមកនោះឡើយ។ប៉ុន្តែដោយសេចក្តីស្រលាញ់នៃទ្រង់,ព្រះអង្គបានបញ្ជូនព្រះរាជបុត្រាតែ១ដែលគ្មានបាបណាទាល់តែសោះមកសុគតដើម្បីទទួលទោសជួសយើង
១០.៣ ។ការដែលយើងមិនអាចធ្វើអ្វីដើម្បីអោយទទួលបានហើយមិនសក្តិសមនឹងទទួលនេះគឺជាព្រះគុណនៃព្រះ។ព្រះគម្ពីរបានបង្រៀនយើងថា យើងមិនអាចធ្វើអ្វីដើម្បីសង្គ្រោះខ្លួនឯងនោះឡើយ។[១៣] ប្រសិនបើមនុស្សណាម្នាក់ព្យាយាមធ្វើអ្វីមួយដើម្បីអោយបានកើនសេចក្តីសង្គ្រោះតាមរយៈការសន្សំកុសលរបស់គេនោះ,ពួកគេកំពុងតែបង្ហាញថាសេចក្តីសង្គ្រោះគឺជាអ្វីមួយដែលពួកគេសក្តិសមនឹងទទួលបានវាមិនមែនជាព្រះគុណដ៏វិសេសនៃព្រះនោះឡើយ។ព្រះគម្ពីរក៏បានចែងទៀតថាយើងអាចទទួលយកព្រះគុណនៃព្រះបានតាមរយៈសេចក្តីជំនឿ។យើងមានជំនឿលើព្រះដោយការស្តាប់តាមអ្វីដែលព្រះអង្គបញ្ជាអោយយើងធ្វើ(ក៏អាចហៅបានថា "ការស្តាប់តាមដំណឹងល្អ")។[១៤] តើព្រះមានគម្រោងអ្វីសម្រាប់មនុស្សមានបាបដែលដឹងកំហុសម្នាក់អោយធ្វើក្នុងសេចក្តីជំនឿ?

## ១០.៤ *តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីឲ្យបានសង្គ្រោះ?*

ព្រះគម្ពីរបានបង្រៀនថាជំនឿកើតឡើងដោយការ ស្តាប់ឮដំណឹងល្អ។[១៥] ជំនឿគឺ ទទួលជឿ[១៦] ថាព្រះយេស៊ូគ្រីស្ទគឺជាអ្នកណាដូចដែលព្រះអង្គទ្រង់បានប្រកាសថាទ្រង់ជាអ្នកណានោះ។ជំនឿគឺត្រូវបានបង្ហាញដោយការ ផ្លាស់ប្រែ[១៧] ចេញពីអំពើបាប។ ការផ្លាស់ប្រែគឺជាការផ្លាស់ប្តូររបៀបនៃការរស់នៅពីការបម្រើអំពើបាបមកបម្រើព្រះជាម្ចាស់វិញ។ជំនឿត្រូវបានបញ្ជាក់ដោយការ ប្រកាស[១៨] ថាព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះ។ពាក្យទាំងនេះគឺត្រូវប្រកាសនៅពេលដែលមនុស្សម្នាក់ត្រៀមខ្លួនជាស្រេចនៅក្នុងការទទួលយកសេចក្តីសង្គ្រោះ,ប៉ុន្តែនេះមិនមែនជាការបញ្ចប់នោះទេ។ជិវិតថ្មីនៃការកោតខ្លាចព្រះបានប្រែក្លាយជាការប្រកាសអំពីព្រះគ្រីស្ទ។សេចក្តីជំនឿគឺត្រូវបានបង្ហាញនៅពេលដែលមនុស្សមានបាបដែលដឹងកំហុសម្នាក់ទទួលពីធីជ្រមុជទឹកសម្រាប់ជាការលាងសំអាតអំពើបាប។[១៩]




[១២] អេភេសូរ ២:៨-១០,មសព ១០,៣ គ្រប់ចំនុចអំពីការប្រព្រឹត្ត
[១៣] អេភេសូរ ២:៦,៨;មសព ១០,៤ តើអ្នកប្រែក្លាយជាគ្រីស្ទានដោយរបៀបណា?
[១៤] ២ថែស្សាឡូនិច ១:៨
[១៥] រ៉ូម ១០:១៧
[១៦] ម៉ាកុស ១៦:១៦
[១៧] ២កូរិនថូស ៧:១០
[១៨] ម៉ាថាយ ១០:៣២-៣៣;កិច្ចការ ៨:៣៦-៣៨;រ៉ូម ១០:៩-១០
[១៩] កិច្ចការ ២:៣៨,កាឡាទី ៣:២៧-២៨;សូមមើលទំព័របន្ទាប់



### សំនួរពិភាក្សា:

- សូមចំណាយពេលមួយចំនួនក្នុងការពិភាក្សាអំពីព្រះគុណ, ជំនឿ,ហើយនឹងការសាងកុសល។សូមសួរថា "តើជាអ្វី,យ៉ាងណា,ហេតុអ្វី" អំពីពាក្យនិមួយៗ។



ការជ្រមុជទឹកគឺជាដំណាងអោយការសុគត,ការបញ្ចុះ និងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ។ព្រះអង្គបានចុះចូលនៅក្នុងការប្រព្រឹត្តខាងសាច់ឈាម (ការសុគតនៅលើឈើឆ្កាង)ដើម្បីសម្រេចកិច្ចការខាងព្រលឹងវិញ្ញាណ(ការប្រោសលោះមនុស្សពីអំពើបាប)។ ដូចគ្នានេះដែរ,មនុស្សមានបាបដែលដឹងខ្លួនម្នាក់បានធ្វើតាមការដំណាងនេះជាការស្លាប់ក្នុងអំពើបាប,ហើយត្រូវបានបញ្ចុះជាមួយនឹងព្រះគ្រីស្ទ,ហើយរស់ពីស្លាប់ឡើងវិញជាមនុស្សថ្មីដែលទទួលបានសេចក្ដីសង្គ្រោះ![២០] មនុស្សមានបាបដែលដឹងខ្លួនចុះចូលក្នុងកិច្ចការខាងសាច់ឈាម(ដោយជ្រមុជទៅខាងក្រោមទឹក)ដើម្បីសម្រេចកិច្ចការខាងព្រលឹងវិញ្ញាណ(សម្រាប់ជាការលាងសំអាតអំពើបាប)។

នៅពេលមនុស្សមានបាបដែលដឹងខ្លួនម្នាក់ទទួលពិធីជ្រមុជទឹកនោះ,នៅក្នុងទឹកនោះគ្មានវេទមន្ដដែលអាចសំអាតយើងអោយបានស្អាតនោះទេ។ទឹកនោះមិនមែនជាទឹកបរិសុទ្ធនោះឡើយ។ការប្រព្រឹត្តនៃសេចក្ដីជំនឿដែលស្ដាប់តាមបញ្ញារបស់ព្រះគឺជាចំនុចដែលបានសង្គ្រោះយើង។ព្រះគម្ពីរបានចែងថា:

១០.៦ *នេះជានិមិត្តរូបនៃពិធីជ្រមុជទឹក -ដែលសង្គ្រោះបងប្អូននាបច្ចុប្បន្នកាល តែពិធីជ្រមុជទឹកមិនមែនជាពិធីលាងជំរះរូបកាយនោះទេ គឺជាការថ្វាយជីវិតទាំងស្រុងទៅព្រះជាម្ចាស់ ដោយមនសិការល្អវិញ។ ពិធីជ្រមុជទឹកនេះសង្គ្រោះបងប្អូន ដោយសារព្រះយេស៊ូគ្រីស្ទមានព្រះជន្មរស់ឡើងវិញ។*[២១]

ការដែលបានស្ដាប់ឮដំណឹងល្អ,ទទួលជឿ,ផ្លាស់ប្រែពីអំពើបាប,ហើយនឹងទទួលពិធីជ្រមុជទឹកការទាំងនេះត្រូវតែធ្វើដោយសេចក្ដីជំនឿ។បើគ្មានជំនឿទេនោះ,ការស្ដាប់ឮដំណឹងល្អ,គឺគ្រាន់តែជាការដែលបានស្ដាប់ឮ ពាក្យមួយចំនួនតែប៉ុណ្ណោះ; ការដែលប្រកាសអំពីព្រះគ្រីស្ទគឺគ្រាន់តែជាការដែលនិយាយនូវពាក្យមួយចំនួនតែប៉ុណ្ណោះ;ការដែលទទួលជ្រមុជទឹកគឺគ្រាន់តែជាការដែលធ្វើអោយទទឹកខ្លួនតែប៉ុណ្ណោះ។ដោយព្រះគុណនៃព្រះ,យើងស្ដាប់តាមដំណឹងល្អនៃព្រះយេស៊ូដោយសេចក្ដីជំនឿនៅពេលដែលយើងស្ដាប់តាមអ្វីដែលជាគម្រោងនៃព្រះ។ចាប់តាំងពីវេលានោះ,យើងបានប្រែក្លាយជាកម្មសិទ្ធរបស់ព្រះគ្រីស្ទហើយយើងត្រូវធ្វើអោយអស់ពីចិត្តនៅក្នុងការរស់នៅក្នុងជីវិតជាគ្រីស្ទានម្នាក់។

## *រំលឹកឡើងវិញ: មនុស្សគ្រប់គ្នាអាចទទួលបានសេចក្ដីសង្គ្រោះ!*

បន្ទាប់ពីព្រះយេស៊ូយាងទៅស្ថានសួគ៌វិញ,មនុស្សដែលបានដើរតាមព្រះអង្គបានបង្រៀនដំណឹងល្អនៅក្នុងក្រុងយេរូសាឡឹម។មនុស្សជាង ៣០០០ នាក់បានផ្លាស់ប្រែក្លាយជាគ្រីស្ទានដោយសេចក្ដីជំនឿ។ព្រលឹងវិញ្ញាណទាំងនេះទទួលបានសេចក្ដីសង្គ្រោះដោយព្រះគុណនៃព្រះតាមរយៈសេចក្ដីជំនឿ(ដូចជាយើងទទួលបានសេចក្ដីសង្គ្រោះនៅសព្វថ្ងៃនេះដែរ)។ព្រះទ្រង់មានព្រះទ័យអោយមនុស្សគ្រប់គ្នាទទួលបានសេចក្ដីសង្គ្រោះ។ក្នុងពេលដែលមនុស្សមួយចំនួនមានអារម្មណ៏ថាមានទោសឬមិនសក្ដិសមនោះ, ព្រះគម្ពីរបង្រៀនថាព្រះគុណនៃព្រះអាចនឹងប្រទានដល់មនុស្សណាដែលមានបំណងនៅក្នុងការស្ដាប់តាមដំណឹងល្អដោយសេចក្ដីជំនឿ។សូមចងចាំថាព្រះយេស៊ូតែងតែ នឹកចាំពីអ្នកនៅក្នុងព្រះទ័យទ្រង់ជានិច្ចនៅពេលដែលទ្រង់មានព្រះបន្ទូលអំពីការនេះ:

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[២០] រ៉ូម ៦:៣-៦
[២១] ១ពេត្រុស ៣:២០-២១(បកប្រែថ្មី);មសព ១០.៥-៦, គ្រប់ចំនុចអំពីពិធីជ្រមុជទឹក

**សំនួរពិភាក្សា:**

- នៅក្នុងគំនិតរបស់អ្នកសូមពន្យល់ពីរបៀបដែលមនុស្សម្នាក់ប្រែក្លាយជាគ្រីស្ទាន។
- Have you been baptized for the remission of sins? If not, why not?

# លំហាត់មេរៀន

# មេរៀនទី ១០: មនុស្សគ្រប់គ្នាអាចទទួលបានសេចក្ដីសង្គ្រោះ!

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១. ដែលថា "ដើម្បីទទួលបានសេចក្ដីសង្គ្រោះ"និង "ប្រែក្លាយជាគ្រីស្ទានម្នាក់" គឺបង្ហាញពីចំនុចពីរផ្សេងគ្នា។ |
| ☐ | ☐ | ២.បន្ទាប់ពីការបង្រៀនរបស់លោកពេត្រុសមានមនុស្សច្រើនជាងបីពាន់នាក់បានទទួលពិធីជ្រមុជទឹក។ |
| ☐ | ☐ | ៣.លោកប៉ូល(សុល) បានហៅខ្លួនឯងថា"ជាលេខ១ក្នុងចំណោមមនុស្សមានបាប"ដែលធ្លាប់បានរស់នៅទាំងអស់។ |
| ☐ | ☐ | ៣.យើងអាចប្រព្រឹត្តការល្អសន្សំកុសលដើម្បីអោយបានកើនសេចក្ដីសង្គ្រោះ។ |
| ☐ | ☐ | ៥.ព្រះគុណគឺជាអ្វីដែលព្រះទ្រង់រៀបគម្រោងហើយបានសម្រេចដោយសារមនុស្ស។ |
| ☐ | ☐ | ៦.ជំនឿគឺជាអ្វីមួយដែលបានបង្កើតគម្រោងហើយសម្រេចដោយមនុស្ស។ |
| ☐ | ☐ | ៧.បើគ្មានជំនឿទេនោះ,ការដែលទទួលជ្រមុជទឹកគឺគ្រាន់តែជាការដែលទទឹកខ្លួនប៉ុណ្ណោះ! |
| ☐ | ☐ | ៨. មនុស្សគ្រប់គ្នានៅក្នុងពិភពលោកអាចប្រែក្លាយជាគ្រីស្ទានបាន។ |



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. "ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយ________________ទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ"។(កិច្ចការ ២:៣៨)

២, ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូទ្រង់បានយាងមកក្នុងលោកីយ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជា________________________ក្នុងពួកគេ (១ធីម៉ូថេ ១:១៥)

៣, ព្រះអង្គសង្គ្រោះបងប្អូនដោយសារ_________________តាមរយៈ__________________។ ការសង្គ្រោះមិនមែនមកពីបងប្អូនទេ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ហើយក៏មិនមែនមកពី______________________ដើម្បីកុំអោយនរណាម្នាក់អួតខ្លួនបាន។ (អេភេសូ ២:៨-៩)(បកប្រែថ្មី)

៤,នេះជានិមិត្តរូបនៃពិធីជ្រមុជទឹកដែល_____________________________នាបច្ចុប្បន្នកាល តែពិធីជ្រមុជទឹកមិនមែនជាពិធីលាងជំរះរូបកាយនោះទេ គឺជាការថ្វាយជីវិតទាំងស្រុងទៅព្រះជាម្ចាស់ ដោយមនសិការល្អវិញ។ ពិធីជ្រមុជទឹកនេះសង្គ្រោះបងប្អូន ដោយសារព្រះយេស៊ូគ្រីស្ទមានព្រះជន្មរស់ឡើងវិញ ។ (១ពេត្រុស ៣:២១;បកប្រែថ្មី)



## សំនួរសំខាន់

១. ហេតុអ្វីបានជាអ្នកគិតថា,មនុស្សណាម្នាក់ដែលព្យាយាមប្រព្រឹត្តអំពើល្អសន្សំកុសលដើម្បីអោយបានកើនសេចក្ដីសង្គ្រោះគឺជាការប្រមាថដល់ព្រះ?

២.តើអ្វីគឺជាការខុសគ្នារវាងទង្វើរនៃការប្រព្រឹត្តអំពើល្អសន្សំកុសលហើយនឹងការស្ដាប់បង្គាប់ព្រះ?

៣. តើមនុស្សម្នាក់ប្រែក្លាយជាគ្រីស្ទានបានដោយរបៀបណា?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព

<u>ការសិក្សាបន្ថែមសម្រាប់មេរៀនទី ១០:</u>

- ១០.១ អំណោយទាននៃការធ្វើការអស្ចារ្យ នៅក្នុងគម្ពីរសញ្ញាថ្មី(ផ្នែកទី១)
- ១០.២ អំណោយទាននៃការធ្វើការអស្ចារ្យ នៅក្នុងគម្ពីរសញ្ញាថ្មី(ផ្នែកទី ២)
- ១០.៣ គ្រប់ចំនុចអំពិការប្រព្រឹត្ត
- ១០.៣ របៀបនៃការប្រែក្លាយជាគ្រីស្ទាន
- ១០.៥ គ្រប់ចំនុចអំពីពិធីជ្រមុជទឹក (ផ្នែកទី១)
- ១០.៦ គ្រប់ចំនុចអំពីពិធីជ្រមុជទឹក (ផ្នែកទី ២)

<u>បទគម្ពីរសម្រាប់មេរៀនបន្ទាប់</u>



- លូកា១៦
- កិច្ចការ ២៨
- ២ធីម៉ូថេ៤

# មេរៀនទី ១១: រហូតដល់ព្រះយេស៊ូយាងមកវិញ

## *សេចក្តីផ្តើម: ការរង់ចាំដោយការអត់ធ្មត់*



ពួកជំនុំនៅតែបន្តរីកចំរើនទោះបីជាមានការបៀតបៀន, ហើយក៏នៅតែនាំយកដំណឹងល្អទៅពាសពេញពិភពលោកដោយសេចក្តីជំនឿ។សាតាំងវាគ្មានអំណាចនៅលើពិភពលោកទៀតទេចាប់តាំងពីពេលដែលព្រះយេស៊ូសុគតហើយនឹងមានព្រះជន្មរស់ឡើងវិញ។យ៉ាងណាមិញ, វាគឺជាមេបញ្ឆោត( ហើយនៅតែ) ជាមេបោកបញ្ឆោត។សត្រូវដ៏ធំរបស់ប្រជារាស្ត្រនៃព្រះបានចូលមកក្នុងជំនាន់គ្រីស្ទាន។តាមរយៈឥទ្ធិពលរបស់សាតាំង, រដ្ឋអំណាចហើយនឹងមនុស្សផ្សេងបានបៀតបៀនដល់ពួកជំនុំ។គ្រីស្ទានរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះ
១១.១ យេស៊ូដោយភាពអត់ធ្មត់ហើយរស់នៅក្នុងជីវិតដែលពោរពេញដោយជំនឿរហូតដល់ស្លាប់ខាងរូបកាយនេះទៅ។[១]

## *ការកត់ត្រាព្រះគម្ពីរសញ្ញាថ្មី*

មានសាសន៍យូដា,និងប្រជាជនសាសន៍ដ៏ទៃជាច្រើន,សូម្បីតែពួករដ្ឋអំណាចរបស់ចក្រភពរ៉ូមមិនពេញចិត្តនឹងពួកគ្រីស្ទាននោះឡើយ។មានគ្រីស្ទានជាច្រើនត្រូវបានសម្លាប់ដោយព្រោះតែសេចក្តីជំនឿរបស់ពួកគេ។ពួកសាវ័កបានរងការបៀតបៀនហើយនឹងសេចក្តីស្លាប់។ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំពួកសាវ័កហើយនឹងមនុស្សនៃសេចក្តីជំនឿនៅក្នុងជំនាន់សញ្ញាថ្មីអោយសរសេរដំណឹងល្អអំពីព្រះយេស៊ូហើយនឹងការបង្រៀនរបស់គ្រីស្ទានដើម្បីអោយព្រះបន្ទូលព្រះអាចផ្សព្វផ្សាយទៅគ្រប់ប្រទេសទាំងអស់។ជាសេចក្តីបន្ថែមនៅក្នុងដំណឹងល្អទាំងបួនដែលបង្ហាញពីព្រះជន្មរបស់ព្រះយេស៊ូ,ពួកគេបានសរសេរសំបុត្រនៃការលើកទឹកចិត្តហើយនឹងការណែនាំដល់ពួកជំនុំផ្សេងៗ។សំបុត្រទាំងនេះត្រូវបានហៅថាសំបុត្ររបស់ពួកសាវ័ក ។មានសំបុត្រចំនួន ២២សំបុត្រនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។សំបុត្រទាំងនេះគឺដើម្បីបង្រៀនដល់គ្រីស្ទានទាំងអស់អោយចេះស្រលាញ់ព្រះហើយនឹងស្តាប់តាមព្រះ,បម្រើដល់អ្នកដ៏ទៃព្រមទាំងរក្សាសេចក្តីជំនឿអោយបានរឹងមាំ។ព្រះគម្ពីរបានចែងថា:

> *គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចោញព្រះវិញ្ញាណបណ្តាលឲ្យតែងទេក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត។ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ។*[២]



ជាមួយនឹងការសរសេរព្រះគម្ពីរសញ្ញាថ្មី,ការចម្លងហើយបន្តរពីពួកជំនុំមួយទៅពួកជំនុំមួយទៀត។ពួកជំនុំនៃព្រះគ្រីស្ទាបានចាប់ផ្តើមហើយក៏បានរីកចំរើន,ហើយនៅតែបន្តរីកចំរើនដល់សព្វថ្ងៃនេះដែរ!





---

[១] មសព ១០,៧ តើយើងធ្វើអ្វីបន្ទាប់ពីយើងទទួលបានសេចក្តីសង្គ្រោះ?
[២] ២ធីម៉ូថេ ៣:១៦-១៧ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដែលយើងទទួលព្រះគម្ពីរ, សូមពិចារណាអំពីមេរៀនដ៏សាមញ្ញក្នុងព្រះគម្ពីអំពីរៈមេរៀននៃព្រះគម្ពីរ

### សំនួរពិភាក្សា:

- តើអាចអោយគ្រីស្ទានមានការរីកចំរើនដោយរបៀបណានៅពេលដែលមនុស្សព្យាយាមបៀតបៀនឬសូម្បីសម្លាប់គ្រីស្ទាននោះ?

# មានអ្នកខ្លះចាកចេញពីជំនឿ

គួរអោយសោកស្តាយ,មិនមែនមានត្រឹមតែដំណឹងល្អដើម្បីប្រាប់អំពីជំនាន់គ្រីស្ទាននោះទេ។ក៏មានដំណឹងអាក្រក់ដែលយើង
គួរតែពិចារណាផងដែរ។សាតាំងបានដឹងយ៉ាងច្បាស់ថាការតាំងចិត្តរបស់ពួកជំនុំចំពោះដំណឹងល្អនៃព្រះយេស៊ូគឺខ្លាំងក្លាណាស់។
សាតាំងវាបានប្រើឧបាកលដដែលនៅក្នុងការបោកប្រាស់អេវ៉ាកាលពីនៅក្នុងសួនច្បារអេដែន។វាបានសាបព្រោះគ្រាប់ពូជនៃម
១១.២ ន្ទិលសង្ស័យចំពោះព្រះបន្ទូលនៃព្រះ។ដោយព្រោះឥទ្ធិពលនៃសាតាំង,គ្រូក្លែក្លាយហើយនឹងគ្រីស្ទានដែលគិតតែពីប្រយោជ
ន៏ខ្លួនឯងបានចាប់ផ្តើមធ្វើការផ្លាស់ប្តូរជំនឿហើយនឹងការប្រព្រឹត្តរបស់ពួកជំនុំ។[៣] លោកសាវ័កប៉ូលបានដាស់តឿនថា:

*"ព្រះវិញ្ញាណមានព្រះបន្ទូលយ៉ាងច្បាស់ថា នៅគ្រាចុងក្រោយ នឹងមានអ្នកខ្លះបោះបង់ចោលជំនឿ ទៅជាប់ចិត្តនឹងវិញ្ញាណបោកបញ្ឆោត ហើយទៅជាប់ចិត្តនឹងសេចក្តីប្រៀនប្រដៅរបស់អារក្ស។ គេចាញ់បោកពុតត្បុតរបស់មេបោកប្រាស់។ មនសិការរបស់អ្នកទាំងនោះជាប់ជាខ្ញុំបំរើរបស់អារក្ស។"* [៤]



គ្រីស្ទានដែលមានជំនឿរឹងមាំបានក្រោកឈរឡើងចំពោះអ្វីដែលជាភាពត្រឹមត្រូវពួកគេបាន
បដិសេធចំពោះការបោកបញ្ឆោតរបស់សាតាំងក៏មិនបានយល់ស្របជាមួយនឹងគ្រូ
ក្លែងក្លាយទាំងនោះដែរ។ដោយព្រោះតែគ្រូក្លែងក្លាយទាំ
ងនោះមិនបានបោះបង់ចោលការដែលគេធ្វើ
នោះ,ពួកគេបានចាកចេញពីសេចក្តីជំនឿហើ
យបានចាប់ផ្តើមបង្កើតពួកជំនុំខ្លួនគេ។ទោះ
បើព្រះយេស៊ូបានមានបន្ទូលថាព្រះអង្គបាន
បង្កើតពួកជំនុំក៏ដោយនោះ[៥] ,មនុស្សផ្សេង
ទៀតបានបង្កើតពួកជំនុំដើម្បីតម្រូវតាមបំណ
១១.៣ ងប្រាថ្នារបស់ពួកគេ។[៦] ក៏នៅតែមានរហូ
តដល់សព្វថ្ងៃនេះ,ក្រុមមនុស្សដែលមិនស្តាប់តាមបញ្ញត្តិឬស្តាប់តាមការបង្រៀនរបស់មនុស្សណាម្នាក់មិនមែនជាផ្នែកនៃពួ
កជំនុំដែលព្រះយេស៊ូបានបង្កើតនោះទេ។ពួកគេបានដកយកព្រះយេស៊ូចេញពីបល្ល័ង្កនៅក្នុងដួងចិត្តរបស់ពួកគេហើយគេបាន
ឡើងគ្រងរាជ្យដោយខ្លួនគេវិញ។

# គ្រីស្ទានដែលមានជំនឿរឹងមាំនៅតែរក្សាជំនឿ

ទោះបើសាតាំងកំពុងតែមានការមមាញឹកក្នុងការជះឥទ្ធិពលលើមនុស្សអោយធ្លាក់ទៅក្នុងអំពើបាបហើយនឹងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណក៏ដោយនោះ,គ្រីស្ទានបាននឹងកំពុងតយុទ្ធជាមួយនឹងវាដោយការនាំយកដំណឹងល្អនៃព្រះយេស៊ូដែលជា:សេចក្តីសង្គ្រោះហើយនឹងការរស់នៅដោយកោតខ្លាចដល់ព្រះទៅពាសពេញពិភពលោក។សង្គ្រាមខាងព្រលឹងវិញ្ញាណមួយនេះគឺជាសង្គ្រាមរវាងដំណឹងល្អនៃព្រះយេស៊ូហើយនឹងឥទ្ធិពលអាក្រក់របស់សាតាំងដែលនឹងនៅតែបន្តរនៅក្នុងជំនាន់គ្រីស្ទាន។តាមរយៈការរស់នៅដោយការកោតខ្លាចព្រះ,ការយកចិត្តទុកដាក់ចំពោះជនក្រីក្រនិងអ្នកទន់ខ្សោយ,ហើយនឹងការផ្សាយដំណឹងល្អ,គ្រីស្ទានបានបានលាតត្រដាងអំពីអំពើបាបហើយនឹងផ្លូវដ៏អាក្រក់របស់សាតាំង។

---

[៣] មសព ១១,២ សេចក្តីបញ្ឆោត
[៤] ១ធីម៉ូថេ ៤:១-២ (បកប្រែថ្មី)
[៥] ម៉ាថាយ ១៦:១៦-១៨
[៦] មសព ១១,៣ ការយល់ខុស ទាំងប្រាំមួយអំពីជំនឿគ្រីស្ទាន

## សំនួរពិភាក្សា:

- ហេតុអ្វីបានជាក្រុមមនុស្សដែលមិនធ្វើតាមបញ្ញត្តិនៃព្រះឬស្តាប់តាមការបង្រៀនរបស់មនុស្សណាម្នាក់មិនត្រូវបានរាប់ថាជាផ្នែកនៃពួកជំនុំនៃព្រះអម្ចាស់?



ជំនឿរបស់គ្រីស្ទានគឺស្ថិតលើការផ្សព្វផ្សាយ,គឺមានន័យថាការចែករំលែកអំពីដំណឹងល្អនៃព្រះយេស៊ូ។គ្រីស្ទានតែងតែផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងថ្មីមួយទៀតហើយនាំយកដំណឹងល្អទៅជាមួយគេ។កាលដែលពួកជំនុំមានការរីកចំរើនជុំវិញពិភពលោក,ហើយក៏មានមនុស្សជាច្រើនកំពុងតែស្តាប់តាមព្រះដោយសេចក្តីជំនឿ។ព្រះយេស៊ូបានបញ្ជាថាដំណឹងល្អរបស់ព្រះអង្គគឺត្រូវតែបាននាំយកទៅពាសពេញពិភពលោកទាំងមូល។ព្រះអង្គបានមានព្រះបន្ទូលថា:

> *ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធចុះហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្បៗ*[៧]

ព្រះយេស៊ូបានប្រទានបញ្ញត្តិដ៏ច្បាស់លាស់បំផុតសម្រាប់គ្រីស្ទានគឺថា:. ចូរទៅហើយបង្កើតអោយមានសិស្សនៅគ្រប់ទាំងសាស្រ្ត។តាមរយៈសេចក្តីសង្គ្រោះហើយនឹងការស្អាងចិត្ត(ដែលបានលើកឡើងដោយព្រះយេស៊ូថា "ជ្រមុជទឹកអោយគេ"ហើយនឹង "បង្រៀនគេ"),មនុស្សដែលរស់នៅក្នុងពិភពលោកទាំងមូលកំពុងរង់ចាំថ្ងៃដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញដោយសេចក្តីជំនឿ។ហើយរហូតដល់ពេលនោះ,គ្រីស្ទានគួរតែរក្សាសេចក្តីជំនឿដោយមានការលូតលាស់ខាងព្រលឹងវិញ្ញាណតាមរយៈការបង្រៀនរបស់ព្រះគម្ពីរ,ការរស់នៅដោយការកោតខ្លាចព្រះ,ហើយនឹងការចែករំលែកដំណឹងល្អជាមួយនឹងអ្នកដ៏ទៃ។

## *រក្សាសេចក្តីជំនឿរហូតដល់ថ្ងៃស្លាប់*

គ្រីស្ទាបានធ្វើការរង់ចាំសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូអស់រយៈពេលជាយូរណាស់មក ហើយ។ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់យើងទាំងអស់គ្នាអោយមានការអត់ធ្មត់,ដោយព្រោះតែពេលវេលានៃព្រះអង្គមិនដូចជាពេលវេលារបស់យើងនោះឡើយ។ព្រះគម្ពីរចែងថា:

> *តែពួកស្ងួនភ្ងាអើយ កុំឲ្យភ្លេចសេចក្តី១នេះឡើយ គឺថា នៅចំពោះព្រះអម្ចាស់១ថ្ងៃទុកដូចជា១ពាន់ឆ្នាំ ហើយ១ពាន់ឆ្នាំក៏ទុកដូចជា១ថ្ងៃដែរ។*[៨]

នៅពេលដែលព្រះយេស៊ូមានព្រះបន្ទូលថាព្រះអង្គទ្រង់នឹងយាងមកជាឆាប់,ការនេះមិនមែនជាការដែលផ្តោតទៅលើការវាស់ស្ទង់អំពីពេលវេលានោះទេ។,ប៉ុន្តែជាការអះអាងអំពីស្ថានសួគ៌វិញគឺថា: ទ្រង់នឹងយាងមកវិញ,សូមជ្រាបថា,គ្រីស្ទានកំពុងព្យាយាមអស់ពីសមត្ថភាពក្នុងការរស់នៅក្នុងជីវិតរបស់គេទាំងមូលដោយការស្តាប់តាមព្រះ។ជីវិតមួយដែលរស់នៅជាការបម្រើដល់ព្រះគឺសក្តិសមចំពោះរង្វាន់ដ៏អស់កល្បជានិច្ចដែលមាននៅក្នុងស្ថានសួគ៌![៩] នៅក្នុងទីបញ្ចប់នៃជីវិតរបស់យើង,តើនឹងមានរឿងអ្វីកើតឡើងនៅពេលដែលយើងស្លាប់ទៅហើយព្រះយេស៊ូមិនទាន់យាងត្រឡប់មកវិញ?តើមានរឿងអ្វីកើតឡើងចំពោះអស់អ្នកដែលបានស្លាប់មុនជំនាន់របស់យើងទាំងអស់គ្នា?

មនុស្សបានព្យាយាមប្រឌិតចម្លើយសម្រាប់សំនួរនេះជាច្រើនហើយចម្លើយទាំងនោះសុទ្ធតែខុសៗគ្នាទាំងអស់។មនុស្សមួយចំនួនជឿថាយើងនឹងមិនមានវត្តមានទៀតឡើយ។ពួកគេគិតថាជីវិតមួយនេះគឺជាជីវិតតែមួយដែលយើងមាន។អ្នកផ្សេងទៀតជឿថាជីវិតមួយនេះគឺជាការវិលជុំដ៏ធំនៃការកើត,មានជីវិតរស់នៅ,ស្លាប់ហើយនឹងកើតឡើងវិញ។មានពេលជាច្រើន ពួកគេជឿថាជីវិតមួយនេះគ្មានទីបញ្ចប់ហើយវាជាការរស់នៅដែលគ្មានរង្វាន់អ្វីអស្ចារ្យនោះឡើយ។ប៉ុន្តែនៅតែមានអ្នកដ៏ទៃជឿថាយើងនឹងប្រែក្លាយជាព្រះដោយខ្លួនឯង។គំនិតដែលមានខាងលើនេះសុទ្ធសឹងតែជាការបង្កើតរបស់មនុស្សមិនមែនមកពីព្រះឡើយ។ព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញនៅក្នុងព្រះគម្ពីរថានឹងមានរឿងអ្វីកើតឡើងប្រសិនបើយើងស្លាប់មុនពេលដែលព្រះយេស៊ូយាងត្រឡប់មកវិញ។

---

[៧] ម៉ាថាយ ២៨:១៩-២០
[៨] ២ពេត្រុស ៣:៨
[៩] ២កូរិនថូស ៤:១៧

សំនួរពិភាក្សា:

- តើអ្នកធ្លាប់មានបំណងចង់បានអ្វីមួយយ៉ាងខ្លាំងប៉ុន្តែអ្នកត្រូវចាំរយៈពេលយូរដែរឬទេ?
- ហេតុអ្វីបានជាអ្នកគិតថាមានការយល់ឃើញជាច្រើនអំពីជំនឿថាមានរឿងអ្វីកើតឡើងបន្ទាប់ពីស្លាប់ទៅ?

ព្រះគម្ពីរបានចែងថានៅពេលដែលយើងស្លាប់ខាងរូបកាយនេះទៅ,ឱកាសនៅក្នុងការទទួលបានការអត់ទោសហើយនឹងការប្រោសលោះបានកន្លងផុតហើយ។ប្រសិនបើយើងមានជំនឿរឹងមាំចំពោះព្រះអង្គ,ទ្រង់នឹងស្មោះត្រង់ចំពោះយើង។ប្រសិនបើយើងបដិសេធព្រះអង្គ,នោះទ្រង់នឹងបដិសេធយើងដែរ។[10] ព្រះគម្ពីរបានចែងថានៅពេលដែលយើងស្លាប់ទៅព្រលឹងរបស់យើងនឹងទៅកន្លែងរង់ចាំមួយដែលហៅថាស្ថានឃុំព្រលឹងមនុស្សស្លាប់។[11] នៅក្នុងអណាចក្រនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ជាកន្លែងដែលមនុស្សដែលបានស្លាប់ទៅរង់ចាំថ្ងៃជំនុំជំរះ។ ព្រះយេស៊ូបានរង់ចាំនៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់អស់រយៈពេលបីថ្ងៃចាប់តាំងពីពេលដែលព្រះអង្គសុគតរហូតដល់ទ្រង់មានព្រះជន្មរស់ឡើងវិញ។[12]




បន្ទាប់ពីព្រះអង្គយាងទៅស្ថានសួគ៌វិញ,ព្រះយេស៊ូកំពុងសោយរាជ្យជាមួយនឹងព្រះដែលជាព្រះវរបិតា។[13] ដូច្នេះហើយ,ស្ថានឃុំព្រលឹងមនុស្សស្លាប់មិនមែនជាស្ថានសួគ៌នោះឡើយ។នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់មានជង្ហុកមួយយ៉ាងធំដែលញែកមនុស្សសុចរិតពីមនុស្សទុច្ចរិត។ជង្ហុកនោះធំណាស់ដែលគ្មានអ្នកណាអាចឆ្លងពីម្ខាងទៅម្ខាងបានឡើយ។ពួកមនុស្សសុចរិតរស់នៅក្នុងផ្នែកមួយនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ដែលហៅថាស្ថានបរមសុខជាកន្លែងដែលមានសេចក្ដីសុខសាន្តនឹងភាពកក់ក្ដៅ។ពួកមនុស្សទុច្ចរិតនៅក្នុងផ្នែកមួយនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ដែលជាកន្លែងទទួលទណ្ឌកម្មនិងការឈឺចាប់។[14] ក្នុងវេលាដែលមនុស្សដែលមានជីវិតកំពុងរស់ចាំការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូនៅលើផែនដី,ពួកអ្នកដែលបានស្លាប់ទៅក៏រស់ចាំនៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់រហូតដល់ព្រះយេស៊ូយាងមកវិញម្ដងទៀតដែរ។

## *រំលឹកឡើងវិញ:រហូតដល់ព្រះយេស៊ូយាងមកវិញ*

ជំនាន់គ្រីស្ទានបានចាប់ផ្ដើមជាមួយនឹងពួកសាវ័កហើយនឹងមនុស្សនៅក្នុងជំនាន់សញ្ញាថ្មីជាច្រើនទៀតបានសរសេរព្រះបន្ទូលនៃព្រះដោយមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ។ការសរសេរនោះបានបន្តពីពួកជំនុំមួយទៅពួកជំនុំមួយទៀត។សាតាំងបានបន្តបញ្ឆោតហើយនឹងប្រើប្រាស់មនុស្ស។មនុស្សបានធ្លាក់ទៅក្នុងសេចក្ដីល្បួងដោយសារបំណងប្រាថ្នាឬអំពើបាបដ៏ទៃទៀតបានធ្វើអោយមនុស្សខ្លះបានចាកចេញ(ហើយក៏នៅតែមានអ្នកចាកចេញ)ពីពួកជំនុំហើយទៅចាប់ផ្ដើមក្រុមដោយខ្លួនគេដែលគេប្រកាសថាពួកគេជឿលើព្រះប៉ុន្តែមិនបានគោរពព្រះអង្គដោយការចុះចូលតាមព្រះហឫទ័យព្រះអង្គ។គ្រីស្ទានដែលមានជំនឿរឹងមាំនៅតែបន្តផ្សាយដំណឹងល្អ,ជួយអ្នកដែលមានសេចក្ដីត្រូវការ,បង្ហាញអំពើអាក្រក់ហើយនឹងអំពើបាបថាវាអាក្រក់យ៉ាងណា។

ព្រះគម្ពីរបានពន្យល់ថានៅពេលដែលយើងស្លាប់ទៅ,ឱកាសដែលយើងអាចទទួលបានសេចក្ដីសង្គ្រោះបានកន្លងផុតទៅហើយ។កន្លែងរង់ចាំមួយដែលត្រូវបានបង្កើតមកសម្រាប់ព្រលឹងវិញ្ញាណរបស់ចាំការជំនុំជំរះ។ ខគម្ពីរចងចាំសម្រាប់មេរៀនអាចធ្វើជាអ្នកផ្ដល់ភាពកក់ក្ដៅសម្រាប់គ្រីស្ទានដែលយកចិត្តទុកដាក់និងរង់ចាំការជំនុំជំរះមកដល់:

*“ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ”*—(យ៉ូហាន ៣:១៦)

[10] ២ធីម៉ូថេ ២:១១-១៣
[11] លូកា ១៦:២២-២៣
[12] កិច្ចការ ២:៣១
[13] សូមមើលក្នុង វិវរណៈ ៤-៥
[14] លូកា ១៦:១៩-៣១

# លំហាត់មេរៀន

# មេរៀនទី ១១: រហូតដល់ព្រះយេស៊ូយាងមកវិញ

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.ព្រះគម្ពីរគឺជាការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធហើយត្រូវបានកត់ត្រាដោយមនុស្សនៃសេចក្តីជំនឿ។ |
| ☐ | ☐ | ២. សាតាំងវាប្រើវិធីដដែលនៅក្នុងការបោកបញ្ឆោតគ្រីស្ទានដោយព្យាយាមធ្វើអោយព្រះបន្ទូលព្រះគ្មានតម្លៃ។ |
| ☐ | ☐ | ៣.ដោយព្រោះតែគ្រូក្លែងក្លាយទាំងនោះមិនបោះបង់ចោល,ពួកគេបានចាកចេញសេចក្តីជំនឿហើយបង្កើតពួកជំនុំដោយខ្លួនគេ។ |
| ☐ | ☐ | ៤. ការរងទុក្ខវេទនារយៈពេលប៉ុន្មានឆ្នាំសក្តិសមចំពោះរង្វាន់អស់កល្បជានិច្ចនៅក្នុងស្ថានសួគ៌ជាមួយនឹងព្រះ។ |
| ☐ | ☐ | ៥. ដោយព្រោះតែគ្មានអ្នកណាម្នាក់អាចដឹងថាពេលណាដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញនោះ,យើងគួរតែរស់នៅក្នុងជីវិតដែលមានសេចក្តីជំនឿពេញមួយជីវិតយើង! |
| ☐ | ☐ | ៦. ព្រះគម្ពីរមិនបានចែងច្បាស់ថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ពីយើងស្លាប់ទៅនោះឡើយ។ |
| ☐ | ☐ | ៧. ស្ថានឃុំព្រលឹងមនុស្សស្លាប់ហើយនឹងស្ថានសួគ៌ជាកន្លែងតែមួយ។ |
| ☐ | ☐ | ៨. ព្រះទ្រង់អត់ធ្មត់,ទ្រង់មានព្រះទ័យឲ្យមនុស្សទាំងអស់ទទួលបានសេចក្តីសង្គ្រោះ។ |

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. តែព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលយ៉ាងជាក់ច្បាស់ថា នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹង______________________ ___________________________ ដោយស្តាប់តាមវិញ្ញាណបញ្ឆោត និងសេចក្តីបង្រៀនរបស់ពួកអារក្ស។(១ធីម៉ូថេ ៤:១)

២.ព្រះអម្ចាស់មិនផ្អាកសេចក្តីសន្យារបស់ទ្រង់ ដូចជាមានអ្នកខ្លះគិតស្មាននោះទេ គឺទ្រង់មានព្រះហឫទ័យអត់ធ្មត់នឹងយើងរាល់គ្នាវិញ ដោយមិនចង់ឲ្យ_______________________________________________________គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ ។ រីឯថ្ងៃនៃព្រះអម្ចាស់ នោះនឹងមកដូច ______________________________ នៅថ្ងៃនោះផ្ទៃមេឃនឹងបាត់ទៅ ដោយសូរគ្រាំគ្រេង ឯធាតុសព្វសារពើនឹងរលាយទៅ ដោយកំដៅដ៏ក្រៃលែង ហើយផែនដី និងការសព្វសារពើ នឹងត្រូវឆេះអស់រលីងទៅ។(២ពេត្រុស ៣:៩-១០)



## សំនួរសំខាន់

១. ហេតុអ្វីបានជាមានមនុស្សចាកចេញពីសេចក្តីជំនឿ?

២.  ហេតុអ្វីបានជាសាតាំងចង់ល្បួងគ្រីស្ទានអោយបោះបង់ចោលសេចក្តីជំនឿរបស់គេ?

៣. តើយើងត្រូវរស់នៅយ៉ាងដូចម្តេចដោយព្រោះតែយើងមិនដឹងថាពេលណាដែលព្រះយេស៊ូយាងត្រឡប់មកវិញនោះ?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្តីអធិស្ឋាន

# ការរៀបចំ

មសព ការសិក្សាបន្ថែមសម្រាប់មេរៀនទី ១១:

- ១១.១ តើយើងត្រូវធ្វើអ្វីបន្ទាប់ពីយើងទទួលបានសេចក្តីសង្គ្រោះ
- ១១.២ ការបោកបញ្ឆោត
- ១១.៣ ការយល់ឃើញខុសទាំងប្រាំមួយអំពីជំនឿគ្រីស្ទាន

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



- វិវរណៈ ២០-២២

# មេរៀនទី ១២: រង្វាន់ដ៏អស់កល្បជានិច្ច

## *សេចក្ដីផ្ដើម:គ្រាចុងក្រោយ*

ជំនាន់គ្រីស្ទាននឹងបន្តរហូតដល់ពេលដែលព្រះអម្ចាស់យេស៊ូយាងត្រឡប់មកវិញដើម្បីនាំយកការជំនុំជំរះមកលើពិភពលោក។ព្រះទ្រង់មានសេចក្ដីអត់ធ្មត់។ទ្រង់មានព្រះទ័យអោយមនុស្សគ្រប់គ្នាទទួលបានសេចក្ដីសង្គ្រោះ[១] ។ជាន់ក្រោយបង្អស់,នឹងឈានទៅដល់ពេលដែលព្រះទ្រង់សម្រេចព្រះទ័យថាទ្រង់បានមានព្រះទ័យអត់ធ្មត់គ្រប់គ្រាន់ហើយ។ទ្រង់នឹងបញ្ចាប់ពេលវេលាដោយបញ្ជូនព្រះយេស៊ូត្រឡប់មកវិញម្តងទៀត។គ្មានអ្នកណាម្នាក់អាចដឹងពីពេលវេលាច្បាស់លាស់ដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញនោះឡើយគឺជ្រាបតែព្រះវរបិតាតែប៉ុណ្ណោះ។[២] សេចក្ដីសន្យាដែលយើងទទួលបានពីព្រះគឺថា, ព្រះយេស៊ូនឹងយាងត្រឡប់មកវិញ,ហើយរហូតដល់ទ្រង់យាងមកយើងគួរតែរស់នៅថ្វាយទ្រង់!



ព្រះគម្ពីរបានចែងថាទ្រង់នឹងមកដូចជាចោរនៅពេលយប់,គឺមានន័យថាគ្មានអ្នកណាអាចដឹងពីពេលវេលានោះឡើយ។ព្រះយេស៊ូនឹងលេចមកលើមេឃជាមួយនឹងពួកទេវតា,មនុស្សទាំងអស់(ទាំងមនុស្សដែលមានជីវិតរស់នៅនិងអ្នកដែលបានស្លាប់)នឹងត្រូវហៅទៅឈរនៅមុខទីជំនុំជំរះ។នៅពេលដែលមនុស្សទាំងអស់មកជុំគ្នាហើយនោះ,គ្រប់គ្នានឹងលុតជង្គង់ហើយសារភាពថាព្រះយេស៊ូជាព្រះអម្ចាស់។[៣] ក្រោយដែលមនុស្សហៅមកជុំគ្នាហើយនោះនឹងមានការជំនុំជំរះហើយនឹងទទួលបានរង្វាន់ដ៏អស់កល្បជានិច្ច។

## *ការជំនុំជំរះ*

មនុស្សគ្រប់គ្នាដែលបានរស់នៅ,ចាប់តាំងពីមនុស្សដំបូងគឺលោកអ័ដាមរហូតមកដល់អ្នកហើយនឹងខ្ញុំ,នឹងប្រឈមមុខចំពោះការជំនុំជំរះ។ព្រះគម្ពីរបានចែងថាបញ្ជីរនឹងបើកឡើងហើយជីវិតដែលយើងបានរស់នៅគឺជាភស្តុតាងសម្រាប់យើងទាំងអស់គ្នា។ជីវិតរបស់យើងម្នាក់ៗគឺជាការបង្ហាញពីសេចក្ដីជំនឿរបស់យើងចំពោះព្រះឬពីការដែលយើងបះបោរជាមួយនឹងទ្រង់។[៤] ព្រះលោហិតរបស់ព្រះយេស៊ូនឹងគ្របបាំងអំពើបាបអស់អ្នកដែលមានជំនឿហើយនឹងស្តាប់តាមដំណឹងល្អរបស់ ១២.១
ព្រះអង្គ។ឈ្មោះរបស់មនុស្សដែលទទួលបានសេចក្ដីសង្គ្រោះនឹងមាននៅក្នុងបញ្ជីរជីវិត។មនុស្សដែលមិនមានឈ្មោះនៅក្នុងបញ្ជីរជីវិតនឹងត្រូវបោះទៅក្នុងស្ថាននរកអស់កល្បជានិច្ច។[៥] ព្រះយេស៊ូជាអ្នកកាត់ទោសផ្ទាល់។គ្មានអ្នកណាម្នាក់អាចប្រកែកតវ៉ារឿងក្ដីរបស់គេនៅចំពោះព្រះភក្ត្រនៃព្រះបានឡើយ។គ្មានអ្នកម្នាក់អាចធ្វើការផ្លាស់ប្តូរការកាត់ទោសដែលគេបានទទួលនោះឡើយ។ព្រះទ្រង់នឹងកាត់ទោសដល់ព្រលឹងនិមួយៗតាមការរស់នៅកាលដែលគេមានជីវិតរស់នៅ(ទោះបីជាដោយសេចក្ដីជំនឿឬបះបោរ)




[១] ២ពេត្រុស ៣:៩
[២] ម៉ាថាយ ២៤:៣៦,២ពេត្រុស ៣:១០-១៣,១ ថែស្សាឡូនិច ៥:១-១១
[៣] ១កូរិនថូស ១៥:៥០-៥៨,ភីលីព ២:១០
[៤] មសព ១២,១ សង្គ្រោះដោយព្រះគុណ-ជំនុំជំរះដោយសេចក្ដីជំនឿ
[៥] វិវរណៈ ២០:១១-១៥

### សំនួរពិភាក្សា:

- ហេតុអ្វីបានជាអ្នកគិតថាព្រះមិនទាន់បានបង្ហាញពីពេលវេលាច្បាស់លាស់នៃកាយាងមកវិញរបស់ព្រះយេស៊ូ?
- តើថ្ងៃជំនុំជំរះគឺជាអ្វីដែលមានតែគ្រីស្ទានប៉ុណ្ណោះគួរយកចិត្តទុកដាក់មែនទេ?

# ស្ថាននរកៈជាការបណ្តេញចេញពីព្រះវត្តមាននៃព្រះអស់កល្បជានិច្ច



ស្ថាននរកគឺជាអ្វីមួយដែលមានដែលមាននៅក្នុងព្រះទ័យនៃព្រះ។ការដាក់ទោសនេះមិនមែនបង្កើតមកសម្រាប់មនុស្សនោះទេ;ព្រះបានបង្កើតស្ថាននរកសម្រាប់សាតាំងហើយនឹងទេវតាដែលដើរតាមវាតែប៉ុណ្ណោះ។[៦] ប៉ុន្តែស្ថាននរកបានក្លាយជាកន្លែងសម្រាប់មនុស្សបន្ទាប់ពីការបះបោរជាមួយនឹង ព្រះនៅក្នុងសួនច្បារអេដែន។[៧] ក្នុងកាលដែលមនុស្សមួយចំនួនមិនចង់គិតអំពីស្ថាននរកនោះ,មនុស្សត្រូវតែដឹងថាមានអ្វីកំពុងតែរង់ចាំយើងទាំងអស់គ្នា,ប្រសិនបើយើងមិនព្រមធ្វើការផ្លាស់ប្រែទេនោះ។ស្ថាននរកត្រូវបានបង្កើតមកមានចំនុចបីយ៉ាងរួមគ្នា:ការដាក់ទណ្ឌកម្ម,ការបំផ្លាញ,ហើយនឹងការបណ្តេញចេញពីព្រះវត្តមាននៃព្រះ។[៨]

ព្រះគម្ពីរបានប្រើអារម្មណ៍ខាងសាច់ឈាមទាំងប្រាំដែលរៀបរាប់អំពីស្ថាននរកគឺជា(ការស្តាប់ឮ,ការប៉ះពាល់,រស់ជាតិ,ការមើលឃើញ,ហើយនឹងការដឹងឃ្លិន)។អារម្មណ៍ទាំងនេះគឺដើម្បីធ្វើជាតំណាងអោយអនាគតនៃព្រះលឹងវិញ្ញាណ។ គំនិតរបស់យើងអាចនឹងគិតអំពីអារម្មណ៍ទាំងនេះតាមរយៈខាងសាច់ឈាម,ប៉ុន្តែព្រះគម្ពីរប្រើអារម្មណ៍ទាំងនេះសម្រាប់រៀបរាប់អំពីការដាក់ទោសខាងព្រលឹងវិញ្ញាណវិញ:

- ការស្តាប់ឮ: នឹងបានឮការយំសោកហើយនឹងការសង្កៀតធ្មេញដ៏ខ្លាំង។[៩]
- ការប៉ះពាល់:ភ្លើងឆេះដ៏អស់កល្បជានិច្ច,ការឈឺចាប់ហើយនឹងដង្កូវដែលនឹងបន្តរចោះស៊ីអ្នកតែអ្នកនឹងមិនស្លាប់នោះឡើយ។[១០]
- ការដឹងរស់ជាតិ(ឬគ្មានរស់ជាតិអ្វីសោះ):ស្ថាននរកគឺប្រៀបធៀបទៅនឹងការស្រេកឃ្លានដែលមិនអាចបំពេញបាន។[១១]
- ការមើលឃើញ (ឬមើលមិនឃើញអ្វីសោះ ):ស្ថាននរកគឺជាកន្លែងដែលពោរពេញដោយយោភាពងងឹត។[១២]
- ការដឹងឃ្លិន។ ឃ្លិនដ៏សែនស្អុយរលួយហើយនឹងឃ្លិនឆេះដែលនឹងមានពេញទាំងរន្ធច្រមុះអស់អ្នកដែលនៅក្នុងស្ថាននរក។[១០]

# តើអ្នកណានឹងនៅក្នុងស្ថាននរក?

សាតាំងហើយនឹងអ្នកដែលដើរតាមវានឹងត្រូវបោះទៅក្នុងស្ថាននរក[១៣] ។ក្រៅពីវិញ្ញាណទាំងនេះ,តើអ្នកណាទៀតនឹងត្រូវបញ្ជូនទៅក្នុងស្ថាននរក?ដោយព្រោះតែគ្មានមនុស្សណាម្នាក់ដែលជាអ្នកកាត់ក្តីហើយអាចយល់ពីចិត្តរបស់មនុស្សគ្រប់គ្នា(ឬអ្នកណាម្នាក់)ដែលនៅលើផែនដីនោះ,យើងគួរតែអាចយល់ពីអ្វីដែលព្រះគម្ពីរបានបង្រៀនគឺថាផ្លូវទៅស្ថានសួគ៌នោះពិបាកណាស់,ហើយផ្លូវទៅស្ថាននរកនោះងាយណាស់:

> *"ចូរនាំគ្នាចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅរកសេចក្តីវិនាសអន្តរាយធំណាស់ ហើយផ្លូវទៅរកសេចក្តីវិនាសក៏ទូលាយដែរ មានមនុស្សជាច្រើនចូលតាមទ្វារនោះ។ រីឯទ្វារដែលនាំទៅរកជីវិតចង្អៀតហើយពិបាកដើរផងមានមនុស្សតិចទេរកផ្លូវនោះឃើញ។"*[១៤]



មនុស្សខ្លះជឿថាស្ថាននរកគឺជាកន្លែងសម្រាប់តែមនុស្សមានបាបដែលអាក្រក់ជាទីបំផុតតែប៉ុណ្ណោះ។តើអ្នកណាជាអ្នកដែកអាចសម្រេចថាអំពើបាបណាមួយដែលអាក្រក់បំផុតហើយអំពើបាបណាមួយដែលអាចលើកលែងអោយបាន?ព្រះគម្ពីរបានបង្រៀនថាគ្រប់ទាំងអំពើបាប-ដែលមិនទាន់បានទទួលបានការអត់ទោស-នឹងត្រូវជាប់ទោសនៅក្នុងការជំនុំជំរះរបស់ព្រះជាម្ចាស់។

នេះជាហេតុផលដែលគ្រីស្ទាននាំយកដំណឹងល្អទៅពាសពេញពិភពលោក។មនុស្សគ្រប់គ្នាអាចទទួលបានសេចក្តីសង្គ្រោះ។[១៥] យ៉ាងណាមិញ,ការសុគតរបស់ព្រះយេស៊ូមិនមែនមានន័យថាមនុស្សគ្រប់គ្នានឹង ទទួលបានសេចក្តីសង្គ្រោះឡើយ។ប៉ុន្តែមានន័យថាយើងមានឱកាស នៅក្នុងការទទួលបានសេចក្តីសង្គ្រោះ,ប្រសិនបើយើងតាំងចិត្តនៅក្នុងការស្តាប់តាមដំណឹងល្អនៃព្រះយេស៊ូគ្រីស្ទ!ប៉ុន្តែតើនឹងមានរឿងអ្វីកើតឡើងចំពោះមនុស្សល្អនិងមនុស្សដែលមានសីលធម៌ល្អដែលមិនបានទទួលជឿព្រះហើយនឹងស្តាប់តាមដំណឹងនៃព្រះយេស៊ូ?ព្រះគម្ពីរបានបង្រៀនថាធ្វើជាមនុស្សល្អតែម៉្យាងមិនអាចយកឈ្នះអំពើបាបបានឡើយ។មានតែព្រះគុណនៃព្រះហើយនឹងសេចក្តីជំនឿដោយការស្តាប់បង្គាប់ព្រះយេស៊ូគ្រីស្ទតែប៉ុណ្ណោះដែលអាចសង្គ្រោះយើងពីស្ថាននរកបាន។[១៦]

---

[៦] ម៉ាថាយ ២៥:៣១,២ពេត្រុស ២:២០-២២
[៧] ២ថែស្សាឡូនិច ១:៨-៩,រ៉ូម ៦:២៣
[៨] ២ថែស្សាឡូនិច ១:៥-៧,វិវរណៈ ២០:១៥
[៩] លូកា ១៣:២៧-២៨
[១០] ម៉ាកុស ៩:៤៣-៤៨
[១១] លូកា ១៦:២៤
[១២] ម៉ាថាយ ៨:១២
[១៣] វិវរណៈ ២០:១០
[១៤] ម៉ាថាយ ៧:១៣-១៤ (បកប្រែថ្មី)
[១៥] កាឡាទី ៣:២៦-២៨
[១៦] យ៉ូហាន ១៤:៦,កិច្ចការ ៤:១២,១យ៉ូហាន ៥:១២

# ព្រះយេស៊ូបានសងថ្លៃលោះ




ស្ថាននរកគឺជារង្វាន់ដ៏សែនរន្ធត់សម្រាប់មនុស្សទុច្ចរិត។យ៉ាងណាមិញ,អស់អ្នកណាដែលមានជំនឿលើព្រះនឹងមិនប្រឈមមុខជាមួយនឹងការគំរាមកំហែងនៃអំពើបាបឡើយ។ព្រះជាម្ចាស់បានឃុំគ្រងការទាំងនោះជាមួយនឹងគម្រោងនៃការប្រោសលោះរបស់ព្រះអង្គជាស្រេចហើយ។ព្រះយេស៊ូបានដកអនាគតដ៏គួរអោយភ័យខ្លាចនេះចេញមនុស្សដែលជឿហើយនឹងស្តាប់តាមទ្រង់ជាស្រេចហើយ។ព្រះយេស៊ូបានប្រឈមមុខនឹងការដាក់ទោសនៃអំពើបាបជំនួសយើងទាំងអស់គ្នា។[១៧] ការលោះបាបរបស់ព្រះយេស៊ូត្រូវបានបញ្ចប់ដោយការសុគត,ជាការបំផ្លាញនៃព្រះកាយរបស់ព្រះអង្គ។[១៨]ព្រះយេស៊ូត្រូវបានញែកចេញពីការប្រកបទាក់ទងជាមួយនឹងព្រះមួយរយៈគឺមានន័យថាទ្រង់ត្រូវបានឃ្លាតឆ្ងាយពីព្រះ។[១៩] សូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះយេស៊ូ!ព្រះគម្ពីរបានចែងថា:

> *"វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយឲ្យខ្ញុំរួច ពីតួសេចក្តីស្លាប់នេះទៅបាន ។ អរព្រះគុណដល់ព្រះអង្គ គឺដោយសារព្រះយេស៊ូគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា!*[២០]

# ស្ថានសួគ៌:ជាផ្ទះដ៏អស់កល្បជានិច្ចជាមួយនឹងព្រះ

មានការរៀបរាប់ពីស្ថានសួគ៌ជាច្រើនដែលមាននៅក្នុងគម្ពីរចុងក្រោយនៃព្រះគម្ពីរ, គម្ពីរវិវរណៈនៃព្រះយេស៊ូគ្រីស្ទ (ជាទូរទៅគឺផ្តោតទៅជា ការបង្ហាញ)។ ទំនាយអំពីគ្រីស្ទានមួយនេះប្រាប់អំពីផលវិបាកអំពីការល្អនិងការអាក្រក់សម្រាប់ចិត្តគំនិតរបស់មនុស្ស។គម្ពីរនេះបញ្ចប់ដោយជ័យជំនះនៃព្រះយេស៊ូលើសាតាំងហើយនឹងការចាប់ផ្តើមនៃជំនាន់ថ្មីដែលហៅថាជំនាន់អស់កល្បជានិច្ច។គម្ពីរវិវរណៈបានចែងថា:

> *ខ្ញុំមានឮសំឡេង១យ៉ាងខ្លាំង ចេញពីស្ថានសួគ៌មកថា មើលរោងឧបោសថរបស់ព្រះបាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ។ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ។* [២១]

យើងទាំងអស់គ្នាបានដឹងហើយថាស្ថានសួគ៌គឺជាកន្លែងដែលរាល់ទាំងរោគសញ្ញានៃអំពើបាបត្រូវបានដកចេញ។គ្មានការឈឺចាប់ឬរងទុក្ខវេទនាទៀតនោះឡើយ។មនុស្សនឹងមិនបាត់បង់សេចក្តីស្រលាញ់នៅពេលដែលអ្នកណាម្នាក់ស្លាប់នោះឡើយ។ការសំអប់គ្នា,ការអាក្រក់,នឹងរាល់ទាំងអាវុធដ៏សំបើមរបស់សាតាំងនៃភាពងងឹតក៏លែងមានទៀតដែរ។យើងនឹងរស់នៅទៅតាមអ្វីដែលព្រះបង្កើតយើងមកគឺ:រស់នៅក្នុងភាពល្អឥតខ្ចោះហើយនឹងក្នុងព្រះវត្តមាននៃព្រះ!ព្រះគម្ពីរចែងថា:

> *ទេវតាក៏បង្ហាញ ឲ្យខ្ញុំឃើញទន្លេទឹកជីវិត ថ្លាដូចជាកែវចរណៃ ដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម ។ ឯនៅកណ្តាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេទាំងសងខាង នោះមានដើមជីវិត ដែលបង្កើតផ្លែ១២ដង គឺ១ខែម្តងៗ ហើយស្លឹកឈើនោះ ក៏សំរាប់នឹងមើលអស់ទាំងសាសន៍ឲ្យជា។*[២២]

គ្រានោះនឹងគ្មានសេចក្តីបណ្តាសាទៀតឡើយ ហើយបល្ល័ង្កនៃព្រះ និងកូនចៀម ក៏នឹងនៅក្នុងក្រុងនោះ ឯពួកបាវរបស់ទ្រង់ គេនឹងបំរើទ្រង់ ។គេនឹងឃើញព្រះភក្ត្រទ្រង់ ហើយព្រះនាមទ្រង់នឹងនៅលើថ្ងាសគេ។ក៏នឹងឥតមានយប់ទៀតឡើយ ហើយគេមិនត្រូវការនឹងចង្កៀងណា ឬពន្លឺព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបំភ្លឺគេ ហើយគេនឹងសោយរាជ្យ នៅអស់កល្បជានិច្ចរៀងរាបទៅ។

---

[១៧] ២កូរិនថូស ៥:២១
[១៨] ម៉ាកុស ១៥:៤២-៤៧
[១៩] ម៉ាថាយ ២៧:៤-៦
[២០] រ៉ូម ៧:២៤-២៥
[២១] វិវរណៈ ២១:៣-៤
[២២] វិវរណៈ ២២:១-៥

សំនួរពិភាក្សា:

- ហេតុអ្វីបានជាអ្នកគិតថាស្ថាននរកគឺជាកន្លែងដែលព្រឺព្រួច?
- តើអ្វីគឺជាសេចក្តីសង្ឃឹមដ៏ធំដែលអ្នកតែងតែស្រមៃចង់បានសម្រាប់ការគិតអំពីស្ថានសួគ៌?

ដើមឈើជីវិតគឺជាអំណោយដែលព្រះបានប្រទានដល់អ័ដាមនិងអេវ៉ាអស់រយៈពេលជាយូរមកហើយ,គឺដាំនៅក្នុងស្ថានសួគ៌។វាគឺជាសញ្ញានៃការផ្សះផ្សារដ៏ពេញលេញរវាងទំនាក់ទំនងរបស់មនុស្សជាមួយនឹងព្រះ។នៅក្នុងស្ថានសួគ៌គ្មានយប់;យើងនឹងមិនត្រូវការចង្កៀងឬពន្លឺថ្ងៃនោះឡើយ,ដោយព្រោះតែព្រះអម្ចាស់ដ៏ជាព្រះទ្រង់ជាពន្លឺ។មនុស្សដែលមានជំនឿរឹងមាំនៃព្រះនឹងបានរស់នៅជារៀងរៀបតទៅក្នុងភាពល្អឥតខ្ចោះជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ,ព្រះអម្ចាស់យេស៊ូ,ហើយនឹងព្រះវរបិតា។



# *តើអ្នកត្រៀមខ្លួនហើយឬនៅ?*

នៅក្នុងខចុងក្រោយនៃព្រះគម្ពីរ,ព្រះគម្ពីរ,ជាព្រះបន្ទូលរបស់ព្រះយេស៊ូ។មនុស្សដែលសរសេរគឺជាលោកសាវ័កយ៉ូហាន។ព្រះយេស៊ូបានមានបន្ទូលថា"អើ អញមកជាឆាប់។" លោកសាវ័កយ៉ូហានត្រេកអរយ៉ាងខ្លាំងដោយព្រះបន្ទូលនោះហើយគាត់ក៏បានឆ្លើយវិញដោយប្រកាសថា, "អាម៉ែន ព្រះអម្ចាស់យេស៊ូអើយ សូមយាងមក។" [២៣]

ចុះអ្នកវិញ?តើអ្នកត្រៀមខ្លួនសម្រាប់ការយាងមកវិញរបស់ព្រះយេស៊ូហើយឬនៅ?ចម្លើយសម្រាប់សំនួរនេះ,មានលទ្ធផលដ៏អស់កល្បជានិច្ចសម្រាប់អ្នក,យើងសង្ឃឹមថាអ្នកបានត្រៀមខ្លួនជាស្រេចហើយ។នៅក្នុងមេរៀននេះបានគ្រប់ដណ្តប់នូវពត៌មានរាប់ពាន់ទំព័រដែលមាននៅក្នុងព្រះគម្ពីរដែលត្រូវបានចងក្រងឡើយជាមេរៀនសង្ខេប។ដោយព្រោះតែមានពត៌មានយ៉ាងច្រើនដែលមាននៅក្នុងព្រះគម្ពីរនោះ,យើងទាំងអស់គ្នាគួរតែបានយល់ពីតម្លៃនៃចំនុចមួយដ៏សំខាន់គឺថា:ព្រះយេស៊ូបានយាងមកក្នុងពិភពលោកដើម្បីប្រោសលោះមនុស្សមានបាប,ក្នុងចំណោមនោះក៏មានយើងទាំងអស់គ្នាផងដែរ។

## ១២.២ *ការរំលឹកមេរៀនឡើងវិញ* [២៤]

កាលដើមដំបូងឡើយ,ព្រះបានបង្កើតរបស់គ្រប់ទាំងអស់។មនុស្សត្រូវបានបង្កើតនៅក្នុងរូបអង្គនៃព្រះជាមួយនឹងព្រលឹងវិញ្ញាណដែលមិនចេះស្លាប់។នៅពេលដែលព្រះប្រទានអោយមានអំណោយទាននៃការជ្រើសរើសនោះ,មនុស្សបានជ្រើសរើសនៅក្នុងការបដិសេធព្រះហើយស្តាប់តាមខ្លួនឯងវិញ។អំពើបាបដែលមិនអាចលាងជំរះបាននេះ,បំផ្លាញពិភពលោកជាមួយនឹងការឈឺចាប់,ការរងទុក្ខវេទនាហើយនឹងសេចក្តីស្លាប់។មនុស្សមានបញ្ហារជាមួយនឹងអំពើបាបហើយមិនអាចស្វែងរកផ្លូវដោយខ្លួនគេដើម្បីជៀសផុតពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណបានឡើយ។

ប៉ុន្តែព្រះទ្រង់មានគម្រោងមួយ។នៅក្នុងពេលមួយដែលបានកំណត់,ព្រះជាម្ចាស់បានបញ្ជូនព្រះយេស៊ូមកលើផែនដី។ព្រះយេស៊ូបានបង្ហាញផ្លូវ,ទ្រង់បានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប,ហើយបានសុគតនៅលើឈើ ឆ្កាង។ការសុគតហើយនឹងការរស់ពីសុគតឡើងវិញដោយសិរីល្អបានប្រទានអោយមនុស្សនូវឱកាសដើម្បីទទួលបានសេចក្តីសង្គ្រោះពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណប្រសិនបើមនុស្សជ្រើសរើសក្នុងការមានជំនឿហើយស្តាប់តាមព្រះ។តាមរយៈការស្តាប់តាមដំណឹងល្អ,យើងទាំងអស់គ្នាអាចទទួលបានសេចក្តីសង្គ្រោះពីសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ,ហើយរស់នៅអស់កល្បជានិច្ចជាមួយនឹងព្រះនៅក្នុស្ថានសួគ៌!

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"*—(យ៉ូហាន ៣:១៦)

[២៣] វិវរណៈ ២២:២០

[២៤] មសព ១២,២ មេរៀននៃព្រះគម្ពីរ ;មសព ១២,៣ ការសម្លឹងមើលអោយកាន់តែច្បាស់ចំពោះគម្ពីរ យ៉ូហាន ៣:១៦

# លំហាត់មេរៀន
# មេរៀនទី ១២: រង្វាន់ដ៏អស់កល្បជានិច្ច

| ត្រូវ | ខុស | |
|---|---|---|
| ☐ | ☐ | ១.កាលពីដើមឡើយព្រះបានបង្កើតស្ថាននរកសម្រាប់សាតាំងហើយនឹងទេវតាដែលដើរតាមវា។ |
| ☐ | ☐ | ២.ស្ថាននរកជាកន្លែងសម្រាប់តែមនុស្សដែលអាក្រក់បំផុតតែប៉ុណ្ណោះ។ |
| ☐ | ☐ | ៣.ព្រះមិនមានក្រាំងវិន័យដើម្បីកំណត់ថាអំពើបាបណាមួយសក្តិសមធ្លាក់ទៅស្ថាននរកនោះឡើយ។ |
| ☐ | ☐ | ៤,គ្រប់ទាំងអំពើបាបទាំងអស់,ប្រសិនបើមិនទទួលបានការអត់ទោសទេនោះ,មិនខ្វល់យើងមើលវាថាសក្តិសមឬមិនសក្តិសមយ៉ាងណានោះទេ,គ្រប់ទាំងអំពើបាបទាំងអស់គឺស្មើរគ្នាក្នុងព្រះនេត្រនៃព្រះ។ |
| ☐ | ☐ | ៥.ព្រះយេស៊ូបានដកយកអស់ទាំងជោគវាសនាដែលត្រូវធ្លាក់ទៅក្នុងស្ថាននរកពីមនុស្សដែលជឿហើយនឹងស្តាប់តាមទ្រង់។ |
| ☐ | ☐ | ៦.យើងអាចរៀនដើម្បីអោយដឹងថាស្ថានសួគ៌មានរូបភាពដូចម្តេចបាន។ |
| ☐ | ☐ | ៧.នៅក្នុងស្ថានសួគយើងនឹងរស់នៅទៅតាមអ្វីដែលព្រះបានបង្កើតយើងមក:គឺក្នុងភាពល្អឥតខ្ចោះហើយនឹងក្នុងព្រះវត្តមាននៃព្រះ។ |
| ☐ | ☐ | ៨. ខ្ញុំត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកវិញរបស់ព្រះយេស៊ូ។ |



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. ចូរនាំគ្នាចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅរកសេចក្តីវិនាសអន្តរាយធំណាស់ ហើយផ្លូវទៅរកសេចក្តីវិនាសក៏ទូលាយដែរ មានមនុស្សជាច្រើនចូលតាមទ្វារនោះ។ រីឯទ្វារដែលនាំទៅរកជីវិត ____________________ ហើយ ____________________ ដើរផង មានមនុស្សតិចទេរកផ្លូវនោះឃើញ»។ម៉ាថាយ ៧:១៣-១៤(បកប្រែថ្មី)

២.វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយឲ្យខ្ញុំរួច ពី ____________________ នេះទៅបាន ?អរព្រះគុណដល់ព្រះអង្គ គឺដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដូច្នេះ ខ្លួនខ្ញុំគោរពប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះ ដោយគំនិតខ្ញុំ តែខាងសាច់ឈាមខ្ញុំ នោះតាមច្បាប់របស់អំពើបាបវិញ។(រ៉ូម ៧:២៤-២៥)

៣. ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មាន____________________ឬ ____________________ ឬ____________________ ឬ____________________ទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ។(វិវរណៈ ២១:៤)

៤.ក៏នឹងឥតមានយប់ទៀតឡើយ ហើយគេមិនត្រូវការនឹងចង្កៀងណា ឬពន្លឺព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបំភ្លឺគេ ហើយគេនឹងសោយរាជ្យ____________________។(វិវរណៈ ២២:៥)



## សំនួរសំខាន់

១.ហេតុអ្វីបានជាមនុស្សមានបាបត្រូវធ្លាក់ទៅស្ថាននរក?

២.តើមានមនុស្សណាម្នាក់ដែលសក្តិសមនឹងទៅស្ថានសួគ៌ដែរឬទេ?

៣.តើចំនុចអ្វីដែលធ្វើអោយស្ថានសួគ៌វិសេស?

# គំនិតបន្ថែមហើយនឹងសំនួរ

# សេចក្ដីអធិស្ឋាន

# ការរៀបចំ

មសព

ការសិក្សាបន្ថែមសម្រាប់មេរៀនទី ១២:

- ១២.១ សង្គ្រោះដោយព្រោះគុណតាមរយៈសេចក្តីជំនឿ-ជំនុំជំរះដោយភាពស្មោះត្រង់
- ១២.២ មេរៀននៃព្រះគម្ពីរ
- ១២.៣ ការសម្លឹងមើលកាន់តែច្បាស់អំពីគម្ពីរយ៉ូហាន ៣:១៦

បទគម្ពីរសម្រាប់មេរៀនបន្ទាប់



-

# លំហាត់មេរៀន

តើអ្វីខ្លះដែលជាផលលំបាកសម្រាប់អ្នកនៅក្នុងការផ្សាយដំណឹងល្អ?ពេលខ្លះមនុស្សម្នាក់អាចនឹងមិនដឹងថានឹងត្រូវចាប់ផ្តើមពីចំនុចណាមួយ។អ្វីដែលគួរយកចិត្តទុកដាក់នោះគឺជាការផ្តល់ "ពត៌មានច្រើនហួស" ទៅដល់អ្នកណាម្នាក់ដែលអាចនឹងមិនធ្លាប់បានយល់ពីចំនុចសំខាន់នៃដំណឹងល្អនៃព្រះយេស៊ូ។សូមធ្វើតាមការអនុវត្តខាងក្រោមនេះដើម្បីជួយពង្រឹងខ្លួនអ្នកពីរបៀបបង្ហាញពីគម្រោងរបស់ព្រះហើយនឹងសេចក្តីត្រូវការរបស់មនុស្សម្នាក់ក្នុងការចាប់យកព្រះគុណនៃព្រះដោយជំនឿ:

*ប្រើពាក្យមួយឬប្រយោគមួយឃ្លានៅក្នុងការពន្យល់ពីរូបភាពនិមួយៗ:*



ពេលនេះ,សូមសម្រាយពាក្យឬឃ្លានិមួយៗទៅជាគំនិតពេញលេញមួយអំពីរូបភាពនិមួយៗ។អ្នកអាចធ្វើការពិភាក្សាជាមួយនឹងក្រុមសិក្សារបស់អ្នកក្នុងការសរសេរអំពីរូបភាពខាងក្រោម។:
























# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ១: កាលដើមដំបូងឡើយ

ត្រូវ ខុស

១,ខុស -ព្រះគម្ពីរបង្រៀនថាព្រះទ្រង់អស់កល្បហើយទ្រង់បានបង្កើតរបស់គ្រប់ទាំងអស់។
២, ត្រូវ
៣, ខុស - ព្រះបានបង្កើតពិភពលោកទាំងមូលក្នុងរយៈពេលប្រាំមួយថ្ងៃ(លោកុប្បត្តិ ១:៣១)
៤, ខុស- មនុស្សត្រូវបានបង្កើតនៅក្នុងរូបអង្គនៃព្រះ។មានតែមនុស្សប៉ុណ្ណោះដែលមានអភ័យឯកសិទ្ធមួយនេះ។ (លោកុប្បត្តិ ១:២៦-២៨)
៥, ត្រូវ
៦,ត្រូវ
៧, ខុស -ព្រះបានបង្កើតស្ត្រីម្នាក់សម្រាប់បុរស។ព្រះទ្រង់មានព្រះទ័យអោយជំនួយជួយបំពេញគូររៀបការមួយដ៏ពេញលេញ។
៨, ខុស ព្រះគម្ពីរបានបង្រៀនថានៅពេលដែលស្ត្រីម្នាក់ហើយនឹងបុរសម្នាក់រៀបការ,ពួកគេគួរតែទទួលស្គាល់ភាពទទួលខុសត្រូវចំពោះគ្រួសារថ្មីរបស់ពួកគេ។

# ស្វែងរកអត្ថបទព្រះគម្ពីរ

១, បង្កើត
២ ជាការល្អប្រពៃ
៣ . យ៉ាងគួរកោត គួរអស្ចារ្យ
៤. ជាសាច់តែ១សុទ្ធ



# សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៏)

១, លទ្ធផលដែលអាចនឹងមានគឺជា:ការបន្ទាបគុណតម្លៃរបស់មនុស្សដូចជា(ការពន្លូតកូន,អំពើហិង្សា,ការសម្លាប់មនុស្ស,ការសម្លាប់ខ្លួន) ការដែលបន្ទាបតម្លៃខ្លួនឯង,ការបន្ទាបតម្លៃក្នុងគោលបំណងណាមួយ។

២ អំណោយទាននៃព្រះចំពោះការជ្រើសរើសគឺមិនត្រូវបរិភោគផ្លែឈើដែលព្រះហាមឃាត់(ជាការស្តាប់តាមព្រះហើយបដិសេធខ្លួនឯង) ឬក៏បរិភោគផ្លែឈើដែលព្រះហាមឃាត់(ការស្តាប់តាមខ្លួនឯងហើយបដិសេធព្រះ)។ផលដែលកើតឡើងពីការជ្រើសរើសក្នុងការស្តាប់តាមព្រះគឺជាជីវិតហើយនឹងទំនាក់ទំនងដ៏ល្អឥតខ្ចោះ។ផលដែលកើតពីការជ្រើសរើសក្នុងការស្តាប់តាមខ្លួនឯងគឺជាអំពើបាបហើយនឹងសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ។

៣,ប្តីហើយនឹងប្រពន្ធប្រែក្លាយជាសាច់តែ១សុទ្ធ(ដោយទំនាក់ទំនងផ្លូវភេទរបស់រូបកាយខាងសាច់ឈាម)មនោសញ្ចេតនា(អារម្មណ៏រវាងប្តីនិងប្រពន្ធ)ហើយនឹងព្រលឹងវិញ្ញាណ(ដូចជាព្រះគ្រីស្ទហើយនឹងពួកជំនុំអេភេសូ ៥:២២-២៥)។ទំនាក់ទំនងមួយនេះគ្មានអ្វីដែលអាចប្រៀបប្រដូចបានឡើយ,ដោយព្រោះតែមានតែអ្នកទាំងពីរប៉ុណ្ណោះដែលមានទំនាក់ទំនងមួយនេះ។ការដែលអនុញ្ញាតអោយអ្នកដ៏ទៃចែករំលែកទំនាក់ទំនងនេះអាចនឹងបំផ្លាញចំណងអាពាហ៏ពិពាហ៏។(មានសំនួរបន្ថែម)ប្តីគួរតែសម្លឹងមើលទៅប្រពន្ធអោយដូចជាអំណោយដែលព្រះបានប្រទានពីស្ថានសួគ៌មកវិសេសជាងអ្វីទាំងអស់។ប្រពន្ធមានតម្លៃជាទ្រព្យសម្បត្តិទៅទៀត។(សុភាសិត ៣១:១០)

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ២: ការធ្លាក់ទៅក្នុងអំពើបាបរបស់មនុស្ស

ត្រូវ ខុស

១.ត្រូវ
២. ខុស–សាតាំងបានប្រែក្លាយជាសត្រូវរបស់ព្រះហើយបានជ្រើសរើសនៅក្នុងការល្បួងមនុស្ស។
៣. ត្រូវ
៤. ត្រូវ
៥.ខុស– គ្មានវិធីរបស់មនុស្សណាម្នាក់អាចដកអំពើបាបចេញបានទ្បើយ។(ហេព្រើរ ១០:៤)
៦.ខុស– មនុស្សគ្រប់គ្នាសុទ្ធតែមានបាប(រ៉ូម ៣:២៣)គ្រីស្ទានគឺគ្រាន់តែជាមនុស្សមានបាបដែលបានវិលត្រឡប់មករកព្រះវិញដោយសារព្រះគុណតាមរយៈសេចក្តីជំនឿ(អេភេសូ ២:៨-១០)។
៧. ត្រូវ
៨.ត្រូវ



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. អ្នកមិនស្លាប់ជាពិតមែនទេ; បានដូចជាព្រះ
២. សេចក្តីស្លាប់; ជាជីវិតដ៏នៅអស់កល្បជានិច្ច
៣. ពន្លឺភ្លឺ;សេចក្តីងងឹតណា
៤. កិនក្បាលឯង; ចឹកកែងជើងគេ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១.ប្រហែលជាវាចង់ធ្វើការសងសឹកឬខឹងនឹងព្រះដោយព្រោះតែព្រះអង្គបានបណ្តេញវាចេញពីស្ថានសួគ៌។អ្វីដែលគ្មានការសង្ស័យនោះគឺវាមានភាពច្រណែនចំពោះទំនាក់ទំនងដ៏រីករាយដែលព្រះមានជាមួយនឹងមនុស្ស។

២.ព្រះទ្រង់មានព្រះទ័យឲ្យយើងទាំងអស់គ្នារស់នៅអស់កល្បជានិច្ចនៅក្នុងស្ថានសួគ៌,ដែលជារង្វាន់ដ៏អស់កល្បជានិច្ចនៃជីវិតដែលគ្មានអំពើបាបហើយនឹងលទ្ធផលរបស់អំពើបាបណាមួយឡើយដូចជា:ការឈឺចាប់,ការរងទុក្ខវេទនា,ហើយនឹងសេចក្តីស្លាប់។តើព្រះពិតជាស្រលាញ់យើងដែរឬទេប្រសិនបើព្រះអង្គបិទព្រះនេត្រចំពោះអំពើបាបហើយអនុញ្ញាតអោយអំពើបាបចូលទៅក្នុងស្ថានសួគ៌ហើយអស់អ្នកដែលទទួលបានសេចក្តីសង្គ្រោះនឹងត្រូវបំផ្លាញដោយសារតែអំពើបាបម្តងទៀតនោះ?សេចក្តីស្រលាញ់នៃព្រះដែលទ្រង់មានចំពោះយើងនឹងមិនលប់បាំងសេចក្តីស្រលាញ់ដែលទ្រង់មានចំពោះអ្នកដ៏ទៃនោះឡើយ។តើយើងជាមនុស្សដែលគិតតែពីប្រយោជន៍ខ្លួនឯងយ៉ាងណាដែលយើងទាមទារចូលទៅក្នុងស្ថានសួគ៌ហើយថែមទាំងនាំយកអំពើបាបចូលទៅជាមួយនឹងយើងនោះ!

៣. ព្រះជាម្ចាស់បានដាក់សេចក្តីទំនាយថាសាតាំងនឹងត្រូវ "ចឹកកែងជើង" ព្រះយេស៊ូនៅពេលដែលវាល្បួងព្រះយេស៊ូនៅលើឈើឆ្កាង។ព្រះយេស៊ូបាន "ជាន់ក្បាល"សាតាំងដោយការយកឈ្នះលើអំពើបាបហើយនឹងសេចក្តីស្លាប់ក្នុងនាមជាយញ្ញបូជាដ៏បរិសុទ្ធដែលមានជ័យជំនះលើសេចក្តស្លាប់នោះ។

# ចម្លើយសម្រាប់លំហាត់មេរៀន
## មេរៀនទី ៣ : ពិភពលោកមានបញ្ហារជាមួយនឹងអំពើបាប

ត្រូវ ខុស

១.ខុស – អំពើបាបនៅតែបន្តរយាយីមនុស្សជាតិ(រ៉ូម ៣:២៣)
២.ត្រូវ
៣.ត្រូវ
៤.ខុស – មានតែលោកណូអេហើយនឹងគ្រួសារគាត់ប៉ុណ្ណោះដែលមានជីវិតរស់(លោកុប្បត្តិ ៧:២៣)
៥.ត្រូវ
៦.ត្រូវ
៧.ខុស– ពួកគេចង់អោយបានដូចជាព្រះ (លោកុប្បត្តិ ១១:៣)
៨.ត្រូវ

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. បណ្តោយតាមឯង
២. សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ
៣,តាមគ្រប់ទាំងសេចក្តី
៤.ឯងចង់គោរពប្រតិបត្តិតាម; គោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៏)

១.គាត់មានជំនឿដោយការស្តាប់តាមហើយនឹងធ្វើតាមព្រះបន្ទូលនៃព្រះ។

២. ដោយព្រោះតែការរីកចំរើនរបស់មនុស្សជាតិនៅលើពិភពលោកហើយកាន់តែអាក្រក់ឡើងនោះ។ទ្រង់ជ្រាបថាវានឹងនៅតែបន្តរកាន់តែអាក្រក់ទៅ,លើកលែងតែព្រះអង្គកែប្រែស្ថានការណ៏។

៣. ព្រះទ្រង់មានព្រះគុណករុណានៅក្នុងការនេះដោយព្រោះតែទ្រង់បានបញ្ឈប់កុំឲ្យជំនាន់ថ្មីរបស់មនុស្សធ្លាក់ទៅក្នុងអំពើអាក្រក់ថែមទៀត។ព្រះទ្រង់បានបំភាន់ភាសារបស់គេជាជាងការដែលទ្រង់ធ្វើអោយមានការបំផ្លាញលើពិភពលោក(ដូចជាទឹកជំនន់)ដែលបានកើតឡើងជាដើម។

# ចម្លើយសម្រាប់លំហាត់មេរៀន
## មេរៀនទី ៤: គ្រួសារនៃសេចក្តីជំនឿ

ត្រូវ ខុស

១.ត្រូវ
២. ខុស– លោកអ័ប្រាហាំមានវ័យចាស់ណាស់ហើយនៅពេលដែលព្រះប្រទានអោយគាត់មានកូន។
៣. ខុស – ដោយព្រោះតែគ្មានការសង្ស័យដែលជាឧបសគ្គរាំងនោះ,លោកអ័ប្រាហាំបានបង្ហាញសេចក្តីជំនឿដោយការទុកចិត្តលើព្រះហើយនឹងស្តាប់តាមព្រះអង្គ។
៤. ត្រូវ
៥. ត្រូវ
៦. ខុស– មនុស្សទាំងនេះគឺដូចគ្នានឹងយើងដែរ;ពួកគេនៅតែមានបញ្ហារជាមួយនឹងអំពើបាប។
៧. ខុស – អ៊ីស្រាអែល មានន័យថា ជ័យជំនះនៅចំពោះព្រះ។
៨. ខុស – ព្រះបានដឹកនាំ អ៊ីស្រាអែលដើម្បីគេចចេញពីការការប្រព្រឹត្តដ៏ពោរពេញដោយអំពើបាបរបស់ទឹកដីកាណាន។

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. អាប់រ៉ាម; អ័ប្រាហាំ
២. ឯងកោតខ្លាចដល់ព្រះ
៣.នឹងបានពរដោយ; ឯងបានស្តាប់តាមពាក្យអញ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៏)

១. ក្នុងការដែលដឹកនាំអោយព្រះបានបង្កើតសេចក្តីសន្យាជាមួយនឹងលោកអ័ប្រាហាំ,ព្រះទ្រង់មានព្រះទ័យចង់ឃើញពីសេចក្តីជំនឿរបស់លោកអ័ប្រាហាំថាតើសេចក្តីជំនឿហើយនឹងការទុកចិត្តរបស់លោកនៅលើព្រះអស្ចារ្យយ៉ាងណា។

២.ព្រះបានសន្យាថាតាមរយៈពូជរបស់លោកអ័ប្រាហាំគ្រប់សាសន៏ទាំងអស់នឹងបានពរ។ព្រះយេស៊ូគឺជាពូជរបស់លោកអ័ប្រាហាំ,ហើយតាមរយៈព្រះអង្គ,មនុស្សគ្រប់ទាំងសាសន៏អាចទទួលបានព្រះពរ!

៣. ទោះបីជា "វិរៈបុរសនៃព្រះគម្ពីរ" ដូចជាលោកអ័ប្រាហាំគាត់គ្រាន់តែជាមនុស្សតែប៉ុណ្ណោះ។ភាពកម្សោយរបស់ពួកគេបានបង្ហាញថាសូម្បីតែមនុស្សដែលអស្ចារ្យក៏នៅតែមិនអាចសង្គ្រោះខ្លួនឯងបានដែរ។យើងទាំងអស់គ្នាត្រូវការជំនួយពីព្រះសម្រាប់យកឈ្នះលើអំពើបាប។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ៥: អ៊ីស្រាអែលក្លាយជាទាសករនិងការប្រោសលោះ

ត្រូវ ខុស

១. ខុស– លោកម៉ូសេគឺជាប្រជាជនអ៊ីស្រាអែល។គាត់ត្រូវបានចិញ្ចឹមបីបាច់មួយរយៈក្នុងនាមជាសាសន៍អេស៊ីព្ទ។
២. ខុស –លោកម៉ូសេបានសម្លាប់សាសន៍អេស៊ីព្ទម្នាក់(ជាអំពើបាបមួយនៅក្នុងចំណោមអំពើបាបផ្សេងទៀតរបស់គាត់)។
៣. ខុស – គឺត្រូវទាមទារអោយមានគ្រោះកាចចំនួនដប់មុនពេលដែលផារ៉ោនដោះលែងអ៊ីស្រាអែល។
៤. ត្រូវ
៥. ត្រូវ
៦. ត្រូវ
៧. ខុស – ក្រឹត្យវិន័យទាំងដប់គឺជាគ្រឹះរបស់ក្រឹត្យវិន័យលោកម៉ូសេ។
៨. ត្រូវ

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. អំពាវនាវដល់ព្រះ
២. ឲ្យរាស្ត្រអញចេញទៅ
៣.មិនមានម្នាក់ស្លាប់នោះទេ
៤. ឲ្យអស់ពីចិត្ត;អស់ពីព្រលឹង; អស់ពីព្រលឹង



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៏)

១.គាត់គឺជាប្រដាប់ដែលព្រះប្រើនៅក្នុងការរំដោះអ៊ីស្រាអែលពីចំណងទាសករនៅក្នុងប្រទេសអេស៊ីព្ទ។

២. ក្រឹត្យវិន័យគឺដើម្បីបង្រៀនប្រជាជនអ៊ីស្រាអែលអោយចេះស្រលាញ់ហើយនឹងគោរពព្រះ។ក្រឹត្យវិន័យក៏បង្រៀនអោយចេះស្រាលាញ់និងគោរពគ្នាទៅវិញទៅមកផងដែរ។

៣. ព្រះជាម្ចាស់ទ្រង់ជាព្រះនៃសេចក្តីយុត្តិធម៌។ទ្រង់មិនអាចទតរំលងអំពើបាបដោយមិនដាក់ទោសបានឡើយ។យ៉ាងណាមិញប្រសិនបើមានយញ្ញាបូជាដែលគ្មានទោសណាសោះយកមកធ្វើជាយញ្ញបូជានោះនឹងអាចលាងជំរះអំពើបាបរបស់មនុស្សដែលមានបាបបាន។យញ្ញបូជាគឺជាវិធីដែលព្រះទ្រង់នាំមនុស្សមានបាបអោយមកក្នុងទំនាក់ទំនងនៃសេចក្តីសន្យាជាមួយនឹងព្រះអង្គ។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ៦: ភាពរីកចំរើននិងការធ្លាក់ចុះរបស់អ៊ីស្រាអែល

ត្រូវ ខុស

១.ត្រូវ
២. ខុស–នៅចុងក្រោយអ៊ីស្រាអែលត្រូវបានបំផ្លាញដោយសារអំពើបាបដែលពួកគេបានប្រព្រឹត្ត។
៣. ត្រូវ
៤. ត្រូវ
៥. ខុស – ពួកទ្រង់ក៏ជាមនុស្សដូចជាយើងដែរហើយក៏មានបញ្ហារជាមួយនឹងអំពើបាបផងដែរ។
៦. ត្រូវ
៧. ត្រូវ
៨. ខុស –ព្រះយេស៊ូគឺជាការសម្រេចគ្រប់ទាំងសេចក្តីទំនាយដែលមានរាប់រយឆ្នាំនៅក្នុងព្រះគម្ពីរ។



## ស្វែងរកអត្ថបទព្រះគម្ពីរ

១. តាមដែលគេយល់ឃើញ
២. ដែលត្រូវនឹងព្រះហឫទ័យទ្រង់
៣. សំលៀកបំពាក់ទូលបង្គំ; ក៏ធ្វើឆ្នោតចាប់យក
៤. អំពើរំលងរបស់យើង; ឲ្យយើងបានជាមេត្រី



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៏)

១. ពួកគេគួរតែបានបោសសំអាតការប្រព្រឹត្តពោរពេញដោយអំពើបាបដែលមាននៅក្នុងទឹកដីកាណានទាំងស្រុង,ប៉ុន្តែមានពេលខ្លះពួកគេបានបណ្តោយអោយមនុស្សដែលពោរពេញដោយអំពើបាបមានជីវិតរស់នៅ។អំពើបាបដ៏អាក្រក់របស់អ្នកជិតខាងដែលជាសាសន៏កាណានបានជះឥទ្ធិពលលើពួកគេហើយបានល្បួងគេអោយធ្លាក់ទៅក្នុងអំពើបាបទាំងនោះ។

២.ដោយព្រោះតែព្រះជាម្ចាស់តែងតែសព្វព្រះហឫទ័យចំពោះទំនាក់ទំនងដែលកើតឡើងដោយការតាំងចិត្តជាការដឹកនាំដោយសេចក្តីស្រលាញ់។ការដែលមិនអនុញ្ញាតអោយមានការជ្រើរើសនោះគឺជាការដែលមិនអនុញ្ញាតអោយមានការឆ្លើយតបដោយសេចក្តីស្រលាញ់ដ៏ពិតប្រាកដ។

៣. ចាប់តាំងពីគម្ពីរលោកុប្បត្តិដល់គម្ពីរម៉ាឡាគី,មានទំនាយរាប់រយទំនាយដែលផ្តោតលើការយាងមករបស់ព្រះយេស៊ូជាព្រះសង្គ្រោះជាព្រះមេស៊ីដែលព្រះជាម្ចាស់ប្រើជាប្រដាប់នៅក្នុងការប្រោសលោះមនុសពីអំពើបាប។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ៧:ព្រះជន្មរបស់ព្រះយេស៊ូ

ត្រូវ ខុស

១.ខុស– ពួកគេបានរង់ចាំសម្រាប់ការយាងមករបស់ព្រះមេស៊ីអស់រយៈពេល ៤០០ឆ្នាំមកហើយ។
២. ត្រូវ
៣. ខុស – ដំណឹងល្អមានន័យថាដំណឹងអំពីការល្អ។
៤. ខុស – ព្រះយេស៊ូបានប្រើការធ្វើចំការសម្រាប់ជាឧទាហរណ៍នៅក្នុងការបង្រៀន។
៥. ត្រូវ
៦. ខុស– ពួកមេដឹកនាំសាសនាតែងតែស្អប់ព្រះយេស៊ូជានិច្ច។
៧. ត្រូវ
៨. ខុស – ទ្រង់បានរស់នៅក្នុងជីវិតដែលគ្មានបាបណាទាល់តែសោះ (២កូរិនថូស ៥:២១)



## ស្វែងរកអត្ថបទព្រះគម្ពីរ

១.ជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល
២. ជាកូនសួនភ្វាអញ
៣. ជាទីសំរាប់អធិស្ឋាន; ជារោងចោរវិញ
៤. លោកីយទាំងមូល



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១. ជាការបញ្ជាក់ថាព្រះគម្ពីរពិតជាសចក្តីពិតដែលបានសរសេរអស់រយៈពេលជាច្រើនសតវត្ស។ការដែលព្រះយេស៊ូបានសម្រេចសេចក្តីទំនាយបង្រៀនយើងថាព្រះគម្ពីរគឺដូចជាអ្វីដែលព្រះគម្ពីរនោះបានប្រកាសគឺថា:ជាព្រះបន្ទូលនៃព្រះ។

២.ព្រះយេស៊ូបានធ្វើការអស្ចារ្យជាការបង្ហាញថាទ្រង់ពិតជាមានព្រះចេស្តាហើយនឹងអំណាចពីស្ថានសួគ៌។

៣.ការដែលព្រះអង្គរស់នៅក្នុងជីវិតមួយដែលគ្មានអំពើបាបមានសារៈសំខាន់ដោយព្រោះតែការនោះធ្វើអោយទ្រង់ជាយញ្ញបូជាដ៏ល្អឥតខ្ចោះ។ការសុគតដោយគ្មានកំហុសរបស់ព្រះអង្គអាចលាងជំរះអំពើបាបហើយនឹងទោសកំហុសរបស់មនុស្សគ្រប់គ្នា។

# ចម្លើយសម្រាប់លំហាត់មេរៀន
## មេរៀនទី ៨: យប់ចុងក្រោយ,ថ្ងៃមួយពោរពេញដោយភាពងងឹត

ត្រូវ ខុស

១. ត្រូវ
២. ខុស – របស់ទាំងនោះគឺជាតំណាងអោយព្រះកាយរបស់ព្រះយេស៊ូហើយនឹងព្រះលោហិតព្រះលោហិតរបស់ព្រះអង្គ។
៣. ត្រូវ
៤. ខុស – ពួកគេបានហៅសាក្សីក្លែងក្លាយជាច្រើន,ប៉ុន្តែមិនអាចរកចំនុចណាដើម្បីដាក់ទោសព្រះយេស៊ូបានឡើយ។
៥. ខុស – យូដាសបានបង្ហាញពីការដឹងកំហុស,ប៉ុន្តែមិនដែលបានផ្លាស់ប្រែឡើយ,វាបានសម្លាប់ខ្លួន។
៦. ត្រូវ
៧. ខុស – លោកភីឡាត់បានជឿថាព្រះយេស៊ូគ្មានកំហុស។
៨. ខុស – លោកគឺជាមនុស្សកំសាក,ដែលបានបណ្តោយចិត្តទៅតាមហ្វូងមនុស្ស។

## ស្វែងរកអត្ថបទព្រះគម្ពីរ

១.នេះហើយជារូបកាយខ្ញុំ
២. សូមតាមតែព្រះហឫទ័យទ្រង់វិញ
៣. កូនមនុស្ស
៤. មើលចុះ មនុស្សនេះ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១. នំប៉័ងគឺជាតំណាងឲ្យរូបកាយព្រះគ្រីស្ទ។ពែងហើយនឹងទឹកទំពាំងបាយជូរគឺជាតំណាងឲ្យគម្ពីរសញ្ញាថ្មីហើយនឹងព្រះលោហិតរបស់ព្រះអង្គ។

២. ទ្រង់បានជ្រាបយ៉ាងច្បាស់ការសុគតដ៏សោកសង្រេងនឹងត្រូវប្រឈមចំពោះសេចក្តីក្រោធនៃព្រះ។

៤. ពួកមេដឹកនាំសាសនាយូដា,ពួកសាសន៍រ៉ូម,ហើយនឹងយូដាគឺត្រូវទទួលខុសត្រូវចំពោះការដាក់ទោសរបស់ព្រះយេស៊ូ។ប៉ុន្តែអ្នកហើយនឹងខ្ញុំក៏យ៉ាងដូច្នោះដែរ។ការសុគតរបស់ព្រះយេស៊ូមានសារៈសំខាន់សម្រាប់មនុស្សគ្រប់គ្នាដែលចង់បានសេចក្តីសង្គ្រោះ។ដូច្នេះហើយ,យើងទាំងអស់គ្នាមានទោសដែលកាត់ទោសព្រះយេស៊ូអោយសុគត។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ៩: ការសុគតហើយនឹងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូ

ត្រូវ ខុស

១. ខុស – មានមនុស្សជាច្រើនចំអកហើយមើលងាយព្រះអង្គ។
២. ត្រូវ
៣. ខុស – នៅពេលដែលវាំងននដែលបាំងនៅក្នុងព្រះវិហាររហែកជាពីរនោះ,គឺជាសញ្ញាដែលបង្ហាញថាជំនាន់ក្រឹត្យក្រមវិន័យលោកម៉ូសេបានកន្លងផុតហើយជំនាន់គ្រីស្ទានរៀបនឹងចាប់ផ្តើមហើយ។
៤. ខុស – មនុស្សគ្រប់គ្នា-លើកលែងតែព្រះយេស៊ូ-សុទ្ធតែមានបាប។(រ៉ូម ៣:២៣,១យ៉ូហាន ៨-១០)
៥. ត្រូវ
៦. ខុស – ថូម៉ាស មិនជឿថាពួកគេបានឃើញព្រះយេស៊ូដូចដែលគេប្រាប់នោះឡើយ។ សូមមើលក្នុងគម្ពីរយ៉ូហាន ២០:២៤-២៥
៧. ត្រូវ
៨. ត្រូវ

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. ចោលទូលបង្គំ
២. កិនក្បាលឯង; ចឹកកែងជើងគេ
៣. ឥតឃើញសោះ
៤. យើងវេទនា



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១. ចម្លើយនឹងមានភាពខុសគ្នាពីមនុស្សម្នាក់ៗ។

២. ព្រះយេស៊ូបានប្រទានពរដល់អស់អ្នកដែលបានស្តាប់ឮដំណឹងល្អហើយទទួលជឿដោយសេចក្តីជំនឿដោយមិនបានឃើញពីការរស់ពីសុគតឡើងដោយផ្ទាល់នឹងភ្នែករបស់ពួកគេ!

៣. ចម្លើយនឹងមានភាពខុសគ្នាពីមនុស្សម្នាក់ៗ។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ១០: មនុស្សគ្រប់គ្នាអាចទទួលបានសេចក្ដីសង្គ្រោះ!

ត្រូវ ខុស

១. ខុស – គម្ពីរកិច្ចការ ប្រាប់អំពីកិច្ចការ របស់គ្រីស្ទានដំបូងបង្អស់។
២. ត្រូវ
៣. ខុស – យើងមិនអាចធ្វើអ្វីអោយកើនសេចក្ដីសង្គ្រោះឡើយ។
៤. ត្រូវ
៥. ត្រូវ
៦. ត្រូវ
៧. ត្រូវ
៨. ត្រូវ

## ស្វែងរកអត្ថបទព្រះគម្ពីរ

១. ទទួលបុណ្យជ្រមុជទឹក
២. ជាលេខ១ក្នុងពួកគេ
៣. ព្រះគុណ,សេចក្ដីជំនឿ,មិនកើតពីអ្នករាល់គ្នាដែរ
៤.ជាគំរូពីបុណ្យជ្រមុជ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១. សេចក្ដីសង្គ្រោះដែលមនុស្សគិតថាបានមកដោយការប្រព្រឹត្តរបស់យើងឬការសន្សំកុសលនោះអាចក្លាយទៅជាការទាមទារអោយបានចូលទៅក្នុងស្ថានសួគ៌ដោយការពឹងផ្អែកទៅលើផលដែលខ្លួនបានទទួល។ការនេះជាការបដិសេធសេចក្ដីពិតដែលមានគឺថាមនុស្សមិនអាចសង្គ្រោះខ្លួនឯងបានឡើយប៉ុន្តែព្រះទ្រង់មានគម្រោងនៅក្នុងការប្រោសលោះមនុស្ស។

២. ការដែលសន្សំកុសលគឺដូចជាផលដែលយើងទទួលបាន។មានន័យថាត្រូវតែមានអ្វីដែលត្រូវអោយមនុស្សធ្វើ,ហើយផលដែលទទួលបាននោះគឺជាការតបស្នងពីការដែលបានធ្វើនោះ។សេចក្ដីជំនឿគឺជាការទុកចិត្តទាំងស្រុងលើព្រះនៅក្នុងពេលបច្ចុប្បន្ន។ការដែលស្ដាប់តាមព្រះដោយសេចក្ដីជំនឿគឺជាការទុកចិត្តថាយើងមិនអាចសង្គ្រោះខ្លួនរបស់យើងចេញពីបាបបានប៉ុន្តែគឺដោយសារព្រះគុណនៃព្រះដែលយើងទទួលបានសេចក្ដីសង្គ្រោះ,ប្រសិនបើយើងដើរតាមការដឹកនាំរបស់ព្រះអង្គ។ការស្ដាប់តាមព្រះត្រូវបានរាប់ថាជាការប្រព្រឹត្ត(យ៉ូហាន ៦:២៨)។យ៉ាងណាមិញ,អ្វីដែលជាចំនុចដែលត្រូវពិចារណានៅក្នុងគំនិតនោះភាពខុសគ្នាយ៉ាងដាច់ស្រឡះអំពីការប្រព្រឹត្តនៃការសន្សំកុសលនិងសេចក្ដីជំនឿ។

៣. សេចក្ដីសង្គ្រោះបានមកដោយសារព្រះគុណនៃព្រះតាមរយៈសេចក្ដីជំនឿ។យើងស្ដាប់តាមព្រះហើយនឹងដំណឹងល្អនៃព្រះយេស៊ូនៅពេលដែលយើងបានស្ដាប់ឮអំពីព្រះបន្ទូលនោះ,ទទួលជឿ,ធ្វើការផ្លាស់ប្រែ,ប្រកាស,ហើយនឹងទទួលពិធីជ្រមុជទឹកជាការលាងជំរះអំពើបាប។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ១១: រហូតដល់ព្រះយេស៊ូយាងត្រឡប់មកវិញ!

ត្រូវ ខុស

១. ត្រូវ
២. ត្រូវ
៣. ត្រូវ
៤. ត្រូវ
៥. ត្រូវ
៦. ខុស– ព្រះគម្ពីរពិតជាបានបង្រៀនអំពីជីវិតបន្ទាប់ពីយើងស្លាប់ខាងរូបកាយនេះទៅ។
៧. ខុស – ស្ថានឃុំព្រលឹងមនុស្សស្លាប់ហើយនឹងស្ថានសួគ៌មិនមែនជាកន្លែងតែមួយឡើយ។
៨. ត្រូវ

# ស្វែងរកអត្ថបទព្រះគម្ពីរ

១. អ្នកខ្លះនឹងលាកចាកចេញ
២. អ្នកណាមួយវិនាសឡើយ; ដូចជាចោរប្លន់; នឹងត្រូវឆេះអស់រលីង



# សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១.មនុស្សអាចនឹងចាកចេញដោយព្រោះតែគេបានដកព្រះយេស៊ូចេញពីបល្ល័ង្កនៅក្នុងចិត្តរបស់គេ,ហើយបានលើងសោយរាជ្យធ្វើជាស្តេចដោយខ្លួនគេវិញ។មនុស្សអាចនឹងចាកចេញដោយព្រោះតែគេជ្រើសរើសក្នុងការធ្វើតាមការដឹកនាំនៃប្រាជ្ញាឬការបង្រៀនរបស់មនុស្សដែលពួកគេគោរពវិញ។

២.សាតាំងត្រូវបានរងការបំផ្លាញដោយសារការជ្រើសរើសអាក្រក់របស់វា។ពេលនេះវាកំពុងស្វែងរកឱកាសនៅក្នុងការស្វែងរកកំហុសនៃអំពើបាបរបស់អ្នកដ៏ទៃទៀត។ការបំផ្លាញរបស់វាបានដឹកនាំវាអោយល្បួងអ័ដាមនិងអេវ៉ា។វាមិនចង់ឃើញមនុស្សមានទំនាក់ទំនងដ៏រីករាយជាមួយនឹងព្រះនោះឡើយ។វាក៏មិនចង់ឃើញគ្រីស្ទានមានទំនាក់ទំនងយ៉ាងដូច្នោះជាមួយនឹងព្រះនោះឡើយ។

៣. គ្រីស្ទានគួរតែរស់នៅក្នុងជីវិតមួយដែលចុះចូលនឹងព្រះ។ដោយសារព្រះគុណតាមរយៈសេចក្តីជំនឿដែលយើងអាចទទួលបានសេចក្តីសង្រ្គោះ។យើងនឹងទទួលការជំនុំជំរះតាមរយៈការស្តាប់តាមដោយសេចក្តីជំនឿរបស់យើងម្នាក់ៗ។ដោយព្រោះតែយើងមិនដឹងថាពេលណាដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញនោះ,យើងគួរតែរស់នៅហើយនឹងបម្រើព្រះដោយអំណរជារៀងរាល់ថ្ងៃ (រ៉ូម ១២:១-២)។

# ចម្លើយសម្រាប់លំហាត់មេរៀន

## មេរៀនទី ១២: រង្វាន់ដ៏អស់កល្បជានិច្ច

ត្រូវ ខុស

១. ត្រូវ
២. ខុស– ស្ថាននរកគឺជាកន្លែងសម្រាប់អស់អ្នកណាដែលមិនបានលាងជំរះអំពើបាបរបស់គេ។
៣. ខុស – ទ្រង់ពិតជាមាន,គឺជាព្រះគម្ពីរ។
៤. ត្រូវ
៥. ត្រូវ
៦. ខុស – កាលដែលព្រះគម្ពីរផ្តល់នូវការរៀបរាប់មួយចំនួននោះ,គ្មានអ្នកណាម្នាក់អាចដឹងច្បាស់នោះឡើយលើកលែងតែពួកគេបានទៅដល់ទៅនោះ!
៧. ត្រូវ
៨. ***មានតែអ្នកប៉ុណ្ណោះដែលអាចឆ្លើយនឹងសំនួរនេះបាន។

## ? ស្វែងរកអត្ថបទព្រះគម្ពីរ

១. ទ្វារចង្អៀត; ពិបាកដើរ
២. ពីគួសេចក្តីស្លាប់
៣. សេចក្តីស្លាប់;សេចក្តីសោកសង្រេង,សេចក្តីយំទួញ, ទុក្ខលំបាក
៤. អស់កល្បជានិច្ចរៀងរាបតទៅ



## សំនួរសំខាន់

*** ( ចម្លើយគឺមានភាពខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ខាងក្រោមនេះគឺជាឧទាហរណ៍)

១. គឺដោយព្រោះតែព្រះមានមិនមានអាចនឹងប្រកបទាក់ទងជាមួយនឹងមនុស្សមានបាបបានឡើយ។ទ្រង់មិនអាចអនុញ្ញាតអោយមនុស្សមានបាបចូលទៅក្នុងស្ថានសួគ៌បានឡើយពុំនោះទេអំពើបាបនោះនឹងបំផ្លាញស្ថានសួគ៌ដែរ។ព្រះអង្គបានប្រទានឱកាសដោយព្រះគុណរបស់ទ្រង់មនុស្សគ្រប់គ្នាអាចទទួលបានសេចក្តីសង្គ្រោះ។អស់អ្នកដែលមិនបានស្តាប់តាមការត្រាស់ហៅរបស់ទ្រង់នឹងទទួលបានរង្វាន់ជាការដាក់ទោសដ៏អស់កល្បជានិច្ច។

២. ដ្បិតគ្រប់គ្នាសុទ្ធតែមានបាបហើយខ្វះមិនដល់សិរីល្អនៃព្រះ (រ៉ូម ៣:២៣)។យ៉ាងណាមិញ, ស្ថានសួគ៌គឺសម្រាប់អស់អ្នកណាដែលវិលត្រឡប់មករកព្រះជាម្ចាស់ដោយសារព្រះគុណតាមរយៈសេចក្តីជំនឿ។(អេភេសូ ២:៨-១០)

៣. គឺព្រះជាម្ចាស់ទ្រង់គង់នៅទីនោះ,ព្រះយេស៊ូក៏គង់នៅទីនោះ,ក្រុមគ្រួសាររបស់យើង,មិត្តភក្តិរបស់យើងដែលមានជំនឿរឹងមាំនឹងនៅទីនោះ។នៅក្នុងស្ថានសួគ៌គ្មានអំពើបាប។ហើយជាការរស់នៅក្នុងភាពល្អឥតខ្ចោះដ៏អស់កល្បជានិច្ច។

# សេចក្ដីបន្ថែម

## សេចក្ដីបន្ថែម កA – ជំនាន់ទាំងបីខាងព្រលឹងវិញ្ញាណ។




### មេរៀនទី ១: ព្រះបង្ហាញពីព្រះទ័យទ្រង់

នៅក្នុងការបង្ហាញខាងលើ,ជំនាន់សង្ឃទទួលបានការបង្ហាញដូចជាពន្លឺផ្កាយ។ការដំណាងនេះគឺជាកាងបង្ហាញអំពីដែនកំណត់នៃការបង្ហាញដែលព្រះបានប្រទានមកដល់មនុស្ស។ពន្លឺនោះគឺគ្រាន់តែអាចបង្ហាញថាមានព្រះវត្តមាននៃព្រះតែប៉ុណ្ណោះ,ប៉ុន្តែមិនបានបង្ហាញអោយបានយល់ពីគម្រោងនៃព្រះបានគ្រប់គ្រាន់នោះឡើយ។

ជំនាន់ក្រឹត្យវិន័យលោកម៉ូសេគឺជាដូចជាពន្លឺខែ។ដូចដែលពន្លឺខែផ្ដល់ពន្លឺច្បាស់ជាពន្លឺផ្កាយនោះ,ជំនាន់ក្រឹត្យវិន័យលោកម៉ូសេបានផ្ដល់នូវការយល់ដឹងការតែជ្រៀលជ្រៅនៃព្រះទ័យព្រះច្រើនជាងជំនាន់សង្ឃ។នៅក្នុងជំនាន់នេះ ព្រះគម្ពីរសញ្ញាចាស់ត្រូវបានធ្វើការកត់ត្រាហើយនឹងបានប្រមូលផ្ដុំ។

ជំនាន់គ្រីស្ទានគឺជាដូចជាពន្លឺថ្ងៃដែលបានបង្ហាញពីព្រះទ័យនៃព្រះយ៉ាងច្បាស់លាស់តាមរយៈព្រះបន្ទូលដ៏ពេញលេញ។នៅពេលដែលព្រះគម្ពីរសញ្ញាថ្មីត្រូវបានកត់ត្រាប៉ុន្មានឆ្នាំក្រោយការសុគតហើយនឹងរស់ឡើងវិញរបស់ព្រះយេស៊ូនោះ,មនុស្សមានការយល់ដឹងយ៉ាងល្អប្រសើរអំពីបំណងព្រះហឫទ័យនៃព្រះ។




# មេរៀនទី ២: ការព្យាយាមរបស់មនុស្សក្នុងការរក្សាទំនាក់ទំនងជាមួយនឹងព្រះ។

នៅក្នុងជំនាន់សង្ឃ,ពួកសង្ឃបានដឹកនាំក្រុមគ្រួសាររហើយនឹងកុលសម្ព័ន្ធរបស់ពួកគេនៅក្នុងកាបម្រើព្រះ។សង្ឃតែងតែថ្វាយយញ្ញបូជាសម្រាប់ក្រុមគ្រួសារនិងកុលសម្ព័ន្ធរបស់ពួកគេ។

នៅក្នុងជំនាន់ក្រឹត្យវិន័យលោម៉ូសេ,សង្ឃជាអ្នកថ្វាយសត្វជាយញ្ញបូជាសម្រាប់មនុស្សគ្រប់គ្នា។ជាមួយនឹងការបញ្ញត្តិនៃព្រះមានច្បាប់ជាច្រើនអំពីរបៀបនៃការថ្វាយយញ្ញបូជាដែលព្រះសព្វព្រះទ័យ។

នៅក្នុងជំនាន់ចុងក្រោយ,ព្រះយេស៊ូត្រូវបានថ្វាយជាយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់អំពើបាប។ឈាមរបស់សត្វមិនអាចសូមអោយមានការអត់នៃអំពើបាបបានទាំងស្រុងដូចដែលព្រះបានសម្រេចដោយការសុគតនៅលើឈើឆ្កាងនោះឡើយ។

# សេចក្តីបន្ថែម ខ
## ការសិក្សាបន្ថែមពីមេរៀនដ៏សាមញ្ញក្នុងព្រះគម្ពីរ




ព្រះគម្ពីរត្រូវបានកំណត់សំគាល់ថាជាសៀវភៅដ៏ធំមួយក្បាល! មនុស្សមួយចំនួនអាចនឹងមានការភ័យខ្លាចនៅក្នុងការចាប់យកព្រះគម្ពីរមកអានហើយនឹងស្វែងយល់ពីព្រះគម្ពីរដោយព្រោះតែទំហំរបស់ព្រះគម្ពីរនេះ។ការសិក្សានៅក្នុងមេរៀននេះត្រូវបានចងក្រងមកដើម្បីលាតត្រដាងហើយនឹងសម្លឹងមើលអំពីព្រះគម្ពីរក្នុងការដែលស្វែងរកឱកាសនៅក្នុងផ្តល់ជូននូវការយកចិត្តទុកដាក់ដល់សិស្សដែលសិក្សាព្រះគម្ពីរថា: ព្រះគម្ពីរគឺជាប្រដាប់នៃការបង្ហញពីអំណាចរបស់ព្រះ,ជាភស្តុតាងនៃការដឹកនាំដ៏អស្ចារ្យរបស់បទគម្ពីរ;ជាការលាតត្រដាងនៃព្រះគម្ពីរទាំង៦៦កណ្ឌនៃបទគម្ពីរ; ហើយនឹងវិធីចែកចាយព្រះបន្ទូលព្រះអោយកាន់តែយល់។ [សំគាល់ពីអ្នកនិពន្ធ: នេះគឺជាការសិក្សាបន្ថែមនៃមេរៀនៃការប្រោសលោះ។]




តើពាក្យថា "ពួកជំនុំ"មានន័យយ៉ាងដូចម្តេចសម្រាប់អ្នក? សម្រាប់មនុស្សខ្លះអាចជាអារម្មណ៏មួយនៃសេចក្តីសុខសាន្តហើយនឹងការប្រកបទាក់ទងដ៏ល្អមួយ។សម្រាប់មនុស្សខ្លះទៀតអាចជាការរើសអើងមួយ,ចំនុចអាក្រក់ឬជាអ្នកដែលនាំមកនូវការផ្លាស់ប្តូរ។ពួកជំនុំមានសារៈសំខាន់ខ្លះណាស់ចំពោះព្រះយេស៊ូ។ទ្រង់បានសុគតសម្រាប់ពួកជំនុំហើយបានបង់ថ្លៃលោះសម្រាប់សេចក្តីសង្គ្រោះសម្រាប់មនុស្សដែលនៅក្នុងពួកជំនុំដោយព្រះលោហិតព្រះអង្គ(កិច្ចការ ២០:២៨)។ ការសិក្សានៅក្នុងមេរៀននេះនឹងផ្តល់ជូននូវការបង្ហាញពីពួកជំនុំថាអ្វី,ហេតុអ្វីបានជាពួកជំនុំមានសារៈសំខាន់,ហើយពីការប្រព្រឹត្តរបស់ពួកជំនុំ។(ចំនុចពីអ្នកនិពន្ធ: នៅក្នុងមេរៀនដ៏វិសេសនេះសម្រាប់អស់អ្នកដែលធ្លាប់ទទួលបានការបង្ហាញអំពីគ្រីស្ទានពីមុនប៉ុន្តែមិនធ្លាប់បានពិចារណាអំពីបទគម្ពីរដែលបង្ហាញពីចំនុចសំខាន់។]




ក្នុងចំណោមមនុស្សដែលរស់នៅជុំវិញពិភពលោកទាំងមូលមានមនុស្សច្រើនជាង ១កោដនាក់ដែលកាន់តាមការបង្រៀនរបស់ព្រះពុទ្ធសាសនា។អំឡុងពេលដែលមនុស្សភាគច្រើនសុទ្ធសឹងតែរាប់ថាជំនឿរបស់ប្រទេសខាងកើតនោះ,មានមនុ ស្សជាច្រើនដែលរស់នៅប្រទេសខាងលិចកំពុងតែរៀនហើយនឹងកាន់តាមការបង្រៀននៃព្រះពុទ្ធដែរ។សម្រាប់គ្រីស្ទានវិញ,តើការបង្រៀនរបស់ព្រះពុទ្ធអាចប្រៀបធៀបយ៉ាងណាចំពោះការបង្រៀនរបស់ព្រះយេស៊ូ។សម្រាប់ពុទ្ធិសាសនិក,តើផ្លូវដែលគ្រីស្ទានដើរអាចប្រៀបធៀបយ៉ាងដូចម្ដេចចំពោះផ្លូវដែលពុទ្ធិសាសនិកកំពុងដើរ?

តើសេចក្ដីជំនឿទាំងពីរនេះអាចធ្វើការផ្លាស់ប្ដូរគ្នាបានឬដាច់ដោយឡែកពីគ្នា?ផ្នែកនេះមេរៀននេះមានគោលបំណងនៅក្នុងការផ្ដល់ជូននូវការប្រៀបធៀបដ៏សមស្របសម្រាប់សេចក្ដីជំនឿទាំងពីរសម្រាប់អោយសិស្សដែលសិក្សាព្រះគម្ពីរអាចស្វែងយល់ទាំងសងខាង,វាយតម្លៃ,ហើយនឹងធ្វើការសម្រេចពីអ្វីដែលជំនឿនោះបានផ្ដល់អោយ។ក្នុងកាលដែលសេចក្ដីពិតអាចនឹងមានផលពិបាកនៅក្នុងការស្វែងរកនោះ,គុណសម្បត្តិនៃការស្វែងរកសេចក្ដីពិតនោះគឺមានតម្លៃសម្រាប់ព្រលឹងវិញ្ញាណរបស់យើង។